# រឿង

# សំនៀងស្នេហ៍កវី

ប្រលោមលោកមនោសញ្ចេតនា

ដោយ     អ្នកស្រី កែវ ចន្ទ័បូរណ៏

ហៅ មិត្រ មេត្រី

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

ខែមិនា២០០៦

រក្សាសិទ្ធិគ្រប់យ៉ាង

# សូមឧទ្ទិសចំពោះ

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី **សុវណ្ណធី ធម្មិកា បារមីបុណ្យ** ជាបុត្រីទោល
- លោកឪពុក ប៊ុនថង និងអ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់
- លោកគ្រូប៊ុនឈុននាម លោកគ្រូប៊ុនណាំ អ្នកគ្រូអ៊ុកវ៉ាន់ថា លោកគ្រូរស់សាន់
- លោកគ្រូអ្នកគ្រូរបស់នាងខ្ញុំទាំងអស់
- អ្នកគ្រូទូចសារៀង អ្នកគ្រូកែវសុផុន លោកគ្រូលីតាយហុង ជាមិត្តសំលាញ់ទាំងបី
- លោកគ្រូរីនរស់ អ្នកគ្រូមៀចសុខារី អ្នកគ្រូស៊ីមចាន់យ៉ា
- អ្នកនាងប៉ក់ដារិនី អ្នកនាងមាឃបេងយង់ លោកលេកស៊ីវហុង
- លោកខូតារាឫទ្ធិ នាយកគ្រប់គ្រង សមូហកម្មអក្សរសិល្ប៍នូហាច ភ្នំពេញ
- លោកអ៊ឹមសុនាថ លោកជាសយនា លោកជិនសោរិន កាសែតកោះសន្តិភាព។




អ្នកស្រី កែវ ចន្ទ័បូរណ៌
រដ្ឋមិនីសូតា សហរដ្ឋអាមេរិក
khmervissal@yahoo.com
www.angkorwat.com

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្ទឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្អែកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្អែក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្នើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង លីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិដេដ្ឋភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភួងមាលា
៣៦- រឿង វាយោដួងចិត្ត

# វាចាអ្នកនិពន្ធ

សំនៀងស្នេហ៍កវីជាកំរងមនោសញ្ចេតនា ដែលកើតឡើងដោយការបូជាពលី របស់បុរសមួយរូប ដើម្បីការពារកិត្តិយសនារីដែលត្រូវទ្រុស្តមិត្តយាយីប្រមាថ ធ្វើ អោយរូបគេក្លាយជាអ្នកទោសដួងចិត្តអស់ជាយូរឆ្នាំ ទំរាំទេវតាបើកព្រះនេត្របំភ្លឺផ្លូវជីវិតរបស់គេសាជាថ្មី ដើម្បីសេចក្តីសុខមួយដែលគេគិតស្មានមិនដល់ ។

សំនៀងស្នេហ៍កវីជារឿងប្រឌិតសុទ្ធសាធដោយមិនមានទាក់ទងនឹងជីវិតរបស់ បុគ្គលណាមួយនៅក្នុងសង្គមខ្មែរបច្ចុប្បន្នឡើយ ។ ចំពោះកំហុសអក្ខរាវិរុទ្ធ ដោយ អចេតនាទាំងឡាយនៅក្នុងសាច់រឿង សូមប្រិយមិត្តមេត្តាជួយកែសំរួលអោយបាន ត្រឹមត្រូវតាមវេយ្យាករណ៍ខ្មែរប្រពៃផង ។ សូមប្រសិទ្ធិពរជ័យដល់ប្រិយមិត្តអ្នក អានទាំងអស់អោយបានជួបតែវឌ្ឍនសុខ សុវត្ថិភាព និងសុភមង្គលរាល់ទិវារាត្រី ។

អ្នកនិពន្ធ

អ្នកស្រី កែវ ចន្ទ័បូរណ៍

ខែមិនា ឆ្នាំ២០០៦

# ទឹកត្រជាក់ត្រីកុំ

ខែក្ដៅទឹកខះត្រីនឹងស្លាប់ ច្មេះត្រូវប្រញាប់ពួនកាយា
ជីវិតកូនត្រីផុយយ៉ាងណា បើទឹកក្ដៅផ្សា រស់មិនបាន ។
ស៊ូនៅដេកពួនក្រោមសម្រាស់ ឫសឈើសែនក្រាស់ក្រែងរស់រាន
ត្បិតទឹកត្រជាក់ជួយត្រីក្សាន្ត ជាងទ្រាំរំខានទឹកក្ដៅស្រោច ។
កូនចៅស្រលាញ់ម្លប់ត្រជាក់ ម៉ែឪពំនាក់ផុតផ្សាខ្លោច
អប់រំប្រដៅជាប្រយោជន៍ ទូន្មានពីតូចដោយសីលធម៌ ។
ណែនាំកូនដោយពាក្យពិរោះ ខន្តីសប្បុរសយ៉ាងបវរ
ចាកផុតហឹង្សាផុតអស់មោហ៍ កូនៗត្រេកអរត្រេងត្រាប់យក ។
ម៉ែឪជាម្លប់ដ៏ត្រជាក់ កូនចៅពំនាក់ពឹងជំរក
បើសិនហឹង្សាក្ដៅវិបយោគ កូនចៅសោយសោកលង់វិបត្តិ ។
ក្នុងសង្គមវិញក៏ដូចគ្នា មេកោយកាចជាភូមិសង្កាត់
បើសិនយង់ឃ្នងអាងអុងអាត់ កូនចៅប្រាយបាត់ស្វាត់ដូចសេះ ។
មេកោយប្រមុខយុគសម័យ កាន់កាប់ទឹកដីថៃប្រទេស
បើសិនត្រជាក់កូនច្រើនស្វេះ បើមេឆាវឆេះកូននឹងស្លាប់ ។
តែបើត្រជាក់លាក់ចិត្តជា ស្រោចស្រង់ប្រជាសាងផលទ្រព្យ
សង្គមជឿនលឿនមានវិវត្តន៍ ថ្កុំថ្កើងគួរគាប់ត្បិតមេកោយជា ។

## ភាសារលត់ជាតិរលាយ

អ្នកស្រុកល្ងិតល្ងង់សរសេរខ្មែរ　　អ្នករៀនខ្ពស់ដែរស្ទើយខ្មែរអស់
អ្នកថ្កើងមុខការមានសក្តិយស　　រលត់ខ្មែរអស់សល់បរទេស ។
ស្មេរសារឆ្លើយឆ្លងជូនបងប្អូន　　អ្នកល្ងង់ដឹងខ្លួនមិនប្រហែស
សរសេរពាក្យខ្មែរឥតបើធ្វេស　　ប្លែកអីអ្នកចេះបរទេសពេញ ។
អ្នកខ្ពស់អ្នកថ្កើងស្មេរបារាំង　　អ្នកប្រាជ្ញខ្លាំងៗអង់គ្លេសវិញ
ភ្លេចថ្កើងភាសាជាតិនោះមិញ　　នាំគ្នាប្រដេញអំនួតអង្គ ។
កវីសែនស្តាយលោកអ្នកចេះ　　តម្រេះក្រាលមាសល្អថ្លាយង់
ចោលភាសាជាតិដ៏ផូផង់　　ហើយបែរតម្រង់បរទេសព្រាត ។
សូមចិត្តលោកចារភាសាខ្មែរ　　ឆ្លើយឆ្លងហូរហែនឹងផៅញាតិ
ខេមរាភាសាល្អវរនាថ　　ស្មេរខ្មែរជូនញាតិថៃជាតិយើង ។

**ត្រិះរិះ:** អ្នកដែលរក្សាភាសាជាតិបំផុតគឺអ្នកល្ងង់និងអ្នករៀនក៏រិតទាបត្បិតគេប្រើភាសា ខ្មែរតែម្យ៉ាងគត់ ដើម្បីប្រស្រ័យទាក់ទងគ្នាជាភាសានិយាយឬក៏ជាស្មេរ គឺគេមិនអាចយក ភាសាបរទេសមកប្រើជំនួសអោយបាត់បង់ឧត្តមភាពនៃខេមរាភាសាឡើយ ។

## ខ្មាំងរបស់ខ្មែរ

ខ្មាំងរបស់ខ្មែរមានជុំខ្លួន    មិនមែនចិនយួនសៀមលាវចាម
រាល់ថ្ងៃខ្មាំងចេញប្រដេញតាម    ទាញខ្មែររហាមអាប់ឱនថយ ។
ខ្មាំងមួយគឺភាពអវិជ្ជា    ល្ងង់ខ្លៅប្រាជ្ញាគិតថយក្រោយ
មិនស្វែងសិក្សាស្វែងឱបាយ    ជួយខ្លួនអោយស្បើយភាពក្រីក្រ ។
ខ្មាំងពីរគឺភាពកំជិលផេះ    មិនស្វែងតម្រេះសាងខ្លួនល្អ
គិតតែស្ទូមទានឫធ្វើចោរ    ទុច្ចរិតលិបលពេញភូមិស្រុក ។
ខ្មាំងបីគឺចិត្តស្រោបហឹង្សា    ផឹកស៊ីឡូឡាល្បែងអែអុក
វាយកូនប្រពន្ធបង្កទុក្ខ    ផ្អើលអស់ភូមិស្រុកមុខក្លាយស្វា ។
ខ្មាំងបួនគឺចិត្តទ្រុស្តមានះ    ប្រឹងយកតែឈ្នះមិនពិចារ
មិនស្តាប់ហេតុផលកែឫកពា    វង្វេងអាត្មាលង់មោហ៍បាំង ។
ខ្មាំងប្រាំគឺខ្មែរខ្វះសាមគ្គី    ចាប់ដៃសាងទីមានកំលាំង
អ្នកមានជាន់កអ្នកក្រក្រាំង    អ្នកមានស្រវាំងលង់ទឹកប្រាក់ ។
ខ្មាំងទីប្រាំមួយព្រួយជាងគេ    នោះគឺចិត្តខ្មែរលង់លោភៈ
មានហើយនៅខំមិនបណ្តាក់    ជាន់កក្បៀបប្រាក់ចាក់ក្រាលថ្នល់ ។
ខ្មាំងទីប្រាំពីរគឺសង្គម    អ្នកខ្ពស់ភ្លេចខំស្រាយកង្វល់
អ្នកទាបត្រូវឃ្មៀបយំរចល់    អ្នកគ្រាន់បែរយល់លោកដុល្លារ ។
ខ្មាំងទីប្រាំបីគឺសីលធមិ    ខ្មែរភ្លេចសាងល្អនឹងញាតិការ
លែងចេះអត់អោនមានមេត្តា    ប្រឹងតែហឹង្សាខែងយកឈ្នះ ។
ខ្មាំងទីប្រាំបួនកើនហែហូរ    ខ្មែរអកត្តញ្ញូភ្លេចខ្លួនច្បាស់
បំផ្លាញសម្បត្តិជាតិដេរដាស    ភ្លេចគុណលោកចាស់ថែកឱ្យថៃ ។

ឯខ្ទាំងទីដប់កប់ខ្លួនឯង　　ភ្នែកព្រិលចិត្តស្រែងមិនព្រមកែ
ពេលណាខ្មែរឡើងថ្កើងជាងគេ　　មិនបាច់គ្រូកែហារស្តីប្រាប់ ។
ខ្ទាំងចុងក្រោយនេះច្រេះសោតសល់　　មិនមានថ្ងៃយល់ផុតស្រអាប់
ជោរនឹងបុណ្យអង្គមិនប្រញាប់　　កែខ្លួនអោយឆាប់ភ្លឺជាថ្មី ។
ខ្ទាំងនៅច្រើនទៀតរាប់មិនអស់　　កវីសូមស្លេះពាក្យសំដី
ទុកអោយប្រិយមិត្តគិតកែឆ្នៃ　　បន្ថែមអត្ថន័យខ្ទាំងរបស់ខ្មែរ ។

# ភ្លឺ ល្អ ថ្លៃ មាំ

ភ្លឺអ្វីមិនស្មើមានវិជ្ជា        កោសល្យសិក្សាស្ពានចំណេះ
សប្បាយត្រេងត្រេកគ្រប់តម្រេះ        ជាយានជំនិះទៅថ្កុំថ្កើង ។
ល្អអីមិនស្មើចិត្តល្អជា        នឹងមនុស្សដូចគ្នាថៃជាតិយើង
មិនប្រទុស្តរាយមិនរំលើង        គិតតែដំកើងលើកទឹកចិត្ត ។
ថ្លៃអ្វីមិនស្មើមានសេរី        រស់នៅប្រពៃមានសុក្រិត
ជួបជុំគ្រួសារនិងញាតិមិត្ត        មិនរស់ភ័យភិតឃ្មៀបអំណាច ។
មាំអ្វីមិនស្មើនឹងសាមគ្គី        ជាធ្លុងសាងទីយ៉ាងអង់អាច
កក់ក្ដៅក្នុងចិត្តលែងគិតខ្លាច        ជាតិខាងខ្លួបខ្លាចត្បិតយើងក្លា ។

## វិបត្តិអ្នកក្រនិងអ្នកមាន

អ្នកក្រទុច្ចរិតត្បិតគំលាន អ្នកមានទុច្ចរិតត្បិតមហិច្ឆតា
អ្នកក្រធ្វើចោរព្រោះអវិជ្ជា អ្នកមានស្រវ៉ាព្រោះលោភៈ។
អ្នកក្រលួចគេរស់មួយពេល អ្នកមានក្រាស់ក្រែលកេងគ្មានអាក់
ស្រវ៉ាកើបក្បង់ខ្វះថង់ដាក់ ចាយក្រឡាប់ចក្រប្រាក់មិនអស់។
អ្នកក្របំរើពួកអ្នកមាន បានលុយផ្សះឃ្លានត្រឹម "ម៉ារស់"
អ្នកមានជីវិតគ្មានថ្ងៃលោះ អ្នកក្រអាប់យសរស់វេទនា។
លុះគ្រាច្បាប់ចេញប្រដេញកែង អ្នកក្រលេបស្លែងធ្វើមុខស្វា
អ្នកមានរួចខ្លួនអាងដុល្លារ អ្នកក្រខ្លោចផ្សារដេកក្នុងគុក។
សង្ឃឹមថ្ងៃមួយអ្នកមានសីល មមិលមើលឃើញសំណោកទុក្ខ
អ្នកក្រខ្វះជោគលង់កន្លុក ជួយស្រង់ផុតទុក្ខឃ្មោរៀបអ្នកមានទុច្ចរិត។

## សង្គម (១៩៨០)

យើងមានបន្លែជាអាហារ ត្បិតអ្នកចំការខំដាំដុស
ភូមិមានអង្ករស្រូវចំរុះ ត្បិតអ្នកស្រែចុះធ្វើទាំងស្រុក ។
យើងមានកណ្ដៀវកាំបិតកាប់ ពូថៅដឹងផ្គាក់ច្រើនសព្វមុខ
ព្រោះដៃជាងដែកដុតដំទុក ផលិតគ្រាន់គ្រប់ប្រើយារយូរ ។
ដោយសារស្នាដៃពួកជាងឈើ វត្ថុសារពើគ្រែតុទូ
សាងសង់លំនៅជ្រកហែហូរ យើងមានបរិបូណ៌មក៏ប្រើប្រាស់ ។
ឯរោងតំបាញមានកម្មករ ត្បាញក្រណាត់មក៏ប្រើមិនខ្វះ
រោងឡានមានជាងមីរដេរដាស យន្តយានថ្មីចាស់ច្បាស់លែងខូច ។
សំណង់គ្រឹស្ថានសែនបវរ ត្បិតវិស្វករឆ្នៃកែគួច
ស្ពានវែងផ្លូវល្អឡានធំតូច ផលិតចេញរួចយ៉ាងអស្ចារ្យ ។
នៅមន្ទីរពេទ្យវេជ្ជបណ្ឌិត ជំនាញពិសិដ្ឋថៃរក្សា
យើងឆាប់ធូរស្រាលចាករោគា សប្បាយចិន្តាគ្រាសះស្បើយ ។
បើសិនសិស្សឆ្ងល់សួរអែអ៊ូ គ្រូប្រឹងស្វែងរក៏អស់ចំលើយ
បំភ្លឺសាស្ត្រាចំងល់ស្បើយ សិស្សរៀនខ្ពស់ហើយថ្កើងសង្គម ។
ជាតិគ្មានទាហានពើងទ្រូងការ ម្ល៉េះសមបច្ចាមិត្រចូលជ្រៃ
ឈ្លានពានទឹកដីធ្លោយទុក្ខធំ ស្រែក្រុងដីភ្នំស្លុងដៃខ្លាំង ។
ច្នេះយើងទាំងឡាយគប្បីគិត កាន់ដៃក្រៀករិតរួមកំលាំង
សាងសង្គមយើងអោយក្លាខ្លាំង កុំច្បាំងប្រទុស្តតែគ្នាឯង ។
គ្មាននរណាគ្រាន់ជាងនរណា ខ្មែរគ្រប់សក្តាត្រូវចេះក្រែង
នាទីមុខងារមានផ្សេងៗ ម្នាក់ឯងមិនអាចជ្រែងបានឡើយ ។
ត្រូវដឹងនាទីខ្លួនម្នាក់ៗ បំរើភារៈកុំកន្តើយ
មុខងារសំខាន់ដូចគ្នាហើយ យកមួយខ្វះមួយព្រួយមិនខាន ។
នាទីយើងល្អដូចៗគ្នា ខ្វះមួយរងាខ្វល់ពេញប្រាណ
ជាតិក៏ឱនថយមិនថ្កើងថ្កាន ដូចស្រីកល្យាណខ្វះលក្ខិណា ។

បើយើងគ្រប់គ្នាស្គាល់តំលៃ ភារៈគ្រប់វ័យល្អថ្លៃថ្លា
បំរើសង្គមស្មើៗគ្នា នោះជាតិខេមរានឹងថ្កើងថ្កានរុងរឿង
ជាមិនខាន!!!

## ផ្លែខ្នុរ (១៩៨៤)

ខ្នុរមានសំបកសុទ្ធបន្លា ខុសពីផលាផងដទៃ
តែផ្លែមានឈ្មោះប្រជាប្រិយ អ្នកស្រុកប្រុសស្រីធីសមចិត្ត ។
ផ្លែខ្ចីយកស្លម្ជូរកកូរ ពេលទុំគេយក៏បកសិរិត
ក្លែបផ្អែមក្រអូបលឿងប្រណិត ចែកញាតិឆ្ងាយជិតធីភោក្តា ។
សំលឹងតំលៃត្រឹមសំបក យើងច្បាស់ជាខកអស់ចិន្តា
ដូចមនុស្សខ្វះរូបមានប្រាជ្ញា សំបកក្រៅជាមិនអាចវាស់ ។
កិរិតវិជ្ជាចំណេះដឹង តំលៃមនុស្សហ្នឹងពិតខ្ពង់ខ្ពស់
ត្រឹមតែសំបកមិនអាចវាស់ ជាអ្នកទាបខ្ពស់កិរិតអ្វី ។
ខ្នុរពឹងរសជាតិក្លែបគន្ធា មនុស្សពឹងវិជ្ជាការឈ្លាសវៃ
កិរិយាសមរម្យអមសំដី ពិរោះអត្ថន័យស្ដីហៅញាតិ ។
ច្នេះកុំសំលឹងត្រឹមរូបក្រៅ ត្រឹមក្របសៀវភៅថាវរនាថ
យើងត្រូវស្វែងយល់ខាងក្នុងទៀត កុំឱ្យឃ្លាឃ្លាតខ្លឹមប្រពៃ ។

ផ្លែខ្នុរពឹងក្លែប មនុស្សពឹងគំនិត រសជាតិល្អពិត ស្ថិតខ្លឹមខាងក្នុង!!

## ញញឹម (២០០០)

គ្រាន់តែញញឹមមិនខាតអ្វី ញញឹមប្រឹមប្រិយមានមង្គល
ញញឹមស្រស់ស្រាយគ្រប់កាយកល រាសីនិមលខ្ពស់ជតា ។
ញញឹមជូនញាតិគេត្រេកអរ ថាយើងចិត្តល្អមានមេត្តា
រាប់អានមិត្តញាតិជាតិខេមរា អ្នកភូមិផងគ្នាជាបងប្អូន ។
ញញឹមនាំមកនូវសប្បាយ សុខាគ្រប់កាយផុតស្រពោន
ញញឹមនាំមិត្តច្រើនជុំខ្លួន ញញឹមសមសួននាំក្តីសុខ ។
ញញឹមនាំស្រាន្តដល់អ្នកព្រួយ ញញឹមនឹងជួយអ្នកអផ្សុក
ផ្តល់កំលាំងចិត្តអ្នកមានទុក្ខ ជារស្មីសុខដល់អ្នកឈឺ ។
ញញឹមសាងនូវក្តីរាប់អាន នាំញាតិលំអានជួបពន្លឺ
រស្មីសុភមង្គលភ្លឺ ញញឹមពិតនាំនូវជោគមង្គលគ្រប់ប្រការ ។

## ថ្នាំគ្រុនចាញ់ (១៩៩៥)

គ្រុនចាញ់ពេទ្យប្រាប់លេបគីនីន   រសជាតិសែនល្វីងខ្ទីមណាស់រឿយ
ទោះបីយល់ថាលេបហើយស្បើយ   ក៏ចិត្តនៅឡើយខ្ទីមជាតិថ្នាំ ។
លុះបែរប្រទះផ្លែស្វាយទុំ   ទន្ទេញរង់ទាររកញុំាំ
បានមួយចំណិតសុំថែមប្រាំ   លេបផុតលែងទ្រាំគ្រុនជាថ្មី ។
គីនីនដូចពាក្យម៉ែប្រដៅ   ស្តាប់ទៅទាស់ចិត្តត្បិតល្វីងប្រៃ
ពាក្យម៉ែនាំល្អតែមិនខ្វី   ស៊ូគ្រុនអោបដៃញ័រញាក់ប្រាណ ។
ឯស្វាយទុំផ្អែមជាតិពិសពុល   កូនគ្រុនដេកឈ្ងុលពន់ប្រមាណ
បែរធ្មេចមិនជឿពាក្យទូន្មាន   មិនផឹកទេថ្នាំញុំាំស្វាយវិញ ។
ជីវិតឈាមរាវដូចជាតិស្វាយ   គ្រេបផ្អែមសប្បាយឥតទោម្ទេញ
ទោះបីដឹងថាស្វាយនោះមិញ   នាំរូបអ្នកវិញគ្រុនមិនជា ។
ថ្វីបើគីនីនល្វីងយ៉ាកផឹក   បើកូនបែរនឹកតាមមាតា
ម្ល៉េះសមកូនចាកអស់រោគា   ផុតឈឺអង្គានិងអន្តរាយ!!!

## ទ្រខ្មែរខ្សែបី (១៩៨០)

ទ្រខ្មែរខ្សែបីលាន់គ្រលួច សព្ទសៀងខាបគួចយកអារម្មណ៍
ឆ្លើយឆ្លងសំលេងវៃរងំ ព្រលប់ជើងភ្នំក្នុងសន្ធិយា ។
សៀងទ្រស្រទន់សណ្តំចិត្ត ស្តាប់ភ្លេងប្រណិតលង់ទ័យា
ទ្រខ្មែរអង្រួនអស់សោតា កុលបុត្រធិតាខេមរាជាតិ ។
សុរិយ៍យាងលានភាមាស ចាំងសែងឱភាសល្អវរនាថ
សៀងទ្ររសាត់ដាស់អស់ញាតិ ខ្មែរអើយកុំឃ្លាតក្តីមេត្តា ។
ស្លឹកដូងយោលយោគរេតាមខ្យល់ ផ្សំសៀងនិមលទ្រខេមរា
លាយឡំសំលេងសព្ទបក្សា ហាក់សៀងមាតាអង្វរកូន ។
ឱកូនមាសម្តាយចូរកុំភ្លេច រក្សាជានិច្ចណាំបុត្រស្ងួន
ការកើ្តជាតិខ្មែរកុំអោយសូន្យ កុំពើភ្លេចខ្លួនណាំកូនណាំ ។
ទ្រខ្មែរម៉ែផ្តាំបុត្រវរលក្ខណ៍ សូមកូនចាំជាក់ក្នុងចិន្តា
មានតែកូនទេថែរក្សា ពុំមានជាតិណាស្រលាញ់ខ្មែរជាងខ្មែរឡើយ!

អ្នកស្រីកែវចន្ទ័បូរណ៏

កំណាព្យ កំរងកែវ និងចម្រៀង

និពន្ធដោយអ្នកស្រីកែវចន្ទ័បូរណ៍


| | | | |
|---|---|---|---|
| ១. | បេះដូងរន្ធត់ | ទំព័រ | ២៩ |
| ២. | ស្រលាញ់ | ទំព័រ | ៣៩ |
| ៣. | រាត្រីរងា | ទំព័រ | ៤២ |
| ៤. | ម្កុដផ្កាស្មៅ | ទំព័រ | ៥១ |
| ៥. | ពន្លឺសុភមង្គល | ទំព័រ | ៦៣ |
| ៦. | សច្ចា | ទំព័រ | ៧២ |
| ៧. | អង្រឹងស្នេហ៍រមនា | ទំព័រ | ៧៨ |
| ៨. | ស្រស់ឆោម | ទំព័រ | ១៣១ |
| ៩. | រាត្រីក្បែមក្សាន្ត | ទំព័រ | ១៣៥ |
| ១០. | រង់ចាំ | ទំព័រ | ១៣៨ |
| ១១. | សំនៀងស្នេហ៍កវី | ទំព័រ | ១៥៤ |
| ១២. | បង្អែកជីវិត | ទំព័រ | ១៧១ |
| ១៣. | ព្រាត់ដើម្បីជួប | ទំព័រ | ១៧៦ |
| ១៤. | សន្សើមដួងចិត្ត | ទំព័រ | ២០៤ |
| ១៥. | ម្កុដផ្កាស្លា | ទំព័រ | ២០៨ |
| ១៦. | ទេពអប្សរកំពូលដួងចិត្ត | ទំព័រ | ២១៤ |

# វគ្គទីមួយ
# និស្ស័យ

ជាយក្រុងបាត់ដំបង តាមដងស្ទឹងសង្កែ លើផ្លូវទៅបាណន់...

នៅសាលាបឋមសិក្សាវត្តគរ...

អ្នកគ្រូសារៀងជាចាងហ្វាងសាលាកំពុងដឹកដៃកុមារីតូចមួយរូបអាយុ ប្រហែល៦ឆ្នាំសំដៅថ្នាក់រៀនមួយ ។ ភ្លាមនោះ អ្នកគ្រូដ៏ក្មេងច្រឡឹងយ៉ាង ស្រស់ស្អាតមួយរូបដើរចេញពីក្នុងថ្នាក់មកទទួល ។

- ជំរាបសួរអ្នកគ្រូភារាណី (អ្នកគ្រូសារៀងមានប្រសាសន៍ឡើង) ថ្ងៃនេះ សាលាយើងទទួលបានកុមារីម្នាក់ទៀតហើយ ។ នាងតូចទើបតែត្រូវឪពុក យកមកចុះឈ្មោះចូលរៀនអំបាញមិញនេះឯង ។

អ្នកគ្រូភារាណីក្រលេកឃើញកុមារីភ្លាមក៏ញញឹមឡើង :

- សួស្តីនាងតូច! នាងឈ្មោះអីដែរ? អាយុប៉ុន្មានហើយ?
- ចាំស ឈ្មោះសោភាអាយុ៦ឆ្នាំហើយ អ្នកគ្រូ!
- នាងតូចទើបតែចូលរៀនលើកដំបូងទេមែនទេ?
- ចាំស ខ្ញុំឈឺទើបតែជា... ទើបពុកនាំខ្ញុំមកចុះឈ្មោះថ្ងៃនេះចាំស!

រំពេចនោះអ្នកគ្រូសារៀងមានប្រសាសន៍ថា :

- សាលាយើងបើកចូលរៀនពីរអាទិត្យមកហើយ ប្រហែលជាអ្នកគ្រូត្រូវ ជួយបង្ហាត់បង្រៀនថែមទៀត ទើបគេអាចចូលផ្លូងនឹងកម្មវិធីសាលាវិញ បាន ។ សូមអ្នកគ្រូជួយមើលផង ។
- ចាំសអ្នកគ្រូ! នេះជាភារៈរបស់ខ្ញុំស្រាប់ហើយ សូមទទួលដោយរីករាយ!

បន្តិចមក អ្នកគ្រូចាងហ្វាងក៏ដើរចេញទៅវិញទៅ ទុកអោយអ្នកគ្រូ ភារាណីដឹកដៃនាងតូចចូលទៅក្នុងថ្នាក់រៀន ។ មើលទៅកុមារីនោះ គួរឱ្យ ស្រលាញ់ណាស់ ពិតមែនតែនាងស្លៀកពាក់របៀបក្រីក្របន្តិចក៏ដោយ ក៏ ឫកពាររបស់នាងស្រស់ស្រាយទន់ភ្លន់ ហើយមានទឹកមុខញញឹមយ៉ាងបំព្រង ហាក់ដូចជានាងបានទទួលនូវភាពកក់ក្តៅក្នុងគ្រួសារគ្រប់គ្រាន់ ។ ប៉ុន្តែ មិន ដឹងជាហេតុអ្វីទេ តាំងពីអ្នកគ្រូភារាណីយើងបានជួបកុមារីសោភានេះពេល ណាមក អ្នកគ្រូមានអារម្មណ៍ថា ខ្លួនមាននិស្ស័យជាមួយកុមារីនេះយ៉ាង

ជិតជិតតែម្តង។ នាងតូចដើរកាត់វាលស្រែជាមួយក្រុមកុមារពីរបីនាក់រៀង រាល់ថ្ងៃ មកសាលាត្រឹមត្រូវទាន់ពេល ដូចក្មេងផងទាំងពួងដែលនៅម្តុំ១ នោះដែរ ថែមទាំងជូនកាលមានកាច់ផ្កាពីវាលស្រែផ្ញើអ្នកគ្រូទៀតផង។

និយាយអោយពិតទៅ អ្នកគ្រូភារាណីក៏ជាបុគ្គលិកថ្មីនៅសាលាបថម សិក្សានេះដែរ។ នេះជាឆ្នាំដំបូងហើយដែលអ្នកគ្រូចូលបង្រៀនសិស្ស។ ដូច នេះ ទាំងភារាណី ទាំងនាងតូចសោភាសុទ្ធតែជាមនុស្សចំណូលថ្មីក្នុងសាលា នេះដូចគ្នា។

ជាច្រើនខែកន្លងទៅ...

កុមារីសោភាដើរមកដល់ថ្នាក់រៀនមុនគេ ថែមទាំងមានកាន់អ្វីលាក់ពី ក្រោយខ្នងផង។ លុះមកដល់ប្រទះអ្នកគ្រូដ៏ស្រស់ស្អាតរបស់នាង ធិតាក៏ ពោលឡើងថា :

- ថ្ងៃនេះជាថ្ងៃពិសេសសំរាប់អ្នកគ្រូ សោភាមានអ្វីមកផ្ញើអ្នកគ្រូណា៎!

អ្នកគ្រូភារីណីដែលកំពុងនៅអង្គុយឈ្ងោកសរសេរនៅតុ ក៏ងើបមុខ ឡើងបែរមើលមកម្ចាស់សំដី។ លុះប្រទះនាងតូចយើង អ្នកគ្រូក៏ញញឹម ឡើងយ៉ាងស្រស់ស្រាយ :

- សោភាបានអ្វីទៅមកផ្ញើ អ្នកគ្រូ? អ្នកគ្រូចង់ដឹងណាស់!

- នេះនែ៎... ស្អាតទេ អ្នកគ្រូ?

នោះគឺជាកំរងផ្ការាជដ៏មានពណ៌លឿងឆ្នៅគួរអោយចេតនា។ នាង តូចក៏ស្រដីទៀតថា :

- ខ្ញុំបានអោយពុកបេះក្រង ដើម្បីខ្ញុំយកមកផ្ញើអ្នកគ្រូជាទីស្រលាញ់របស់ ខ្ញុំនោះអី ព្រោះជិតចូលឆ្នាំខ្មែរហើយ អ្នកគ្រូនឹងមានសំណាងល្អ។

អ្នកគ្រូភារាណីទទួលយកកម្រងផ្កាមកពាក់ហើយក៏សួរនាងថា :

- ម៉េចក៏សោភាដឹងកើត ថាអ្នកគ្រូសំណាងល្អ?

- ព្រោះអ្នកគ្រូជាអ្នកគ្រូដ៏ល្អរបស់សោភាខ្ញុំនោះអី ដូច្នេះទេវតានឹងតាមថែ រក្សាអ្នកគ្រូជានិច្ច។

ឮសំដីលើកទឹកចិត្តយ៉ាងពិរោះរបស់កុមារី អ្នកគ្រូយើងញញឹមសាជាថ្មី បញ្ចេញថ្ពាល់ខួចគួរអោយបេតី :

- នាងតូចសំដីពិរោះណាស់! មើលទៅ ឪពុកម្តាយរបស់នាងប្រដៅប្រដៅ កូនបានល្អប្រពៃណាស់។

- សោភាមានតែឪពុក មិនមានម្តាយទេ តែពុករបស់សោភាក៏ជាមនុស្សល្អ ដូចអ្នកគ្រូអញ្ចឹងដែរ។

- អូហ៎.. ពុទ្ធោ! គួរអោយស្រណោះនាងតូចណាស់... ហើយចុះនាងមាន បងប្អូនដែរទេ?

- ចាំស គ្មានទេ (នាងតូចគ្រវីក្បាល) មានតែម្នាក់ឯងនិងពុកតែប៉ុណ្ណោះ។ អូហ៎.. មានបងប្រុសម្នាក់ដែរ ចាំស!...

រំពេចនោះ ស្នូរជួងក៏លាន់រន្ថើនឡើងជាសញ្ញាថាដល់ម៉ោងចូលថ្នាក់ រៀនហើយ។ អ្នកទាំងពីរក៏អាក់ខានការសន្ទនាទៀតទៅ។ ថ្ងៃត្រង់ គេក៏ បំបែកជួរធ្វើដំណើរទៅកាន់គេហដ្ឋានរៀង១ខ្លួន។

អ្នកគ្រូភារាណីឡើងជិះម៉ូតូបរសំដៅទៅផ្ទះ ស្រាប់តែប្រទះនឹងមិត្ត ភក្តិពីរនាក់បើកឡានមកដល់ :

- ភារាណី! សុខសប្បាយទេហ៎?

- អូហ៎ ដាវ៉ាន់ រតនា អ្នកទាំងពីរមកពីណាទៅណាបានជាមកដល់ស្រុកភូមិ ខ្ញុំនេះ?

- នឹកភារាណីឯងហ្នឹងណា បានជាមកលេង។ នែ! សាលាឯងមិនទាន់វ៉ាកង តូចទេហ៎ បានជា...

- នៅទេ! វ៉ាកងអាទិត្យក្រោយ។ ម៉ោះ! ចូលលេងផ្ទះខ្ញុំសិន! បែកគ្នាយូរ ហើយ មិនដឹងឯងសុខទុក្ខយ៉ាងណាដែរ?

អ្នកគ្រូភារាណីក៏បរម៉ូតូនាំមុខអ្នកទាំងពីរ មកដល់ដីឡូត៍ចំការដំណាំ មួយនៅតាមផ្លូវឡើងទៅលើ តាមដងស្ទឹងសង្កែ ដែលមានផ្ទះឈើធំមួយ សង់យ៉ាងស្អាតវិចិត្រនៅចំកណ្ដាលដីភូមិ។ បន្ទាប់មក អ្នកគ្រូយើងក៏លើក ទឹកត្រជាក់មកទទួលមិត្តរបស់នាងភ្លាម។ រតនាក៏សួរទៅថា :

- ឪពុកម្ដាយឯងមិននៅទេ ភារាណី?

- ថ្ងៃនេះ ប្រហែលជាគាត់នៅចំការហើយ ទៅមើលកម្មករធ្វើការ

- អូហ៎ គាត់ធ្វើចំការដាំអ្វីដែរ?

- ដាំក្រូច ដាំម្នាស់ និងខ្ទឹមបន្តិចបន្តួច តែខែនេះជាខែប្រាំង ទាល់តែបូមទឹក ស្រោចទើបដំណាំអាចរស់បាន។

រំពេចនោះ ស្រាប់តែមានរថយន្តមួយទៀតបរចូលមកដល់ដែរ។ ភារាណីបែរសម្លឹងមើលទាំងឆ្ងល់ ស្រាប់តែដាវ៉ាន់ពោលឡើង :

- នោះគឺលោកកោមល ឯងចាំទេ? គេបានសុំមកលេងនឹងឯងដែរ... ខ្ញុំក៏ ហៅគេអោយមកជាមួយទៅ។

ភារាណីធ្វើមុខភាំងពេលដែលឃើញលោកកោមលចុះពីរថយន្ត ដើរ សំដៅចូលទៅក្នុងផ្ទះ :

- ជំរាបសួរអ្នកគ្រូភារាណី! ខានឃើញយូរនៅតែស្រស់ដដែល។

ភារាណីលើកដៃសំពះទទួលស្វាគមន៍ភ្ញៀវដោយសុភាព :

- ចាំស! ជំរាបសួរ! តើខ្យល់អ្វីទៅដែលបក់លោកអោយធ្វើដំណើរតាំងពី ភ្នំពេញរហូតមកដល់ទីនេះដែរ?

- មិនមែនខ្យល់បក់ទេ តែការពិត គឺជាក្លិនផ្កាភូមិវត្តគរដ៏ក្រអូប បានអូស ទាញរូបខ្ញុំមកទេតើហ៎!

លោកកោមលតបវិញដោយក្រសែភ្នែកមានបង្កប់អត្ថន័យចំពោះអ្នក គ្រូដ៏ប្រិមប្រិយរបស់យើង។ ឮសំដីផ្អែមល្ហែមដូច្នោះ ភារាណីក៏នៅស្ងៀមហើយ ក៏ដូរប្រយោគភ្លាម :

- រតនា ដាវ៉ាន់ ចង់ទៅលេងចំការទេ? ខ្ញុំជូនទៅ នឹងអាលជួបពុកម៉ែរបស់ ខ្ញុំផងណា៎។

លោកកោមលក៏សុំខ្លួនទៅដែរ :

- សូមធ្វើអង្គរក្សជូនដំណើរសុភាពនារីទាំងបីផងបានទេបាទ?

ភារាណីមិនឆ្លើយទេ។ នាងក៏ស្រវាមួកមកពាក់ដើរនាំមុខអ្នកទាំងបី ចេញទៅកាត់តាមក្រោយផ្ទះ លើផ្លូវលំក្រវិកក្រវក់មួយស្របក់ក៏មកដល់ ចំការ។ តាមផ្លូវ រតនាសួរថា :

- ភារាណី! ឯងរៀនបានយ៉ាងច្រើនសន្ធឹកសន្ធាប់ តែហេតុអីបានជាមក
ធ្វើគ្រូបង្រៀនកំប៉ិកំប៉ុកនៅសាលាបឋមសិក្សាឯជនបទនេះទៅវិញ?

ភារាណីញញោចស្នាបន្តិច ក៏ឆ្លើយវិញថា :

- មកពីគ្នាចង់នៅជិតពុកម៉ែចាស់ៗហ្នឹងណា៎។

- មិនមែនទេដឹង? ខ្ញុំថាឯងប្រាកដជាកំពុងតែរត់គេចពីនរណាហើយ...

រតនានិយាយផង លួចចោលកន្ទុយភ្នែកដាក់លោកកោមលផង។ មែន ហើយ
លោកកោមលជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យភូមិន្ទភ្នំពេញ នៅ លីវយូរហើយ មិនដែលនឹកគាប់ភ្នែកគាប់ចិត្តនារីណាទេ
ទើបតែមកបើក ភ្លើងខៀវ នៅពេលដែលគេបានជួបអ្នកគ្រូភារាណីនៅផ្ទះដាវ៉ាន់ កាលពី ប៉ុន្មានខែមុននេះ
មុននឹងភារាណីត្រលប់មកបាត់ដំបងវិញ ក្រោយពីធិតា បញ្ចប់ការសិក្សាបានទទួលបរិញ្ញាបត្រ័មក។ ទាំងពីរនាក់ រតនានិង ដាវ៉ាន់
ជាមិត្តសម្លាញ់របស់ភារាណី តាំងពីគេរៀននៅវិទ្យាល័យនេតយ៉ង់មក ម្ល៉េះ។
ដាវ៉ាន់ជាអ្នកណែនាំផ្សាភ្ជាប់អោយភារាណីនិងកោមលឱ្យបានស្គាល់ គ្នាជិតដិត តែរតនាបែរជាអ្នកទប់ស្កាត់ទៅវិញ មិនដឹងថា
អ្នកទាំងពីរមាន បំណងអ្វីទេដែលគេគិតផ្ទុយគ្នាធ្វើផ្ទុយគ្នា ដើម្បីមិត្តនីរបស់ខ្លួនតែម្នាក់នោះ ឡើយ។
ចំណែកភារាណីវិញក៏ហាក់ដូចជាស្ងៀមស្ងាត់ មិនឃើញបញ្ចេញ អាកប្បកិរិយាអ្វីប្លែកដែលថា
នាងពេញចិត្តនឹងលោកគ្រូកោមលដែរឃើញ តែរាប់អានគ្នាធម្មតាៗប៉ុណ្ណោះ។

ពេលមកដល់កណ្ដាលចំការក្រូចមួយដែលមានដាំជាជួរៗ អ្នកទាំងបួន ក៏ប្រទះឃើញរងខ្ទឹដាំជាជួរ នៅតាមចន្លោះដើមក្រូច។
នៅជួរខ្លះ មានដាំ ម្ទេសដែលកំពុងដកកបញ្ចេញផ្លែរហង់ មើលទៅគួរអោយស្រក់ទឹកមាត់ ចង់ឆី។ ភ្លាមនោះ
គេក៏ប្រទះអ្នកស្រុកម្នាក់កំពុងជួសជុលម៉ាស៊ីនទឹក ភារាណី ក៏សួរគាត់ថា:

- ពូសេត! ម៉ែពុកគាត់នៅក្នុងចំការទេ?

- នៅ! តែកំពុងសំរាកជើងនៅក្នុងខ្ទមឯជាយចំការឯណោះ។

ពូសេតនិយាយផងបូញមាត់ចង្អុលផង។ ធិតាក៏នាំមិត្តដើររឹងបន្តទៀត ស្រាប់តែ លោកគ្រូកោមលស្រែកឡើង :

- អីយ៉ាស់! អីយ៉ូយ! យើងឈប់ត្រឹមហ្នឹងបានទេ ភារាណី មើលទៅខ្ញុំទ្រាំ មិនបាននឹងលុយបន្លាម្ទេសក្នុងចំការនេះទេ។

ភារាណីមិនទាន់ឆ្លើយផង ស្រាប់តែរតនាឆ្លើយជួសមុនបាត់ :

- លោកគ្រូកោមលស្លៀកខោជើងវែងហើយទៅរអ៊ូធ្វើអី បន្លាមានទៅមុត អ្វីដល់សាច់នោះ...

- ហែសៗ តែវាមុតជើកខោរហែកអស់សោភ័ណនោះអី...

មើលទៅលោកគ្រូកោមលហាក់ដូចជាប្រកាន់ខ្លួនណាស់ មិនចង់ដើរ កាត់ចំការ
អោយប្រលាក់ខោអាវដ៏សមរម្យរបស់លោកទេ។ រំពេចនោះ ស្រាប់តែអ្នកទាំងអស់ឮសំលេងហៅ :

- អឺ! នាងណី.. កូននាំនរណាគេមកហ្នឹងកូន?

- ចាំសម៉ែ! គឺមិត្តរបស់កូនបីនាក់ គេចង់មកឃើញចំការរបស់យើង។

ភារាណីក៏ម្ចីម្នានាំអ្នកទាំងបីមកដល់កូនខ្ទមមួយ ដែលសង់មានតែ ដំបូលនិងគ្រែ គ្មានជញ្ជាំងទេ។ នៅទីនោះ គេឃើញបុរសចាស់ម្នាក់ក្នុងវ័យ ខ្ទង់ហា កំពុងទំរេតកាយនៅក្នុងអង្រឹងចងនៅក្នុងម្លប់ខ្ទម និងស្ត្រីចំណាស់ម្នាក់ទៀតកំពុងបង្វិលកន្ទេលរៀបចែកភ្ញៀវអង្គុយ។ នោះគឺមេឃុំផែងនិង ប្រពន្ធរបស់គាត់ឈ្មោះមីងផាវជាឪពុកម្តាយរបស់អ្នកគ្រូភារាណី។ ភ្លាម នោះ ភ្ញៀវទាំងបីក៏លំទោនកាយគារវៈចំពោះមេឃុំនិងប្រពន្ធគាត់យ៉ាង សមសួន។ មីងផាវក្រលេកឃើញមាណវីទាំងពីររូបក៏លាន់មាត់ឡើង :

- យីអើ! នោះគឺដារ៉ាន់និងរតនាទេហ៎... យី! មីងមើលឯងទាំងពីរសឹងតែ មិនស្គាល់តែម្តង! ហើយសព្វថ្ងៃរកស៊ីធូរធារទេដឹងបានជាមានសាច់ឈាម ល្អប្រសើរយ៉ាងនេះ?

រតនានិងដារ៉ាន់ងាកសម្លឹងមុខគ្នាហើយញញឹម។ បន្តិចមក រតនាមាន វាចាតបទៅគាត់ថា :

- ដារ៉ាន់គេធូរធារណាស់មីង ! ខុសតែខ្ញុំទេដែលមិនទាន់រកការបានធ្វើ..

- អឺ! បន្តិចទៀតរកការបានធ្វើក៏ធូរធារដូចគ្នាដែរហើយណា៎! មីងសូមជូន ពរអោយឆាប់បានការធ្វើផង។

រំពេចនោះ មីងយើងដាក់ភ្នែកឃើញលោកគ្រូកម្លោះ ក៏សួរថា :

- ហើយមីងនិងពូមានដែលជួបក្មួយពីមុនមកទេ?

លោកគ្រូកោមលក៏ឆ្លើយវិញថា :

- នៅទេបាទ! ខ្ញុំជាសាស្ត្រាចារ្យនៅភ្នំពេញ ជាមិត្តរបស់អ្នកទាំងបីនេះបាទ

ភ្លាមនោះ លោកកោមលហាក់ចាប់អារម្មណ៍ថា មេឃុំផែងកំពុងតែ សម្លឹងមករូបលោកដោយក្រសែភ្នែកយ៉ាងមុត ហាក់ដូចជាកំពុងចង់វិភាគ ពីគុណសម្បត្តិចរិយារបស់លោកតែម្តង ធ្វើអោយលោកគ្រូយើងបែក ញើសក្តៅខ្លួនភាយ។ ការពិត មីងផាវជាមនុស្សស្រដីរួសរាយណាស់ ខុសពីពូមេឃុំដែលមានសំដីម៉ាត់ៗបំផុត ម្ល៉ោះហើយនរណាក៏ខ្លាចគាត់ដែរ ព្រោះគាត់មិនចូលចិត្តនិយាយលេងសើចកំប្លែងដាក់នរណាទេ គឺសាច់ការ ជានិច្ច។ ចៃដន្យ ពេលនោះ លោកគ្រូកោមលជាមនុស្សមានប្រាជ្ញនិង វោហារពិរោះ ជាពិសេសពេលជជែកគ្នាពីរឿងសង្គមទូទៅនិងការចាត់ ចែងក្នុងសង្គម ធ្វើអោយមេឃុំផែងនឹកចង់សួរហើយសួរទៀត រហូតដល់ ទៅក្លាយជាវេញធ្លុងមួយជាមួយគ្នាតែម្តង រហូតដល់ជក់មាត់ភ្លេចការងារក្នុងចំការអស់រលីង។

នៅក្នុងឱកាស ដែលលោកកោមល និងមេឃុំផែង ជជែកគ្នាពីនេះ ពីនោះ មីងផាវបាននាំរតនានិងដារ៉ាន់ទៅបេះក្រូច ទុកអោយភារាណីនៅ ក្បែរឪពុកក្រែងលោលោកមានការត្រូវប្រើ។ កាលបើឃើញឪពុកជក់មាត់ សំណេះសំណាលជាមួយលោកកោមល ភារាណីក៏ដើរទៅជាយចំការឈរ មើលក្មេងរត់ប្រលែងគ្នានៅវាលស្រែ ខ្លះបង្ហោះខ្លែង ខ្លះឡើងដើមឈើ ស្រែកច្រៀងខ្ញើយៗ ខ្លះកំពុងបាចទឹកថ្លុករកត្រី ខ្លះរត់ប្រដេញគ្នាប្រលែង សើចអឹងកងគួរអោយសប្បាយណាស់។ ធិតាក៏នឹកគិតសង្វេគដល់ខ្លួននាង ដែលជាបុត្រីទោលរបស់មេឃុំ

រស់នៅក្នុងដង្ហែបវិន័យគ្រួសារយ៉ាងតឹងរ៉ឹង មិនធ្លាប់មានមិត្តភក្តិទៅមកឡើយ ក្រៅតែពីដាវ៉ាន់និងរតនាដែលពូមេឃុំស្គាល់ក្រុមគ្រួសាររបស់គេច្បាស់លាស់ ។

វិពេចនោះ ភារាណីចាប់ភ្លឹកថា ក្នុងចំណោមក្មេងដែលរត់លេងទាំង ឡាយនៅកណ្តាលវាលស្រែនោះ នាងបានឃើញសោភាដែលជាកូនសិស្ស របស់នាងកំពុងរត់លេងយ៉ាងសប្បាយនៅលើភ្លឺស្រែ ។ ធិតាយើងបែរទៅក្រោយឃើញឪពុករបស់នាងនៅជជែកគ្នាជាមួយលោកកោមលភ្លេចខ្លួន ក៏ លួចដើរសសៀរចេញពីចំការ សំដៅទៅរកនាងតូចភ្លាម :

- សួស្តីនាងតូច!

កាលបើក្រលេកឃើញអ្នកគ្រូភ្លាម សោភាក៏ញញឹមពព្រាយឡើង :

- អ្នកគ្រូ! អ្នកគ្រូភារាណី! ពួកយើង មើលហ្នែក! នេះជាអ្នកគ្រូរបស់ខ្ញុំ នៅឯសាលាណា៎ ឃើញទេ អ្នកគ្រូស្រស់ស្អាតណាស់ ។

នាងតូចស្រដីផង រត់ទៅកាន់ដៃរបស់អ្នកគ្រូយើងផង បង្ហាញនូវក្តី ស្រលាញ់ចំពោះអ្នកគ្រូយ៉ាងស្និទ្ធស្នាល ។ ភ្លាមនោះ ក្មេងៗមួយហ្វូងបានរត់

មកឈរជុំជិតអ្នកគ្រូ បញ្ចេញទឹកមុខរីករាយ ។ កុមារម្នាក់សួរអ្នកគ្រូថា :

- ថ្ងៃក្តៅខ្លាំងណាស់ អ្នកគ្រូត្រូវការម្លប់ទេ? នៅឈរហាលថ្ងៃយ៉ាងនេះ អ្នកគ្រូច្បាស់ជាឈឺមិនខាន ។

ភ្លាមនោះ កុមារជំទង់ក៏កាច់មែកឈើមួយមែកមកឈរបាំងថ្ងៃជូន អ្នកគ្រូយើងភ្លាម ។ ភារិណើសម្លឹងមុខកុមារនោះដោយចំលែកចិត្ត រួចមកក៏ ញញឹមដាក់ក្មេងនោះហើយស្រដីទៅវិញថា :

- អរគុណណាស់ ក្មួយប្រុសដែលមានទឹកចិត្តមកថែទាំអ្នកគ្រូពេលនេះ សូមអោយឯងធំឡើង មានសិរីសួស្តី និងក្លាយជាបុគ្គលគំរូម្នាក់ក្នុងសង្គម ជាតិខ្មែរយើង ។

ភ្លាមនោះ កុមារីសោភាក៏បបួលអ្នកគ្រូថា :

- តោះអ្នកគ្រូ... ចូលម្លប់សិនទៅចាស!

ថាហើយ សោភាក៏ដឹកដៃអ្នកគ្រូនាំទៅដល់ដើមដង្កោមួយដែលមាន ម្លប់ត្រជាក់ រួចហើយក៏និយាយបន្តថា :

- អ្នកគ្រូពិសារពុទ្រាស្រែទេ? ចាំពួកយើងទៅបេះមកអោយ... ជ្រលក់ អំបិលម្ទេស ពិតជាឆ្ងាញ់ណាស់ ។

- មិនអីទេសោភា... យើងជិតដល់ម៉ោងត្រលប់ទៅសាលារៀនវិញហើយ ណា៎ បើអាល័យតែអង្គុយញុំាច្បាស់ជាហួសម៉ោងចូលរៀនមិនខាន ។

- បើអញ្ចឹង អ្នកគ្រូដាក់ថ្នក់ទុកពិសារតាមផ្លូវទៅណា៎...ពេលធ្វើដំណើរទៅ សាលាល្ងាចនេះ ។

កុមារីរួសរាយគួរអោយស្រលាញ់ណាស់ ។ ភារាណីមានអារម្មណ៍ថា បេះដូងរបស់នាងមាននិស្ស័យជាប់ជំពាក់នឹងកុមារីមួយរូបនេះដល់ហើយ ។ រីឯក្មេងភូមិវិញក៏នាំគ្នារត់ទៅរត់មកពាសពេញ ខ្លះមកនិយាយជាមួយជា មួយអ្នកគ្រូពីរបីម៉ាត់ក៏រត់ទៅវិញបាត់ ខ្លះក៏នៅអង្គុយក្បែរៗនោះ អង្គុយ មើលអ្នកគ្រូធ្វើប្រហើរ ត្បិតគេមិនដែលឃើញអ្នកគ្រូណាចេញដើរមក លេងស្រុកស្រែជួបពួកគេផ្ទាល់ដូច្នេះទេ ។ បន្តិចមក កុមារីសោភាក៏កាច់ផ្កា

ស្មៅធ្វើជាកម្រងម្កុដមួយមកជូនអ្នកគ្រូយើង :

- អ្នកគ្រូស្រស់ស្អាតណាស់ បើសិនពាក់ម្កុដនេះទៅ អ្នកគ្រូនឹងក្លាយជាទេព អប្សរមិនខានឡើយ ។

ស្រដីចប់ នាងតូចក៏ហុចម្កុដផ្កាស្មៅនោះទៅអ្នកគ្រូភ្លាម ។ លុះទទួល បានម្កុដផ្កាស្មៅនោះមកកាន់ពេលណា ស្រាប់តែភារាណីភ្ញាក់ព្រើត ថ្លោះ ទឹកមុខតែម្តង ។ អ្នកគ្រូយើងក៏លាន់មាត់ថា :

- នាងតូចចេះក្រងម្កុដផ្កាស្មៅនេះពីណាមក?

- គឺឪពុករបស់ខ្ញុំបង្រៀន អ្នកគ្រូ!

រំពេចនោះ ស្រាប់តែភារាណីបានឮសំលេងមួយកួកហៅ :

- សោភា... ជិតដល់ម៉ោងទៅរៀនហើយណ៎ា ឆាប់ទៅមុជទឹកដូរសំល្បៀក បំពាក់ទៅកូន...!

- ចាំស ពុក! ( ថាហើយ នាងតូចក៏រត់រឹងចេញទៅ)

ភារាណីក្រលេកទៅរកម្ចាស់សម្លេងភ្លាម ស្រាប់តែប្រទះឃើញបុរស ម្នាក់មាឌធំ សាច់ដុំមាំ ទំនងជាអ្នកធ្វើការនឹងកម្លាំង ដើរចូលមកដល់ ។ គ្រាន់តែប្រទះឃើញវត្តមានរបស់បុរសនោះភ្លាម ភារាណីបើកភ្នែកធំៗ ឡើងមូលក្រឡង់ ធ្វើមុខភាំងហាក់ដូចជាភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ចំណែក បុរសយើងក៏ដូចគ្នាដែរ ។ កាលបើប្រទះធិតាយើងនៅចំពោះមុខ មាណព ឈរធ្វើស្រលាំងកាំង រកសំដីនិយាយមួយម៉ាត់ក៏មិនចេញឡើយ ។ ក្មេងៗ ដែលរត់លេងនៅទីនោះ ក៏ធ្វើឡឹងឡង់ៗមិនយល់ហេតុការណ៏ ។ មួយ ស្របក់ក្រោយមក ទើបមាណពប្រមូលស្មារតីបានវិញ ហើយក៏លើកដៃ ឡើងប្រណម្យ :

- ជំរាបសួរបាទ! បែកគ្នាយូរឆ្នាំហើយ អ្នកគ្រូសុខសប្បាយទេហ៎?

ភារាណីនៅតែឈរធ្វើភន្ត័ភាំងដដែល ។ ក្នុងចិត្តរបស់នាងវិញក៏រំភើប ញាប់ញ័ររកថាមិនត្រូវ ញ័រដៃញ័រខ្លួនទទ្រើក កកអស់អណ្តាតនិយាយមិន ចេញ ។ មួយភ្លែតក្រោយមក ទើបអ្នកគ្រូយើងសំរួលអារម្មណ៏បានវិញ ហើយក៏សួរខ្សិបៗទៅមាណពវិញថា :

- ... បងកវី... ?

- បាទ! គឺ.. កវីពិតមែនហើយ...!

គ្រាន់តែនិយាយគ្នាបានពីរម៉ាត់ ទាំងពីរនាក់ក៏រកនឹកអ្វីមកនិយាយគ្នា ទៀតលែងឃើញដែរ ក្រៅពីឈរសម្លឹងមុខគ្នាធ្វើអេះអុញ លេបទឹកមាត់ ផ្សើមបំពង់កដ៏ស្ងួតរបស់គេ ហើយក៏ឈ្ងោកមុខគេចក្រសែភ្នែកពីគ្នារៀងៗ ខ្លួនដោយបេះដូងរន្ធត់ញាប់ញ័យ៉ាងចម្លែកយ៉ាងណាមិនដឹងសោះ ។

បេះដូងរន្ធត់

រន្ធត់ក្នុងចិត្តឥតឧបមា ពេលយល់ភក្រ្តាស្រស់ចរណៃ
ញាប់ញ័រអារម្មណ៏ក្រំសំដី រំភើបហប្ញទ័យថ្លែងមិនត្រូវ ។
រន្ធត់ដួងចិត្តត្បិតត្រេកអរ ពេលជួបបវរកែវនោមឆ្នៅ

យល់ភក្ត្រ័ជាថ្មីភ័យពេកកូវ មិនដឹងពាលពៅគិតយ៉ាងណា ។
រន្ធត់ភ័យអរញ៉ៀរបេះដូង គគ្រឹកពេញទ្រូងដូចសង្ឃរា
ហារស្លាក់ជំពាក់លាក់ទ័យា ចិត្តស្នេហ៍ពំងាជាយូរឆ្នាំ ។
រន្ធត់ចិត្តណាស់ម្ចាស់ជីវិត ពេលជួបវរមិត្រស្រស់ស្រងាំ
វៀមតែងទន្ទឹងពាក្យបណ្តាំ ពៅអោយបងចាំអូនវិលវិញ ។

ភ្លាមនោះ ស្រាប់តែឮសំលេងកូកហៅពីជាយចំការក្រូចមកថា :

- ភារាណី... !

កាលបើឮសំលេងរតនាកូកហៅ ភារាណីក៏ស្រដីទៅមាណពយើងថា :

- ខ្ញុំមានការ ត្រូវត្រលប់ទៅផ្ទះវិញសិនហើយ...

ភារាណីសម្លឹងមុខមាណពជាចុងក្រោយ ហាក់ដូចជាចង់និយាយអ្វីជា មួយនាយ តែក៏និយាយមិនចេញមួយម៉ាត់សោះ ។ បន្តិចមក ធិតាក៏បែរ ខ្លួនដើរត្រលប់ទៅចំការរបស់នាងវិញ ។ នៅលើភ្លឺស្រែ អ្នកគ្រូដើរបណ្តើរ លួចបែរក្រោយបណ្តើរ... ពេលក្រលេកម្តងណា ឃើញតែបុរសយើងឈរ ច្រងុក សម្លឹងមើលតាមរូបនាង រហូតដល់បាត់ស្រមោលទៅ ។

គ្រាន់តែមកដល់ខ្ទមវិញមិនទាន់ ឪពុករបស់នាងសួរផ្ទួងថា :

- ភារាណី! កូនដើរទៅម្តុំហ្នឹងធ្វើអី?

- ចាំស! គឺ... កូនឃើញក្មេងបាចត្រី បានជាចង់ទៅមើលលេង..

- អោយតែវាពិតតាមសំដីឯងចុះ... តែថ្ងៃក្រោយ ពុកហាមមិនអោយទៅ ម្តុំហ្នឹងទៀតទេ.. ឮហើយនៅ?

- ចាំសពុក!

សំដីហាមឃាត់នេះ ធ្វើអោយភ្ញៀវទាំងបីរូបចាប់អារម្មណ៍តែម្តង តែ គ្មាននរណាគេធ្វើមាត់កអ្វីទេ ត្បិតវាជារឿងក្នុងក្រុមគ្រួសាររបស់អ្នកគ្រូ គេជាអ្នកក្រៅគ្មានសិទ្ធិហៃហៃឡើយ ។

តាមផ្លូវត្រលប់មកផ្ទះវិញ ដារ៉ាន់លួចកេះសួរ :

- នៅដីភូមិម្តុំនេះ គេមានរឿងអ្វីមែនទេ បានជាឪពុករបស់ឯងហាមឃាត់ មិនអោយឯងទៅទីនោះអញ្ចឹងភារាណី?

ស្រាប់តែ រតនានិយាយឃាត់ :

- ប្រហែលជារឿងមេឃុំនិងអ្នកភូមិហើយ.. ឬក៏ម្តុំនោះសំបូណិមនុស្សមិន ល្អ ឬក៏...

- កុំពិចារណាច្រើនពេកអីរតនា ( ភារាណីស្រដីកាត់) ពុកគាត់ហាមខ្ញុំ ក្នុង បំណងល្អសំរាប់កូនចៅទេតើហ៎.. ចាំបាច់ទៅគិតច្រើនធ្វើអី?

ថ្វីបើមាត់នាងស្រដីដូច្នោះ ប៉ុន្តែទឹកមុខរបស់អ្នកគ្រូក្មេងយើងមិនបាន គាំទ្រពាក្យវាចារបស់នាងទេ ។

នៅរសៀលថ្ងៃដដែល អ្នកគ្រូបានត្រលប់ទៅធ្វើការដូចប្រក្រតីវិញ ប៉ុន្តែចៃដន្យ ថ្ងៃនោះស្រាប់តែបាត់មិនឃើញកុមារីសោភាមកចូលរៀន ដូចធម្មតា ធ្វើអោយអ្នកគ្រូនឹកពិភាល់ក្នុងចិត្តណាស់មិនដឹងជាមានរឿងអ្វីកើតឡើងចំពោះនាងតូច ។ ចៃដន្យមិនល្អ...រសៀលថ្ងៃនោះ ជាថ្ងៃចុងក្រោយរបស់សាលាមុននឹងចូលវិស្សមកាលតូចសំរាកចូលឆ្នាំខ្មែរ ។ ដូច្នេះ ភារាណីមិនអាចជួបមុខកុមារីបានទៀតដែររហូតដល់សាលាបើកបវេសន កាលថ្មី បន្ទាប់ពីចូលឆ្នាំរួចហើយ ។ ករណីនេះ ធ្វើអោយអ្នកគ្រូអន្ទះសាក្នុងចិត្តយ៉ាងចម្លែកខុសធម្មតា...

រៀងរាល់ថ្ងៃតាំងសាលាបឋមសិក្សាបិទទ្វារមក ភារាណីក៏លែងរីក រាយសប្បាយចិត្តដូចមុនទៀតហើយ ។ នាងក៏ប្រែក្លាយជាមនុស្សស្ងាត់ ស្ងៀមហើយចូលចិត្តទៅពួនលាក់ខ្លួនក្នុងចំការតែម្នាក់ឯង ទោះបីជាឪពុកម្តាយនាងមិនបានប្រើអោយទៅមើលចំការក៏ដោយ ។ ពេលនោះ មីងផាវ ម្តាយរបស់នាងក៏ហាក់ដូចជាសង្កេតឃើញអកប្បកិរិយារបស់កូនស្រីប្រែ ប្រួលខ្លះៗ ដែរតែមិនហ៊ានមាត់កអ្វីប្រាប់មេឃុំផងអ្វីឡើយ ហើយក៏ចេះតែនៅស្ងៀមៗមិនស្រដីថាយ៉ាងណាឡើយ ។

0000000000000000

00000

0

# វគ្គទី២

# ម្កុដផ្កាស្មៅ

ព្រឹកនេះ មេឃុំផែងនិងភរិយាចេញទៅចូលរួមធ្វើបុណ្យមួយនៅឯវត្ត សំពៅ
បាត់តាំងពីព្រឹកដោយផ្តាំពូសេតអោយប្រាប់កូនស្រីថា គាត់នឹងនៅ
សំរាន្តនៅទីនោះមួយយប់រហូតដល់ចប់បុណ្យទើបត្រលប់មកវិញ។ គ្រាន់ តែមេឃុំចេញពីផ្ទះបាត់មិនទាន់
ភាវាណើផ្លាស់សម្លៀកជាអ្នកចំការ ទាញ ក្រមានិងមួកស្លឹកត្នោត ស្ទុះដើរចេញពីផ្ទះសំដៅចំការដំណាំរបស់ឪពុកនាង
ភ្លាមយ៉ាងរហ័ស។ ពូសេតនិងកម្មករបួនដប់នាក់ទៀត ស្មានថានាងទៅរក ជួយធ្វើកិច្ចការចំការក៏ស្រែកឃាត់ឡើង :
- អ្នកគ្រូអើយ! ថ្ងៃក្តៅណាស់! កុំបាច់ទៅចំការអី ទុកអោយពួកយើងធ្វើ បានហើយ អ្នកគ្រូសំរាកនៅផ្ទះចុះ។

ស្រាប់តែអ្នកគ្រូយកដៃបក់ហៅពូសេតមកខ្សិបថា :

- ស៊ូច! កុំស្រែកញពេកពូសេត... ខ្ញុំមានការផ្ទាល់ខ្លួនបន្តិច សូមពូជួយលាក់
កុំមាត់កប្រាប់ពុកអីណា៎... ខ្ញុំទៅដីទួលភូមិខាងក្រោយចំការយើងនេះទេ!
- ហ្អាស់? អ្នកនាងទៅទីនោះធ្វើអ្វី.. មិនបានទេ...អ្នកនាងដឹងស្រាប់ហើយ តើហ៎ ថាលោកមេឃុំគាត់ហាម...
បើយើងធ្វើខុសបំរាមគាត់ ច្បាស់ជា យើងត្រូវទទួលទោសឈឺខ្លួនមិនខាន។
- អញ្ចឹង ពូធ្វើមិនដឹងទៅ.. គឺមិនបានឃើញ មិនបានដឹង.. ទុកអោយខ្ញុំ ទទួលខុសត្រូវម្នាក់ឯងចុះ!
- អត់ទេ! កុំទៅអីអ្នកនាង! ដឹងទេថាពេលលោកមេឃុំក្រេវក្រោធ លោក កាចយ៉ាងណា... អ្នកនាងមិនត្រូវ...
- ប៉ុន្តែពេលនេះ ខ្ញុំជាមនុស្សពេញវ័យហើយជាគ្រូទៀតផង... ខ្ញុំគិតថា ពុក មិនវាយដំរូបខ្ញុំដូចកាលពីក្មេងទៀតទេ។
- ហ៊ឺ... យ៉ាងណាក៏ពូនៅតែបារម្ភដដែលហ្នឹង!
- ណ្ហើយចុះ... ពូសេតទៅធ្វើការវិញទៅ បន្តិចខ្ញុំត្រលប់មកវិញហើយ!

ថាហើយ ធិតាក៏បោះជំហានយ៉ាងលឿនចេញទៅ។ ពូសេតសម្លឹង តាមពីក្រោយ គ្រវីក្បាលថែមទាំងលើកដៃបន់ស្រន់ថា :

- សូមអោយលោកមេឃុំធ្វើបុណ្យហើយបើកចិត្តទូលាយ លែងធ្វើបាបកូន ចៅរបស់លោកតទៅទៀតផងចុះលោកអើយ...!

ភារាណីដើរកាត់តាមភ្លឺស្រែក្រវិកក្រវក់មួយស្របក់ធំ ក៏បានមកដល់ ដីទួលភូមិមួយមានកូនផ្ទះឈើតូចមួយខ្ពង់សង់ផុតពីដី មានកូនដំណាំដាំដុះ ជុំជិត មានមាន់ទាជ្រូកដើរចុះដើរឡើងខ្វាត់ខ្វែងពេញទួល ។ នៅខាងកើត ដីភូមិ មានស្រះធំមួយដែលមានទឹកថ្លាឆ្វេង ថែមទាំងមានផ្កាឈូកអើតក រហង់ពាសពេញផ្ទៃស្រះ ឃើញហើយគួរអោយចាប់ចិត្តចេតនាក្រៃលែង ។ រំពេចនោះ ធិតាក៏ប្រទះឃើញកុមារីសោភាដើរបុំងខ្ញើចមកដល់ :

- ជំរាបសួរអ្នកគ្រូ!

កាលបើយល់វត្តមានរបស់កុមារីសោភាភ្លាម ស្រាប់តែភារាណីរលីង រលោងទឹកភ្នែកដោយក្តីត្រេកអរ :

- ស្លាប់ហើយនាងតូច កើតអីហ្នឹងបានជារុំជើងដូច្នោះ?
- គឺខ្ញុំរត់ទៅសាលា ជាន់អំបែងកែវមុតជើង ប៉ុន្តែឥលូវអស់អីហើយ ពុក គាត់ថា ពីរបីថ្ងៃទៀត ខ្ញុំជាសះស្បើយវិញមិនខាន ។
- ហើយចុះនាងតូច.. នៅផ្ទះតែឯងទេ?
- ចាំស បងសាវេតក៏នៅដែរ កំពុងដាក់បាយជ្រូកក្រោយផ្ទះឯណោះ
- នរណាគេទៅឈ្មោះបងសាវេត?
- គឺបងប្រុសដែលកាច់មែកឈើបាំងជូនអ្នកគ្រូពីថ្ងៃមុននោះអី
- អូហ៎ អញ្ចឹងសាវេតជាកូនប្រុសរបស់ពុកដែរមែនទេ?
- មិនមែនទេ...បងវេតមានម៉ែមានពុករបស់គាត់ តែគាត់ស្លាប់អស់ហើយ ទើបពុកយកមកអោយនៅបានគ្នាពីរនាក់នឹងសោភាទៅ ។
- ហើយចុះពុករបស់សោភាទៅណាហើយ?
- ព្រឹកនេះ គាត់ដើរចាក់ថ្នាំអោយជ្រូក អោយគោ នៅមុំបឹងរាំងឯណោះ ហើយក៏ដឹកជ្រូកបាទៅបង្កាត់ពូជអោយគេផង ប្រហែលល្ងាចបន្តិចបាន គាត់ត្រលប់មកផ្ទះវិញ ។
- អូហ៎ ពុករបស់នាងតូចធ្វើពេទ្យសត្វផងហ្អែស? ហើយចុះនាងតូចបានពី ណាជួយដាំបាយធ្វើម្ហូបអោយញុំាដែរទៅ?
- គឺពុកគាត់ដាំបាយទុកអោយរួចហើយ មុននឹងគាត់ចេញទៅ ។

ភ្លាមនោះ សាវេតក៏ចូលមកដល់ ដោយមានកាន់ទឹកមួយផ្តិលមកផង

- ជំរាបសួរអ្នកគ្រូ...! អញ្ជើញពិសារទឹក បាទ!
- អឺ! អរគុណណាស់ សាវេត ។

ភារាណីសម្លឹងមើលមុខក្មេងទាំងពីរ ដោយក្តីអាណិតពេញបេះដូង ។ ថ្វីបើគេនៅក្មេងមែនពិត តែមានសមានចិត្ត មានចរិតគួរអោយស្រលាញ់ ពន់ពេកណាស់ ។ នឹកគិតយូរៗទៅ នាងហាក់ដូចជានឹកស្ងើចសរសើរបុរស ជាឪពុកនៅក្នុងចិត្តដែលគេអាចអប់រំក្មេងបានយ៉ាងល្អប្រពៃ ទោះបីគេមាន ជីវភាពអត្តខាត់បន្តិចក្តី ប៉ុន្តែ

សុភមង្គលគ្រួសាររបស់គេពិតជាសុខដុម រមនាណាស់ ។ មើលទៅក្មេងទាំងពីរចុះ គេហាក់ដូចជាស្រលាញ់គ្នា ហើយថែមទាំងមានសន្ដានចិត្តល្អ ធ្វើអ្វីៗ ដោយមិនបាច់ចាស់ទុំដាស់តឿនទៀត ផង ។ ភ្លាមនោះ ភារាណីស្រដីទៅកាន់អ្នកទាំងពីរថា :

- កូនៗទាំងពីរបរិភោគបាយហើយនៅ?
- ចាស! នៅទេ! (នាងតូចឆ្លើយឡើង) ពុកដាំតែបាយទុក តែមិនទាន់ធ្វើ ម្ហូបនៅឡើយ ។ បងវេតគាត់ថា គាត់នឹងស្ទោរពេងទាញាំុសិន ទំរាំល្ងាច ពុក មកពីផ្សារវិញ គាត់នឹងដាំស្លអោយពួកយើងញុំាទៀត ។
- អញ្ចឹង! កូនទាំងពីរចង់សាកស្នាដៃអ្នកគ្រូទេ.. ចាំអ្នកគ្រូស្លអោយអ្នក ទាំងពីរបរិភោគ យ៉ាងម៉េចដែរ?
- អូហ៎! បើពិតមែន យើងទាំងពីរមានសំណាងធំណាស់! (សាវេតឆ្លើយ)

បន្ទិចមក ភារាណីបាននាំក្មេងទាំងពីរទៅកាត់ត្រយូងចេកមកស្លម្ជូរគ្រឿ ឆ្អើ ថែមទាំងនាំគ្នាចុះបេះក្រអៅឈូកយកមកញាំយ៉ាងឆ្ងាញ់ទៀតផង ។ ពិតមែនតែអាហារទាំងនោះមានភាពក្រៀមក្រោះបន្តិច ត្បិតគេមិនមាន សាច់ស្រស់មកធ្វើអាហារ ក៏អ្នកទាំងបីជួយគ្នាធ្វើហើយបរិភោគយ៉ាងរីក រាយជុំគ្នាទាំងបីនាក់ក្នុងបរិយាកាសយ៉ាងរមនាទៀតផង ។ ពេលសាវេត កំពុងរៀបចំលាងចានក្បាន ស្រាប់តែ សោភាស្រដីថា :

- អ្នកគ្រូ! បើសិនអ្នកគ្រូជាម៉ែរបស់សោភាវិញ មិនដឹងខ្ញុំសប្បាយចិត្ត យ៉ាងណាទេ...
- ហើយនាងតូចចង់បានម្ដាយទេ?
- ចង់! តែពុកប្រាប់ថា បងវេតនិងខ្ញុំគ្មានសំណាងនឹងមានម៉ែដូចគេដទៃទេ
- បើអ្នកគ្រូស្ម័គ្រខ្លួនជាម្ដាយរបស់អ្នកទាំងពីរ តើកូនយល់យ៉ាងណាដែរ?

ភ្លាមនោះ សាវេតនិងសោភាបែរមើលមុខគ្នា មួយស្របក់មកក៏ ស្រែកព្រមគ្នាឡើងថា :

- ជយោ!... ម៉ែ... ពួកយើងមានម៉ែហើយ..!

ទាំងពីរនាក់រត់មកអោបអ្នកគ្រូភារាណីយ៉ាងលឿនតែម្ដង :

- ម៉ែ... កូនស្រលាញ់ម៉ែណាស់...ខ្ញុំមានម៉ែនឹងគេហើយ...!!

ភារាណីរំភើបក្នុងចិត្តខ្លាំងណាស់រហូតដល់រលីងរលោងទឹកភ្នែក រួចក៏ ស្រវាអោបអ្នកទាំងពីរវិញយ៉ាងណែន ។ មួយភ្លែតក្រោយមក អ្នកគ្រូ យើងក៏ស្រដីទៅកាន់អ្នកទាំងពីរថា :

- តែម៉ែសូមអោយកូនទាំងពីរសន្យារឿងមួយសិន
- រឿងអ្វីទៅម៉ែ...? (នាយសាវេតសួរ)
- គឺថា នេះជារឿងសម្ងាត់រវាងយើងទាំងបីនាក់ ។ កូនអាចហៅម៉ែបាន ពេលម៉ែមកដល់ទីនេះ តែពេលកូនឃើញម៉ែនៅសាលាឬទីណាក៏ដោយ សូមអោយកូនហៅម៉ែថាអ្នកគ្រូ.. តើបានទេហ៎?
- ម៉េចអញ្ចឹងទៅវិញម៉ែ? (នាយវេតសួរបន្ថែមទៀត)
- គឺយើងត្រូវរង់ចាំអោយដល់ពេលសិន ។ តែពេលនេះ ម៉ែនៅទីនេះ កូន អាចហៅម៉ែថាម៉ែបានណា៎...

ទាំងពីរនាក់សម្លឹងមុខអ្នកគ្រូហើយក៏ញញឹមឡើង ។ បន្តិចមក សោភា ក៏សួរអ្នកគ្រូថា :

- បើម៉ែក្លាយជាម៉ែរបស់សោភា តើម៉ែអាចមករស់នៅជាមួយយើងនៅទី នេះបានទេ? ខ្ញុំចង់អោយម៉ែមកណាស់...

- មិនទាន់បានទេ... គឺម៉ែនៅមានរឿងច្រើនទៀតដែលត្រូវដោះស្រាយ ដូច្នេះកូនត្រូវជួយលាក់ការសម្ងាត់សិន ។ ចាំថ្ងៃមួយ យើងនឹងរស់នៅជួប ជុំគ្នា ដូចម៉ែពុកនិងកូនទាំងពួង ៗហើយនៅ?

- បាទ! ចាស !

ទាំងពីរនាក់ឆ្លើយព្រមគ្នាឡើង ។ បន្តិចមក អ្នកគ្រូក៏ងូតទឹកអោយ សោភាហើយសិតសក់ក្រងអោយនាងយ៉ាងស្អាត ថែមទាំងជួយលាងរបួស ជើងរបស់កុមារី ហើយរុំក្រណាត់សាជាថ្មីយ៉ាងផ្ចិតផ្ចង់ ។ មិនតែប៉ុណ្ណោះ ភារាណីក៏បានច្រិបជើងសក់អោយសារ៉េតយ៉ាងស្អាតដែរ ថែមទាំងបបួល គ្នាបោកគក់ខោអាវរបស់អ្នកទាំងពីរដាក់ហាលថ្ងៃយ៉ាងល្អទៀតផង ។

ស្រលាញ់

| | |
|---|---|
| យើងស្រលាញ់គ្នាជាគ្រួសារ | មាតាបិតាព្រមទាំងបុត្រ |
| ស្រលាញ់ដោយចិត្តស្មោះបរិសុទ្ធ | លុះលង់ថ្ងៃផុតសូន្យជីវី ។ |
| ស្រលាញ់គ្នាណាស់ផ្លាស់មិនបាន | ទាំងដួងចិត្តប្រាណអង្គអញ្ជលី |
| សច្ចាថៃធួនសួនពលី | រក្សា រមណីក្នុងគ្រួយើង ។ |
| ស្រលាញ់ជិតដិតស្និទ្ធដួងថៃ | មង្គលប្រពៃក្រៃថ្កុំថ្កើង |
| គ្រួសារក្រីក្រត្រដរឡើង | ទោះទ្រព្យស្តួចស្តើងចិត្តយើងមាន ។ |
| យើងស្រលាញ់គ្នាលង់តទៅ | ជាគ្រួសារនូវសីលនិងទាន |
| ស្រលាញ់ពុកម៉ែញាតិគ្រប់ប្រាណ | គ្រួសារយើងថ្កានក្សាន្តរៀងអើយ ។ |

រសៀលបន្តិចហើយ...

ភារាណីក៏ម្នីម្នាលាក្មេងទាំងពីរត្រលប់មកផ្ទះវិញ ទោះបីជាក្មេងឃាត់ អោយនៅជួបឪពុករបស់គេសិនក៏ដោយ ។ តាមផ្លូវ ធិតាយើងហាក់ដូចជា មានអារម្មណ៍ស្រស់ថ្លាមកវិញ ថែមទាំងដើរញញឹមតែម្នាក់ឯងរហូតដល់ ផ្ទះ ។ សូម្បីតែពូសេតក៏នឹកឆ្ងល់ដែរ ចំពោះភាពរីករាយចម្លែករបស់អ្នកគ្រូ របស់យើង ។ លុះត្រលប់មកដល់ផ្ទះវិញ អ្នកគ្រូក៏រត់ចូលពួនក្នុងបន្ទប់គេង លែងចេញមកក្រៅ នៅសំងំធ្វើអ្វីមិនដឹងទេ សូម្បីតែពូសេតហៅមកពិសារ បាយក៏មិនព្រមចេញមកសោះឡើយ ។

ថ្លែងពីនាងតូចសោភានិងកុមារសារ៉េតម្តង...

ការពិតសារ៉េតមានអាយុប្រហែល១០ឆ្នាំប៉ុណ្ណោះ ប៉ុន្តែស្ថានភាពក្រី ក្រក្នុងគ្រួសារ បានបង្ខំអោយសារ៉េតធ្វើការដូចជាមនុស្សពេញវ័យម្នាក់ ដើម្បីបំប៉នសេចក្តីខ្វះខាតនានា ហើយគេក៏បានក្លាយជាបងប្រុសដែលត្រូវថែទាំប្អូនស្រីសព្វបែបយ៉ាង នៅពេលដែលឪពុកធមិមិននៅ ។

ម៉ោងប្រហែលបួនរសៀល នាថ្ងៃដដែល...

បុរសម្នាក់មាឌមាំដំបង មានសាច់ដុំមាំមួន បានបរម៉ូតូកញ្ចាស់មួយ ដឹកដុចជ្រូកបាមួយដែលមានដាក់ជ្រូកបាយ៉ាងធំក្នុងនោះមកដល់មុខផ្ទះ។ អ្នកទាំងពីរក៏រត់ស្រចេញទៅទទួល :

- ពុក! ពុកមកវិញហើយ... (សោភាលាន់មាត់ឡើង)

សាវេតលូកដៃទៅទទួលកញ្ចប់នំឥវ៉ាន់ ដែលឳពុកទិញមកពីផ្សារយក
ទៅទុក។ គ្រាន់តែក្រលេកឃើញអ្នកទាំងពីរភ្លាម ស្រាប់តែបុរសយើង បើកធំៗមូលក្រឡង់ហើយលាន់មាត់ថា :

- សាវេត? សោភា? ហើយកូនឯងបានប្រាក់ពីណាចូលហាងកាត់សក់ ធ្វើ សក់ យ៉ាងស្អាតបែបនេះ?

សាវេតនិងសោភាលួចមើលមុខគ្នា រួហើយសោភាក៏ពោលថា :

- គឺពួកយើងមិនបានទៅហាងកាត់សក់ទេ..

- អឺ បើមិនទៅហាង ហេតុអីក៏ម្នាក់ៗ...

- គឺ អ្នកភូមិក្បែរនេះ គេចិត្តល្អជួយកាត់សក់អោយបងវេត ហើយក្រង សក់អោយសោភាទៀតផង (នាងតូចឆ្លើយឡើង)

- នរណាគេ អីក៏ចិត្តល្អម្ល៉េះ? ពុកនៅម្តុំនេះយូរហើយ.. មានតែអ្នកមើល បំណាំគ្រួសារយើងប៉ុណ្ណោះ
មិនសូវប្រទះឃើញអ្នកចិត្តល្អចំពោះយើងទេ។ ថ្ងៃក្រោយ កូនកុំទៅលេងផ្ទះគេហើយរំខាន គេទៀត ឮហើយនៅ?

- ចាំស! កូនមិនបានទៅផ្ទះគេទេ.. គឺគេមកលេងផ្ទះយើងតើហ៎...

- ហ្អាំស កូនថាម៉េច? មានគេមកលេងផ្ទះយើង?

មាណពឧទានឡើងទាំងងឿងឆ្ងល់ ត្បិតជាយូរឆ្នាំមកហើយ ផ្ទះរបស់ នាយមិនដែលមានភ្ញៀវទេ។ ហេតុអ្វីថ្ងៃនេះ
មានគេមកលេងទីនេះទៅ វិញ? នាយយើងធ្វើមុខទំនងមិនចង់ជឿការពិត។

- មែនណាំពុក.. ជាមនុស្សស្រីហើយស្រស់ស្អាតណាស់ ពុកទាយទៅមើល៍ ថាជាអ្នកណា?

រំពេចនោះ កុមារសាវេតលួចយកដៃកេះប្អូន កុំអោយមាត់ច្រើនពេក ត្បិតខ្លាចចិត្តឳពុក តែហួសពេលទៅហើយ។
មាណពក៏សួរកូនស្រីថា :

- ជាមនុស្សស្រី? តើគេជានរណា?

ស្រាប់តែមាណព ចំហមាត់បើកភ្នែកធំៗហើយឧទានថា :

- ស្លាប់ហើយ!... ជាអ្នកគ្រូភារាណីមែនទេកូន?

- ចាំស! ជាអ្នកគ្រូភារាណីពិតមែន តែគាត់មិនស្លាប់ទេ.. ហើយចុះម៉េច បានជាពុកដឹងកើតថាជាអ្នកគ្រូ?

គ្រាន់តែឮសំនួររបស់កូនស្រីភ្លាម មាណពបែរជានៅស្ងៀមទៅវិញ ហើយក៏បែរជានិយាយបន្លប់ថា :

- អូហ៎ នែ៎ ! ពុកទិញសាច់ជ្រូកអាំងពីផ្សារមកផ្ញើកូនណាំ។ ថ្ងៃនេះពុកលក់ ឥវ៉ាន់ដាច់ណាស់ ទើបគិតថាជប់លៀងកូនទាំងពីរម្តង។

កាលបើប្រទះអាហារឆ្ងាញ់ ក្មេងទាំងពីរក៏ភ្លេចរឿងអ្នកគ្រូភារាណី អស់រលីងតែម្តង។
មួយស្របក់ក្រោយមកគេក៏នាំគ្នាបរិភោគអាហារយ៉ាង
ឆ្ងាញ់ពិសារជុំកូនជុំឳពុកយ៉ាងសុខដុម។

នៅរាត្រីនោះ...

មាណពយើងបាននាំកូនទាំងពីរចូលដំណេក លក់ស្ងាត់ឈឹងអស់រលីង រួចហើយគេក៏ដើរចុះជណ្តើរផ្ទះមកក្រោតម្រង់ទៅស្រះឈូក ហើយក៏ដាក់ ខ្លួនលើស្ពានឈើមួយ សំយុងជើងក្នុងទឹកត្រវីចុះឡើងៗ ភ្នែកសម្លឹងទៅ ព្រះចន្ទ័ដែលកំពុងតែរះភ្លឺថ្លាពណ្ណរាយឯនភាល័យ ។ អារម្មណ៍គេអណ្តែត ទៅឆ្ងាយ សែនឆ្ងាយ... យូរៗម្តងក៏លួចដកដង្ហើមធំតែម្នាក់ឯង ហាក់កំពុង តែនឹកអាណិតទៅដល់ជីវិតអតិតកាលមួយដ៏សង្វេគ ។ រំពេចនោះ គេក៏បន្លឺ សំនៀងមួយយ៉ាងលន្លង់លន្លោចចិត្ត  ហាក់បីដូចជាមានបំណងទំលាយ នូវ អារម្មណ៍ណែនណាន់តាន់តឹងទាំងឡាយ ដែលគេកំពុងបៀមលាក់ទុកនៅ ក្នុងឱរារបស់គេជាយូរឆ្នាំមកហើយ...

រាត្រីរងា

| | |
|---|---|
| រាត្រីស្ងាត់សូន្យស្រពោនចិត្ត | នឹកកែវវរមិត្រម្ចាស់ចិត្តស្នេហ៍ |
| បងរង់ចាំអូនច្រើនឆ្នាំខែ | ដួងចិត្តមិនប្រែពីស្នេហា ។ |
| រាត្រីសែនជ្រៅដំបៅទ្រូង | កាត់ទងបេះដួងផ្ញើជីវ៉ា |
| ជីវិតបងមួយប្តូរមរណា | ដើម្បីកន្និដ្ឋាម្នាក់ក្នុងលោក ។ |
| រាត្រីជ្រងំយំដង្ហោយ | ហឫទ័យសែនសោយទុក្ខវិយោគ |
| មិនដឹងពេលណាអូនវិលមក | សាងស្នេហ៍ពន្លកលាស់ជាថ្មី ។ |
| រាត្រីសន្ធិយារងារអង្គ | ឱរាបងលង់ក្តីស្រម័យ |
| សង្ឃឹមអូនវិលរកប្រុសថ្លៃ | សាងស្នេហ៍ជាថ្មីត្រចង់អើយ... |

នៅដៃ បុរសយើងកំពុងកាន់ម្កុដផ្កាស្មៅមួយយោលទៅយោលមក ។ បន្តិចមក គេក៏ពោលខ្សិបៗទៅម្កុដនោះថា :

- ឱ! ម្កុដកំសត់អើយ... អ្នកពុំមានតម្លៃសំរាប់បំពាក់ថ្វាយទេពអប្សរណា មួយរូបឡើយ ក្រៅតែពីកេសាអ្នកក្រីក្រវណ្ណ:ដូចគ្នានឹងពួកយើង...!

ព្រឹកស្អែកឡើង...

មាណពភ្ញាក់ឡើងចេញទៅជួញដូរដូចរាល់ថ្ងៃ ។ មុននឹងចេញដំណើរ ទៅ គេងាកមកផ្តែផ្តាំកូនទាំងពីរថា :

- សាវេត មើលប្អូនផងណាំកូន! ហើយកុំដើរលេងឆ្ងាយផ្ទះអោយសោះ ។ ចាំពីរថ្ងៃទៀត ពេលចូលឆ្នាំខ្មែរ ចាំពុកនាំកូនដើរលេងណាំ!

- បាទ! ពុក!

ទាំងពីរនាក់សាវេតនិងសោភាឈរសម្លឹងមើលតាមឪពុក ដែលបញ្ជេះ ម៉ូតូកញ្ជាស់បរចេញទៅតាមភ្លឺស្រែ ដោយមានដឹកមាន់បួនដប់ទៅលក់នៅ ឯផ្សារផង ។

នៅក្រោមដើមអំពិលដែលមានម្លប់ត្រឈៃ សាវេតឈរបុកដើមចេក លាយកន្ទក់ដាក់បាយជ្រូក ។ ចំណែកសោភាវិញ កំពុងកាន់ត្រកដើររើស ពងទានៅក្នុងទ្រុងដែលទាពងចោលពីយប់មិញ ។ ភ្លាមនោះ នាងក៏សួរទៅ បងប្រុសនាងថា :

- បងវេត! បងគិតថា ម៉ែរបស់យើងគាត់មកលេងយើងទេ ថ្ងៃនេះ?

- ម៉ែយើងស្លាប់បាត់ទៅហើយ តើគាត់មកលេងនឹងយើងយ៉ាងម៉េចកើត?

- មិនមែនទេ បងវេត គឺអ្នកគ្រូភារាណី ម៉ែថ្មីរបស់យើងណា៎... ខ្ញុំនឹកគាត់ ចង់អោយគាត់មកលេងយើងទៀតដល់ហើយ..

- ប្រហែលជាគាត់រវល់អីទេដឹង... បើគាត់ទំនេរ គាត់ច្បាស់ជាមកលេង នឹងយើងមិនខានឡើយ ។

- ខ្ញុំចង់អោយគាត់មកឥលូវនេះ... បងវេត តើខ្ញុំលួចចេញទៅតាមរកគាត់ នៅឯផ្ទះរបស់គាត់បានទេហ៎?

- មិនបានទេ អូនភា! ពុកផ្តាំស្រេចហើយថាមិនអោយយើងចេញដើរទៅ ឆ្ងាយផ្ទះទេណា៎!

សោភាដកកធ្វើអើតអើម សម្លឹងទៅតាមដងភ្លឺដែលនាងចំណាំឃើញ អ្នកគ្រូដើរចេញមកពីចំការក្រូចរបស់គាត់ ហាក់ដូចជាកំពុងជារង់ចាំផ្លូវ អ្នកគ្រូរបស់យើងសំបើមណាស់ ។ ភ្លាមនោះ ស្រាប់តែនាងស្រែកហៅ ឡើង :

- បងវេត! នុ៎ះហ្ន៎... ម៉ែគាត់ដើរមកហើយ...!

សាវេតមើលតាមដៃរបស់ប្អូនស្រី ក៏ប្រទះឃើញអ្នកគ្រូស្លៀកពាក់ របៀបអ្នកធ្វើការក្នុងចំការ កំពុងដើរកាត់ស្រែ សំដៅមករកដីភូមិរបស់គេ មែន ។ សាវេតក៏ដាក់អង្រែចុះ ហើយក៏ទាញដៃប្អូនរត់ទៅទទួល :

- ជំរាបសួរម៉ែ ( ទាំងពីរនាក់សំពះសួរព្រមគ្នា)

- អឺ! ល្អហើយកូនភា កូនវេត! ពុករបស់កូននៅទេហ៎?

- មិននៅទេ ( សាវេតឆ្លើយ) គាត់ចេញទៅរកស៊ីទៀតបាត់ហើយ រសៀល ទើបមកវិញ ។

ឮដូច្នេះ អ្នកគ្រូយើងក៏ញញឹមឡើង ហើយក៏ស្រដីថា :

- អញ្ចឹង... ថ្ងៃនេះយើងត្រូវធ្វើអ្វីខ្លះទៅ ដើម្បីអោយពុកមកវិញ ឃើញ ហើយ សប្បាយចិត្ត?

- គឺខ្ញុំត្រូវដាក់បាយជ្រូក ចំណែកអូនភាដើររើសពងទា រួចហើយបើទំនេរ បោសផ្ទះរៀបផ្ទះ ប៉ុណ្ណឹងឯង ។ ពុកថា ពួកយើងនៅតូច១ មិនអោយ ធ្វើការធ្ងន់ទេ ខ្លាចឈឺ ព្រោះពុកក្រគ្មានប្រាក់អោយថ្លៃពេទ្យ ។ គាត់អោយ យើងនៅតែយាមផ្ទះ មិនអោយដើរលេងរកេតរកូតទេ ។ បើសិនគាត់នៅ ផ្ទះវិញ ទើបគាត់អោយពួកយើងចេញទៅបង្ហោះខ្លែងនៅវាលស្រែជាមួយ ក្មេងភូមិជិតខាងម្តងម្កាល ។

- អញ្ចឹង យើងនាំគ្នាហាន់ដើមចេកបុកបាយជ្រូក យ៉ាងម៉េចដែរកូន?

សារេតញញឹមឡើង កាលបើឃើញអ្នកគ្រូយើងមកជួយសម្រាលកិច្ច ការរបស់នាយ ។ អ្នកទាំងបីធ្វើការព្រមគ្នាបណ្ដើរ ជជែកគ្នាសើចក្អាកក្អាយ បណ្ដើរ ។ មិនតែប៉ុណ្ណោះ អ្នកគ្រូបានបង្រៀនអោយគេចេះច្រៀងចំរៀងពីរ បីបទយ៉ាងពិរោះទៀតផង ។ បន្ទាប់ពីទំនេរដៃមក អ្នកគ្រូក៏រៀបចំបេះបន្លែ បំរុងស្លដាំអោយអ្នកទាំងពីរបរិភោគ ។ កំពុងតែរៀបចំ ស្រាប់តែនាងតូច សោភាសួរថា :

- ម៉ែ! តើម៉ែអាចនៅពិសារបាយពេលល្ងាចជាមួយពួកយើងបានទេ?

- មិនបានទេ កូន! ម៉ែត្រូវត្រលប់ទៅផ្ទះវិញបំរើលោកតាលោកយាយ ។

- ហ៊ឺ! ស្ដាយមែន ដែលពុកមិនបានពិសារបាយជុំគ្នាជាមួយពួកយើង...

សោភាត្អូញខ្សិបៗ ។

- មិនអីទេកូន... ថ្ងៃណាមួយ មិនយូរមិនឆាប់គង់តែយើងបានបរិភោគ
បាយជុំគ្នាទេ (ភារាណីពោលលួងលោមនាងតូច)

សារេតដងទឹកមួយផ្តិលមកផ្ញើអ្នកគ្រូ :

- ពិសារទឹកទេម៉ែ? ថ្ងៃនេះមេឃក្ដៅខ្លាំងណាស់ ពិសារទឹកអោយញ៉ឹក បន្តិចទៅ ដើម្បីអោយស្រួលខ្លួន ។

ភារាណីទទួលផ្តិលទឹកពីសារេតហើយក៏ពោលថា :

- អរគុណណាស់កូន ដែលចេះស្គាល់ទុក្ខធុរៈ! ម៉ែពិតជាមានសំណាង ណាស់ ដែលមានកូនល្អយ៉ាងនេះ ។

បន្តិចមក ភារាណីបានរំលែកម្ហូបមួយចាន ទុកអោយឪពុករបស់
សោភា ហើយក៏បបួលក្មេងបរិភោគបាយ បន្ទាប់មកក៏នាំនាងតូចនិង សារេតអានសៀវភៅរំលឹកមេរៀនសាលា ។ មិនយូរប៉ុន្មានសោភាក៏គេង លង់លក់នៅក្នុងរង្វង់ដៃរបស់អ្នកគ្រូ ដែលកំពុងអង្គុយយោលអង្រឹងពីរ នាក់ជាមួយនាងតូចទៅមកយឺតៗ ។ រីឯសារេតក៏ចេញទៅក្រៅវិញ ដើម្បី ច្រៀកអុសសំរាប់ដណ្ដាំអាហារពេលល្ងាច ។ ភារាណីលើកសៀវភៅអាន យូរៗទៅ ស្រាប់តែងងុយគេងដែរ ។ ធិតាយើងដាក់សៀវភៅចុះហើយក៏ ធ្មេចភ្នែកសំងំជាមួយកុមារីទាំងពីរនាក់នៅក្នុងអង្រឹងក្រោមផ្ទះ លង់លក់ ព្រមជាមួយគ្នាទៅដែរ ។ មិនដឹងជាអស់ពេលយូរប៉ុន្មានទេ ពេលនាង ភ្ញាក់ស្មារតីមកវិញ ស្រាប់តែប្រទះនឹងបុរសមួយរូបកំពុងតែលួចឈរ សម្លឹងរូបនាងពីមាត់ទ្វារផ្ទះបាយមក ។ ធិតាយើងភ្ញាក់ព្រើត នឹករន្ធត់ញាប់ ញ័រក្នុងចិត្ត ខ្មាសខ្លួនយ៉ាងណាមិនដឹង ។ ចៃដន្យ នាងតូចនៅគេងលក់ក្នុង រង្វង់ដៃរបស់នាងនៅឡើយ ធ្វើអោយភារាណីកកស្ទុកស្ទឹង មិនអាចងើប គេចមុខទៅណាបានឡើយ ។ លុះឃើញអ្នកគ្រូមានកិរិយាទំនងជាខ្លាចចិត្ត ហើយទ្រង់ខ្មាសៗ បុរសនោះក៏ចោលក្រសែភ្នែកញញឹមយ៉ាងស្រទន់ចំពោះ មាណវី រួចហើយគេចខ្លួនចេញទៅ ដោយមិនឃើញស្រដីសួរអ្នកគ្រូអំពីអ្វី មួយម៉ាត់សោះឡើយ ។

មួយសន្ទុះធំក្រោយមក សោភាក៏ភ្ញាក់ពីដំណេកដែរ ។ ភារាណីក៏ស្រដី ខ្សិបៗទៅកាន់នាងតូចថា :

- ម៉ែត្រូវដល់ពេលត្រលប់ទៅវិញហើយ... បើស្អែកទំនេរ ម៉ែនឹងមកលេង កូនសាជាថ្មីទៀតណាំកូន!

- ម៉េចក៏ប្រញាប់ទៅម្ល៉េះ ម៉ែ? នៅលេងអោយយូរមិនបានទេហ៎?

- មិនបានទេ... បើនៅយូរ លោកតាលោកយាយច្បាស់ជាខឹងនឹងម៉ែហើយ

- អញ្ចឹង ចាំខ្ញុំទៅសុំច្បាប់លោកតាលោកយាយឱ្យ

- ទេ! កុំអី! លោកតាមិនចូលចិត្តអោយក្មេងៗទៅរំខានទេ។ ចាំម៉ែសុំគាត់ ដោយខ្លួនឯងវិញណា៎។ សន្យានឹងម៉ែមក៍ ថាកូននឹងធ្វើជាក្មេងល្អ ស្តាប់ម៉ែ ស្តាប់ពុកប្រដៅណា៎កូន។

នាងតូចញញួហើយ ងក់ក្បាល ធ្វើមុខស្មើក ដែលភារាណីមិនព្រមនៅ លេងអោយបានយូរតាមចិត្តនាងចង់បាន។ មែនហើយ! នាងជាក្មេងដែល គ្មានម្តាយថ្នាក់ថ្នមយូរមកហើយ ហើយតែងតែដង្ហោយរកការថ្នាក់ថ្នម ជានិច្ច។ កាលបើនាងបានទទួលការថែទាំយ៉ាងកក់ក្តៅពីអ្នកគ្រូយើង កុមារី មានអារម្មណ៍ថានាងមានសេចក្តីសុខខ្លាំងណាស់។ សោភាសម្លឹង តាមអ្នកគ្រូដើរចេញទៅរហូតដល់ក្រៅផ្ទះ។ លុះភារាណីដើរមកដល់ជាយ ដីភូមិ ក្បែរស្រះទឹក ស្រាប់តែនាងប្រទះនឹងឪពុករបស់សោភា នៅឈរវង់ ចាំនាងទីនោះជាស្រេច។ កាលបើឃើញវត្តមានរបស់បុរសយើង អ្នកគ្រូ ហាក់ដូចជាមានអារម្មណ៍តក់ស្លុតរន្ធត់សាជាថ្មីញ័រខ្លួនគគ្រឹកគគ្រេង រហូត មិនហ៊ានសម្លឹងចំក្រសែភ្នែករបស់មាណពទេ។ ធិតាឈ្ងោកមុខចុះ សម្តែង កិរិយាទំនងខ្លាចចិត្តបុរសយើង ហើយក៏ឧទានខ្សិបៗថា :

- បងកវី....?

ភ្លាមនោះ បុរសយើងក៏វាចាមកភារាណីថា :

- កវី... សូមអរគុណអ្នកគ្រូណាស់ ដែលបានមកជួយមើលក្មេងៗ !

- ចាំស! គឺខ្ញុំ... អាចជួយបានបន្តិចបន្តួចប៉ុណ្ណោះ... មិនអាចធ្វើអ្វីបាន លើសពីហ្នឹងទេ...

មាណពយើងបែរសម្លឹងទៅកូនទាំងពីរ ដែលកំពុងអង្គុយនៅមាត់ ជណ្តើរផ្ទះ បែរមើលតាមអ្នកគ្រូយើង សំដែងទឹកមុខសោកស្តាយ ហាក់មិន ចង់អ្នកគ្រូត្រលប់ចេញទៅវិញសោះ។ នាយក៏បែរមកភារាណី វិញ រួចពោលបន្តថា :

- គេកំព្រាម្តាយយូរហើយ.. បានអ្នកគ្រូមកផ្តល់ភាពកក់ក្តៅដល់គេ.. គេ ពិតជាមានអំណរក្នុងចិត្តរកពាក្យនិយាយអោយសមស្មើមិនបានឡើយ មិន ដឹងថា តើថ្ងៃក្រោយ អ្នកគ្រូអាចមកលេងពួកគេញឹកញាប់ដែរឬទេ?

ភារាណីងើបមុខឡើងសម្លឹងមុខបុរសយើង ហើយក៏ឆ្លើយថា :

- បើម្ចាស់ផ្ទះមិនទើសទាល់.. ភារាណីនឹងឆ្លៀតមកលេងឱ្យបានញឹកញាប់ បំផុត តាមដែលអាចមានលទ្ធភាពធ្វើទៅបាន។

មាណពយើងឮវាចានេះកាលណា ក៏ញញឹមឡើង :

- ជាកត្តិយសធំណាស់ បើសិនជាអ្នកគ្រូអាចមកលេងថ្ងៃក្រោយទៀត...

ភារាណីឃើញមាណពញញឹមដាក់នាងយ៉ាងបំព្រង ធិតាហាក់មាន អារម្មណ៍ធូរស្រាលក្នុងចិត្តបន្តិច រួចហើយក៏លាចេញទៅ :

- ភារាណីទៅសិនហើយ ក្រែងម៉ែពុកគាត់មកទាន់.. ចាំមានពេល ខ្ញុំមក លេងទៀត...

- មកបរិភោគបាយជុំគ្នាម្តងបានទេ បាទ...? ( មាណពសួរ)

- គឺ... ភារាណីមិនទាន់ហ៊ានសន្យាទេ.. !

- ស្អែកនេះ បានទេ..? ខ្ញុំនៅរង់ចាំ.. ខ្ញុំមិនចេញទៅជួញដូរទេ ( មាណព តឿនរន្ថើនឡើង ) ស្អែក អ្នកគ្រូមកកុំខានណា៎!... ណា៎!

- គឺ... មិនទាន់ដឹងទេ.. បើម៉ែពុកនៅផ្ទះ ខ្ញុំពិតជាមិនអាចមកបានទេ!

- ទោះបីជាយ៉ាងណា ក៏កវីនៅរង់ចាំអ្នកគ្រូវិលវិញជានិច្ច...!

អ្នកគ្រូយើងញញឹមទំនងសោកស្តាយ ដែលត្រូវលាចេញទៅ ទុកឱ្យ នាយកវីឈរសម្លឹងមើលនាងពីក្រោយ ដោយក្រសែភ្នែកសោកាអាល័យ... រំពេចនោះ កូនទាំងពីរក៏រត់មកដល់ក្បែរមាណពភ្លាមដែរ ។ សាវេតក៏សួរ មាណពឡើងថា :

- តើថ្ងៃស្អែក អ្នកគ្រូនឹងមកលេងពួកយើងទៀតទេពុក?

- ពុកមិនដឹងទេ កូន! តែពុកសូមបន់អោយអ្នកគ្រូត្រលប់មកសាជាថ្មី មក លេងកូនរាល់ថ្ងៃកុំអោយខានឡើយ ។

កវីឈរអោបកូនទាំងពីរសម្លឹងតាមស្រមោលរបស់អ្នកគ្រូ រហូតដល់ បាត់ពីក្រសែភ្នែករបស់គេទៅ ។

និយាយពីអ្នកគ្រូយើងម្តង...

លុះឈានដល់មាត់ទ្វារផ្ទះកាលណា ស្រាប់តែធិតាប្រទះនឹងឪពុក ម្តាយរបស់នាងដែលមកដល់ផ្ទះវិញតាំងពីអង្កាល់ ។ គ្រាន់តែក្រលេក ឃើញមុខកូនស្រីភ្លាម មេឃុំផែងក៏គំហកយ៉ាងលឿនថា :

- ទើបមកពីណា ភារាណី?

- ចាំស! គឺ.. កូនទើបតែមកពីចំការ..

- កុហក! កូនទើបតែមកពីម្តុំដីភូមិនាយកវីមែនទេហ៎?

- ចាំស! អត់ទេពុក!

- ពុកបានអោយគេដើររកឯងពេញចំការពេញម៉ាង៉ៃ តែរកមិនឃើញសោះ បើកូននៅចំការមែន ម៉េចគេរកមិនឃើញ?

- ប្រហែលជាពួកហ្នឹង រកមិនសព្វហើយ ។ ខ្ញុំនៅគេងអានសៀវភៅលេង នៅក្រោមដើមឈើហើយក៏លក់អស់ម៉ាកំណាត់ថ្ងៃទៅ... ឬក៏ប្រហែលជា គេមិនហ៊ានដាស់កូនទេដឹង?

- អឺ! អោយតែវាពិត... តែកុំអោយពុកដឹងអោយសោះណា៎ ថាកូនទៅផ្ទះ នាយកវីនិងកូនៗរបស់វា !!!!

ភារាណីមិនឆ្លើយថាម៉េចទេ ។ កាលបើឃើញឪពុកសម្លុតនាងខ្លាំង ពេក មីងផាវជាម្តាយក៏សម្រុះសម្រួលឡើង :

- កុំកាចដាក់កូនពេក ពុកវាអើយ! កូនធំពេញវ័យហើយជាគ្រូរបស់គេផង មាត់ខ្លាំងដូច្នេះ បើលាន់ឮទៅដល់ផ្ទះជិតខាងវាមិនល្អស្តាប់ទេ...

- គ្រាន់តែស្ដីប្រដៅកូនអោយដើរផ្លូវប្រពៃ វាខុសដែរឬ?

- រឿងចង់អោយកូនល្អនោះមិនខុសទេពុកវា តែដែលខុសនោះគឺពុកវាស្ដី អោយកូនមើលតែគេជាកូនក្មេង ហើយឡូឡាឡូងឡាង ឡើងធ្លាប់មាត់ អស់រលីងតែម្ដង។ មើល៉ លួមដូរចរិតខ្លះទៅ ទុកអោយកូនគេគិតដោះ ស្រាយជីវិតរបស់ខ្លួនគេខ្លះ កុំសូវកៀបសង្កត់ផ្លូវចិត្តរបស់គេពេកអីណាំពុក វា។ ពាក្យចាស់លោកថា តឹងពេកវាដាច់ ធូរពេកវាខ្ទិល ដូច្នោះដើរផ្លូវ កណ្ដាលខ្លះទៅទើបចិត្តយើងមិនសូវហ្មួហ្មង... នែ៎ កាន់សីលហើយត្រូវរៀន រំងាប់កំហឹងខ្លះទៅបានទេ ពុកវា?

ព្ធមឹងផាវមានប្រសាសន៍ចំប៉ាច់ៗ ព្ធមេឃុំលែងហើបមាត់រួចតែម្ដង។

នៅក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់អ្នកគ្រូយើង...

ធិតាទាញយកម្កុដផ្កាស្មៅក្រៀមកញ្ចាស់មួយពីថតតុរបស់នាង មក កាន់សម្លឹងមើលយ៉ាងស្ញៀមស្ងាត់។ រំពេចនោះ ទឹកភ្នែកពីតំណក់ក៏ស្រក់ ហូរចុះចាកនេត្រាដ៏ស្រស់ស្អាតរបស់អ្នកគ្រូយើង.. រួចហើយ ឆវីក៏ស្រវា ម្កុដយកមកផ្ទាប់នឹងដើមទ្រូងហើយក៏យំខ្សឹកខ្សួលតែម្នាក់ឯង...

### ម្កុដផ្កាស្មៅ

ឱ! ម្កុដផ្កាស្មៅសំណៅក្ដីស្នេហ៍ ដានជើងក្នុងស្រែថៃអនុស្សា
ចំណងដួងចិត្តតាំងពីកុមារ យុវវ័យកាលណាសច្ចាស្នេហ៍ស្មោះ។
ម្កុដផ្កាស្មៅក្រៀមបៀមទុក្ខក្នុងទ្រូង អង្រួនបេះដូងត្បិតឡើយស្រណោះ
ពេលនេះម្កុដអើយក្រៀមស្រពោនអស់ តើស្នេហ៍យើងរស់ឬប្រែយ៉ាងណា?
ម្កុដផ្កាស្មៅចាំបណ្ដាំគ្រប់ម៉ាត់ ប្រុសបងធ្លាប់ស្ពាត់ផ្ញើសៀងកាព្យា
ចចារពាក្យពេចន៍ស្មោះស្ម័គ្រនឹងគ្នា ថ្នាក់ថ្នមទ័យាពំងាស្រាន្តចិត្ត។
ឱម្កុដផ្កាស្មៅជាំទូវសំដី ដាស់ដួងហឫទ័យយប់ថ្ងៃរៀងពិត
រង់ចាំថ្ងៃមួយយើងវិលរួមស្និទ្ធ សាងស្នេហ៍អម្រិតសុខសាន្តរៀងទៅ..

ភារាណីអង្គុយកាន់ម្កុដផ្កាស្មៅក្រៀម សំរក់ទឹកភ្នែកពេញមួយរាត្រី... តែម្នាក់ឯងចំបែងក្នុងឱរា។ តើអ្នកគ្រូដ៏ស្រស់ស្អាតរបស់យើងបានប្រទះ វិបត្តិអ្វីខ្លះទៅក្នុងជីវិត ដែលបណ្ដាយអោយដួងចិត្តសោកសៅនិយាយមិន ចេញបែបនេះ?

មួយរាត្រីដ៏យូរលង់... កល្យាណីផ្ដេកកេសានៅខ្នើយ ដាក់ម្កុដផ្កាស្មៅ លើដើមទ្រូង ហើយវាចាខ្សិបៗតែម្នាក់ឯងលួងលោមចិន្ដាថា :

- តើថ្ងៃណាទៅ ទើបម្ចាស់ម្កុដផ្កាស្មៅគេមកបំពាក់ម្កុដដល់ទេពអប្សរ របស់គេ សាជាថ្មីម្ដងទៀត?

000000000000000000

00000

0

# វគ្គទី៣

# ខ្ទួចសន្យា

ព្រឹកនេះ មេឃុំផែងមិនព្រមចេញទៅណាសោះ មើលទៅទំនងហាក់ដូចជាគាត់កំពុងលួចសង្ស័យនឹងកិរិយារបស់កូនស្រីហើយ ។ នៅក្នុងបន្ទប់អ្នកគ្រួយើងលួចមើលឪពុកតាមបង្អួចសំដែងឫកពាអើតអើម១តែម្នាក់ឯង យ៉ាងអន្ទះសាច្រាសច្រាល់ដូចមេមាន់រកពងអង្គុយមិននឹង ឈរមិនជាប់ ចេះតែដើរទៅដើរមកពេញក្នុងបន្ទប់មិនឈប់សោះ ។ នៅលើជញ្ជាំងផ្ទះនាឡិកាប៉ោលដើរតិកតក់១យ៉ាងយឺត១មិនព្រមទៅមុខសោះ ។ ភារាណី មានអារម្មណ៍កន្ទះរាក្នុងចិត្តរកថាមិនត្រូវមិនដឹងថានឹងរកមធ្យោបាយ យ៉ាងណានឹងបានចេញទៅក្រៅដោយគ្មានការលបតាមដានពីមេឃុំផែង ។

ថ្ងៃត្រង់ហើយ ធិតាក៏ចេញទៅចូលរួមស្ពកបាយជាមួយម្តាយឪពុក ទាំងទឹកមុខសោកសៅចម្លែកថ្វីបើនាងខិតខំប្រឹងញញឹមបន្លប់យ៉ាងណាក៏ ដោយ ។ មីងផារលួចសង្កេតឃើញកិរិយារបស់កូនស្រី ក៏ចេះតែនិយាយពីនេះពីនោះបន្លប់បរិយាកាសដើម្បីកុំអោយមេឃុំផែងលួចសង្ស័យលើកូន ។

បន្ទាប់ពីបរិភោគបាយហើយ ធិតាក៏ស្ទុះឡើងចូលបន្ទប់វិញសម្ងំលាក់ ខ្លួនសាជាថ្មី ។ រសៀលបន្តិចស្រាប់តែមីងផារដើរទៅគោះទ្វារ :

- ណីកូន!
- ចាំសម៉ែ!

ភារាណីបើកទ្វារឡើង ឃើញម្តាយឈរញញឹមដាក់នាង ។ ធិតានឹក ពិភាល់ក្នុងចិត្តក៏សួរឡើងថា :

- ម៉ែត្រូវការប្រើកូនមែនទេ?
- អត់ទេ.. ម៉ែគិតថា ប្រហែលជាកូនចង់ទៅដើរលេងរំសាយចិត្តនៅក្នុង ចំការហើយ បានជាមកប្រាប់...
- ខ្ញុំមិនចង់ទៅទេម៉ែ... ចង់សំរាកជាជាង..
- តែរសៀលនេះពុកឯងមិននៅទេ ។ គាត់ទៅជួយមើលការខុសត្រូវបុណ្យសពអ្នកភូមិម្នាក់ដែលជាមិត្តភក្តិរបស់គាត់នៅម្តុំខ្សាច់ពោយ ។ គាត់បានផ្តាំ ថាមិនត្រលប់មកផ្ទះទេ រហូតដល់បូជាសពហើយ ។ ម៉ែគិតថាពឹងកូនឱ្យ ទៅជួយមើលការខុសត្រូវក្នុងចំការជំនួសពុកឯង...

ឮមីងផាវមានប្រសាសន៍ដូច្នោះ ធិតាក៏យល់ភ្លាមថាម្ដាយរបស់នាង កំពុងបើកផ្លូវអោយនាងចេញទៅក្រៅហើយ ។ ភារាណីក៏ប្រញាប់លើកដៃ សំពះម្ដាយភ្លាម :

- អរគុណម៉ែណាស់... ដែលម៉ែលើកទឹកចិត្តកូនជានិច្ច មិនថាពេលណា...

ធិតាស្រវាអោបម្ដាយយ៉ាងណែន បន្ទាប់មកក៏ស្រវាក្រមាយកមក ទទូរហើយក៏ចុះជណ្ដើរដើរចេញសំដៅចំការក្រូចយ៉ាងលឿន ។ លុះដើរ ចេញមកពីផ្ទះបានបន្តិច នាងក៏ងាកមើលទៅក្រោយ ឃើញម្ដាយនាងលើក ដៃបក់បោយអោយប្រញាប់ធ្វើដំណើរចេញទៅ ថែមទាំងញញឹមដាក់នាង យ៉ាងស្រស់បំព្រងទៀតផង ។ ពេលនោះ ភារាណីមានកម្លាំងចិត្តប្រឹសតែ ម្ដង ។ នាងញញឹមតបទៅម្ដាយហើយក៏ឈ្ងោកមុខដើរបន្តទៅទៀត ។

មួយស្របក់ក្រោយមក...

ធិតាក៏បានមកដល់ទួលដីភូមិរបស់នាយកវី ។ ចៃដន្យថ្ងៃនេះ ផ្ទះរបស់ កវីមានភាពស្ងាត់ជ្រងំខុសធម្មតា មិនឃើញនរណានៅផ្ទះម្នាក់សោះ ។ ប៉ុន្តែនាងឃើញទ្វារផ្ទះចំហ ក៏ស្ទុះឡើងកាំជណ្ដើរទៅអើតមើលខាងលើ ទៀត ។ ទោះជាយ៉ាងណា ក៏អ្នកគ្រូរបស់យើងមិនបានប្រទះនរណា ឡើយ ។ ឆវីទឹកពិភាល់ខកចិត្តយ៉ាងណាមិនដឹង ដោយមិនបានជួបមនុស្ស ដែលនាងប្រាថ្នាចង់ជួប ។ ធិតាដាក់ខ្លួនអង្គុយនៅលើកាំជណ្ដើរផ្ទះយកដៃ ច្រត់ចង្កា សំដែងឫកពាហាក់ដូចជាអស់កម្លាំងចិត្តស្រលេតតែម្ដង ។ រំពេច នោះ ភារាណីឮសូរសម្លេងសើចរអឺកមកពីជាយម្ខាងទួលឆ្លើយឆ្លងគ្នាយ៉ាង រីករាយក្អាកក្អាយ ។ នាងភ្ញាក់ព្រើត ស្ទុះងើបទៅរកមើលយ៉ាងរហ័ស ស្រាប់តែប្រទះឃើញសារេត និងឪពុករបស់គេ កំពុងជ្រមុជទឹកស្រះ ប្រណាំងគ្នា ដកក្រអៅឈូក ដោយមាននាងតូចសោភាអង្គុយនៅលើស្ពាន ឈើជាអ្នកទះដៃសើចបន្ទរទៀតផង ។ អ្នកទាំងបីបាចទឹកដាក់គ្នាប្រលែង លេងយ៉ាងសប្បាយ មើលទៅហាក់ដូចជាពួកគេកំពុងមានសុភមង្គល រមនាណាស់ ។ ពេលនោះភារាណីមានអារម្មណ៍ថា ខ្លួននាងក៏បានទទួល នូវឥទ្ធិពលនៃភាពសុខដុមរវាងគេទាំងបីយ៉ាងចម្លែក ។ ភាពញញឹមក៏បាន វិលមកវិញសាជាថ្មីនៅលើវង្វង់ភក្ត្រឆវីយើង ដែលប្រកបដោយភាព ក្រៀមក្រំមួយយប់មួយថ្ងៃមកហើយ ។ រំពេចនោះ ស្រាប់តែនាងតូច សោភាក្រលេកមកឃើញវត្តមានរបស់អ្នកគ្រូយើងនៅទីនោះ ក៏ស្រែករឹង ឡើងថា :

- ពុក! ពុក! មើលហ្ន៎! អ្នកណាគេមកលេងផ្ទះយើងហ្ន៎?

មាណពយើងក៏បែរសម្លឹងទៅតាមក្រសែភ្នែករបស់កូនស្រី ស្រាប់តែ ធ្វើមុខភាំង ហើយលាន់មាត់ខ្សិប១តិច១ថា :

- ភារាណី...?

ភ្លាមនោះ សោភាស្ទុះងើបឡើងទៅទាញដៃអ្នកគ្រូអោយមកអង្គុយ លើស្ពានឈើក្បែររូបនាង :

- អញ្ជើញអង្គុយត្រង់នេះមកម៉ែ...!

ឮសំដីនាងតូចភ្លាម បុរសយើងរឹតតែភ្ញាក់ផ្អើលខ្លាំងឡើង :

- ម៉ែ?... កូនភាហៅនរណាថាម៉ែ? ( មាណពសួរ)

- គឺអ្នកគ្រូនោះអី... គាត់ជាម៉ែរបស់ភានិងបងរេត...!

ពេលនោះ មាណពកាន់តែស្រលាំងកាំងមែនទែនហើយ ។ ភារាណីក៏
នៅឈរធ្វើអេះអុញទំនងនឹកខ្មាសក្នុងចិត្តយ៉ាងណាមិនដឹងសោះ ។ កាលបើ ឃើញអ្នកគ្រូនៅឈរទ្រឹងមិនព្រមអង្គុយចុះ
សាវេតក៏ស្ទុះឡើងពីទឹក ទាញ ដៃអ្នកគ្រូភារាណីអោយដាក់ខ្លួនអង្គុយចុះ :

- សាវេតសប្បាយចិត្តណាស់ដែលម៉ែមកលេងពួកយើង ។ សូមម៉ែអង្គុយ ចុះសិនមក់
ចាំកូនដកក្រអៅឈូកជូនម៉ែយកស្លម្ជូរពិសារជុំគ្នាល្ងាចនេះ ។

មាណពស្ដីលែងចេញតែម្ដង កាលបើវត្តមានរបស់អ្នកគ្រូបានប្រមូល
យកចំណាប់អារម្មណ៍របស់ក្មេងទាំងពីរអស់រលីងពីរូបគេ ។ គេបែរសម្លឹង ទៅធិតាដោយក្រសែភ្នែកលាក់គំនួចយ៉ាងជ្រៅ
ដែលគ្មាននរណាអាចយល់ បានឡើយថានាយកំពុងគិតអំពីអ្វី ។ ឃើញកិរិយារបស់បុរសយើង ទំនង ដូចជារារែក
ធិតាយើងក៏មិនហ៊ានដាក់ខ្លួនចុះដែរ ។ នាងបែរជាបន្ទឺវាចាតប ត្រលប់ទៅវិញថា :

- មិនដឹងថា ខ្ញុំមករំខានសេចក្ដីសុខនៅក្នុងគ្រួសាររបស់...

- អត់ទេ អ្នកគ្រូ... គឺ... សូមអង្គុយចុះសិនមក៏.. យើងទាំងបីចាំមើល ផ្លូវអ្នកគ្រូតាំងពីព្រឹកមកម្ល៉េះ...

បុរសយើងឆ្លើយយ៉ាងលឿន កាត់សំដីរបស់ភារាណីភ្លាម ហើយថែម ទាំងផ្លាស់ប្ដូរទឹកមុខទៅជាញញឹមយ៉ាងត្រកាល
ដាក់អ្នកគ្រូដ៏ស្រស់ស្អាត របស់យើងវិញផង ។ កល្យាណីឃើញដូច្នោះ ក៏បញ្ចេញភាពញញឹមនៅលើ ក្រសែភ្នែកដាក់មាណពវិញ
ហើយក៏សំរូតខ្លួនអង្គុយលើស្ពានឈើក្បែរនាង តូចទាំងចិត្តរំភើបរីករាយ ។ ទាំងពីរនាក់លួចសម្លឹងគ្នាទៅវិញទៅមកក្នុង
ក្រសែភ្នែកមួយដែលមានលាក់ភាសាសាសងយ៉ាងសម្ងាត់ ដែលក្មេងទាំង ពីរនាក់នោះមិនអាចយល់បានឡើយ ។ មួយស្របក់មក
កវីក៏ស្ទុះហែលទៅ កណ្ដាលស្រះ កាច់ផ្កាឈូកមួយទងយកមកហុចអោយសោភា រួចក៏ស្រដី ប្រាប់នាងតូចថា :

- ភា! យកផ្កានេះទៅជូនម៉ែរបស់កូនទៅណាំ...! គេសក្ដិសមនឹងទទួលផ្កា
ដ៏ស្រស់ស្អាតបរិសុទ្ធបែបនេះពីកូនស្រីរបស់ពុកបំផុតហើយ!!

សោភាឮហើយញញឹមភ្លាម ហើយលូកដៃទទួលផ្កាឈូកពីដៃឪពុក ទៅហុចជូនអ្នកគ្រូយើងយ៉ាងលឿនថែមទាំងស្រដីថា :

- ម៉ែ! កូនសូមជូនផ្កាឈូកនេះជូនម៉ែដ៏ល្អបំផុតរបស់កូន!

គ្រាន់តែឮប្រយោគនេះ កាលណា ភារាណីមានទឹកភ្នែករលីងរលោង ភ្លាមតែម្ដង ។
ធិតាលូកដៃទទួលផ្កាពីកុមារីហើយក៏ស្រវាអោបនាងតូច យ៉ាងណែនថ្នាប់នឹងឱរា ដែលកំពុងតែញាប់ញ័រវន្ទត់ក្រៃលែង រួចស្រាប់តែ
នាងយំខ្សឹកខ្សួលនិយាយអ្វីលែងចេញតែម្ដង ។ សាវេតនិងនាងតូចឃើញ ដូច្នោះក៏បែរសម្លឹងមុខគ្នានឹកឆ្ងល់ក្នុងចិត្តយ៉ាងខ្លាំង ។
បន្តិចមក សាវេតក៏ ពោលទៅកាន់អ្នកគ្រូយើងថា :

- ម៉ែសប្បាយចិត្ត រហូតដល់ស្រក់ទឹកភ្នែក... កូនវិញ ក៏សប្បាយចិត្តរហូត ចង់យំដែរ...

សាវេតនិយាយអួលបំរុងនឹងយំដែរ ស្រាប់តែភារាណីងើបមុខឡើង យកដៃជូតទឹកភ្នែកយ៉ាងរហ័ស
ហើយក៏តបវិញដោយញញឹមថា :

- ណេ្ហីយ! យើងគួរតែញញឹមវិញ ដែលយើងបានមកជួបជុំគ្នា.. ឈប់យំ ទៅណាំកូនសម្លាញ់! ថ្ងៃនេះ កូនចង់ញ៉ាំអីទេ.. ម៉ែនឹងទៅដាំស្លអោយណាំ!

ពិតមែនតែមាត់នាងស្រដីទៅសារេត តែភ្នែករបស់កល្យាណីបែរជា ចោលសំនួរទៅមាណពដែលជាឪពុកឯណោះ ហាក់ដូចជាកំពុងតែចង់សួរ យោបល់នាយអញ្ចឹង ។ មាណពយល់ចិត្តក៏ឆ្លើយឡើងថា :

- សម្លម្ជូរក្រអៅឈូកជាមួយកូនត្រី ប្រហែលជាមានឱជារសណាស់មើល ទៅ... កូន១ចង់ញ៉ាំទេ?

ក្មេង១នាំគ្នាហ៊ោរកញ្ជ្រៀវយល់ព្រមភ្លាមយ៉ាងសប្បាយ ។ មាណពក៏ស្ទុះឡើងពីទឹកស្រីទៅលើស្ពាន រួចក៏ដើរដឹកដៃកូនដើរសំដៅត្រលប់ទៅផ្ទះវិញដោយមានអ្នកគ្រូយើងដើរតាមពីក្រោយយ៉ាងស្ងៀមស្ងាត់ ។ ថ្វីបើ ពេលនោះ គេទាំងពីរមិនបាននិយាយអ្វីនឹងគ្នាច្រើនក៏ដោយ ក៏ក្រសែភ្នែក របស់គេបានហោះឆ្លើយឆ្លងទៅមកមិនដាច់ចង្វាក់សោះឡើយ ហាក់បីដូច ជាគេកំពុងតែផ្ញើសារអាឋិកំបាំងក្នុងចិត្ត ចំពោះទៅមករកគ្នាយ៉ាងមាន ជំរៅជ្រៅធំធេង ។

រសៀលនោះ អ្នកទាំងបួនបរិភោគបាយជុំគ្នាតែស្តកមួយជាលើកដំបូង ក្នុងបរិយាកាសយ៉ាងមនោរម្យ ។ ពេលនោះ សារេតនិងសោភាសង្កេត ឃើញថា ឪពុករបស់គេហាក់ដូចជាយកចិត្តយកថ្លើមអ្នកគ្រូយ៉ាងប្លែកតែ ម្តង តែដោយគេសប្បាយចិត្តនឹងអាហារឆ្ងាញ់ គេមិនបានគិតខ្វល់អ្វីច្រើន ទេ ក្រៅតែពីបរិភោគផងជជែកសួរគ្នាពីនេះពីនោះផង យ៉ាងរីករាយ ។

ពេលវេលាកន្លងទៅសន្សឹម១... ព្រះសុរិយាក៏យាត្រាលាក់ខ្លួនទៅ ក្រោយភ្នំព្រះសុមេរុបាត់ទៅ ទុកបណ្តោយអោយសន្ធិយាលាស្បែងដណ្តប់ ប្រថពីជំនួសវិញម្តង ដោយមានដួងចន្ទ័និងហ្វូងផ្កាយចូលខ្លួនមកជួយរះបំភ្លឺ កំដរពិភពលោកដ៏សែនងងិតអោយមានភាពត្រកុំត្រកាលឡើង ។

នៅក្នុងផ្ទះ សោភាទទូចអោយអ្នកគ្រូនៅសំរាកជាមួយនាងមួយយប់ តែអ្នកគ្រូប្រកែកមិនហ៊ាននៅ ។ មុននឹងចាកចេញត្រលប់ទៅវិញ ភារាណី ក៏នៅអង្គុយអានសៀវភៅរឿងព្រេងមួយ ដែលខ្លួនបានកាន់យកតាំងពី ផ្ទះមក ។ ធិតាគេងអានឱ្យនាងតូចនិងសារេតស្តាប់ រហូតដល់ក្មេងទាំងពីរលង់លក់ក្នុងដំណេកទៅ ។

បន្តិចមក នាងក៏ងើបដើរចេញពីក្នុងផ្ទះ គិតបំរុងថានឹងត្រលប់ទៅវិញទៅហើយស្រាប់តែប្រទះនឹងនាយកវីនៅឈរចាំនៅរានហាលខាងមុខផ្ទះ ។ កាលបើឃើញវត្តមានបុរសយើងភ្លាម កល្យាណីក៏បន្លឺវាចាទៅគេថា :

- ខ្ញុំត្រូវត្រលប់ទៅផ្ទះវិញហើយ...!

- ប៉ុន្តែពេលនេះ យប់ងងិតណាស់... ចាំខ្ញុំជូនដំណើរអ្នកគ្រូទៅណាំ...

ឮប្រយោគនេះ ធិតានៅស្ងៀមមិនហ៊ានប្រកែកទេ ត្បិតយប់ងងិត ដូច្នោះ ដើរយប់ព្រលប់ម្នាក់ឯង ពិតជាមិនមានសុវត្ថិភាពមែន ។ ភារាណីក៏ ឆ្លើយវិញថា :

- អរគុណ ដែលជួយជូនដំណើរខ្ញុំពេលនេះ!

- បាទ៎! ខ្ញុំក៏អរគុណអ្នកគ្រូដែរ ដែលចំណាយពេលមកលេងគ្រួសារយើង!

អ្នកគ្រូសម្លឹងមុខមាណពមួយស្របក់ក៏បោះជំហានចេញទៅ ត្បិតនាង រកទឹកមិនឃើញប្រយោគអ្វីមកនិយាយជាមួយបុរសយើងសោះ...ថ្វីបើក្នុង ជំរៅចិត្តរបស់នាង នៅមិនទាន់ចង់វិលត្រលប់ទៅវិញក៏ដោយ ។ មកដល់ មាត់ជណ្តើរផ្ទះ ភារាណីយកដៃកាន់បង្កាន់ដៃជណ្តើរ រួចបែរក្រោយសម្លឹង មុខមានមាណពយ៉ាងស្ងៀមស្ងាត់ ប៉ុន្តែនាងរកទឹកនិយាយទៅមាណពថែម ទៀតមិនបានមួយម៉ាត់សោះ ។ ឯបេះដូងរបស់នាងវិញ ក៏កាន់តែរណ្តំ ញាប់ញ័រឡើងខ្ទរឱរាយ៉ាងចម្លែក ។ រីឯមាណពយើងវិញ បែរជានៅឈរ ទ្រឹងមិនឮវាចាអ្វីទៅរកនាងដែរ ។ ទាំងពីរនាក់សម្លឹងមុខគ្នាទៅមកដោយ ដួងចិត្តញាប់ញ័ររន្ធត់រវើងៗខ្លួន ។ ភារាណីនៅឈររវេរវាមួយស្របក់ហើយ តែមិនឃើញមាណពស្តីវាចាអ្វីមករកនាង ធិតាក៏ឈ្ងោកមុខបែរក្រោយ ឈានជើងចុះជាន់កាំជណ្តើររកនឹងចេញពីផ្ទះទៅ ។ ស្រាប់តែ...

- អូនណី...

កវីកាត់ចិត្តដែលកំពុងញាប់ញ័ររន្ធត់នោះ ហៅធិតាយើងខ្សិបៗតិចៗ តែក៏ល្មមអាចអោយធិតាបានឮយ៉ាងច្បាស់ពេញត្រចៀក ។ កល្យាណីយើង ឮហើយទុចដំណើរង៉ក់ រួចបែរក្រោយមករកបុរសយើងយ៉ាងរហ័ស ។ ភ្លាម នោះ មាណពឧទានឡើងម្តងទៀតយ៉ាងញាប់ញ័រថា :

- អូនណី ទេពអប្សរតែមួយរបស់បង..!

កវីស្រដីហៅឈ្មោះធិតា ដោយសំនៀងអួលៗនៅក្នុងបំពង់ក ។ ទឹក ភ្នែកពីរតំណក់បានជ្រែកកែវភ្នែករបស់នាយ ហូរចុះមកលើផ្ទៃមុខរបស់ មាណព ហាក់បីដូចជាកំពុងបរិយាយប្រាប់នូវមនោសញ្ចេតនាដ៏មានជំរៅ យ៉ាងធំធេងមួយដែលមិនអាចបង្ហាញបានដោយពាក្យសំដីរបស់គេបាន ។ រី ឯភារាណីយើងវិញ កាលបើឮវាចានោះកាលណា ក៏ស្រាប់តែរន្ធត់ចិត្តញាប់ ញ័រក្នុងឱរា រហូតដល់ទប់ទឹកភ្នែកលែងបានដូចគ្នាដែរ ។ ឈរីក៏ឧទានហៅ មាណពវិញដោយដួងចិត្តរំភើបហួសព្រំដែន :

- បងកវី...!

ភ្លាមនោះ កវីស្ទុះមកជិតនាងយ៉ាងរហ័សរួចហើយស្រវាលូកដៃត្រកង ក្រសោបកាយរបស់ឆវីមកអោបរិតយ៉ាងណែន ផ្ទាប់នឹងដើមទ្រូងរបស់គេ ដោយក្តីរំភើបរកស្មានមិនត្រូវថែមទាំងស្រដីទាំងរន្ធត់ចិត្តថា :

- អូនណី កំពូលដួងចិត្តរបស់បង!... បងនឹកអូនណាស់...!

ព្រមជាមួយគ្នានោះដែរ មាណវីយើងមានអារម្មណ៍ថា បេះដូងរបស់ នាងកំពុងតែកញ្ជ្រោលយោលយោគគគ្រឹកគគ្រេង ចង់តែធ្លាយទ្រូងម្តងៗ ទៅហើយ ហើយក៏ទទួលអារម្មណ៍ថាបេះដូងរបស់មាណពវិញក៏កំពុងតែ រណ្តំញាប់ញ័រមិនខុសពីនាងប៉ុន្មានឡើយ ។ ភារាណីក៏លាតដៃស្រវាអោបក បុរសយើងតបវិញយ៉ាងណែនដូចគ្នារួចខ្សិបដាក់ត្រចៀកគេថា :

- ណារីក៏នឹកបងកវីដូចគ្នា... នឹក.. នឹកគ្មានថ្ងៃណាភ្លេចមួយគ្រាឡើយ...!

ទាំងពីរកាយាក៏ស្រក់ទឹកភ្នែកហូរច្រោក១ យំសស៊ឹកខ្សឹកខ្សួលអួល ដើមកនឹកស្រណោះអាណិតខ្លួនយ៉ាងខ្លាំងឥតឧបមា.. គេស្រវាអោបគ្នាទៅ វិញទៅមកយ៉ាងណែនពេញរង្វង់ដៃមិនលែងហាក់ដូចជាមានបំណងសំដែង នូវអារម្មណ៍សម្ងាត់ដែលគេបានលាក់ទុកក្នុងចិត្តមិនហ៊ានបញ្ចេញប្រាប់គ្នា ច្រើនថ្ងៃមកហើយ គឺតាំងពីថ្ងៃដែលគេបានជួបគ្នាលើកដំបូងនោះមកម្ល៉េះ មែនហើយ! គេរលឹកគ្នាណាស់! គេស្រលាញ់គ្នាណាស់! ប៉ុន្តែហេតុអ្វីបាន ជាគេត្រូវព្រាត់ពីគ្នាអស់រយៈពេលដ៏យូរយ៉ាងដូច្នេះ? តើអ្វីទៅជាឧបសគ្គ រារាំងគេទាំងពីរមិនអោយជួបគ្នា?

គេនៅឈរសម្ងំក្នុងរង្វង់ដៃរបស់គ្នាទៅវិញទៅមក រួចហើយក៏យំខ្សឹក ខ្សួលសំរក់ទឹកភ្នែកដាក់គ្នាយ៉ាងយូរ... ទំរាំគេដាច់ចិត្តលើកដៃជូតទឹកភ្នែក អោយគ្នាទៅវិញទៅមក.. ហើយក៏ញញឹមដាក់គ្នាឡើងសាជាថ្មីដោយការរំភើបចិត្តដែលគេមានឱកាសបានមកឃើញគ្នាសាជាថ្មីវិញ ។ ពេលវេលាក៏ ហាក់ដូចជាឈប់នៅនឹងថ្កល់មួយកន្លែង ទំនងបំរុងផ្តល់ឱកាសដល់គូស្នេហ៍ ទាំងទ្វេហា បានទទួលនូវសុភមង្គលក្នុងចិត្តយ៉ាងធំធេង ជាលើកដំបូង ។

បន្តិចមក កវីក៏វាចាខ្សិប១ទៅផិតាបណ្តូលចិត្តរបស់គេថា :

- ភារាណី... បងរំភើបចិត្តណាស់ ដែលបងបានជួបអូនវិញ...

- អូនក៏រំភើបចិត្តដូចគ្នាដែរ.. ដែលយើងជួបគ្នាសាជាថ្មី.. !

- អូនណី... បងតែងតែបែរបន់រាល់ថ្ងៃអោយបានឃើញភក្ត្រ័អូនទៀត...

- ឥលូវបងក៏បានឃើញវិញហើយ ឃើញភារាណីរបស់បងដដែល ឥតផ្លាស់ ប្តូរប្រែប្រួលទេ...

- បង..រីករាយក្នុងចិត្តពន់ពេកណាស់អូន ដែលទេវតាមិនដាក់បណ្តាសា ឱ្យបងក្លាយជាអ្នកទោសស្នេហារងដំបៅដួងចិត្តអស់មួយជីវិត...

កវីញញឹមដាក់គូស្នេហ៍ទាំងទឹកភ្នែករលីងរលោង ។ គេសម្លឹងមុខផិតា មួយស្របក់ធំរួចទើបបង្អោននាសាស្រង់ក្លិនថ្ពាល់កល្យាណី ដោយដួងចិត្ត រំភើបរំជើបរំជួលឥតព្រំដែន ។ រីឯផិតាយើងវិញ ក៏ញញឹមតបវិញដើម្បី ទទួលនូវចម្លើយសុភមង្គលដ៏ផ្អែមល្ហែមមួយក្នុងអារម្មណ៍ ដែលនាងធ្លាប់ បានគេងទន្ទឹងរង់ចាំអស់ជាយូរឆ្នាំមកហើយ.. យូរឆ្នាំដែលគេមិនដែលឮ ដំណឹងពីគ្នាសូម្បីបន្តិច ។ ឆវីផ្តេកកេសាឈរសម្ងំនៅក្នុងរង្វង់ដៃដ៏កក់ក្តៅ របស់គូស្នេហ៍យ៉ាងយូរ... ហាក់មិនចង់ឃ្លាតទៅណាសោះឡើយ...

នៅលើលើរានហានខាងមុខផ្ទះ គូគាប់ដួងចិត្តទាំងទ្វេហាគេងយោល អង្រឹងយឺត១ កៀកកើយសាសងគ្នាខ្សិប១ ទំលាយនូវអាថិកំបាំងក្នុងជីវិត ផ្សេង១នៅក្នុងអំឡុងរយៈកាលជាយូរឆ្នាំដែលគេបានបែកពីគ្នាទៅ ។ គេ សន្ទនាគ្នា យំផង សើចផង ថ្នាក់ថ្នមដួងចិត្តស្នេហាដ៏សែនរមនាពេញមួយ យប់ទល់ភ្លឺ ។ រាត្រីនោះ កវីក៏បញ្ចេញសំនៀងរហ៊ឹម១យ៉ាងស្រទន់ បំពេរ ទ័យាគូស្នេហ៍របស់គេ អោយយល់នូវភាពសុខមនោរម្យក្សេមក្សាន្ត ក្នុង រង្វង់ដៃដ៏សែនកក់ក្តៅក្រៃលែងរបស់មាណព ។ រីកល្យាណីវិញផ្តេកកេសា លើដើមទ្រូងកវី ញញឹមទទួលយកនូវសេចក្តីសុខយ៉ាងត្រចះត្រចង់...

## ពន្លឺសុភមង្គល

រំលងទឹកស្រណោះសម្រស់រាត្រី		គ្រារួមភិសម័យចរណៃនឹងបង
ចន្ទ្រាពណ្ណរាយរង្សីថ្មីថ្កើង		បំភ្លឺស្នេហ៍យើងសែនសុខក្សេមក្សាន្ត
រាត្រីយប់យន់ស្រទន់វាតា		បបោសកាយាព្រឺអស់អង្គប្រាណ
ដៃនៅក្នុងដៃថ្នាក់ថ្នមកល្យាណ		ស្នេហាថ្កើងថ្កានពេញដោយមង្គល ។
ពពករសាត់ណាត់ពន្លឺផ្កាយ		ហឫទ័យសប្បាយព្រឺព្រួចកាយកល
បេះដូងយោលយោគរណ្តំរចល់		បន់ព្រះនិមលសូមស្នេហ៍អង្វែង ។
បើចន្ទ័លិចហើយសូរ្យអើយយាងរះ		ផ្តល់ភាពត្រចះចាកអស់ចំបែង
ជួយរក្សាស្នេហ៍អមតៈដូចសែង		សូរ្យអង្គក្រៃលែងភ្លឺអង្វែងអើយ ។

ទាំងទ្វេកាយាគេងយោលអង្រឹង សម្លឹងមើលព្រះចន្ទ័ ដោយដួងចិត្ត រមនា ក្រោមជំនោររាត្រីមេសាបក់មករហើយៗ បបោសអង្អែលប្រាណ ថ្នាក់ថ្នមបេះដូងរបស់គេ អោយយល់នូវភពស្នេហាក្សេមក្សាន្តមួយ ដែលគ្មាននរណាម្នាក់អាចយល់ជំរៅបានឡើយ ។

មាន់រងាវខ្ញើយៗ... បីដងមកហើយ...

- បងកវី! អូនត្រលប់ទៅវិញសិនហើយណា៎ ទាន់នៅងងិតនៅឡើយ..
- ចាំដល់ភ្លឺច្បាស់សិនទៅបានទេ? បងនឹងជូនអូនត្រលប់ទៅវិញ ។
- មិនបានទេ... ខ្លាចកម្មករគេឃើញ នឹងយកដំណឹងទៅជំរាបពុក...

ឮដូច្នោះ កវីក៏ទម្លាក់ទឹកមុខជ្រប់ :

- ណ្ហើយ! បងជូនអូនទៅវិញពេលនេះក៏បាន គឺដើម្បីសុវត្ថិភាពរបស់អូន

ថាហើយមាណពក៏លូកស្រវាកាន់ដៃកល្យាណីម្ចាស់ដួងចិត្តដើរចេញពី ដីភូមិរបស់ខ្លួន កាត់តាមភ្លឺស្រែក្រវិកក្រវក់រហូតទៅដល់ជាយចំការរបស់ មេឃុំផែងវិញ ។

- បងជូនអូនត្រឹមនេះចុះ អូនអាចដើរទៅដល់ផ្ទះវិញដោយសុវត្ថិភាព ។

ភារាណីនិយាយទៅកវី ។ រំពេចនោះ នាយយើងតបមកវិញថា :

- ថ្ងៃនេះ អូនគេងសំរាកយកកម្លាំងចុះណា៎ ចាំស្អែកយើងជួបគ្នាទៀត...
- ចា៎ស! ស្អែកយើងជួបគ្នាទៀត.. នៅផ្ទះរបស់បងណា៎!
- អត់ទេ... ព្រឹកស្អែកជាថ្ងៃចូលឆ្នាំថ្មី... បងគិតថានឹងនាំកូនទៅលេងនៅភ្នំ បាណន់ម្តង.. តើអូនអាចទៅបានទេ? យើងទៅជួបគ្នានៅទីនោះ...
- ភ្នំបាណន់?... ចា៎ស! អូននឹងទៅជួបបងនៅទីនោះ ម៉ោង៩ព្រឹក ។
- បាទ! ស្អែកយើងជួបគ្នាទៀតណា៎អូន...!

ថាហើយ មាណពញញឹមដាក់គូស្នេហ៍ដោយក្រសែភ្នែកផ្អែមល្ហែមក្រៃ លែង។ ធិតាដើរចេញទៅហើយ លុះក្រលេកមកក្រោយ ឃើញកវីនៅឈរ សម្លឹងនាងហាក់ដូចជាមានក្តីអាល័យនៅក្នុងចិត្ត នាងក៏ត្រលប់រត់មកវិញ រឹងហើយស្រវាអោបប្រាណនាយយើងយ៉ាងណែន :

- បងកវី..! អូនណីមិនចង់ឃ្លាតពីបងទៅវិញទេ...!

កវីស្រវាទទួលធិតាក្នុងរង្វង់ដៃក៏កក់ក្តៅរបស់ខ្លួនសាជាថ្មីម្តងទៀត :

- បងក៏មិនចង់អោយអូនឃ្លាតចាកចេញឆ្ងាយពីទ្រូងរបស់បងដែរ... បង ស្រឡាញ់អូនណាស់ ភារាណី..! បងស្រឡាញ់អូនស្មើជីវិតរបស់បង។

ធិតាស្រក់ទឹកភ្នែករលីងរលោង :

- យើងមានចិត្តតែមួយទេ បងកវី...អូនក៏ស្រឡាញ់បងដូចគ្នា...ចាំអូនណា៎ កំពូលដួងចិត្ត.. យើងនឹងពុះពារឧបសគ្គជាមួយគ្នា ដើម្បីថ្ងៃមួយ យើងបាន វិលមករស់ជួបជុំគ្នាវិញសាជាថ្មីណា៎បង...!

- បងនឹងចាំ... ចាំអូនជានិច្ច មិនថាបងត្រូវចាំយូរប៉ុនណាឡើយ បងសន្យា ថានឹងរង់ចាំភារាណីតែម្នាក់រហូតតរៀងទៅ...!

គូស្នេហ៍ទាំងទ្វេប្រវាអោបគ្នាយ៉ាងណែន បណ្តោយទុកទៅឱ្យសៀង ចង្វាក់បេះដូងរបស់គេរណ្តំឆ្លើយឆ្លងទៅមក យ៉ាងរន្ថើនគ្រាំគ្រេងនៅក្នុង ឱរា ហាក់បីដូចជាកំពុងប្រាប់គ្នាថា កំសួលនៃដួងចិត្តស្នេហារបស់គេនៅតែ មានអនុភាពយ៉ាងខ្លាំងក្លាដដែល។

បន្តិចក្រោយមក ធិតាយើងក៏បោះជំហានដើរត្រលប់ទៅចំការរបស់ នាងវិញ ទុកបណ្តោយអោយកវីមាណពសម្លឹងមើលតាមស្រមោលរបស់ នាងដោយដួងចិត្តសែនមហាអាល័យជាទីបំផុត...

00000000000000000000

0

# វគ្គទី៤

## ឧប្បត្តិហេតុលើខ្នងភ្នំបាណន់

ថ្ងៃនេះ មីងផាវសង្កេតឃើញកូនស្រីរបស់គាត់ហាក់ដូចជាមានទឹកមុខ ញញឹមបំព្រងវិញហើយ ។ កាលបើក្រលេកឃើញកូនបរិភោគអាហារជា មួយគាត់ប្រកបដោយអារម្មណ៍ក្សេមក្សាន្ត គាត់ក៏មានប្រសាសន៍ថា :

- ណើកូន! ពេលល្ងាចនេះ ពុកឯងនឹងមកផ្ទះវិញ ដើម្បីសែនទេវតាឆ្នាំថ្មី តែ ព្រឹកស្អែកពុកម៉ែទៅធ្វើបុណ្យនៅវត្តហើយ មិនដឹងថាកូនវិញចង់ដើរលេង ទៅណាមកណាទេ.. ។ ម៉ែគិតថា ឯងគួរបបួលមិត្តភក្តិដើរទៅលំហែនៅ ក្រៅផ្ទះខ្លះទៅ ក្រែងលោបានសប្បាយចិត្តខ្លះ នៅតែផ្ទះយ៉ាងនេះ សុញ គំនិត សុញស្មារតីណាស់ ។ សួរនាងរតនានិងដារ៉ាន់មើលក្រែងគេទំនេរនាំឯងទៅដើរលេងផង ។

ឮម្តាយមានប្រសាសន៍ដូច្នោះ ភារាណីនឹកអររភើតតែម្តង ត្បិតចំគោល បំណងរបស់នាង ដែលកំពុងតែបំរុងសុំឪពុកម្តាយទៅលេងនៅបាណន់ ស្រេចហើយ ។ រសៀលបន្តិច មេឃុំផែងក៏ត្រលប់មកដល់ផ្ទះមែន ដូចដែល ម្តាយនាងនិយាយប្រាប់ ។ កម្មករដែលនៅបំរើមេឃុំទាំងអំបាលម៉ាន ក៏នាំគ្នាឈប់សំរាកពីការងារ មកជួយសំអាតទីធ្លាផ្ទះតុបតែងរៀបចំយ៉ាងស្អាត ដើម្បីទទួលទេវតាឆ្នាំថ្មី ។ ទាំងអស់គ្នាបានមកជួបជុំសែនទេវតាយ៉ាងរីក រាយសប្បាយព្រមទាំងមានចាត់ចែងអោយមានការរាំលេងជាមួយវង់ភ្លេង ស្គរដៃប្រគំដោយកម្មករក្នុងចំការ និងការចូលជួបជុំរបស់អ្នកភូមិផងរបង ជាមួយយ៉ាងកុះករផង ។ ចៃដន្យ.. ភារាណីមិនបានចេញទៅសប្បាយជា មួយញាតិមិត្តនៅខាងក្រៅទេ គ្រាន់តែអង្គុយសម្លឹងតាមបង្អួចពីលើផ្ទះទៅមើលអ្នកស្រុករាំលេងនៅទីធ្លាមុខផ្ទះរបស់មេឃុំផែងតែប៉ុណ្ណោះ ។ បន្តិច មកនាងក៏ចូលគេងសំងំយកកម្លាំង ដើម្បីទៅជួបបុរសជាគូស្នេហ៍របស់ធិតា យើងវិញនៅថ្ងៃស្អែកនេះ ។

ព្រឹកស្អែកឡើង..

កាលបើក្រលេកឃើញភារាណីស្លៀកពាក់តុបតែងខ្លួនស្អាតបាត មេឃុំ ផែងសម្លឹងមើលកូនស្រីឡើងចំហមាត់ :

- យី! តែងខ្លួនស្រស់ស្អាតយ៉ាងនេះ ទៅវត្តជាមួយពុកម៉ែឬភារាណី?

- ចាំស! អត់ទេ ពុក! ថ្ងៃនេះ កូនសូមដើរលេងជាមួយរតនានិងដារ៉ាន់

- ទៅណា?...

- ចាំស! ទៅភ្នំបាណន់!

- ចាំបាច់ទៅអីឆ្ងាយដល់ម្លឹង? ដើរលេងជិតៗពុកនេះបានហើយកូន?

មីងផាវ័យកដៃកេះមេឃុំផែង :

- គេនៅក្មេងៗ អោយគេមកដើរលេងជាមួយយើងដែលជាមនុស្សចាស់ យ៉ាងម៉េចកើត? អោយគេដើរលេងតាមរបៀបគេក្មេងទៅ។ ម៉ោះ! ពុកវ៉ា យើងប្រញាប់ទៅវត្ត ក្រែងយឺតមិនទាន់ឆាន់ព្រឹកទៅ។

ថាហើយ មីងផាវ័ក៏អូសដៃមេឃុំផែងចេញទៅ។ រំពេចនោះ រតនានិងដារ៉ាន់ក៏បររថយន្តមកដល់មុខផ្ទះដើម្បីទទួលភារាណីដែរ។ ចៃដន្យ ពេលនោះមានអ្នកដំណើរពិសេសទីបីមកជាមួយផង។ នោះគឺជាលោកគ្រូ កោមលដែលអ្នកគ្រូរបស់យើងមិនចូលចិត្តចង់ជួបទាល់តែសោះ។ កាលបើយល់វត្តមានរបស់លោកកោមលភ្លាម មេឃុំផែងស្រែកផ្ទងឡើងថា :

- អូហ៏! លោកគ្រូ! សូមផ្ញើមើលខុសត្រូវសន្តិសុខកូនចៅរបស់ពូផងណា ហើយសូមទៅដើរលេងអោយបានសប្បាយ..!

- បាទ! ពូមេឃុំ! ជំរាបលាបាទ!!

មេឃុំផែងនិងភរិយា ក៏ឡើងរថយន្តជាមួយអ្នកជិតខាង ធ្វើដំណើរ ចេញទៅ។ ដោយទើសទាល់ ភារាណីក៏ទ្រាំឡើងរថយន្តលោកកោមល ទាំងអារម្មណ៍ហ្មួហ្មង។ ការពិត លោកកោមលជាបុរសមានរូបសង្ហាណាស់ គ្រាន់តែប្រកាន់ខ្លួនបន្តិច ហើយចូលចិត្តនិយាយឌឺដងផ្លែផងផ្កាផង មិនត្រូវ និស្ស័យនឹងភារាណីទេ ដែលនិយាយអ្វីធ្វើអ្វីត្រង់ៗទៅមកចំពោះមុខ មិន ចូលចិត្តកាច់កុងវែងឆ្ងាយច្រើនទេ។ បន្តិចមក ដារ៉ាន់ក៏បរនាំអ្នកទាំងបីទៅដល់ជើងភ្នំបាណន់ដែលមានមនុស្សម្នាខ្សៀវខ្សា មានលក់នំចំណី ទឹកកក ការេមកី ម្ហូបអាហារ មានក្រុមតន្ត្រីលេងភ្លេងកំដរ មានអ្នកអង្គុយច្រៀង តាមកាំជណ្តើរឡើងទៅលើកំពូលភ្នំ មានមនុស្សប្រុសស្រីស្លៀកពាក់ហ៊ីហា ទាំងហ្វូងទាំងក្រុម ខ្លះជាអ្នកស្រុកក្នុងខេត្ត ខ្លះមកពីខេត្តក្រៅ ខ្លះមកពី ប្រទេសក្រៅ.. ឃើញអ្វីអរប្លែកភ្នែកប្លែកអារម្មណ៍មែន។

រំពេចនោះ ភារាណីដើរសំដៅទៅតូបមួយក្រោមដើមឈើរកទិញទឹក ផ្លែឈើកំប៉ុងព្រមទាំងនំកញ្ចប់ពីរបីកញ្ចប់ផង។ ដារ៉ាន់ឃើញហើយក៏លាន់ មាត់ឡើងថា :

- អូហ៏! ភារាណី! ឥលូវចេះដើរទិញចំណីញ៉ាំអីកំប៉ិកកំប៉ុកផងហ្ន៎ស? កាលពីដើមឃើញឯងប្រកាន់ខ្លួន មិនទិញអីតាមផ្លូវបរិភោគទេ។

ភារាណីមិនឆ្លើយវិញទេ គ្រាន់តែញញឹមហើយនៅស្ងៀម ស្រាប់តែ រតនាឆ្លើយជំនួសថា :

- មនុស្សយើងប្រែប្រួលទៅតាមវ័យ តាមទីកន្លែង។ កាលនោះ គេនៅ ភ្នំពេញហើយនៅក្មេង គេមិនដើរទិញបរិភោគរហេតរហូតខុសវិន័យទេ។ ហើយពេលនេះ ទីនេះ ជាទឹកដីស្រុកភូមិខ្លួនឯង ហើយគេក៏...

ភ្លាមនោះ ភារាណីកេះរតនាកាត់ប្រយោគ :

- តោះ ! ទៅឡើងភ្នំ.. កុំអាល័យជជែកឥតប្រយោជន៍!

ថាហើយនាងក៏យូរកំប្រោងឥវ៉ាន់ដើរឡើងកាំជណ្ដើរទៅ ដោយមិនព្ង បបួលលោកគ្រូកោមលមួយម៉ាត់សោះ ។ អ្នកទាំងបីក៏ដើរឡើងទៅតាម ដែរ ។ តាមកាំជណ្ដើរ ដារ៉ាន់ រតនា និងលោកកោមលនាំគ្នាជជែកពីនេះពី នោះមិនដាច់សោះ វៀរលែងតែអ្នកគ្រូភារាណីម្នាក់ទេ ដែលហាក់ដូចជា ស្ងៀមស្ងាត់ជាងគេ ហើយមិនសូវជាយកចិត្តទុកដាក់នឹងវត្តមានរបស់អ្នកទាំងបីឡើយ សូម្បីតែគេបបួលថតរូបជាអនុស្សាវរីយ៍ ក៏ធិតាត្រវីក្បាល មិនចូលរួមដែរ ឃើញតែប្រញាប់ប្រញាល់ដើរឡើងទៅលើកំពូលភ្នំតែម្នាក់ ឯង ។ អ្នកទាំងបីអាល័យតែចាប់អារម្មណ៍រឿងទិដ្ឋភាពស្រស់បំព្រងនៅតាមចង្កេះភ្នំ ព្រមទាំងលង់ចិត្តលង់អារម្មណ៍នឹងបុរសខ្វាក់ពីនាក់ ម្នាក់លេង កូតទ្រ ម្នាក់ច្រៀងយ៉ាងពិរោះ នៅអង្គុយតាមកាំជណ្ដើរ ច្រៀងជូនពរដល់ ភ្ញៀវទាំងឡាយដែលដើរកាត់មុខគេឡើងទៅលើ ។ គេនៅឈរស្ដាប់អស់ពីរបីបទទើបនឹកបបួលគ្នាឡើងភ្នំបន្តទៀត ។ ពេលនោះ ភារាណីបានឡើង ដល់កំពូលបាត់ស្រមោលទៅហើយ ។

មកដល់ទីធ្លាប្រាសាទបាណន់កាលណា ភារាណីងាករំពៃចុះឡើងគ្រប់ ទីកន្លែង សម្លឹងរកនាយកវីព្រមទាំងកូនរបស់គេទាំងពីររំពេចនោះ ស្រាប់ តែនាងញញឹមឡើងយ៉ាងស្រស់តែម្ដង ។ ការពិត អ្នកទាំងបីបានមកដល់ទី នោះចាំធិតាយើងតាំងពីយូរហើយ ។ គេបាននាំគ្នាក្រាលកន្ទេលអង្គុយលេង នៅក្រោមដើមឈើតូចមួយក្បែរប្រាសាទ ។ នៅក្បែរៗនោះ ក៏មានអ្នកថ្មើរកំសាន្តចូលជ្រកម្លប់សំរាកជើងដែរ ត្បិតពួកគេដើរឡើងតាមកាំជណ្ដើរ រាប់រយកាំមកហាក់ដូចជាហត់នឿយបន្ដិចហើយ ។ គ្រាន់តែក្រលេកឃើញ ភក្ដ្ររបស់អ្នកគ្រូយើងពេលណា កុមារីសោភាក៏ស្ទុះរត់មកទទួលមុនគេ :

- ម៉ែ!...

នាងតូចក៏លាតដៃស្រវាអោបអ្នកគ្រូយើង ដែលកំពុងបន្ទាបខ្លួនស្រវា អោបនាងតូចតបទៅវិញហើយស្រដីថា :

- នាងតូចញ៉ាំអីហើយនៅកូន? នេះម៉ែទិញនំមកផ្ញើកូនហើយនឹងបងវេត របស់កូនផងដែរ ( ថាហើយ ភារាណីក៏ស្រាយថង់យកចំណីចេញមក)

សាវេតក៏លូកដៃទទួលបញ្ញើដែលភារាណីទិញផ្ញើ :

- អរគុណម៉ែ!

- អឺ! អាយុវែងណាំកូន!

ភ្លាមនោះ ធិតាចោលកន្ទុយភ្នែកទៅមាណពយើង ដែលអង្គុយនៅ ស្ងៀមស្ងាត់ក្បែរនោះយូរហើយ ឃើញនាយលួចសម្លឹងមកនាងដោយទឹក មុខញញឹមរីករាយត្រេកអរ ធ្វើអោយបេះដូងរបស់នាងបានទទួលនូវភាព ក្សេមក្សាន្តរមនាដូចគ្នាដែរ ។ ធិតាក៏ញញឹមតបវិញថែមទាំងពោលថា :

- បងពិសារអីហើយនៅ? ឃ្លានទេ? ចាំភារាណីទៅទិញយកមកឱ្យណា៎!

- ឱ! បាទ! មិនអីទេ..! បានឃើញភាពញញឹមនៅលើផ្ទៃមុខរបស់អ្នកគ្រូ ហើយនិងកូនទាំងពីរ កវីមានសេចក្ដីសុខណាស់មិនត្រូវការអ្វីទៀតឡើយ ។

មែនហើយ ទីនោះ ជាតំបន់សាធារណៈ ។ គេមិនអាចនិយាយស្រដីអ្វី ឬមានកិរិយាអ្វីស្និទ្ធស្នាលនឹងគ្នាក៏ពិតមែន ប៉ុន្តែភាសាក្រសែភ្នែករបស់អ្នក ទាំងពីរដែលកំពុងសាសងទៅមក ហាក់ដូចជាមានអត្ថន័យស៊ីជំរៅណាស់ លើសពីភាសាពាក្យពេចន៍សន្ទនារាប់រយដងទៅទៀត ។ គេអង្គុយញញឹម លួចសម្លឹងមុខគ្នាភ្លេកៗមិនដាច់ចង្វាក់សោះឡើយ ។ បន្តិចមក កវីក៏វាចា បបួលកល្យាណីយើងថាៈ

- ទៅអុជធូបថ្វាយអ្នកតាម្ចាស់ភ្នំ និងបារមីសក្តិសិទ្ធិទេ អ្នកគ្រូ? ទៅបួងសួងសុំពរជ័យពីព្រះអង្គឱ្យយើងបានសម្រេចនូវពាក្យសច្ចារបស់យើង?

ភារាណីក៏ញញឹមឡើយយ៉ាងស្រស់ស្រាយភ្លាម :

- ដោយរីករាយបំផុតចាស បងកវី!

កវីក៏ងើបដើរនាំមុខធិតា សំដៅទីសក្ការៈមួយ ដែលមានមនុស្សកុះករចូលមកអុចធូបបបួងសួង ។ បន្ទាប់មក គេក៏លុតជង្គង់ចុះទន្ទឹមគ្នា ទាំងពីរ កាយញញឹមដាក់គ្នាហើយក៏ឱនក្រាបបង្គំបួងសួងនៅក្នុងចិត្តស្ងាត់ៗ ។

សច្ចា

ប្រណម្យបួងសួងឱនអញ្ចលី បន់ព្រះរមណីដ៏សក្តិសិទ្ធិ
សូមលោកប្រទានពរអម្រឹត ដល់គូជីវិតស្នេហ៍ភក្តី ។
យើងស្រលាញ់គ្នាជាយូរឆ្នាំ រង់ចាំថ្ងៃរីលសាជាថ្មី
ចាប់ដៃសាងគ្រួសមប្រពៃ ចាកឧបសគ្គភ័យផងទាំងពួង ។
យើងសូមថ្វាត់ថ្វាយកាយបង្គំ ដល់ព្រះភិរម្យមានផ្កាភួង
មានទាំងធូបទៀនទាំងចេកដូង ប្រណម្យបួងសួងលោកមានបុណ្យ ។
ទាំងគូសច្ចាចាំជាប់នៅ ស្នេហាជានៅមិនស្រពោន
មិនថាត្រូវចាំលុះថ្ងៃសូន្យ ក៏ស្ម័គ្របូរខ្លួនស្ងួនស្នេហ៍តែមួយរៀងអើយ....

រំពេចនោះ ស្រាប់តែគេឮសម្លេងស្រែកយ៉ៃ ព្រមទាំងឮសម្លេងមនុស្ស ចាស់លាន់មាត់សម្តុតក្មេងផង ។ លុះភារាណីនិងកវីបែរមកមើល ស្រាប់តែ ប្រទះនឹងបុរសសង្ហាមួយរូប កំពុងចាប់ក្រញៀងនាងតូចសោភាហើយច្រាននាងវឹងអោយដួលទៅដីអុកគូថយ៉ាងដំណំ ថែមទាំងស្រដីខ្លាំងៗថា :

- ភ្លើទេហ៎ មីច្រមក់! រត់លេងភ្លើៗមកបុកយើង ហើយកំពប់ទឹកផ្លែឈើ ប្រឡាក់ពាសពេញលើអាវរបស់យើងអស់ ។ ចំជាក្មេងចង្រៃមែន!

នាងតូចសោភាក៏យំវ៉ាឡើងដោយក្តីភិតភ័យ ។ ឃើញដូច្នោះ សារេត ក៏ស្ទុះយ៉ាងរហ័សទៅស្រវាលើកកុមារីឡើងលួងលោមអោយនាងបាត់យំ ។ បុរសនោះមិនទាន់អស់ចិត្តខឹង ក៏លើកដៃលាឡើងបំរុងនឹងទះ នាងតូចមួយ

ដៃទៀតទៅហើយ ស្រាប់តែករីមកចាប់ដៃជាប់ ព្រមទាំងស្រដីថា ៖
- ហេតុអីចាំបាច់ប្រើកម្លាំងបាយវាយក្មេងផង? គេខុសអី ស្តីប្រដៅតែ មាត់ទៅបានហើយ
កុំលេងដៃជើងមើលតែមនុស្សព្រៃយ៉ាងនេះ?

ភារាណីក៏ស្ទុះទៅស្រវាកុមារីយកមកអោបក្នុងដើមទ្រូងរបស់នាងឱ្យ នាងតូចបានទទួលនូវការកក់ក្តៅបាត់ភិតភ័យ ។ លុះក្រលេកបែរមើលទៅ បុរសនោះវិញ ស្រាប់តែនាងបើកភ្នែកធំៗ ភ្ញាក់ស្រលាំងកាំងហើយឧទាន ភ្លាមថា ៖
- ហារិន? នេះគឺជាឯងតើហ៎?...

តែបុរសសង្ហាឫកខែងរែងនោះ ធ្វើមិនឮ ។ គេបែរបើកភ្នែកធំៗ ខម ដាក់ករីវិញយ៉ាងយង់ឃ្នងបំផុត ព្រមទាំងគំហកថា ៖
- ឯងចង់ថានរណាជាមនុស្សព្រៃ? ពួកឯងខ្វាក់ឫក៏ធ្វើជាខ្វាក់បានជាមិន ឃើញមីល្អិតនេះវារត់មកបុកយើង
ហើយថែមទាំងកំពប់ទឹកផ្លែឈើពណ៌ ក្រហមប្រលាក់ពេញអាវយើងទៀតផង? ឫកពាមនុស្សព្រៃដូចពួកឯង នេះ
ទៅណាមកណាមិនច្រលំនឹងគេទេ ។ តើមាននឹកអាមាសខ្លួនទេហ៎ដែល
កូនចៅរបស់ឯងរត់សស្លាក់សស្លើតមកកំពប់ទឹកក្រូចប្រលាក់អាវយើង?

គេបញ្ចេញឫកពាច្រឡោងខាម ថែមទាំងយកដៃចង្អុលមុខករីយើង គំហកខ្លាំងៗ ធ្វើអោយមនុស្សម្នាដែលដើរកំសាន្តទីនោះ នាំគ្នាផ្អើលរត់មក ចោមរោមឈរមើលយ៉ាងអ៊ូអរ ថែមទាំងមានអ្នកខ្លះលើកកាម៉ារ៉ាដេញ ថតហេតុការណ៍ទាំងនោះផង ។ ភ្លាមនោះ ស្រាប់តែភារាណីងើបឈរវឹង ឡើង រុញកុមារីហុចទៅអោយករី រួចស្ទុះដើរទៅជិតបុរសនោះ បើកភ្នែក ខមដាក់នាយវិញដោយកំហឹង ។ នាងក៏វាចាយ៉ាងត្រជាក់ស្រេបដល់ឆ្អឹងខ្នង តបទៅបុរសចម្លែកនោះថា ៖
- ហារិន ចេះស្គាល់ពាក្យថាអាមាសដែរហ៎? បើស្គាល់មែន សូមបកស្រាយ អត្ថន័យប្រាប់ភារាណីផងថា ត្រឹមអំពើកុមារីម្នាក់ កំពប់ទឹកក្រូចលើអាវ របស់លោក លោកថាវាគួរអាមាសទៅហើយ ចុះទំរាំបើ បុរសពេញវ័យ មួយរូប មានការសិក្សា មានត្រកូលខ្ពង់ខ្ពស់ មានកត្តិយសឧត្តម តែបែរជា ប្រព្រឹត្តអំពើរំលោភផ្លូវភេទជាន់ឈ្លីកត្តិយសនារីក្រមុំម្នាក់ ឱ្យជីវិតរបស់ នាងប្រឡាក់ប្រឡូសទៅដោយឈាមនរកអវិចី តើក្តីអាមាសនោះវាគួរ មានកំរិតកំពស់ដល់ណាដែរសំរាប់បុរសម្នាក់នោះ? ឆ្លើយមក៏! ឆ្លើយមក៏!

កល្យាណីស្រដីផង យកដៃទៅរុញដើមទ្រូងរបស់បុរសសង្ហានោះស្ទើរ តែដួលផ្ងាកៗក្រោយម្តងៗទៅហើយ ។ តែម្តងនេះ បុរសឈ្មោះហារិននោះ បែរជាគាំងសំដីរកនឹកតបអ្វីលែងឃើញតែម្តង ។ រំពេចនោះ ស្រាប់តែនារី
សិចស៊ីមួយរូបដើរវែកហ្វូងមនុស្សចូលមកដល់ ៖
- ពុទ្ធោ! មានរឿងអ្វីហ្នឹងបងហារិន?

រួចហើយនារីនោះ ក៏បែរមុខសម្លក់ភារាណីរួចស្រដីថា ៖
- ចុះនាងជានរណាដែរ ដែលហ៊ានថ្លើមធំបំបាក់មុខបងហារិនកណ្តាលហ្វូង ចំណោមយ៉ាងនេះ? ស្គាល់ទេ ថាគេជានរណា?
- ថីក៏មិនស្គាល់.. ស្គាល់យ៉ាងច្បាស់ទៀតផង.. ស្គាល់ទាំងប្រវត្តិល្អ ទាំង
ប្រវត្តិអាក្រក់របស់គេ...គ្រប់យ៉ាង..!

ភារាណីឆ្លើយវិញ ដោយសម្លឹងខមទៅហារិនដោយមិនដាក់ភ្នែកសោះ
ឡើយ ។ ឃើញធិតាយើងមិនខ្លាចបារមីរបស់ហារិន ឆវីសិចស៊ីក៏បន្ថែមថា:
- នែ៎! នាង!...អាងស្អី បានជាហ៊ានជាន់កន្ទុយខ្លា? តិចថា...
- ខ្លាហ្អេស?... ហារិនមិនមែនខ្លាទេ! ការពិត គេគ្រាន់តែជាកូនសុនខ... ដែលមានកន្ទុយខ្សៀន.. តែប៉ុណ្ណោះ
( អ្នកគ្រូយើងឆ្លើយកាត់សំដីនាង)
ឆវីសិចស៊ីឮដូច្នោះ ក៏បែរទៅនាយហារិនហើយឧទានឡើងថា :
- បងហារិនឮទេ..? គេកំពុងត្មះតិះដៀលថា បងជាសត្វឆ្កែណា...
- បងឮហើយ អូនវិល័យ... មិនបាច់មកប្រាប់បង ផ្ទួនថែមទៀតទេ...
ហារិនគំហកទៅនារីសិចស៊ីមួយរូបនោះ ហើយបែរមកសម្លឹងមុខធិតា ភារាណីសឹងតែស៊ីសាច់ទាំងរស់តែម្តង
ទទួលគេបានក្រលេកឃើញមនុស្ស
ឈរកាន់កាម៉ារ៉ា ចោមរោមច្រើនពេក ក៏ប្រែជាទប់មាត់ទប់កទៅវិញ រួចក៏ដើរថយចេញទៅ
ដោយមិនស្តីអ្វីមួយម៉ាត់តបទៅភារាណីឡើយ ។
មនុស្សម្នាក៏បែកហ្វូងបែកជួរវិញអស់ទៅ ។ កវីដើរចូលមកជិតអ្នកគ្រូ យើងហើយក៏ស្រដីថា :
- សូមទោសអ្នកគ្រូ ដែលកូនសោភាធ្វើអោយអ្នកគ្រូត្រូវចេញមុខអំពល់ ក្តៅក្រហាយដោយសារ...
ភារាណីឮហើយក៏យកដៃអង្អែលក្បាលនាងតូចហើយតបវិញថា :
- គ្មានអ្វីដែលត្រូវសូមទោសទេ បងកវី! នាងតូចគឺជាក្មេងដែលគួរអោយ អាណិតបំផុតហើយ ។
ការពិតគឺមនុស្សចាស់ម្នាក់នោះវិញទេ ដែលមកត្រូវ
មកសូមទោសនាងតូចទេតើហ៎...
នាងតូចបានឃើញហេតុការណ៍ទាំងឡាយសព្វយ៉ាង តែនាងមិនយល់
ទេថាចាស់ៗកំពុងនិយាយប្រកែកគ្នាពីអ្វី ។ បន្តិចមកស្រាប់តែដាវ៉ាន់ រតនា និងលោកកោមលដើរចូលមកដល់ ។
គ្រាន់តែប្រទះកវីនៅទីនោះ រតនា ឈរធ្វើភាំងចំហមាត់ ។ រីឯកវីយើងវិញ កាលបើប្រទះឃើញវត្តមានរបស់ រតនាភ្លាម
ក៏បញ្ចេញកិរិយាទំនងទើសទាល់ក្នុងចិត្តបន្តិចដែរ តែគេឈរនៅ ស្ងៀមមិនមាត់មិនស្តីអ្វីឡើយ មានតែដាវ៉ាន់នឹងលោកកោមល
ពីរនាក់ ប៉ុណ្ណោះដែលស្រដីចេចចាចមិនចាប់ភ្លឹកនឹងរឿងអ្វី ។ បន្តិចមកកវីក៏លាអ្នក ទាំងបួន នាំកូនដើរចុះពីភ្នំត្រលប់ទៅផ្ទះវិញទៅ
ទុកឱ្យភារាណី ឈរសម្លឹង តាមមើលពីក្រោយទាំងអារម្មណ៍មិនដាច់អាល័យ ។ បន្ទាប់មក លោកគ្រូ
កោមលក៏នាំនារីរូបស្រស់ទាំងបីទៅលេងស្ពានយោល ថែមទាំងបានដើរ ថតរូបទេសភាពនាមាត់ស្ទឹងសង្កែបានជាច្រើនទៀតផង ។
ព្រលប់បន្តិច គេ ក៏នាំគ្នាត្រលប់ទៅផ្ទះវិញដោយអារម្មណ៍ប្លែកៗរៀងខ្លួន ។
នៅលើអង្រឹងដែលចងនៅរានហាលមុខផ្ទះ កវីគេងយោលយឺតៗទៅ មកៗ បណ្តែតអារម្មណ៍ទៅឆ្ងាយសែនឆ្ងាយ
នឹកទៅដល់រឿងរ៉ាវនាគ្រា អតិតកាលជាច្រើន ដែលតែងតែមកលងអារម្មណ៍របស់មាណពមិនឈប់ ឈរ ។

កូនរបស់គេទាំងពីរក៏ចូលនិទ្រាលង់លក់ស្កាត់អស់ហើយ នៅសល់ តែរូបគេម្នាក់ឯង ដែលប្រឹងធ្មេចមិនលក់ទាល់តែសោះ ។ គេក៏នឹកមិនអស់ ចិត្តអំពីរឿងរ៉ាវពីព្រឹកមិញដែលកើតឡើងនៅលើខ្នងភ្នំបាណន់... នឹកមិន យល់ ...ថាតើនាយហារិនជានរណា? ហើយតើគេមានទំនាក់ទំនងអ្វីនឹង

អ្នកគ្រូរបស់យើងដែរ? មើលទៅឥរិយាបថអ្នកទាំងពីរ ហាក់សំដែងថាគេ

ជាសត្រូវប្រចាំជាតិនឹងគ្នាពីកាលណាក៏មិនដឹង...

កំពុងតែលង់ក្នុងការគិតចាក់ស្រេះមិនដាច់ស្រេច ស្រាប់តែមាណព ឃើញស្រមោលមនុស្សដើរស្ទុង១ ចូលមកដល់បរិវេណដីភូមិរបស់នាយ ។ បុរសយើងងើបឡើងសម្លឹងមើល ស្រាប់តែលាន់មាត់ថា :

- ភារាណី? ពុទ្ធោអើយ! ហេតុអ្វីក៏អូនដើរមកទីនេះទាំងយប់ដូច្នេះ?

កវីស្ទុះរឹងចុះទៅទទួលនាងយ៉ាងលឿន ។ ធិតាក៏ឆ្លើយតបវិញថា :

- មកពីខ្ញុំច្របូកច្របល់ចិត្តពេកអំពីរឿងរ៉ាវថ្ងៃនេះ ខ្លាចបងគិតសង្ស័យ...

- បងមិនមានសង្ស័យអ្វីទេ ភារាណី! បងគ្រាន់តែនឹកបារម្ភពីអូនប៉ុណ្ណោះ ។ មើលទៅគេម្នាក់នោះ ហាក់ដូចជាមានឫកពាបែបជាកូនអ្នកមានអំណាច ផង ។ អូននិយាយថ្លោស១ដាក់គេថ្ងៃនេះ ធ្វើអោយបងនឹកបារម្ភក្រែងគេគុំគួនតាមធ្វើបាបពួកយើងថ្ងៃក្រោយ...ជាពិសេសគឺរូបអូនតែម្តង ។

- ខ្ញុំមិនខ្លាចទេ មនុស្សអាក្រក់ ។ បើគេមកតាមសងសឹកពិតមែន ភារាណី ក៏សច្ចាថានឹងតស៊ូលុះគ្រាចុងក្រោយដែរ មិនអោយមនុស្សអាក្រក់វាមាន ឱកាសដើរធ្វើបាបនរណាស្រេចនឹងចិត្តបានទៅទៀតឡើយ ។

បន្តិចមក ធិតាយើងបានមកដល់ក្បែរជើងមុងរបស់កុមារីសោភានិង សាវេត ក៏លូកដៃអង្អែលក្បាលនាងតូចហើយស្រដីថា :

- គេងអោយបានក្សេមក្សាន្តទៅណា៎កូនម្តាយ! សូមអោយអ្នកចាកផុតនូវ

អំពើអាក្រក់និងការប៉ុនប៉ងយាយីទាំងឡាយពីមនុស្សដែលមានចិត្តអប្រិយ

ចំពោះកូន ។ សូមអោយជីវិតរបស់កូនជួបតែសេចក្តីសុខតរៀងទៅ...

អ្នកគ្រូយើងអង្គុយសម្លឹងភក្ត្រនាងតូចយ៉ាងយូរ ទំរាំលាត់មុងថយខ្លួន ចេញមកវិញ ។ នៅខាងក្រៅ កវីតាមដានគ្រប់សកម្មភាពទាំងអស់របស់ នារីយើងជានិច្ច ។ វត្តមានរបស់នាងមកដល់ចំពោះមុខរបស់នាយ បានធ្វើ អោយបេះដូងដ៏ក្រៀមក្រំរបស់គេ ប្រែជារីកស្រស់បំព្រងភ្លាមមួយរំពេច ។ ពេញមួយរាត្រី

អ្នកទាំងពីរគេងយោលអង្រឹងនៅលើរានហាលខាងក្រៅ ផ្ទះ សន្ទនាគ្នាខ្សិប១រហូតទាល់ភ្លឺ មិនដឹងថាគេនិយាយអ្វីខ្លះទេ ត្បិតគេបាន បែកគ្នាអស់រយៈពេលជាយូរឆ្នាំមកហើយ ។ ពេលនេះ ភ្លើងស្នេហ៍ចាស់ កំពុងតែឆាបឆេះឆួលចោលឥទ្ធិពលសាជាថ្មីម្តងទៀត ហើយហាក់ដូចជា កំពុងតែចោលកំសួលខ្លាំងជាងពេលមុនទ្វេឡើងថែមទៀតផង ។

## អង្រឹងស្នេហ៍រមនា

អង្រឹងយោលយោគជោគក្លិនស្នេហ៍ ក្រោមពន្លឺខែថ្លាពណ្ណរាយ
រៀមច្រៀងបំពេរពៅឆោមឆាយ ក្នុងរង្វង់ដៃក្សាន្តទ័យា ។
កើយទ្រូងបងមកណាំវរមិត្រ ទោះយប់ងងិត ចិត្តរមនា
ពន្លឺស្នេហ៍យើងសុខសោភា នាំដួងទ័យាហោះត្រៃត្រឹង្ស ។
ផ្ទេចគេងទៅអូនស្ងួនមាសមុំ បងច្រៀងលួងលោមថ្នមព្រលឹង
គូគាប់សន្ទនាយប់ស្ងាត់ឈឹង ក្នុងថ្នក់អង្រឹងស្នេហ៍ភក្ដី ។
ជំនោះរំភើយថ្នមកាយា សន្សើមអន្ធការធ្លាក់រោយស្បៃ
ប្រស់ប្រសិទ្ធិពរគូភិសម័យ រួមរក្សមេត្រីភក្ដីស្នេហ៍....

0000000000000000000000

# វគ្គទី៥

# គំនុំ

ស្អែកឡើងពេលថ្ងៃត្រង់...

មេឃុំផែងកំពុងតែជជែកគ្នាជាមួយនឹងចាស់ទុំក្នុងភូមិពីរបីនាក់ពីរឿង បុណ្យងាន នៅលើគ្រែឫស្សីក្រោមម្លប់ព្រីងមួយដើមកណ្តាលធ្លាមុខផ្ទះ ស្រាប់តែមានរថយន្តហ្ស៊ីបមួយយ៉ាងសង្ហាចូលមកដល់។ រំពេចនោះ បុរសម្នាក់ក្នុងសម្លៀកមន្ត្រីយោធាជាន់ខ្ពស់មួយរូបពាក់វ៉ែនតាខ្មៅ ចុះពីលើរថ យន្តដោយមានអង្គរក្សហែហមពីរបីនាក់គ្រាក់ៗផង ស្រែកសួរមកថា :

- នរណាមួយទៅជាមេឃុំផែង?

ភ្លាមនោះ ចាស់ៗទាំងអស់ដែលនៅទីនោះ ក៏ភ្ញាក់ស្រលាំងកាំងបែរ មើលទៅក្រុមមនុស្សចំណូលថ្មីយ៉ាងស្រុះគ្នាតែម្តង។ មេឃុំផែងក៏ងើបឈរ ឡើងហើយតបទៅវិញថា :

- គឺខ្ញុំនេះជាមេឃុំផែង!

ស្រាប់តែមន្ត្រីរូបនោះដែលមានចំណាស់ប្រហាក់ប្រហែលគ្នានឹងមេឃុំ
ផែងដែរក៏ដើរចូលមកជិត ហើយស្រាប់តែស្រវាចាប់ក្របួចកអាវមេឃុំ ផែង រួចស្រដីថា :

- ថ្លើមធំ! ហ៊ានប្រមាថកត្តិយសយើងដល់ម្លឹងផង? ដឹងទេ ថាយើងគួរ ប្រដៅឯងយ៉ាងម៉េចដែរ?

មេឃុំផែងធ្វើមុខស្រលាំងកាំង យកដៃគៀសប្រច្រានមន្ត្រីជាន់ខ្ពស់ ម្នាក់នោះ ចេញហើយឆ្លើយថា :

- យើងមិនដែលស្គាល់គ្នាពីមុនមកសោះ ហេតុអ្វីជួបមុខគ្នាភ្លាម ក៏សំដែង ទោសៈដាក់គ្នាយ៉ាងនេះ? លោកមានរឿងអ្វីហ្នឹង?

- ធ្វើដល់មេឃុំដែរ ម្តេចក៏ងោះមិនដឹងខ្យល់យ៉ាងនេះ? ចង់ដឹងណាស់ មែនទេ ថាជារឿងអ្វី?

ភ្លាមនោះ មន្ត្រីរូបនោះក៏បោកកាសែតមួយក្បាលផាំងទៅលើដីហុយ ធូលីទ្រលោម រួចហើយស្រដីយ៉ាងមុតថា :

- នេះ៎ បើចង់ដឹងយកកាសែតនេះទៅអានទៅ.. ហើយកុំភ្លេចវារក្បាល ជង្គង់បួនទៅសូមទោសលោក ប៉ុក ហារ៉ាន់ យើងនេះដល់ការិយាល័យផង ត្បិតសមាជិកក្រុមគ្រួសាររបស់យើងជាមនុស្សថ្លៃថ្នូរ មិនប្រព្រឹត្តផ្តេស ផ្តាស
ហើយមិនយកកើ្តទៅចោលកណ្តាលខ្នាស់ដូចកូនចៅរបស់មេឃុំឯង នោះទេ។ បើមិនព្រមទៅសូមទោសយើងទេ.. ឯងងាប់!!

ថាហើយ មន្ត្រីរូបនោះហក់ឡើងរថយន្តវិញយ៉ាងរហ័ស ត្រលប់ចេញ ទៅ។ មេឃុំផែង ឈរធ្មើភ្នែកឡឹងឡង់មិនយល់ហេតុការណ៍។ ភ្លាមនោះ គាត់ក៏ឈ្ងោករើសយកសារពត៌មានមួយច្បាប់នោះមកអាន ឃើញថាជាសំណៅដែលទើបតែចេញផ្សាយថ្ងៃនេះតែម្តង។ លុះមេឃុំលាតកាសែត អាន ដោយមានចាស់ៗជាអ្នកភូមិក្បែរខាងមកឈរចោមរោមមើលផង ដែរ ស្រាប់តែប្រទះនឹងរូបដែលផ្តិតយ៉ាងធំជិតពេញមួយទំព័រដំបូង។ គ្រាន់ តែក្រលេកឃើញរូបនោះកាលណា មេឃុំបើកភ្នែកធំៗដូចពងមាន់ ហើយ លាន់មាត់ថា :

- ភារាណី...ឯងទៅបង្កចលាចលអ្វីទៀតហើយ?

មែនហើយ នៅក្នុងរូបនេះ មេឃុំឃើញរូបភារាណីកំពុងប្រឈមមុខ នឹងបុរសសង្ហាមួយរូប។ នៅខាងឆ្វេងដៃរបស់នាងមានរូបកវីនិងកូនរបស់ គេទាំងពីរ ថែមទាំងមានពត៌មានដែលសរសេរថា :

- កម្លោះកំពូលសង្ហាប្រចាំក្រុងបាត់ដំបងឈ្មោះ ប៉ុកហារិន ជាកូនប្រុស ទោលរបស់លោកឧត្តមសេនិយ ប៉ុកហារ៉ាន់ ដែលជាមន្ត្រីជាន់ខ្ពស់ដ៏ល្បី ល្បាញមួយរូប បានត្រូវអ្នកគ្រូសាលាបថមសិក្សាមួយរូបឈ្មោះ ភារាណី ដែលត្រូវជាកូនស្រីរបស់មេឃុំផែង ហែកកេរ្តិ៍ថា កម្លោះនេះបានប្រព្រឹត្ត រឿងអាមាសខុសសីលធមិទៅលើនារីភេទមួយរូប ហើយបានត្រូវអ្នកគ្រូ ភារាណីដាក់ឧទ្ទិសនាមអោយកម្លោះនោះថាជាសុនខកន្ទុយខ្មៀន។ ក្រុម អ្នកយកការណ៍របស់យើង មិនបានដឹងថារឿងនេះ ជាការពិតឬក៏យ៉ាងណា ទេ ប៉ុន្តែគ្រាន់តែដឹងថា កម្លោះសង្ហាប៉ុកហារិនមិនឃើញហ៊ានហើបមាត់ស្រដីតបវិញអ្វីឡើយ ចំពោះពាក្យត្មះតិះដៀលរបស់អ្នកគ្រូ ដ៏សែនស្រស់ ស្អាតមួយរូបនោះ។ យើងចង់ដឹងណាស់ថា តើលោក ប៉ុកហារ៉ាន់ ដែលជា ឪពុករបស់កម្លោះសង្ហាវិញ នឹងមានប្រតិកម្មយ៉ាងណាដែរ កាលបើកូន ប្រុសទោលរបស់លោក ប្រព្រឹត្តខុសសីលធមិទៅលើនារីភេទ នៅក្នុង ឱកាសដែលរូបលោក ជាឧត្តមសេនីយបំរើសង្គម ដោយយុត្តិធមិ? ឬក៏ លោកត្រូវបិទភ្នែកបិទច្រមុះមិនអើពើនឹងរឿងតូចតាចនេះ?

រំពេចនោះ មេឃុំផែងសង្រ្កឹតធ្មេញឡើងហើយស្ទុះរំយ៉ាងលឿនសំដៅ ទៅលើផ្ទះ :

- នាងណី! នៅឯណាឆាប់ចេញមក៏! នាងណី!

ភារាណីឮសម្លេងឪពុកស្រែកហៅនាងខ្លាំងៗក៏ស្ទុះចេញមកពីក្នុងបន្ទប់ របស់នាងយ៉ាងរហ័ស :

- ពុកមានការអ្វីត្រូវប្រើកូនឬ?

មេឃុំផែងយកសំណៅកាសែតគប់មុខធិតាផាំង ហើយគំហកថា:

- កូនពន្យល់ពុកបន្តិចមក៏ ថាពីម្សិលវាមានរឿងអ្វី? ដឹងទេថា ពុកបាន ហាមមិនអោយឯងទៅជួបអាកវី..! តែម្សិលមិញឯងទៅលួចជួបវានៅលើ ខ្នងភ្នំបាណន់មែនទេ? ពុទ្ធោអើយ! យើងតែងតែមានប្រផ្នូលអាក្រក់ជាប់ ជានិច្ច គឺអោយតែឯងជួបមុខអាកវីពេលណា ឯងតែងតែនាំរឿងមកដាក់ ផ្ទះមិនឈប់ឈរ...!

ភារាណីស្រវារើសយកកាសែតនោះលើកយកមកលាតអាន តែមិន ឃើញសម្តែងការភ្ញាក់ផ្អើលអ្វីទេ។ នាងបែរជាឆ្លើយវិញថា :

- ហេតុការណ៍ថ្ងៃម្សិល មិនមែនមកពីបងកវីទេ ហើយគាត់ក៏មិនមែនជាតួ

អង្គនៅក្នុងរឿងដែលគេចុះផ្សាយកាសែតនេះដែរ ហេតុអ្វីក៏ពុកបែរជាខឹង
គោវាយរទេះយ៉ាងនេះ?
- ម៉េចក៏ថាមិនមែន? បើកុំតែឯងណាត់គ្នាទៅជួបនៅលើភ្នំ កុំអីឯងក៏មិន មានរឿងរហូតត្រូវគេចុះកាសែត
ហៀរដំណឹងអាមាសពាសពេញស្រុក យ៉ាងនេះដែរ ។ ឯងជាស្រីមិនចេះខ្មាស់គេទេហ៍?
- រឿងអ្វីត្រូវខ្មាស បើខ្ញុំមិនមែនជាអ្នកដែលធ្វើខុសផង? អ្នកដែលគួរ ខ្មាស់ គឺជាអ្នកដែលប្រព្រឹត្តខុសនោះតើហ៏ ។
- តែគេជាប្រុស ទោះជាយ៉ាងណាក៏...
- ប្រុសក្តីស្រីក្តី គឺចេះមានកត្តិយស ហើយចេះអាប់កត្តិយសដូចតែគ្នា ហ្នឹង ។ បើយើងប្រព្រឹត្តលាមកហើយ
មិនថាជាប្រុសឬក៏ស្រីទេ សង្គមគេ នៅតែសើចយំដដែលហ្នឹង គ្រាន់តែថា បុរសមានស្បែកមុខក្រាស់ជាងនារី បន្តិច
ត្បិតពេលបុរសដឹងថា ខ្លួនគេបានប្រព្រឹត្តខុសហើយ គេច្រើនគេចមិន ព្រមកែខ្លួនទេ
ដោយសំអាងលើទ្រឹស្តីដែលថាបុរសជាមាសទឹកដប់មិនចេះ ប្រលាក់ប្រលូស ។ ការពិត មាសទឹកដប់ក៏ចេះសឹក ចេះស្រអាប់
ចេះទ្រុឌ ចេះកូដដាច់ មិនមែនល្អជារហូតនោះទេ ។ ជួលកាលបុរសប្រឹងពារបំពាន
កំហុសរហូតដល់ហួសពេលកែលែងកើតក៏មានដែរ ហើយនៅពេលដែលគេ ខំលាក់កំហុស លាក់ភាពអាមាសរបស់គេ
បុរសតែងតែប្រឹងស្វែងរក ចំណុចខ្សោយ ដើម្បីចង្អុលទៅនារីវិញ អោយនាងទទួលរងភាពអាមាស
ចំពោះការប្រព្រឹត្តដ៏ឆ្គាំឆ្គងរបស់បុរស ជាជំនួសវិញក៏មាន ។
- បានអោយទៅរៀននៅភ្នំពេញចេះដឹងទៅ ឥលូវ សំដីគ្រាន់បើណាស់ហ្ន៎ តមាត់យើងអោយប៉ប៉ែស ។ នាងដឹងទេហ៍ថា
លោកប៉ុកហារ៉ាន់ ដែលជា ឪពុករបស់នាយហារិន គេមកសម្លុតយើងអំបាញ់មិញនេះថា គេនឹងសម្លេះ យើងចោល
បើយើងមិនវារជង្គង់បួនទៅសូមទោសគេ ដល់ការិយាល័យ... នាងណី..! ឯងកំពុងនាំរឿងក្តៅក្រហាយដល់យើងសាជាថ្មីហើយ ។
- មិនអីទេពុក.. កូនជាអ្នកបង្កបញ្ហានេះអោយវាកើតឡើង ទុកអោយកូន
ដោះស្រាយចុះ ។
- អឺ! អោយវាដោះស្រាយចេញទៅ ។ តែយ៉ាងណាក៏ពុកនៅតែហាមកូន ដដែលថា កូនមិនត្រូវទៅរញ៉ីរញ៉ៃស្អីនឹងអាកវីទៀតទេ
បើមិនដូច្នោះទេ ពុកនឹងវាយកូនទៀតមិនខាន ។

ភារាណីឮហើយ បែរសម្លឹងឪពុកឈប់ស្រដីមួយស្របក់ទើបស្រដីថា :
- ហេតុអ្វីក៏ពុកនៅមានអគតិនឹងបងកវីម្ល៉េះ? ហេតុអ្វី?...

ធិតាស្រដីសួរទៅឪពុកយ៉ាងរន្ថើន ទាំងអួលណែនក្នុងបំពង់កថែមទាំង មានទឹកភ្នែករលីងរលោងផង ។
មេឃុំផែងឃើញដូច្នោះក៏គំហកវិញថា :
- យើងជាឪពុក មិនចាំបាច់មកពន្យល់នាងរឿងអ្វីទេ ។ បើនាងមិនស្តាប់ អាកវីនឹងត្រូវឈឺខ្លួនដូចគ្រាមុនៗមិនខាន ។
- ពុក... ហេតុអ្វីក៏បេះដូងរបស់ពុកប្រកបដោយភាពហឹង្សានិងការស្អប់ ខ្ពើមចំពោះបងកវីយ៉ាងនេះ? តើគាត់មានកំហុសអី..
ពុកប្រាប់កូនសិនមក៏ បើមិនដូច្នោះទេ.. ពេលនេះ កូនសូមរើបម្រះពីឃ្មោបកំហឹងរបស់ពុកហើយ

- តែផ្កាស.. យើងចិញ្ចឹមនាងអោយធំធាត់ មិនមែនមកអោយនាងបែរខាំ យើងដូចក្រពើទេ។ នាងដឹងហើយថា ទោសនៃការមិនស្តាប់ឪពុក វានឹង មានលទ្ធផលយ៉ាងណា? ធ្វើជាមេឃុំប្រដៅតែកូនចៅខ្លួនមិនបាន តើនឹងធ្វើជាមេឃុំអោយអ្នកស្រុកកោតខ្លាចយ៉ាងណាកើតទៅ?

- មែនហើយពុក! ធ្វើជាឪពុក មិនផ្តល់គតិយុត្តិធម៌អោយ សូម្បីតែសាច់ ឈាមរបស់ខ្លួនទៅហើយ តើពុកនឹងផ្តល់គតិយុត្តិធម៌ដល់អ្នកភូមិ ល្អត្រឹម ត្រូវបានដល់កំរិតណាដែរទៅ?

ផាំង! មេឃុំយារដៃទះកំផ្លៀងភារាណី :

- ទើបតែចូលធ្វើគ្រូបង្រៀនបឋមសិក្សាមិនទាន់បានមួយឆ្នាំផង ហ៊ាន ថ្លើមធំមើលងាយសមត្ថភាពឪពុករបស់ខ្លួនដល់ថ្នាក់នេះមែនទេហ៎?

ភារាណីដួលប្រូសទៅលើក្តារផ្ទះ។ ភ្លាមនោះ មេឃុំផែងស្រែកថា :

- អាសេត! យកខ្សែនិងរំពាត់មកអោយអញភ្លាម អញនឹងវាយក្មេងថ្លើម ធំមួយនេះ អោយព្រលឹងបិសាចវារត់ចេញពីខ្លួនវាអោយអស់។ ឥលូវនេះ ជាតិបិសាចសណ្តំបេះដូងវាហើយ វាលែងស្គាល់អស់សូម្បីតែឪពុករបស់វា!

ពូសេតឈរអេះអុញនៅខាងក្រោមផ្ទះ កាលបើឮសម្លេងមេឃុំបញ្ជា គាត់មិនហ៊ានប្រកែកទេ តែក៏មិនហ៊ានយករំពាត់ទៅអោយដែរ។ រំពេច នោះ មីងផាវប្រពន្ធគាត់ក៏ស្ទុះមកឃាត់មេឃុំ:

- ពុកវាអើយ! រំងាប់កំហឹងទៅ... កូនស្រីគេធំពេញវ័យហើយ ម្តេចនៅតែ ប្រើកម្លាំងបាយទៀត? នេះជាសម័យ២០០៦ហើយ ស្រុកទេសយើងជឿន លឿនមានអភិវឌ្ឍន៍ គេលែងយកហឹង្សាមកដោះស្រាយក្តីវិវាទហើយណា៎ ពុកវា! ការដែលធ្វើជាឪពុករបស់គេមិនមែនសុទ្ធតែគិតត្រូវ គ្រប់ពេល គ្រប់វេលាទេ។ រីឯការដែលគេជាកូនរបស់យើង ក៏គេមិនមែនសុទ្ធតែមាន កំហុសត្រូវទទួលទោសដោយការវាយដំគ្រប់វេលាដែរ។ យូរឆ្នាំមកហើយ ដែលពុកវាមិនដែលស្តាប់សំដីកូន ឬក៏ដឹងឮអំពីអារម្មណ៍នឹងទឹកចិត្តរបស់ កូនទេ។ ខ្ញុំឃើញតែពុកវាយកចិត្តរបស់ខ្លួនជាធំរហូត ហើយតែងតែយក ឈ្នះកូនចៅគ្រប់ស្ថានការណ៍ទាំងអស់ មិនថាត្រូវប្រើកំហឹង ឬការវាយដំ យ៉ាងណាទេ គឺពុកវាតែងតែយកកម្លាំងបាយជាគោល ដើម្បីយកឈ្នះគេ ជានិច្ច។ ពេលនេះ ដល់ពេលហើយដែល យើងត្រូវរៀនអភិវឌ្ឍន៍ចិត្តគំនិត ការប្រព្រឹត្ត នឹងការអប់រំកូនចៅរបស់យើង ឱ្យបានសមស្របនឹងការវិវត្តន៍ ដ៏រុងរឿងរបស់សង្គមយើងផង។

មីងផាវស្រដីមួយៗដោយអារម្មណ៍ត្រជាក់។ មេឃុំផែងស្តាប់ឮហើយ ក៏បែរមើលមីងផាវដោយទឹកមុខឆ្ងល់យ៉ាងចម្លែកព្រមទាំងគំហកថា :

- ហើយម៉ែវាឯងទៅរៀនធម៌អាបិនេះមកពីណា ចេះសូត្រមើលតែសមា ជិកអង្គការមនុស្សធម៌សង្គ្រោះពិភពលោកយ៉ាងនេះ?

- មកពីខ្ញុំទៅរៀនហ្នឹងណា៎។ ខ្ញុំបានទៅអង្គុយស្តាប់ក្រសួងអង្គការមនុស្ស ធម៌គេបង្រៀនយើងតាមភូមិ។ គេថានឹងអាចអោយប្រទេសមួយមានសន្តិ ភាពបាន លុះណាតែសង្គមគ្រួសារនិមួយៗមានសេចក្តីសុខ មិនមានហឹង្សា

នៅក្នុងចិត្តរវាងគ្នានឹងគ្នា ។ ចុះបើគ្រួសារនិមួយៗប្រកបដោយហឹង្សាគ្រប់ ទីកន្លែង តើថ្ងៃទៅទើបប្រទេសយើងបានស្ងប់សុខសាន្ត ពីកំហឹងគុំគួននិង ការប្រទុស្តរាយនឹងគ្នា.. ប្រទុស្តរាយនឹងសមាជិកក្រុមគ្រួសារ ប្រទុស្តរាយ នឹងញាតិមិត្តជិតខាង ប្រទុស្តរាយនឹងអ្នកណាទាំងអស់ដែលមានគំនិតខុស ពីយើង... បើតែយ៉ាងនេះ ច្បាស់ជាយើងច្បាំងគ្នា គ្មានសេចក្តីសុខឡើយ ។ មនុស្សយើងអាចមានការយល់ឃើញផ្សេងគ្នា ប៉ុន្តែបើឆន្ទៈនិមួយៗមាន ប្រយោជន៍ថ្កុំថ្កើងសម្រាប់គ្រួសារឬសម្រាប់សង្គម នោះយើងគប្បីបើកចំហ ដួងចិត្តអោយទូលាយរៀនត្រងយកគំនិតយោបល់អ្នកដទៃខ្លះទៅ តួយ៉ាង ដូចជាពុកវាឯងនេះ មានះអើយសែនមានះ ថ្ងៃណាក៏យល់ថា ពុកវាឯងគិត ឬធ្វើអ្វីត្រឹមត្រូវជានិច្ច សូម្បីតែវាយកូនឈាមពេញខ្លួនក៏ពុកវានៅតែត្រូវ រហូតហ្នឹង... ។ ចំពោះខ្ញុំវិញ ខ្ញុំមិនយល់ស្របតាមពុកវាទៀតទេ ក្នុងរឿង វាយកូនចៅប្រដៅគេដោយធមិក្តៅបែបនេះ ។ ពេលនេះ ពុកវាជាមេឃុំ ជាមេកោយរបស់គេ បើពុកវាមានអគតិ ចំពោះកូនចៅយ៉ាងនេះទៅហើយ តើអ្នកស្រុកគេនឹងទុកចិត្តដែរទេ ថាការវិភាគកាត់ក្តីរបស់ពុកវាឯងចំពោះ អ្នកស្រុក ពិតជាត្រឹមត្រូវ ដោយមិនមានលាយកំរោលមានះយកឈ្នះ?

ស្រាប់តែ មេឃុំផែងបោសដៃឡើង ហើយស្រែកឆ្លើយរ៉ាំងៗថា :

- អឺ! អោយវាត្រូវដងត្រូវផ្លែទាំងម៉ែទាំងកូនទៅ... ពេលនេះ យើងធ្វើជា មេឃុំធ្វើអី បើនិយាយអ្វីមិនបាន សូម្បីតែជាមួយកូនចៅរបស់ខ្លួន?

ថាហើយ មេឃុំក៏ដើរចេញទៅ ។ មីងផាវក៏ស្ទុះទៅលើកកូនស្រី :

- ត្រូវត្រង់ណាទេកូន?
- ចាស មិនអីទេម៉ែ ។ កូនអរគុណម៉ែណាស់ដែលមកជួយកូនទាន់វេលា កុំ អីច្បាស់ជាទ្រោមខ្លួនហើយ ។
- អឺ.. ហើយកូនសម្របសម្រួលតាមពុកឯងខ្លះទៅ កុំសូវមាត់កតវ៉ានឹង គាត់ច្រើនពេកអី នាំតែគាត់ខឹងមួម៉ៅនឹងកូនរិតតែខ្លាំងឡើង ។

មីងផាវដឹកដៃកូនចូលទៅក្នុងបន្ទប់របស់នាងហើយក៏ស្រដីសួរថា :

- កូនណី! ប្រាប់ម៉ែបានទេហ៎ ថាអ្នកកម្លោះ ប៉ុក ហារិន ជានរណាដែរ? រួច ហើយហេតុអីបានជា  កូននឹងគេ ប្រព្រឹត្តខ្លួនហាក់ដូចជាសត្រូវប្រចាំជាតិ
ចំពោះគ្នាយ៉ាងនេះ?

ភារាណី ឈ្ងោកមុខយកដៃកេះក្រចក នៅស្ងៀមស្ងាត់មួយស្របក់ ក៏ មានវាចាទៅកាន់ម្តាយរបស់ខ្លួនថា :

- ម៉ែ! បើកូននិយាយជំរាបម៉ែនូវរឿងរ៉ាវជីវិតខ្លះៗ តើម៉ែនឹងជឿសំដី របស់កូនទេ?
- បើម៉ែមិនជឿកូនរបស់ម៉ែ តើអោយម៉ែជឿនរណាទៅវិញ? គឺម៉ែចង់ដឹង គ្រប់រឿងទាំងឡាយដែលទាក់ទងទៅនឹងជីវិតរបស់កូន ដើម្បីអោយម៉ែ អាចរកមធ្យោបាយជួយកូនផងណា ។ ម៉ែដឹង ថាកូនមានវិបត្តិក្នុងជីវិត រួច ហើយមិនព្រមស្រដីប្រាប់ពុកនិងម៉ែអោយដឹង ។ នេះប្រហែលមកពីពុកឯង កាចពេកហើយ បានជាកូនខ្លាចមិនហ៊ានពិគ្រោះ រហូតដល់កូនត្រូវបៀម វិបត្តិតែម្នាក់ឯងបែបនេះ.

ឮប្រយោគនេះកាលណា ភារាណីស្រក់ទឹកភ្នែកច្រោក យកដៃស្រវា អោបម្តាយយ៉ាងណែន :

- ម៉ែ...!

កល្យាណីយំខ្សឹកខ្សួលនៅក្នុងរង្វង់ដៃរបស់ម្តាយនាង ដែលអង្អុយលួង លោមបបោសអង្អែលអោយដួងចិត្តនាងបានធូរស្បើយ បន្ទាប់មកក៏ស្តីរៀប រាប់ប្រាប់ដំណើរដើមទងទាំងឡាយដែលទាក់ទងពីជីវិតរបស់នាងនិងនាយ ហារិនជូនម្តាយនាងស្តាប់... តែពីរនាក់ស្ងាត់ៗនៅក្នុងបន្ទប់...

រសៀលថ្ងៃដដែល...

ភារាណីបរម៉ូតូតែម្នាក់ឯងទៅដល់ការិយាល័យរបស់លោកប៉ុកហាវ៉ាន់ ដែលមានអ្នកយាមស្នេកស្កះ ។ ធិតាបានស្រដីទៅកាន់អង្គរក្សមួយរូបថា :

- នាងខ្ញុំឈ្មោះភារាណី សូមមកជួបលោកហាវ៉ាន់ដែលជាឪពុករបស់លោក ហារិន ។

- លោកហាវ៉ាន់ មានការជាប់រវល់មិនអាចជួបអ្នកនាងបានទេ ។

- តែនេះជារឿងសំខាន់ ហើយក៏ជារឿងដែលលោកបានណាត់អោយខ្ញុំមក ជួបលោកដែរ ។ ជំរាបលោកផង ថាយើងបានមកតាមការណាត់ហើយ តែ លោកហាវ៉ាន់មិនគោរពតាមសន្យា ។ ដូច្នេះ បើមានរឿងត្រូវដោះស្រាយ គឺលោកហាវ៉ាន់ត្រូវទៅតាមរកខ្ញុំដោយខ្លួនឯង ។

- ហើយចុះអាស័យដ្ឋានរបស់អ្នកនាងនោះ?

- លោកហាវ៉ាន់ស្គាល់ស្រាប់ហើយ ហើយនឹងរង់ចាំការណាត់របស់លោក ជានិច្ច ។

ថាហើយ ធរីយើងក៏បង្វិលខ្លួនដើរត្រលប់ទៅម៉ូតូរបស់នាងវិញ ស្រាប់ តែ មានសម្តីមួយស្រែកឃាត់ :

- មិនចាំបាច់ថ្ងៃក្រោយទេ យើងមកដល់ហើយ!

ធិតាបែរក្រោយ ក៏ប្រទះនឹងបុរសចំណាស់មួយរូបក្នុងឯកសណ្ឋានជា មន្ត្រីយោធា ។ នាងក៏លាន់មាត់ឡើងថា :

- លោកហាវ៉ាន់?

- មែនហើយ! គឺយើង!

ធិតាក៏ដើរត្រលប់ឡើងកាំជណ្តើរ មកដល់ជិតលោកហាវ៉ាន់ភ្លាម រួចក៏ ស្រដីថា :

- ព្រឹកមិញលោកទៅផ្ទះខ្ញុំហើយសម្លុតគម្រាមឪពុករបស់ខ្ញុំទៀត...

- មែន ហើយនោះវាយ៉ាងម៉េច?

- តែលោកមានគិតទេថា លោកកំពុងតែលាតត្រដាងប្រវត្តិយ៉ាងអសោច នៅក្នុងគ្រួសាររបស់លោក?

- តែផ្តាស! ក្រុមគ្រួសារយើងរស់នៅថ្លៃថ្នូរមានកត្តិយសណាស់ មិនមែន មនុស្សអង្គាច់អង្គោចនោះទេ ។ ហេតុអ្វីនាងបែរជាប្រមាថកេរ្តិ៍ឈ្មោះ របស់កូនប្រុសយើង អោយអ្នកកាសែតវាយកទៅហែកយ៉ាងនេះ? ដឹងទេ ថាវាបានធ្វើអោយប៉ះពាល់ដល់មុខមាត់កត្តិយសរបស់យើងជាឪពុក ប៉ុន ណាដែរ?

ភារាណីពូជដូច្នោះក៏ញញឹមឡើងយ៉ាងជូរចត់ :

- លោកបន្ទោសអ្នកក្រៅ ដើម្បីបិទបាំងអំពើដ៏អាមាសរបស់កូនប្រុស លោក មែនទេ? លោកមានដឹងទេថា អ្នកដែលបង្កហេតុទាំងឡាយឱ្យអ្នក កាសែតគេយកទៅហែកកេ្តីនោះ គឺជាកូនប្រុសរបស់លោកផ្ទាល់? បើកូនប្រុសរបស់លោកមិនបានប្រព្រឹត្ត ហេតុអ្វីក៏គេបិទមាត់អោយ ស្ងាត់ឈឹង មិនហ៊ានចេញមកតវ៉ាចំពោះការប្រកាន់នេះ?

- គេជាកូនប្រុសដែលមានការអប់រំល្អ មិនយកកំហែងទល់កំហល់ មិន ឈ្លោះ មិនបំពានមនុស្សស្រី មិនយកត្តិយសទៅចោលនៅកណ្តាលហ្វូង មនុស្សដូចជារូបនាង...

- លោកជឿជាក់ចំពោះកូនប្រុសរបស់លោកដល់ម្លឹង?

- មែនហើយ! គេជាកូនប្រុសទោលដែលយើងបានអប់រំដោយផ្ទាល់ដៃ ហេតុអីដែលយើងមិនស្គាល់កូនរបស់ខ្លួននោះ?

- ប៉ុន្តែ លោកមិនបាននៅជាប់ជើងជាមួយគេគ្រប់២៤ម៉ោងឯណា? ហើយ លោកមានប្រសាសន៍ថា លោកជឿសំដីគេគ្រប់ម៉ាត់ តែលោកមានបាន ប្រាប់ខ្ញុំឯណាថា លោកជឿលើការប្រព្រឹត្តរបស់គេគ្រប់យ៉ាងនោះទេ?

- សម្តីឡូយណាស់តើហ៏ នាងច្រមក់!

- សូមទោស! ខ្ញុំនិយាយតែការពិតប៉ុណ្ណោះ ។ ពេលនេះ បើលោកជឿជាក់ ចំពោះកូនប្រុសដល់ម្លឹង តើលោកអនុញ្ញាត្តអោយខ្ញុំធ្វើការពិសោធន៍ជា សាធារណ៍បានទេ ថាគេមិនបានប្រព្រឹត្តអនាចារ្យឬអ្វីដែលនាំអាមាសដល់ កិត្តិយសគ្រួសារឬសូម្បីតែកិត្តិយសរបស់លោកជាឪពុក?

- បាន! យើងក៏មិនខ្លាចនឹងស្វែងរកការពិតដែរ.. បើសិនជាគេខុសពិតមែន យើងជាឪពុករបស់វានឹងប្រដៅវាដោយផ្ទាល់ដៃ ។

- លោកហ៊ានមានប្រសាសន៍បែបនេះចំពោះមុខអ្នកកាសែតអោយគេធ្វើ ជាសាក្សីទេ ដើម្បីអោយខ្ញុំដែលជាភាគទន់ខ្សោយ មានការជឿជាក់ថា លោកពិតជាផ្តល់យុត្តិធម៌ចំពោះយើង និងចំពោះកូនប្រុសរបស់លោកឱ្យ អោយសក្តិសមនឹងកៅអីកិត្តិយសរបស់លោកដែលកំពុងអង្គុយសព្វថ្ងៃ?

- ខ្លាចអ្វីនឹងធ្វើ.. បើយើងជាមនុស្សល្អស្រាប់ទៅហើយ...

- មែនហើយលោកពិតជាមនុស្សល្អ... តែមិនមែនបានន័យថា កូនប្រុស របស់លោកល្អដូចគ្នាទេ ។ នោះហ្ន៎! ខ្ញុំបានហៅអ្នកកាសែតប្អូនដប់នាក់មក ហើយ ។ គេនៅចាំងក្រៅរបងឯណោះ រង់ចាំតែការអនុញ្ញាត្តិពីលោក ប៉ុណ្ណោះ នោះគេនឹងមកទទួលពត៌មានពីលោកផ្ទាល់ហើយ ។

លោកហាវ៉ាន់បើកភ្នែកធំៗ :

- នាងហៅអ្នកកាសែតមក៏?...

- ចាស! គឺគេជាកសិណសាក្សីសំរាប់ភាគទន់ខ្សោយដូចខ្ញុំ ។ ពេលនេះ តើ លាកត្រៀមខ្លួនហើយឬនៅ?

លោកហារ៉ាន់មិនទាន់មានប្រសាសន៍ឆ្លើយថាយ៉ាងណាផង ស្រាប់តែ មានសម្តីស្រែកឃាត់លោកថា :

- លោកប៉ា! កុំសន្យាអ្វីជាមួយស្រីម្នាក់ហ្នឹង ប្រយត្ន័ចាញ់បោកគេ...

ភារាណីនិងលោកហារ៉ាន់បែរភ្នែកមើលទៅម្ចាស់សម្តី ស្រាប់តែប្រទះ
នឹងកម្លោះសង្ហាឈ្មោះហារិនដើរចូលមកក្នុងបួកពាយ៉ាងខែងរ៉ែង។ ភ្លាម នោះ ហារិនពោលបន្តថា :

- មនុស្សស្រីខ្លះក្រឡិចក្រឡុច ជាអ្នកក្រ ខ្វះមុខខ្វះក្រោយ តែងតែប្រឹង ស្វែងរកមធ្យោបាយ ដើម្បីទាមទារជម្រិតលុយថ្លៃជម្ងឺចិត្ត រកស៊ីផ្លូវកាត់ លោកប៉ាត្រូវប្រយត្ន័អោយមែនទែន...

ថាហើយ មាណពសង្ហាលួចដៀងកន្ទុយភ្នែកបញ្ឈឺដល់នារីយើងផង។ ភារាណីឃើញមុខបុរសនោះភ្លាម
ក៏នឹកក្តៅក្នុងចិត្តឆ្លើយរឹងថា :

- មនុស្សដែលមិនហ៊ានប្រឈមមុខនឹងការពិត គឺជាមនុស្សដែលកំពុងមាន ខ្ទងដំបៅ។ ពេលនេះ ដល់ពេលហើយដែលដំបៅនោះ ត្រូវពេទ្យវះកាត់ ព្យាបាលដើម្បីកុំអោយរាលដាលឆ្លងជម្ងឺដល់អ្នកដទៃទៀត។

ធិតាយើងក៏បក់ដៃហៅអ្នកកាសែតប្អូនដប់នាក់ ដែលនៅឈរខាង ក្រៅរបង អោយដើរចូលមកខាងក្នុង។
ឃើញភាពម៉ឺងម៉ាត់របស់ធិតា
លោកហារ៉ាន់លែងមាត់តែម្តង។ ភ្លាមនោះ ហារិនស្រែកឡើងថា :

- លោកប៉ា! ម៉េចបណ្តោយអោយពួកគេចូលមកទីនេះធ្វើអី? នេះជា ការិយាល័យរបស់លោកប៉ា
លោកប៉ាមានសិទ្ធិដេញពួកគេចេញទៅវិញណា៎

- ស្ងួច! ហារិន! នៅអោយស្ងៀម! ទុកអោយប៉ាចាត់ការ។ ទីនេះគឺជា
ការិយាល័យរបស់ប៉ា ! កូនក៏គ្មានសិទ្ធិមកបញ្ជាបួរអ្វីរទាំអ្វីដាក់ប៉ាដែរ។

ឮដូច្នោះ ហារិនបិទមាត់ឈឹងភ្លាមមួយរំពេច។ អ្នកគ្រូភារាណីយើង បានទីភ្លាម ក៏បែរទៅអ្នកកាសែតហើយប្រកាសថា :

- អស់លោកជាអ្នកយកពត៌មានទាំងឡាយ! ថ្ងៃនេះ នាងខ្ញុំភារាណីសូម ទទួលយកអស់លោកជាកសិណសាក្សី
នូវរឿងអាស្រូវមួយពីអតិតកាល របស់កម្លោះសង្ហានាមប៉ុកហារិន ជាកូនប្រុសទោលរបស់លោកប៉ុកហារ៉ាន់
ដែលជាមន្ត្រីយោធាជាន់ខ្ពស់នៅក្រុងបាត់ដំបងយើងនេះ មានន័យថាលោក ប៉ុកហារិន
ធ្លាប់បានប្រព្រឹត្តអំពើយ៉ាងអាមាសមួយទៅលើនារី ដោយ ការចាប់បង្ខំរួមភេទ។ មិនត្រឹមតែធ្វើបាបនារីនោះទេ
គេថែមទាំងវាយដំ ធ្វើបាបអ្នកដែលបានជួយសង្គ្រោះនារីនោះទៀតផង។ តើគេជាមនុស្សត ទៀតទេ
កាលបើគេធ្វើបាបនារីភេទដែលមិនទាន់គ្រប់វ័យផង? ពេលនេះ នាងខ្ញុំមានសំណួមពរពីរយ៉ាងដល់លោកហារិន
ដើម្បីបញ្ជាក់ការពិតជូន បពិភពលោកថា តើលោកបានប្រព្រឹត្តយង់ឃ្នង ដូចការចោទប្រកាន់នេះ ដែរឬក៏អត់ទេ។

- និយាយតែផ្តាស។ យើងមិនដែលបានប្រព្រឹត្តអ្វីដូចសម្តីរបស់នាងពេល នេះទេ យើងមិនបានប្រព្រឹត្ត
កុំយកភក់ជ្រាំមកបាចលើខ្លួនយើងឱ្យសោះ!

ថាហើយ នាយហារិនក៏ងើបឈរបំរុងនឹងដើរចេញ ស្រាប់តែឪពុក

របស់នាយមានប្រសាសន៍ថា :

- អង្គុយចុះវិញហារិន! ប៉ាមិនទាន់បានអនុញ្ញាតិអោយឯងក្រោកដើរចេញ ពីទីនេះនៅឡើយទេ។

ហារិនកកដៃកកជើងតែម្តង កាលបើឮលោកហារ៉ាន់មានប្រសាសន៍ ដូច្នោះ។ ភ្លាមនោះ ភារាណីស្រដីបន្តថា :

- សំណូមពរទីមួយសម្រាប់អោយលោកហារិនធ្វើតាមដើម្បីបញ្ជាក់ពីភាព ស្មោះត្រង់នៅក្នុងចិត្តរបស់លោក គឺលោកត្រូវផឹកទឹកសម្បថថា បើលោក ពិតជាបានប្រព្រឹត្តផ្តាំឆ្លងមែន សូមអោយលោកស្លាប់នឹងឡានកិន រន្ទះ បាញ់ នឹងគ្រាប់កាំភ្លើង ឬក៏ត្រូវពិការប្រដាប់ប្រដាអស់មួយជីវិតដោយគ្មាន ថ្ងៃព្យាបាលជាសះស្បើយវិញ ហើយសូមអោយជីវិតរបស់គេប្រទះតែនឹង ការព្រាត់ប្រាសក្តៅក្រហាយ...

- ឈប់សិន.. និយាយអីក៏អពមង្គលម្ល៉េះ? យើងមិនធ្វើតាមទេ ។

ហារិនប្រកែកញ៉ាញ់។ ស្រាប់តែលោកហារ៉ាន់យកដៃកាន់ស្មារបស់ នាយជាសញ្ញាថានៅអោយស្ងៀម។ ធិតាយើងឃើញដូច្នោះក៏បន្តទៀតថា:

- នោះគឺជាដំណោះស្រាយផ្នែកជំនឿ។ ចំណែកសំណូមពរទីពីរវិញជាការ ដោះស្រាយបែបវិទ្យាសាស្ត្រ ដែលគ្មាននរណាម្នាក់អាចប្រកែកចំពោះ លទ្ធផលរបស់វាបាន។ ប៉ុន្តែមុននឹងដល់ចំណុចនោះ នាងខ្ញុំសូមសួរបញ្ជាក់ នាយហារិនសាជាថ្មី ថាតើខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់នោះដែរឬក៏ យ៉ាងណា? លោកនៅមានឱកាសឆ្លើយមួយសាទៀតនៅមុនពេលលទ្ធផល ពិសោធន៍វិទ្យាសាស្ត្រវាតាមជាន់កែង។

- នែ៎ នាងកុំអាងតែមានមាត់ហើយមានអ្នកកាសែតមកគាំទ្រ នោះនាង គិតថាអាចបង្ខំអោយយើងឆ្លើយសារភាពនូវអ្វីដែលយើងមិនបានធ្វើនោះ? កុំសង្ឃឹមអោយសោះ។

ហារិនប្រកែកញ៉ាញ់។ ពេលនោះ ភារាណីក៏និយាយបន្តទៅទៀតថា :

- ការពិសោធន៍ភាពស្មោះត្រង់បែបទីពីរនោះ គឺជាការធ្វើវិភាគឈាម កំណើតរបស់បុរសនេះជាមួយទារកដែលជាសាច់ឈាមរបស់គេ។ បើសិន លទ្ធផលបញ្ជាក់ថាវិជ្ជមាន គេត្រូវលុតជង្គង់សារភាពកំហុសនៅចំពោះមុខ ក្មេងមួយរូបនោះនិងម្តាយរបស់គេ ដោយមានអ្នកកាសែតមកជួយកត់ ព្រឹត្តការណ៍នោះជាសំណៅ ដើម្បីបង្ហាញនូវភាពមិនទទួលខុសត្រូវរបស់ បុរសត្រកូលថ្លៃថ្នូរខ្ពង់ខ្ពស់ម្នាក់ដែលជាឪពុក បានប្រកែកមិនព្រមទទួល ស្គាល់ថាខ្លួនមានការប្រព្រឹត្តផ្តេសផ្តាសដូច្នោះមែន។

រំពេចនោះ អ្នកកាសែតម្នាក់លើកដៃសួរថា :

- ឥលូវយើងអាចយកលោកហារិនទៅដោះឈាមធ្វើវិភាគ **DNA** បានមែន ក៏ប៉ុន្តែក្មេងដែលជាកូនរបស់លោកហារិននៅឯណាដែរ? តើធ្វើម៉េចនឹង អាចអោយយើងទៅរកដើម្បីដោះឈាមធ្វើវិភាគបានទៅ?

- គេនៅកន្លែងដែលមានសុវត្ថិភាពបំផុត ព្រោះថាបើនរណាម្នាក់ក្នុងភាគី ខាងលោកហារិនដឹង... ខ្ញុំបារម្ភក្រែងគេតាមយាយីក្មេងនោះ មិនអោយ យើងអនុវត្តន៍ការពិសោធន៍ចប់ចុងចប់ដើមបាន។ ដូច្នេះ ខ្ញុំសូមឱ្យលោក ប៉ុក

ហារ៉ាន់ ចេញដីការមួយ ធានាសុវត្ថិភាពរបស់ក្មេង ដែលជាសាច់ ឈាមរបស់លោកហារិននោះ ហើយការពារសុវត្ថិភាពរបស់នាងខ្ញុំដែល ជាសាក្សីសំខាន់នៅក្នុងរឿងនេះសិន ដោយយកកត្តិយសរបស់លោកមក ដាក់ចំពោះមុខអ្នកកាសែតពេលនេះ មិនដឹងថាតើលោកហារ៉ាន់អាចធ្វើ បានដែរទេ ដើម្បីជំរះនូវមន្ទិលដែលនៅជាប់នឹងខ្លួនកូនប្រុសរបស់លោក?

លោកហារ៉ាន់ភ្ញាក់ព្រើត ដែលកល្យាណីរបស់យើងចាប់លោកមកធ្វើ តួអង្គមួយជាមួយកូនប្រុសរបស់លោកដែរ ។ ដើម្បីកុំអោយអាមាសមុខ ពេក ព្រោះរឿងរ៉ាវវាកាន់តែរាលដាលវែងឆ្ងាយទៅហើយ លោកហារ៉ាន់ ក៏ មានប្រសាសន៍ឡើងថា :

- ល្អើយចុះ! ដើម្បីយុត្តិធម៌សម្រាប់ភាគីទាំងសងខាង ខ្ញុំសូមយក កិត្តិយសរបស់ខ្ញុំធានាសុវត្ថិភាពរបស់ស្ត្រីមួយរូបនេះ ព្រមទាំងក្មេងម្នាក់ នោះទៀត ដែលពេលនេះ ខ្ញុំក៏មិនដឹងដែរថាគេនៅឯណាដែរ ។ ប៉ុន្តែ យើងជឿទុកចិត្តនូវសមត្ថភាពអ្នកកាសែតទាំងអស់ថា នឹងជួយផ្តល់ យុត្តិធម៌ដល់រូបខ្ញុំនិងកូនប្រុសដូចគ្នាដែរ មិនមែនកាន់ជើងតែអ្នកដែលហៅ លោកមកស៊ើបការណ៍ថ្ងៃនេះនោះទេ ។

ភារាណីញូហើយ ក៏ញញឹមឡើងហាក់ពេញចិត្តនឹងប្រតិកម្មរបស់លោក ហារ៉ាន់ បន្ទាប់មកក៏បក់ដៃហៅស្ត្រីមួយរូបអាយុ ប្រហែលសាមប្លាយចេញ មកពីក្នុងហ្វូងអ្នកកាសែត រួចហើយស្រដីថា :

- នេះជាអ្នកគ្រូពេទ្យមួយរូប ដែលក្រសួងកាសែតបានចាត់មក ។ នាងខ្ញុំ មិនស្គាល់អ្នកគ្រូពេទ្យទេ គ្រាន់តែដឹងថាអ្នកគ្រូធ្លាប់មានស្នាដៃដោះឈាម ឪពុកម្តាយកូន ដែលត្រូវធ្វើសម្ភាសន៍ទៅរស់នៅអាមេរិក ជាពិសេសក្រុម គ្រួសារដែលបែកគ្នាយូរឆ្នាំ មិនចាំមុខគ្នា ។ គេប្រើវិធីនេះដើម្បីបញ្ជាក់ រកសាច់ឈាមពិតប្រាកដរបស់គេថា គេធានាមិនច្រលំមនុស្ស ឬមិនប៉ះ មនុស្សបន្លំខ្លួន! ដូច្នេះ នៅវេលានេះ អ្នកគ្រូពេទ្យនឹងបូមយកឈាមនាយ ហារិន ហើយនៅពេលផ្សេងមួយទៀត អ្នកគ្រូនឹងទៅជាមួយអ្នកកាសែត ដើម្បីទៅដោះឈាមក្មេងមួយរូបនោះយកទៅវិភាគ...

- ហ្អើយ! មាត់ច្រើនគួរអោយធុញមែន! យើងមិនអោយមកដោះឈាម យើងទេ ។ ម្ជុលរបស់ឯងមិនស្អាតនាំតែឆ្លងរោគអេដស៍ដល់យើងទទេៗ ។

បុរសសង្ហាហារិនស្រែកដំអូញ តែភារាណីឆ្លើយកាត់ផ្ទួង :

- បើឆ្លងអេដស៍ គឺឆ្លងមកពីការប្រព្រឹត្តរបស់អ្នក ដែលនៅឯទីអាថិកំបាំង មិនមែនឆ្លងមកពីពេទ្យទេ ។ ហើយបើអ្នកប្រកែកមិនព្រមផ្តល់ឈាមធ្វើ វិភាគ បានន័យថាអ្នកកំពុងលាក់ចំណុចខ្សោយរបស់អ្នកហើយ ។

អ្នកគ្រូពេទ្យក៏ចាប់ខ្លួននាយហារិន ចាក់ម្ជុលបូមយកឈាមភ្លាម ។ ពេលនោះ បុរសសង្ហាខំបែរមើលឪពុក ក្រែងលោលោកជួយអីបាន ប៉ុន្តែ ទាំងពីរនាក់ឪពុកកូនត្រូវអ្នកគ្រូភារាណីចងក្រឡាអស់រលីង រកហាក់លោត ទៅណាក៏លែងរួចហើយក្រៅតែពីមើលមុខគ្នានៅស្ងៀមតែប៉ុណ្ណោះ សូម្បី តែអង្គរក្សដែលនៅឈរក្បែរនោះ ក៏ទឹកឆ្ងល់ដែរដែលលោកហារ៉ាន់ត្រូវ មកស្លាក់ឆ្អឹងទទឹងក ដោយសារកូនប្រុសសំណព្វចិត្ត រហូតដល់ចាញ់ប្រាប ស្រីក្មេងមួយរូបដោយនិយាយមិនរួច ។

00000000000000000

# វគ្គទី៦
# អគ្គីភ័យ

នៅរាត្រីថ្ងៃដដែល...

តុក! តុក! តុក!

- ណីកូន! គេងហើយនៅ?

- នៅទេម៉ែ...!

ភារាណីក៏ងើបទៅបើកទ្វារអោយម្តាយ ស្រាប់តែប្រទះឃើញមីងផាវ កាន់របស់មួយកញ្ចប់ដើរចូលមកដល់ :

- ឥវ៉ាន់ស្អីហ្នឹងចាស?

- គឺលោកកោមលគេមកលេងកូនកាលពីថ្ងៃរសៀលមិញ ថៃដន្យមិនបាន ជួបគ្នា ទើបគេទុកវត្ថុអនុស្សាវរីយ៍បុណ្យចូលឆ្នាំនេះជាមួយនឹងម៉ែ ដើម្បី ទុកអោយកូនណា៎។

ធិតាបើកប្រអប់មក ក៏ប្រទះឃើញកាម៉ារ៉ាឌីជីអូតូចទំនើបមួយដែល ប្រើស៊ីឌីសំរាប់ថតរូបនិងសម្លេងជំនួសខ្សែអាត់។ អ្នកគ្រូក្មេងក៏លាន់មាត់ ឡើងថា :

- ស្លាប់ហើយ! ធ្វើគ្រូមិនសូវ សំបូណ៌ប្រាក់ខែប៉ុន្មានទេ... ហេតុអីគេទិញ របស់ថ្លៃៗបែបនេះមកអោយកូន? នេះជាការចងទឹកចិត្តកូនអោយជាប់ ក្រឡារបស់គេទេដឹង?.... ម៉ែទុកអោយគេវិញទៅ កូនមិនយកទេ។

- ជាទឹកចិត្តរបស់គេទៅហើយ នឹងយកទៅអោយគេវិញយ៉ាងណាទៅ តិច គេមានអារម្មណ៍ថាយើងស្អប់គេទៅ?

- ទោះជាយ៉ាងណា កូនមិនមានអារម្មណ៍ល្អនឹងទទួលកាដូថ្លៃៗយ៉ាងដូច្នេះ ទេម៉ែ។ កូនខ្លាចជំពាក់ទឹកចិត្តណាស់!

- អឺ! បើដូច្នេះ ចាំកូនយកទៅសងគេហើយប្រាប់គេតាមត្រង់ទៅ កុំអោយ គេនឹកគិតសង្ឃឹមចោលលើរូបកូនដោយឥតន័យឥតខ្លឹមសារណា៎!

មានប្រសាសន៍ចប់ មីងផាវក៏ដើរចេញពីបន្ទប់ធិតាយើងទៅ។ ភ្លាម នោះ ភារាណីហាក់មានចិត្តពិភាល់ចង់ដឹងអំពីកាម៉ារ៉ាថ្មីនោះ ក៏លើកយក មកថតលេងពីនេះពីនោះ។ លុះថតក្នុងបន្ទប់មិនអស់ចិត្ត

ស្រាប់តែនឹកភ្ញក់ ចង់ថតរូបខាងក្រៅផ្ទះ ចង់ដឹងថា ពេលយប់ងងិតយ៉ាងនោះ តើកាមេរ៉ាតូច នោះអាចថតរូបជាប់ឬក៏មិនជាប់ ។ នាងក៏បើកបង្អួចឡើង ដាក់កាមេរ៉ា ភ្ញើយថតរូបព្រះច័ន្ទ រួចហើយក៏ដាក់ទៅក្រោមដើមស្វាយមុខផ្ទះឃើញពូសេតកំពុងចងមុងសំរាន្តលេងខាងក្រៅអោយរហើយ ត្បិតខែនេះជាខែ ចេត្រ មេឃមិនសូវជាផ្អមចិត្តមនុស្សលោកប៉ុន្មានទេ ។ លុះនាងដាក់បំបែរ កាមេរ៉ាទៅតាមបង្អួចមួយទៀតក្នុងបន្ទប់របស់នាង ស្រាប់តែប្រទះឃើញ មនុស្សបួននាក់កំពុងដើរអោនងើប១ សសៀរទៅមកតាមជញ្ជាំងផ្ទះរបស់ នាង ទំនងកំពុងចាក់បង្ហៀរទឹក ។ នាងក៏យិតកាមេរ៉ាពង្រីករូបអោយធំដើម្បីអោយឃើញភិនភាគមនុស្សនោះច្បាស់ ស្រាប់តែនាងឃើញគេកេះ ដែកកេះបញ្ឆេះឡើង ។

ភារាណីក៏លាន់មាត់ស្រែកយ៉ាងគ្រលួចឡើងថា :

- ម៉ែ! ពុក!... មានចោរចូលមកលួចដុតផ្ទះរបស់យើងហើយ... ពូសេត...

ធិតារត់ចេញមកក្រៅ ទៅដាស់មេឃុំផែងនិងម្តាយរបស់នាងយ៉ាង រហ័ស ។ អណ្តាតភ្លើងក៏ឆាបភិលឡើងយ៉ាងរហ័សជុំវិញផ្ទះឈើដ៏ប្រណិត នោះដោយឥតប្រណី ។ ភារាណីឆ្លេឆ្លាលើកកាមេរ៉ាព្យួរពាក់នៅកហើយស្ទុះអូសទាញម្តាយចេញពីរង្វង់ផ្សែងភ្លើងដ៏ខ្មៅងងិត ។

នៅឯនាយទួលដីភូមិរបស់នាយកវី...

សាវេតរត់រឹងទៅប្រាប់ឪពុកយ៉ាងរហន់ថា :

- ពុក! ខ្ញុំថាផ្ទះតាមេឃុំត្រូវភ្លើងឆេះហើយ! ពុកមើលហ្ន៎ អណ្តាតភ្លើងពណ៌ក្រហមមានកំពស់ខ្ពស់ជាងដើមស្វាយដើមដូងទៅទៀត ។

កវីកំពុងតែរៀបចំម៉ូតូ ទុកដាក់ឥវ៉ាន់សំរាប់ចេញទៅរកស៊ីនៅពេល ព្រឹក កាលបើឮកូនប្រុសស្រែកប្រាប់ដូច្នោះក៏រត់រឹងទៅមើល ស្រាប់តែ ប្រទះឃើញដូចកុមារសាវេតថាមែន ។ គេក៏បែរមកផ្តាំកូនទាំងពីរថា :

- កូនប្រុសកូនស្រី! កុំទៅណាំចោលផ្ទះឮហើយនៅ? ពុកទៅជួយពន្លត់ ភ្លើងសិន បន្តិចទៀតពុកមកវិញហើយ ។

ថាហើយនាយយើងក៏បើកម៉ូតូកញ្ចាស់របស់នាយកាត់វាលស្រែសំដៅទៅផ្ទះមេឃុំផែងយ៉ាងលឿនស្លេវ ។ ទៅដល់ទីនោះ នាយយើងបានឃើញ ពូសេតនិងអ្នកជិតខាងពីរបីនាក់កំពុងរត់ឆ្លេឆ្លាអូសបំពង់ទឹកពីចំការក្រូច មកបាញ់ពន្លត់ភ្លើង ។ ពេលនោះ មាណពឃើញភារាណីកំពុងអូសម្តាយនាងចេញមកទាំងដង្ហក់គឃូស តែបាត់មិនឃើញមេឃុំផែងទេ ។ គ្រាន់តែប្រទះ ឃើញភក្រ្តបុរសយើងកាលណាភារាណីក៏ស្រែករឹងឡើង :

- បងកវីទៅទទួលពុកផង គាត់កំពុងពុលផ្សែង ដួល..ដើរមិនរួចទេ ។

កវីទាញបាវមួយជ្រលក់ក្នុងពាងទឹកយកមកទទូរ ហើយរត់សំដៅទៅ ក្នុងអណ្តាតភ្លើងយ៉ាងលឿន ។ កាលបើមកដល់កណ្តាលផ្ទះដែលអណ្តាត ភ្លើងកំពុងប្រឹងលេបដោយឃោរឃៅ កវីឃើញមេឃុំដួលស្តូកស្តឹងដើរ លែងរួចទៅហើយ ។ គេក៏ចាប់មេឃុំលីដាក់លើស្មាហើយក៏រត់ថយក្រោយយ៉ាងរហ័សផុតពីឥទ្ធិពលដ៏យង់ឃ្នងរបស់អណ្តាតភ្លើងក្រហម ។ បន្ទាប់មក

គេក៏ផ្ដេកគាត់ទៅលើបាវទទឹកមួយដែលភារាណីលាតចាំទទួល ។ មេឃុំ របស់យើងហាក់ដូចជានៅមានស្មារតីនៅឡើយ ហើយក៏ធ្វើមាត់ម្ញូប១ ហាក់ដូចជាកំពុងនិយាយអ្វី ប៉ុន្តែគ្មាននរណាស្ដាប់បានទេ ថាគាត់ចង់ស្ដីថា ម៉េច ។ មិនយូរប៉ុន្មាន តួផ្ទះដ៏ធំជង្រ្គឹងស្អាតវិចិត្រមួយក៏ត្រូវអគ្គីភ័យលេប យកបាត់រូបអស់សល់តែផេះហុយ១តែប៉ុណ្ណោះ...

មេឃុំបានដឹងខ្លួនហើយ ហើយក៏មានរបួសរលាកជាច្រើនកន្លែងស្ទើរ សុសខ្លួន ។ កវីទារឧបជូនគាត់ទៅមន្ទីរពេទ្យ តែគាត់ប្រកែក.. មិនព្រម ទទួលសគុណអ្វីពីនាយឡើយ ។ អ្នកស្រុកបានយកថ្នាំ យកស្បៃ មកអោយ ភារាណីលាងរបួសរុំអោយមេឃុំផៃ ហើយយកខោអាវមកឱ្យអ្នកទាំងបី ផ្លាស់ ត្បិតសម្លៀកដែលនៅជាប់នឹងខ្លួននោះត្រូវភ្លើងឆេះដាច ស្ទើរបិទខ្លួន មិនជិតទៅហើយ ។ រំពេចនោះ កុមារសាវេតនិងកុមារីសោភា ក៏នាំគ្នា ដើរមកដល់ទីនោះដែរ ។ កវីឃើញហើយក៏លាន់មាត់ឡើង :

- ពុកអោយកូននៅចាំផ្ទះ ម៉េចក៏នាំគ្នាដើរមកដល់ទីនេះអញ្ចឹង?
- គឺកូនយកបានបុកស្លឹកកន្ទុយក្រពើយកមកធ្វើ ដើម្បីជួយបិតរបួសដោយ សារការរលាកភ្លើង កុំអោយឈឺចាប់ (សាវេតឆ្លើយ)
- ពុទ្ធោ កូនមាសឪពុក!...

កវីឧទានឡើង ។ បន្តិចមកនាយយើងក៏ហុចធុងដែលដាក់ថ្នាំបុកនោះ ទៅអោយភារាណី :

- អ្នកគ្រួយកថ្នាំនេះលាបជូនពុកមេឃុំទៅ!

ធិតាសម្លឹងមុខកវីហើយក៏បែរទៅសាវេតរួចឆ្លើយថា :

- អរគុណណាស់សាវេត! ឯងពិតជាក្មេងដែលមានទឹកចិត្តគួរអោយកោត សរសើរមែន ។

ថាហើយនាងក៏យកថ្នាំទៅលាបអោយម្ដាយនាង រួចហើយមេឃុំជា ឪពុកទៀត ស្រាប់តែគាត់គេចផ្ទូងមិនព្រមទទួលយក ។ មាណវីយើង ឃើញដូច្នោះក៏ស្រដីឡើង :

- ពុក! នេះ ក្មេងគេមានទឹកចិត្តបុកថ្នាំយកមកអោយពុកណា៎ ហេតុអ្វីក៏ធ្វើ អោយគេអសទ្ធាទៅវិញ? បើមិនបារម្ភពីសុខទុក្ខរបស់ពុក គេក៏មិនបុកថ្នាំ ដើរយកមកធ្វើពុកទាំងយប់អាធ្រាតដូច្នេះទេ ។ មើល៍ កុំមានអាស្មិមានះ សូម្បីតែជាមួយក្មេងដែលមិនទាន់ដឹងក្ដីនោះអី ណា៎ពុកណា៎!

លុះឮសំដីកូនស្រីនិយាយដូច្នោះ មេឃុំផែងនៅស្ងៀម បណ្ដោយឱ្យ នាងយកថ្នាំបុកលាបអោយតាមសម្រួល ។ សំណាងដែរដែលគាត់មិន ប្រកែកវិញ កុំអីប្រហែលជាមេឃុំផែងត្រូវដេកថ្ងូរ មួយយប់ទើសភ្លឺហើយ ត្បិតថ្នាំបុកនោះបានជួយធ្វើអោយស្នាមរបួសដោយការរលាកភ្លើងនេះថម ថយឥទ្ធិពលយ៉ាងច្រើនបំផុត ។

អ្នកស្រុកក៏ត្រលប់ទៅគេហដ្ឋានរបស់គេរៀង១ខ្លួន ។ មេឃុំនិងក្រុម គ្រួសារព្រមទាំងកម្មករបួននាក់ទៀតរួមទាំងពូសេតផង ក៏គ្មានកន្លែងស្នាក់ ត្បិតនៅបរិវេណផ្ទះមេឃុំ គេឃើញមាននៅសល់តែរានឫស្សីកញ្ចាស់ដែល ពូសេតចងមុងពីព្រលប់មួយប៉ុណ្ណោះ ។ កាលបើឃើញមេឃុំត្រូវការកន្លែង សំរាកបណ្ដោះអាសន្ន កវីក៏ស្មគ្រ័ទទួល :

- បើពុកមេឃុំមិនទើសទាល់ ទៅសំណាក់ផ្ទះរបស់ខ្ញុំសិនទៅ ចាំស្អែកសឹម យើងគិតតទៅទៀត...
- តែផ្ដាស! នរណាជាពុកឯងហ្នា៎ស នាយកវី?

ឃើពេញខ្លួនហើយ មេឃុំនៅមាត់បានទៀត សម្លុតនាយកវីស្មើរលោះ ព្រលឹងតែម្តង។ មឹងផាវញដូច្នោះក៏ឃាត់ឡើង :

- នែ៎ ពុកវា! ក្មេងវាមានចិត្តចំពោះយើងហើយគេពិបាកទល់ភ្នែកមើលពុក វាឯងរហេមរហាមរលាកភ្លើងពេញខ្លួន ទើបគេផ្តល់កន្លែងឱ្យយើងស្នាក់ មើលខ្លួន ហើយចុះហេតុម៉េចបានជានិយាយឱ្យគេអាក់ទឹកចិត្តទៅវិញ? នេះប្រហែលជាពុកវាចង់សំរាន្តក្រោមដើមឈើហើយទេដឹង?

- ដេកនៅឯណាក៏បានដែរ តែយើងមិនទៅផ្ទះអាកវីទេវ៉ឺយ! ( មេឃុំផែង ឆ្លើយ) នែ៎! អាសេត! នាំអញទៅផ្ទះតាមឿនបន្តិច។

ពូសេតក៏ឆ្លើយឡើងថា :

- តាមឿននាំកូនប្រពន្ធទៅថ្មគោលអស់តាំងពីម្សិលម៉្លេះ មិននៅផ្ទះទេ។

- ចុះផ្ទះតាកេន?

- ពុទ្ធោ! កូនគាត់ដប់ ចៅគាត់ជិតពីរឡូ ដេកតាំងពីក្រោលគោដល់ជង្រុក ស្រូវ បើពុកមេឃុំទៅសំរាកនៅផ្ទះនោះ ប្រហែលជាគេដាក់អោយនៅក្នុង ទ្រុងជ្រូកមិនខានឡើយ ។

- យីអើ ពិតជាពឹងមិនបានមែនវ៉ឺយ! ហើយចុះផ្ទះអាចក់?

- ងាប់! នាយចក់ប្រពន្ធពីរ ខាំគ្នាដូចឆ្កែអង្កេរស៊ី តើពុកមេឃុំទ្រាំបានដែរ?

- ហើយចុះ...

- ណ្ហើយពុកវា ( មឹងផាវនិយាយកាត់) សំដីពូៗបែបនេះ សមជាមនុស្ស រឹងប៉ឹងមានសុខភាពល្អ ដូច្នេះពុកវាសំរាន្តលើបាវទទឹកមួយយប់ក្រោមដើម ឈើអោយមូសជំរាបសួរមួយយប់សិនទៅ។ ចំណែកខ្ញុំនិងកូន គិតទៅរកកន្លែងគួរសមនៅទីផ្សេងហើយ ។

- ហើយម៉ែវាឯងទៅណា?

- ទៅផ្ទះនាយកវីហ្នឹងណា៎.. យ៉ាងណាក៏យើងមិនបាច់ដេកហាលមូស ឬក៏ ដេកនៅទ្រុងជ្រូកដូចនាយសេតវាថាដែរណា៎។ ម្យ៉ាងទៀត វាក៏គ្មានប្រពន្ធ ដើម ប្រពន្ធចុងឯណាមកជេរតម្លង់ដែរ។ ម៉េច? នៅសំរាន្តទីនេះម្នាក់ឯង សិន ឬក៏ចង់ដូរចិត្តវិញ...?

មេឃុំផែងឮដូច្នោះ ក៏បែរមើលនាយកវី ឃើញនាយឈ្ងោកមុខនៅ ស្ងៀមហាក់ខ្លាចចិត្តមេឃុំណាស់ មិនឃើញមាត់កអ្វីតបតនឹងមេឃុំយើងអ្វី បន្តិចឡើយ ។ ការពិត គាត់ក៏នឹកចង់ទៅបន្តិចៗដែរ តែដោយគាត់ធ្លាប់ វាយឫកដាក់នាយយើង ហើយធ្លាប់មានរឿងច្រើនពីអតិតកាលដែលគាត់ មិនដែលបានធ្វើអំពើល្អចំពោះនាយ ម្លោះហើយមេឃុំផែងរកហារមាត់មិន រួចថានឹងយល់ព្រមតាមសំណើរបស់នាយ ។ ឃើញឳពុកនៅស្ងាត់ស្ងៀមមិន វាចា ភារាណីមិចភ្នែកដល់កវីអោយនាយជួយលើកគាត់ដាក់ម៉ូតូហើយឱ្យ មឹងផាវជួយដើរទប់ពីម្ខាងទៀត។ បន្តិចមក កវីក៏បណ្តើរម៉ូតូតាមភ្លឺស្រែ សំដៅទៅផ្ទះរបស់នាយភ្លាម ។

ព្រហាមឡើង...

កវីក្រោកបង្កាត់ភ្លើងដាំទឹក ដាំបបរជូនមេឃុំផែងនិងមីងផាវ ស្រាប់ តែភារាណីក្រោកដើរចេញមកដល់ចង្ក្រានបាយដែរ :

- បងកវី! អោយខ្ញុំជួយអ្វីខ្លះទេហ៎?

កវីគ្រវីក្បាល :

- មិនអីទេ.. ខ្ញុំអាចធ្វើម្នាក់ឯងបាន។ អ្នកត្រូវទៅសំរាកចុះ។

- ហើយថ្ងៃនេះ បងមិនចេញទៅរកស៊ីធ្វើការអ្វីទេហ៎? (ភារាណីសួរ)

- ខ្ញុំគិតសំរាកមួយថ្ងៃ ឃើញចាស់ទុំមិនស្រួល គិតថានៅបំរើគាត់សិន។

- អញ្ចឹង ម៉ោះ ខ្ញុំជួយធ្វើក្នុងចង្ក្រាននេះចុះ! បងឆាប់ទៅរែកទឹកមកបន្ថិច ទៀត

ទាំងចាស់ទាំងក្មេងត្រូវការងូតទឹកហើយពេលគេភ្ញាក់ពីដំណេក។

កវីញញឹមឡើងភ្លាម កាលបើឃើញធិតាមកជួយសម្រាលកិច្ចការ។ កំពុងតែញញឹមដាក់គ្នាទៅមក ស្រាប់តែ :

- អាហ៊្អែម! នែ៎រ៉ឺយ! នាំគ្នាផ្គុំក្បាលអីនៅចង្ក្រានបាយ? យើងត្រូវការអ្នក ជួយលើកយើងទៅបន្ទប់ទឹកបន្តិច...

មានអ្នកណាទំនេរទេ?

មេឃុំផែងគ្រហែមឡើង កាលបើឃើញអ្នកទាំងពីរឈរនិយាយគ្នា នៅក្នុងចង្ក្រានខ្សិប១ស្តាប់មិនឮ។ កវីភ្ញាក់ព្រើត

គេចចេញទៅភ្លាមសំដែង កិរិយាហាក់ដូចជាខ្លាចមេឃុំដល់សួរហើយ។

ថ្ងៃនោះ មេឃុំត្រូវកូនស្រីនិងប្រពន្ធបង្ខំអោយក្រោកមកពិសារបាយ ថ្វីត្បិតគាត់ប្រកែកថាមិនឃ្លានក៏ដោយ។ ការពិត

មេឃុំផែងកំពុងបាក់ទឹក ចិត្តដែលផ្ទះរបស់គាត់មួយខ្នងយ៉ាងស្អាតមានតម្លៃត្រូវភ្លើងឆេះរលាយរលំ អស់នៅសល់តែផេះ។

រីឯរឿងមួយទៀតដែលធ្វើអោយមេឃុំអន់ចង់នោះ គឺ គាត់ធ្លាប់មាក់ងាយប្រមាថនាយកវីយូរឆ្នាំមកហើយ ដោយមិននឹកស្មាន

ថាថ្ងៃមួយគាត់នឹងធ្លាក់ខ្លួនមកជ្រកជំរករបស់នាយកវីដ៏ក្រីក្រនោះឡើយ។

ពេលនេះ មេឃុំផែងក៏ក្លាយខ្លួនជាមនុស្សសុញគំនិត ទាល់ច្រកនិយាយមិន ចេញ។ នៅថ្ងៃត្រង់

ពេលដែលឃើញអាហារនៅលើស្លឹកភ្លាម មេឃុំក៏រិត តែលែងហ៊ានប្រកែកទៀតដែរ ព្រោះត្បិតម្ហូបនៅក្នុងស្លឹក ជារបស់ដែល

គាត់ចូលចិត្តពិសារបំផុត។ នោះគឺភ្លាអណ្តាតគោទឹកប្រហុក កាលបើមេឃុំ ឃើញហើយ ក៏ស្រក់ទឹកមាត់ច្រេច១ចង់សាកតែម្តង។

ពេលនេះ មេឃុំនៅស្ងៀមហើយងើបឡើងពេនព្នែន យកស្លាបព្រាលូកចាប់អាហារ ដាក់មាត់ ទំពារលេប

ដោយមិនឮស្រដីអ្វីមួយម៉ាត់។

រសៀលបន្តិចក្រោយពីសំរាន្តថ្ងៃត្រង់ មេឃុំផែងលួចកេះមីងផែថា :

- ម៉ែវា! ដឹងទេហ៎ ថាអាកវីវារកស៊ីអីសព្វថ្ងៃនេះ? មើលទៅជីវភាពវាដូច

ជាធូរធារគ្រាន់បើជាងកាលពីច្រើនឆ្នាំមុនដែលយើងធ្លាប់ឃើញវា។

- មិនដឹងទេពុកវាអើយ។ យើងមិនទៅមករកគ្នាយូរហើយ តែខ្ញុំក៏សង្កេត ឃើញដែរថា ផ្ទះរបស់វាមួយខ្នងនេះ

មិនមែនជាខ្នងដែលយើងធ្លាប់ឃើញ កាលពីច្រើនឆ្នាំមុននោះទេ។ មើលទៅទំនងដូចជាទើបនឹងសង់ប៉ុន្មានឆ្នាំ នេះ ទេដឹង។

ពិតមែនតែផ្ទះនេះមិនមានតម្លៃស្មើនឹងផ្ទះរបស់យើងដែល បាត់បង់ទៅមែន... តែមើលទៅមនោរម្យគួរអោយចង់រស់នៅណាស់ ។ ប្រហែលជាវាសង់ផ្ទះនេះ ទុកការប្រពន្ធទេដឹង?

- ហ្អាស? ការប្រពន្ធ? ការនឹងពីណាគេ?
- មិនដឹងទេ.. ចេះតែថាៗទៅណាំពុកវា ។ ហើយម៉េចបានធ្វើមុខអញ្ចឹង?
- គឺ... ណ្ហើយ... ខ្ញុំមិនបានគិតអ្វីទេ ។ គ្រាន់តែចង់ដឹងថាវារកស៊ីសុចរិតឬក៏ រកស៊ីអ្វីផ្សេងបានជាជីវភាពរបស់វាផ្លាស់ប្តូរលឿនយ៉ាងនេះ?
- មើលទៅវាដូចជាមិនមានពិរុទ្ធអ្វីដែលថាវារកស៊ីទុច្ចរិតទេ ។ មើលកូនៗ របស់គេចុះ ឃើញជាក្មេងមានទឹកចិត្ត ហើយប្រកបដោយគន្លងធម៌ប្រពៃ ទៀតផង ។
- កាលមុនវាមានកូនស្រីតែមួយ ហើយចុះកូនប្រុសនោះវាមកពីណា?
- ខ្ញុំក៏ឆ្ងល់ដូចពុកវាឯងដែរ ម៉េចទៅ? ចង់ហៅវាមកសួរទេ?
- មិនបាច់ទេ.. បើវាចង់ប្រាប់ យើងនឹងស្តាប់ តែបើអោយយើងសួរ យើង មិនសួរវាឡើយ ។
- វាយឫកណាស់ ពុកវាឯងនេះ!

នៅមាត់ស្រះឈូកចំហៀងផ្ទះ...

ទាំងបួននាក់ ករី ភារាណី សោភា និងសារេត កំពុងបោកគក់ខោអាវ ហាលថ្ងៃផង ប្រលែងគ្នាផងយ៉ាងរីករាយ ហាក់បីដូចជាគ្រួសារតែមួយ ឪពុកម្តាយកូន យ៉ាងពោរពេញទៅដោយសុភមង្គល ។ កំពុងតែញញឹមរីក រាយ ស្រាប់តែមាណពដាក់ភ្នែកទៅរានហាលខាងលើផ្ទះ ឃើញមេឃុំផែង កំពុងឈរសម្លឹងមករូបនាយមិនដាក់ភ្នែក ។ ករីទឹកភ័យខ្លួនក៏ដាក់មុខជ្រប់ ហើយក៏ស្រវាលើកកញ្ច្រែងខោអាវដើរចេញទៅ ។ ភារាណីសង្កេតឃើញ ការផ្លាស់ប្តូរអាកប្បកិរិយាយ៉ាងលឿនរបស់នាយយើង ក៏បែរមើលតាម ក្រសែភ្នែករបស់នាយឃើញឪពុកនាងសម្លឹងមក ។ ធិតាទឹកមិនស្រួលក្នុង ចិត្ត ក៏បបួលក្មេងទាំងពីរដើរត្រលប់ចូលទៅក្នុងផ្ទះវិញដោយមិនស្រដី ។

យប់ឡើង បាយហើយ មេឃុំផែងក៏ផ្តេកខ្លួនលើកូនពូកអេប៉ុងដ៏ស្តើង មួយដោយអាការៈល្វិតល្វៃ ដោយបាក់កម្លាំងទាំងកាយទាំងចិត្ត ។ មីងផាវ អង្គុយនៅជិតគាត់យកផ្លិតផាងស្លា បបក់អោយគាត់មានអារម្មណ៍ល្ហមក វិញ ។ នៅក្បែរនោះ កុមារសារេតបាននាំប្អូនចងមុងចូលគេងដោយស្ងៀម ស្ងាត់ហាក់ដូចជាមិនហ៊ានរំខានចិត្តតាយាយដែលកំពុងឈឺ ។ នៅខាងក្រៅ ផ្ទះ ភារាណីអង្គុយលើអង្រឹងយោលទៅយោលមក ។ យូរម្តងក៏លួចមើល ទៅនាយករី ដែលអង្គុយកត់កំណត់ផ្សេងៗនៅលើក្តារផ្ទះ ក្បែរចង្កៀង ។ ធិតាយើងក៏សួរថា :

- សរសេរសំបុត្រទៅណាឬ បងករី?
- បាទ... អត់ទេ? គឺកត់កំណត់ចំនួនស្រូវដែលប្រមូលបានឆ្នាំនេះ ។
- អូហ៎ បងករីធ្វើស្រែនឹងគេដែរ?

- គឺ...ខ្ញុំជាឈ្នួលពេញកណ្ដាល ជួលដីស្រែ ហើយជួលកម្មករអោយធ្វើការ កាច់ សោហ៊ុយអស់ទៅ សល់ប៉ុន្មានគឺផ្លែចំណេញរបស់យើងហើយ ។ ជួនកាល ចេញយកជ្រូកបាទៅបង្កាត់ ហើយក៏ដូរយកជាស្រូវ លុះដល់ខែវស្សាឆ្នាំថ្មី ខ្ញុំបញ្ចេញស្រូវលក់វិញទើបបានថ្លៃ ។

កវីនិយាយប្រាប់ទៅភារាណីវិញដោយមិនបានដឹងទេថាមេឃុំផែងនិង ប្រពន្ធរបស់គាត់កំពុងតែលួចស្ដាប់ផងដែរ ។

- ហើយបងរកស៊ីកាក់កបទេ? (ធិតាសួរបន្ថែម)

- ដូចជាចេះតែរស់បាន មិនអត្តខាត់ពេកទេ ។

- ហើយចុះនៅរដូវប្រាំងបែបនេះ បងធ្វើអីទៅ?

- គឺដើរចាក់ថ្នាំអោយសត្វដែលមានជំងឺ..

- អូហ៏.. ធ្វើជាពេទ្យសត្វផង អញ្ចឹងតើហ៎ បានជាជ្រូកមាន់ទាម្ដុំនេះ ធាត់ ទ្រលុក១ម្លេះ ។

- នោះ ទាល់តែសរសើរកូនវេតហើយ ព្រោះគេជាអ្នកចាត់ចែងកិច្ចការ នេះនៅផ្ទះ ។ ខ្ញុំមិនសូវបានជួយគេប៉ុន្មានទេ ។

- ហើយបើធ្វើការម្លឹង១ កូនមិនខានរៀនសូត្រទៅហើយទេ?

- រៀននៅតែរៀនធម្មតា១ឥចឹងទៅ តែធ្វើម៉េចបើយើងជាអ្នកក្រ បើមិនខំ ទេ តើនឹងបានអ្វីចិញ្ចឹមជីវិត ។ ទំលាប់ក្មេងអោយចេះធ្វើការដូច្នេះប្រសើរ ជាជាងអោយគេរត់លេងឥតប្រយោជន៍ដែរ ។ ថ្ងៃក្រោយទៅ គេនឹងអាច ចេះជួយខ្លួនឯងផង ។

មេឃុំលួចស្ដាប់ពីក្នុងផ្ទះមក ឮសព្ទសំដីដែលនាយចចារជាមួយនឹងកូន ស្រីរបស់គាត់ ហើយក៏លួចញញឹមម្នាក់ឯង ។ ឃើញកិរិយារបស់គាត់ដូច្នោះ មីងផាវសួរថា :

- ម៉េច អន់ឈឺរបួសហើយមែនទេ បានជាសម្រាន្តញញឹមតែម្នាក់ឯង?

មេឃុំផែងមិនឆ្លើយទេ បែរជានិយាយត្រលប់ទៅវិញថា :

- ម៉ែវាឯងទៅហៅអាកវីអោយវាមកណេះម៉ាភ្លែត ខ្ញុំចង់សួរវាបន្តិច...

មីងផាវក៏ងើបទៅកេះមាណពអោយមកជិតមេឃុំផែង ។ កវីលូនចូល មកដល់អង្គុយបត់ជើងដោយក្ដីគោរព ។

- នាយកវី..! (មេឃុំហៅ)

- បាទ! ពុកមេឃុំ!

- យើងមិនមែនពុកឯងទេ ម៉េចបានចូលចិត្តហៅយើងថាពុក១ ដូច្នេះ?

- ព្រោះម៉ែបានផ្ដាំមកអោយហៅពុកដូច្នេះ បាទ ។

- ម៉ែរបស់ឯងផ្ដាំមក?

- បាទ..! គឺផ្ដាំតាំងពីតូចរហូតដល់មុនពេលគាត់ស្លាប់ គាត់ផ្ដាំអោយហៅ ពុកមេឃុំថាជាពុករៀងរហូតទៅ ។

- ឯងចង់មានន័យថាម៉េចនាយកវី? យើងស្ដាប់មិនយល់ទេ...

មែនហើយ! សូម្បីតែមីងផាវជាប្រពន្ធរបស់មេឃុំផែងក៏ជ្រួញចិញ្ចើម ដូចគ្នាដែរ ។ ភ្លាមនោះ ភារាណីក៏សួរថា :

- ពុកមានរឿងអ្វីកាលពីអតិតកាលជាមួយនឹងម្ដាយបងកវីមែនទេ?

មេឃុំផែងបើកភ្នែកធំៗ :

- ហើយកូនឯងចង់ដឹងអីដែរ?

- បើចាស់ៗលាក់ការពិតនឹងក្មេង យើងដែលជាក្មេងជំនាន់ក្រោយនឹងមាន ជីវិត មានអារម្មណ៍វិលវល់ ដោយសារភាពមិនដាច់ស្រេចរបស់ចាស់ៗនោះ មិនខានឡើយ តួយ៉ាងដូចជាខ្ញុំនិងបងកវី... យើងមិនយល់ទេ ថាហេតុអ្វីពុកមិនអោយយើងទៅមកនឹងគ្នា.. ថ្ងៃនេះ កូនសូមដឹងអំពីបុព្វហេតុនេះ បានទេពុក?

ភ្លាមនោះ មេឃុំផែងបែរមើលទៅប្រពន្ធគាត់ ហើយក៏ដកដង្ហើមធំ លាន់យូយ៉ាងវែង ហាក់ដូចជាចង់បន្ធូរនូវភាពតានតឹងនៅក្នុងដើមទ្រូង ដែលរំខានចិត្តគាត់ជាយូរមកហើយ ។ បន្តិចមក មេឃុំក៏មានប្រសាសន៍ថា:

- បើយើងនិយាយរឿងយើងចប់ហើយ តើឯងអាចនិយាយរឿងជីវិតរបស់ ឯងនឹងម្ដាយរបស់ឯងអោយយើងស្ដាប់បានទេ? យើងក៏ចង់ដឹងពីជីវិត របស់ម៉ែឯងដូចគ្នា ។

ភ្លាមនោះ មីងផាវរកនឹងងើបដើរចេញ ស្រាប់តែ មេឃុំក៏លូកកាន់ដៃ ជាប់ហើយស្រដីថា :

- ម៉ែវា នៅស្ដាប់ទីនេះហើយ អោយកូនគេមានការកក់ក្ដៅនៅក្នុងចិត្តផង

មីងផាវព្វហើយ ក៏ដាក់ខ្លួនចុះវិញ ស្ដាប់មេឃុំផែងនិយាយរឿងចាស់ របស់គាត់ដូចតទៅ...

0000000000000

00000

0

# វគ្គទី៧
# ដំបៅចាស់

កាលពី២៨ឆ្នាំមុន... ចុងខែ១២ឆ្នាំ ១៩៧៨

ផែងជាសមាជិកកងចល័តយុវជនដាច់ខាត មានមុខការអង្គការចាត់ តាំងអោយទៅធ្វើស្រែនៅម្តុំវាលទ្រា ខែត្របាត់ដំបង ។ គេក៏បានជួបនារី មួយរូបឈ្មោះវ៉ាន់ ជាកងចល័តនារី ដែលត្រូវអង្គការចាត់អោយមកធ្វើ ស្រែនៅម្តុំៗនោះដែរ ។ រាល់ព្រឹកពេលគេដើរទៅស្រែ គេតែងប្រទះនាង វ៉ាន់ដើរក្នុងជួរជាមួយនារីជាច្រើនទៀតសំដៅទៅស្រែដូចគ្នា ។ កងនារីជាអ្នកច្រូតស្រូវ រីឯកងយុវជនជាអ្នកដឹកកណ្តាប់និងបែនបញ្ជាន់ស្រូវ ។ នៅ សម័យនោះ ជាយុគជិះជាន់ ដោយរបបកុម្មុយនិស្ត ។ ម្នាក់ៗ ធ្វើការនឿយ ហត់មិនសូវបានសំរាកទេ ហើយក៏មិនសូវមានអាហារបរិភោគគ្រប់គ្រាន់ ដែរ ។ នៅរៀងរាល់ថ្ងៃ គេតែងតែឃើញមនុស្សខ្យល់គដួលស្លាប់ ឬក៏ដួល ដេកឈឺរកេតរកូត គ្មានថ្នាំសង្កូវព្យាបាល តាំងពីឈឺតិចរហូតដល់ឈឺខ្លាំង រហូតដល់ស្លាប់បាត់បង់ជីវិតទៅ គ្មាននរណាម្នាក់ហ៊ានតវ៉ានឹងអំណាចរបស់
អង្គការនាគ្រានោះឡើយ ។

ថ្ងៃមួយ ផែងកំពុងតែដឹកគោបញ្ជាន់ស្រូវ ជាមួយគូកនពីរបីនាក់ក្នុង កងជាមួយគ្នា
ស្រាប់តែឮមនុស្សកូកហៅអោយជួយក្បែរៗនោះ ។ ដំបូង ផែងមិនហ៊ានដើរចោលកិច្ចការទេ ត្បិតខ្លាចយោធាអង្គការដាក់ទោស ដែលខ្លួនគេចវេះការងារ តែលុះក្រលេកទៅឃើញ នារីនោះជាវ៉ាន់ដែលគេ លួចចាប់ចិត្តស្រលាញ់ជាយូរមកហើយ កំពុងខ្យល់គដួលបាត់មាត់នៅក្នុង ស្រែដោយធ្វើការហួសកម្លាំងផង ដោយអត់អាហារផង ផែងក៏ព្រលែង គោមួយនឹមនោះចោល ហើយស្ទុះទៅបីត្រកងនាងវ៉ាន់នោះឡើងរត់សំដៅ ជំរុំមិត្តនារី ដែលមានសង់ខ្ទមបណ្តោះអាសន្នសំរាប់ទុកអោយអ្នកឈឺដេក នៅ ។ នៅទីនោះ មិនមានគ្រូពេទ្យប្រចាំទេ មានតែក្រុមកងឈ្លបដែលជា ក្មេងៗជំទង់ៗពីរបីនាក់នៅចាំយាមមើល ថាតើអ្នកជំងឺទាំងនោះឈឺពុត ឬក៏ឈឺ មែនទែន ។ បើឈឺមែនទែន ក៏ដេកឈឺទៅទំរាំដល់ពេលស្លាប់ តែបើឈឺពុត គេនឹងយកទៅដាក់ទោស ហើយទោសនោះក៏មិនមែនជាអ្វី ក្រៅពីសំលេះជីវិតចោលពីលោកនេះដដែលដូចគ្នាដែរ ។

លុះផែងដាក់នាងវ៉ាន់ចុះនៅលើកន្ទេលកញ្ចាស់មួយក្នុងខ្ទម ដែលមាន តែជញ្ជាំងពីរផ្ទាំង គេក៏ដើរចេញមកវិញ ស្រាប់តែយុវជនកងឈ្លបមួយរូប សួរថា :

- មិត្តឯងត្រូវជាស្អីនឹងមិត្តស្រីម្នាក់នេះដែរបានជាហ៊ានបីគេមកដល់ទីនេះ? ដឹងទេថា វាខុសវិន័យអង្គការ? ម៉េចបានជាមិត្តស្រីៗមិននាំមកឥចឹង?

ផែងស្ទួតទឹកមាត់ពីបំពង់ក នឹកថាប្រហែលជាត្រូវគេសំលេះថ្ងៃនេះ ហើយ ។ ភ្លាមនោះ គេក៏ឆ្លើយថា :

- ខ្ញុំមិនចង់មកទេ ព្រោះត្រូវចោលកិច្ចការបំរើអង្គការ តែមិត្តបងកងឈ្លប នៅម្តុំនោះ បានបញ្ជាអោយមក ទើបខ្ញុំមិនហ៊ានប្រកែកនឹងបញ្ជា ។

- អឺ! បើឥចឹងរួចខ្លួន តែកុំអោយយើងដឹងណាំថាមិត្តឯងកុហក បើមិន ដូច្នោះទេ.. មិត្តដឹងហើយថាមិត្តនឹងទទួលទោសយ៉ាងម៉េច ។

- បាទ មិត្តប្អូន!

ផែងដើរត្រលប់ទៅវិញទាំងមិនអស់ចិត្ត ត្បិតនាងវ៉ាន់នៅតែដេកស្ងាត់ ឃើងស្តូកស្តឹងនៅលើដីមិនឃើញកំរើកអ្វីសោះ ។ លុះនាយដើរជិតដល់ស្រែ វិញ ស្រាប់តែមានយុវជននៅកងចល័តជាមួយគ្នាលួចរត់មកប្រាប់ថា :

- ផែង!  មិត្តឯងឆាប់រត់ទៅ ។ មេកងឈ្លបកំពុងតាមរកឯងដាក់ទោស ហើយដែលឯងព្រលែងគោម៉ានឹមនោះ អោយវាដើរទីងណាត់ទីងណែង ពេញស្រែ ។ គ្នាខ្លាចតែគេតាមចាប់ឯងទៅសំលេះទេ ។ ណេ៎ះ គ្នាមានអង្ករ ម៉ាកំប៉ុងដែរ ។ លួចដាក់តាមខ្លួនទៅ រត់យកអាយុទៅ កុំត្រលប់ក្រោយ វិញអោយសោះ ក្រែងងាប់ណាំ ។

ថាហើយ យុវជនមួយរូបនោះក៏គេចខ្លួនបាត់ទៅ ។ ផែងក៏រត់គេចខ្លួន ដែរ តែគេមិនអស់ចិត្តសោះដែលបណ្តោយអោយនាងវ៉ាន់នៅដេកឃើតែ ម្នាក់ឯងគ្មាននរណាមើល ។ លុះព្រលប់បន្តិច កងចល័ត ទាំងយុវជន ទាំង ខាងនារី ព្រមទាំងកងយោធា កងឈ្លបទាំងឡាយ ឡើងពីស្រែទៅហូប បាយនៅការដ្ឋានអស់ ។ ផែងក៏លួចរត់ត្រលប់មករកនាងវ៉ាន់ នៅឯខ្ទម មួយនោះវិញ ឃើញនាងនៅគេងស្តូកស្តឹងតែម្នាក់ឯងដដែល ។ គេក៏លើក បីនាងរត់ចេញទៅ...

ទាំងពីរនាក់ត្រូវលាក់ខ្លួននៅក្នុងព្រៃអស់ជាច្រើនអាទិត្យ ដោយមាន ផែងជាអ្នកចូលភូមិលួចស្រូវអង្ករ លួចដំណាំសហករណ៏របស់អង្គការដើម្បី យកមកបំប៉ននាងវ៉ាន់ដែលកំពុងដេកឈឺ ។ មិនយូរប៉ុន្មាន សុខភាពនាងក៏ បានធូរស្រាលឡើងវិញ ។

នៅដើមខែមួយឆ្នាំ១៩៧៩... ព្រឹត្តការណ៏មួយទៀតក៏បើកទំព័រថ្មីនៅ កម្ពុជា ។ ផែងបាននាំនាងវ៉ាន់រត់រហូតមកដល់ភូមិដំណាក់ហ្លួង រួចនាយបាន ជួបនឹងសាច់ញាតិមួយរូបដែលបបួលនាយចេញទៅរកស៊ីរត់ពន្ធ ដើម្បីដោះ ស្រាយជីវភាព ។ ដោយសារការរស់នៅជិតដិតនឹងគ្នាយូរទៅ ចំណងផ្លូវចិត្ត រវាងអ្នកទាំងពីរក៏កាន់តែមានជំរៅឡើង ។ មិនយូរប៉ុន្មាន នាងវ៉ាន់ក៏មាន ផ្ទៃពោះសម្រាលបានកូនប្រុសមួយនៅចុងឆ្នាំ១៩៧៩ ។ គេបានដាក់ឈ្មោះ អោយទារកនោះថា វៃ ។ កាលណោះ ផែងចេញទៅរកស៊ីកាក់កបណាស់ រហូតដលគេបានមកទិញដីចំការសង់បានផ្ទះមួយនៅម្តុំវត្តគរនេះឯង ។ លុះ ក្រោយមកទៀត ផែងបានជួបនឹងមិត្តភក្តិ ចាស់ដែលធ្លាប់រៀនជាមួយគ្នា នៅវិទ្យាល័យអ៊ាបឃុតពីដើមមិញ ។ គេមកបបួល អោយនាយចូលទៅធ្វើ ការក្រសួងអ្វីធំដុំនឹងគេ តែផែងប្រកែកដោយគេរកស៊ីមានបានចំរុងចំរើន ពេកណាស់ទៅហើយ ។

ពីរបីឆ្នាំក្រោយមក ផែងក៏ចាប់ផ្ដើមមានទុនធ្វើ ចំការផង ធ្វើស្រែប្រវាស់ផង និងរកស៊ីម៉ៅការសំណង់ផង ។ គេក៏ចាប់ផ្ដើមមានឈ្មោះល្បីល្បាញសុះសាយកាន់តែខ្លាំងឡើង ។ អ្នកស្រុកដែលរស់នៅ ម្ដុំជិតៗនោះក៏បានក្លាយជាកម្មករក្នុងចំការ ក្នុងស្រែ ឬក្នុងមុខការម៉ៅ សាងសង់របស់នាយផែងសឹងតែទាំងអស់ ។ ដោយផែងជាមនុស្សអុងអាត់ ពីកំណើត តែក៏មានចិត្តទូលាយចំពោះញាតិជិតខាង  ដោយមិនមើលបំណាំ ក្រោយមកអ្នកស្រុកក៏លើកគេធ្វើមេភូមិ រួចក៏ឡើងជាមេឃុំទៀត ។

ចៃដន្យ លុះផែងក្លាយជាមនុស្សដែលមានទ្រព្យ មានប្រជាប្រិយភាព កាន់តែខ្លាំង គេក៏ប្រែក្លាយជាវង្វេងនឹងការសប្បាយភ្លើតភ្លើនផ្ដេសផ្ដាស ដើរចោលប្រពន្ធកូន លង់ខ្លួនមានស្រីញីក្រៅផ្ទះ រហូតមានកាលនារីទាំង នោះចូលមករំខានជីវិតរបស់នាងវ៉ាន់ ដែលនៅឯផ្ទះមិនដឹងរឿងអីនោះ ទៀតផង ។ ជួនកាលផែងទៅជប់លៀងស៊ីផឹក បង្ហិនបង្ហោចប្រាក់កាស ដែល ខ្លួននិងប្រពន្ធខំប្រឹងរកសន្សំទុកជាយូរឆ្នាំមកដោយមិនគិតស្ដាយ ធ្វើអោយនាងវ៉ាន់កាន់តែអស់ទឹកចិត្តនឹងស្វាមីរបស់ខ្លួនបន្តិចម្ដងៗ ។

នៅថ្ងៃមួយ...

នាងវ៉ាន់រត់ត្រហេបត្រហបហៅអ្នកជិតខាងឡើងមកជួយ ត្បិតកុមារ វៃ ជាកូនប្រុសរបស់នាងមានជំងឺគ្រុនក្ដៅក្អួតចង្អោរចុះរាគយ៉ាងចម្លែក ។ ភ្លាមនោះ មាណពមួយរូបឈ្មោះ ផល បានមកដល់ជួយហៅរ៉ឺម៉កដឹកនាងវ៉ាន់និងកូនទៅមន្ទីរពេទ្យធំជាប្រញាប់ ។ ផលជាអ្នកនៅម្ដុំៗនោះដែរហើយ ក៏ជាកម្មករធ្វើស្រែប្រវាសជាមួយមេឃុំផែង ។ គេនៅលីវហើយជាមនុស្ស មានសន្ដានចិត្តល្អ ខុសត្រង់តែគេក្រីក្រ គ្មានឪពុកម្ដាយសាច់សន្ដានអ្វីទេ ត្បិតគាត់បានអនិច្ចកម្មទៅក្នុងយុគសម័យកុម្មុយនីស្តខ្មែរក្រហម ។ នៅ
ពេលនោះ ផលមានវ័យស្រករៗនឹងផែងដែរ ។

ផលបានជួយមើលខុសត្រូវនាងវ៉ាន់និងកូនដោយចិត្តសទ្ធា មិនបានគិតក្នុងក្រៅទេ ត្បិតគេធ្លាប់ជំពាក់គុណដែលផែងធ្លាប់ផ្ដល់ការងារអោយគេ ធ្វើ ដើម្បីលៀងជីវិត ថែមទាំងលើករូបគេអោយធ្វើប្រធានកម្មករនៅម្ដុំ នោះទៀតផង ។ បីថ្ងៃកន្លងទៅ ផែងក៏ត្រលប់មកដល់ផ្ទះវិញ ឮអ្នកស្រុកប្រាប់ថា កូនរបស់គេមានជំងឺធ្ងន់កំពុងគេងព្យាបាលនៅពេទ្យធំឯក្រុង បាត់ដំបង ។ គេក៏ហក់រឹងទៅរកស្រាប់តែប្រទះវ៉ាក់អើនឹងនាយផលដែល កំពុងបំរើនាងវ៉ាន់និងកូនដោយយកចិត្តទុកដាក់ ។ ក្ដីបារម្ភចំពោះកូនប្រពន្ធក៏បានក្លាយជាកំហឹងប្រចណ្ឌយ៉ាងខ្លាំងក្លា ចំពោះនាងវ៉ាន់និងកម្លោះសង្ហា ឈ្មោះផល :

- យើស៎! គ្រាន់តែប្ដីមិននៅប៉ុន្មានថ្ងៃ ហ៊ានបណ្ដើរប្រុសកម្លោះ ចេញមុខ ផងឬ ស្រីល្អ? (ផែងឧទានខ្សិបៗតែម្នាក់ឯង)

ផែងត្រលប់មកផ្ទះវិញទាំងមួម៉ៅ ។ រសៀលថ្ងៃដដែលលោកគ្រូពេទ្យ បានអនុញ្ញាត្តអោយនាងវ៉ាន់នាំកូនត្រលប់មកផ្ទះវិញ ។ ផលក៏ហៅរ៉ឺម៉ក មកដឹកគេត្រលប់ទៅផ្ទះភ្លាម ។ គ្រាន់តែរ៉ឺម៉កវិលកង់ដល់មុខផ្ទះ ពេលណា នាងវ៉ាន់ប្រទះឃើញផែងឈរចាំនៅមុខផ្ទះទាំងទឹកមុខយ៉ាងកាច ទំនងដូច ជាលាក់កំហឹងក្នុងចិត្តទៀតផង ។ ពេលនោះ នាងបីកូនស្រពន់ដៃណាស់ ទៅហើយ ត្បិតកុមារវៃមានវ័យប្រហែល៦ឆ្នាំហើយ ហើយក៏មានមាឌធំ

គួរសមល្មមនឹងម្ដាយលើកបីមិនរួច ។ លុះក្រលេកឃើញនាងវ៉ាន់បីកូនចុះពីរ៉ឺម៉កមិនរួច នាយផលក៏ស្ទុះទៅជួយលើកក្មេងឡើង ដើម្បីអោយនាងវ៉ាន់ ចុះពីរ៉ឺម៉កតាមសម្រួល ។ ប៉ុន្តែកិរិយានោះ មិនបានធ្វើអោយផែងសប្បាយ ចិត្តឡើយ :

- អាផល! អាព្រហើន!

ផាំង! នាយផែងទះកំភ្លៀងនាយផលមួយទំហឹងដៃស្ទើរតែនាយរបូត ជ្រុះកុមារតូចយើងពីដៃទៅហើយ ។ បន្ទាប់មក ផែងក៏ស្រដីថា :

- យើស៎ ហ៊ានលូកថ្លើមយើងផងហ៉្អែស? ពិតជាចិញ្ចឹមបំបង់បាយមែន ឯង នេះ! សមតែងាប់ទេ ។

គេក៏កញ្ឆក់កូនប្រុសពីដៃរបស់ផល ហើយក៏ចាប់ញ៉ឹងដៃនាងវ៉ាន់ឡើង ទៅលើផ្ទះយ៉ាងរហ័ស ។ លុះឈានដល់លើផ្ទះពេលណា ផែងប្រច្រាន ប្រពន្ធដួលទៅលើក្ដារផ្ទះព្រួសដោយកំហឹង :

- ថោកទាប! ហេតុអ្វីគ្រាន់តែយើងមិននៅពីរបីថ្ងៃ នាងហ៊ានបណ្ដើរប្រុស ឃ្មោលពេញទីសាធារណៈយ៉ាងនេះ?

នាងវ៉ាន់ងើបមុខហើយឆ្លើយថា :

- កុំនិយាយនាំបាបយ៉ាងនេះ បងផែង! គេមិនមែនជាប្រុសឃ្មោលរបស់ខ្ញុំ ទេ..

ផលគ្រាន់តែមានទឹកចិត្តមកជួយសង្គ្រោះកូនយើងប៉ុណ្ណោះ ព្រោះខ្ញុំ រត់ទៅពឹងគេអោយជួយ ត្បិតកូនវិវេគេឈឺខ្លាំង..

- រត់ទៅរកវា? នាងថា នាងរត់ទៅរកវា? ដល់ម្លឹងផងឬ? យ៉ាងម៉េច? មានប្ដីមួយមិនគ្រប់គ្រាន់ទេហ៎ ឬក៏ចង់ថែមប៉ុន្មានទៀតបានស្កប់?

- បងផែង! បងនៅស្រវឹងស្រានៅឡើយ បងពិតជានិយាយដោយមិនប្រើ សតិស្មារតីគិតអោយត្រឹមត្រូវទេ.. ការពិត ផលគេមិនមែនដូចបងគិត ឡើយ ។ ថ្ងៃនេះ ប្រហែលបងមានរឿងអ្វីនៅក្រៅផ្ទះទេដឹង បានជាយក កំហឹងមកជះលើអ្នកផ្ទះយ៉ាងនេះ បងផែង? បងប្រមាថគេខុសហើយណ៎ា!

- កាន់ជើងវាផងហ្អែស នាងវ៉ាន់? កាន់ជើងវាផងហ្អែស?

ជាតិស្រាដែលនៅសល់នៅក្នុងប្រពន្ធ័សរសៃឈាមរបស់ផែង មិនទាន់ ស្រកស្រុតអនុភាពនៅឡើយទេ ។ គេបានក្លាយទៅជាមនុស្សវង្វេងលែង ស្គាល់ខុសត្រូវហើយ ។ ភ្លាមនោះ គេក៏យារដៃទះកំភ្លៀងនាងវ៉ាន់មួយដៃ ហើយមួយដៃទៀត ។ នាយផលដែលកំពុងឈរសម្លឹងពីដីទៅ ឃើញ កិរិយាយង់ឃ្នងបែបនេះ ទ្រាំមិនបានក៏ស្ទុះទៅឃាត់ហើយយកខ្លួនទៅ រងជំនួស :

- បានហើយ លោកនាយ! កុំធ្វើបាបអ្នកវ៉ាន់ធ្វើអី.. គាត់ជាស្រីភេទទន់ ខ្សោយ ពិតជាទ្រាំទ្រនឹងការធ្វើបាបដោយកម្លាំងបាយមិនបានឡើយ ។

ផែងដាក់កូនចុះទៅក្នុងអង្រឹងក្បែរនោះ ហើយក៏ស្ទុះមកទាត់នាយ ផលផាំងៗពីរបីជើង ព្រមទាំងស្រែកគំរាមថា :

- អាក្រពើ! ហ៊ានមកប្រដៅយើងផងហ្អែស?

តែនាយផលមិនតដៃទេ ។ គេសុខចិត្តបណ្ដោយអោយផែងវាយទាត់ ធាក់តាមចិត្ត សឹងតែទ្រោមខ្លួនទៅហើយ ។ បន្តិចមក គេក៏ស្រដីថា :

- មែនហើយ... ខ្ញុំត្រូវតែមានកតញ្ញូចំពោះលោកនាយដែលធ្លាប់សង្គ្រោះ ជីវិតខ្ញុំនាគ្រាមួយ ថែមទាំងធ្លាប់បានផ្តល់ការងារអោយខ្ញុំធ្វើទៀតផង ។ បើសិនណាភាពកតញ្ញូរបស់ខ្ញុំពេលនេះ ធ្វើឱ្យគ្រួសារលោកក្តៅក្រហាយ ផលសូមដើរចេញពីទីនោះទៅចុះ! តែ... សូមកុំធ្វើបាបភរិយារបស់លោក

នាយអី.. អ្នកវ៉ាន់អត់ងងុយថែទាំកូននៅពេទ្យយូរថ្ងៃមកហើយ ។

នាយផលលើកដៃសំពះលាម្ចាស់ផ្ទះហើយក៏ដើរចុះជណ្តើរទៅ ។

ស្រាប់តែកុមារវៃយំឡើងស្រែកហៅរកនាយផល :

- ពូផល ទៅណា៎... ពូផល!

ថាហើយ កុមារតូចក៏ស្ទុះរត់តាមនាយផលយ៉ាងលឿន ។ មែនហើយ តើហេតុអ្វីទៅបានជាកុមារតូចនោះស្រលាញ់នាយផលដល់ម្លឹង? ការពិត ផែងមិនសូវបាននៅផ្ទះជួបជុំប្រពន្ធកូនប៉ុន្មានទេ ត្បិតគេអាល័យតែប្រឹងរក លុយ ហើយបើសិនទំនេរក៏ចេញទៅស៊ីផឹក មានស្រីញីនៅខាងក្រៅ ។ រីឯ ឱកាសសំរាប់ក្រុមគ្រួសារក៏ស្ទើយទៅតាមនោះដែរ ។ រាល់ថ្ងៃកុមារវៃ ស្គាល់តែពូផលរបស់គេប៉ុណ្ណោះ ដែលតែងតែមកអើតមើលនាយព្រឹកល្ងាច ពេលគេចេញពីធ្វើការ ។ ចំណែកនាងវ៉ាន់ក៏រាប់រកនាយផលហាក់បីដូចជា ប្អូនប្រុសមួយរូប ព្រោះគេជាមនុស្សមានទឹកចិត្ត មិនដែលមើលបំណាំនាង និងកូនទេ ។ កាលបើឃើញកូនប្រុសរត់តាមនាយផលទៅ ផែងក៏ស្រែក រំពងឡើងថា :

- អឺ.. អោយវាអញ្ចឹងទៅចុះ អាកូនក្រពើ! ចេញទៅ! ចេញអោយអស់ពី ផ្ទះយើងអោយអស់ទៅ កុំនៅទើសមុខទើសមាត់យើងទៀត ។

រួចហើយ នាយផែងក៏ចាប់អូសនាងវ៉ាន់ច្រានព្រួសអោយរមៀលតាម កាំជណ្តើរចុះទៅដី រួចហើយ គេក៏ដើររឹងចូលផ្ទះបិទទ្វារបាត់ ។ ផលនិង កុមារវៃបែរក្រោយឃើញនាងវ៉ាន់រមៀលរូយ៉ាងលឿនចុះមក រកតែស្ទុះទៅជួយត្រងទប់ក៏មិនទាន់ ។ នាងក៏ធ្លាក់ដល់ដីបោកក្បាលនឹងកាំជណ្តើរ សន្លប់បាត់មាត់មួយរំពេច ។ អ្នកស្រុកកម្មករដែលនៅម្តុំៗនោះបានឃើញ ហេតុការណ៍ទាំងអស់ តែគ្មាននរណាហ៊ានធ្វើអន្តរាគមន៍ និយាយស្តីអ្វីទេ ត្បិតគេខ្លាចចិត្តនាយផែងដែលជាចៅហ្វាយនាយ ។ ផលស្ទុះទៅបីនាងវ៉ាន់ ឡើងយកទៅដាក់នៅលើរានឫស្សីនៅខាងក្រោមដើមស្វាយមុខផ្ទះ ។ អ្នកស្រុកពីរបីនាក់ក៏ស្ទុះរត់មកជួយ ស្រាប់តែនាយផែងបើកបង្អួចស្រែកពី លើផ្ទះមកថា :

- នែវ៉ឺយ! អ្នកណាក៏ដោយដែលជួយនាងវ៉ាន់ អាផល យើងនឹងបណ្តេញឱ្យ ឈប់ធ្វើការទាំងអស់ ហើយមេត្តាជួយដេញវាពីរនាក់ហ្នឹងអោយផុតដីភូមិ របស់យើងផង ។

ថាចប់ នាយផែងក៏បិទទ្វារទៅវិញ ។ មែនហើយ នាយផែងជាមនុស្ស មាត់អាក្រក់តាំងពីណាពីណីមកម្ល៉េះ តែក៏មិនដែលមាត់អាក្រក់ធ្វើបាប ប្រពន្ធដល់ម្លឹងទេ យ៉ាងណាក៏និយាយត្រឹមតែមាត់ ។ ហេតុអីលើកនេះ គេខឹងសម្បារត្រលោតតោតតូង រហូតដល់ដេញប្រពន្ធកូនចេញពីផ្ទះយ៉ាងនេះ ឥចឹង? ការពិត គ្មាននរណាមួយដឹងទេថាពេលនោះ នាយផែងទៅស្រុកថៃ ទើបតែត្រលប់មកវិញ ចាញ់ល្បែងអស់ជិតពីរម៉ឺនដុល្លារ ហើយនារីកំណាន់ចិត្តរបស់នាយផែងឈ្មោះនាងឆោមនី បានបែកចិត្តទៅទាក់ទងថៅកែថៃ មួយរូបបំបាក់មុខនាយនៅចំពោះមុខមិត្តភក្តិ

ដែលរកស៊ីជាមួយគ្នាទៀត ផង ធ្វើអោយនាយផែងរិតតែមានកំហឹងឆាបឆេះក្នុងខ្លួនទ្វេឡើងរហូត ដល់ផឹកស្រាមិនដេកមិនពួនអស់ជាច្រើនថ្ងៃ មុននឹងត្រលប់មកផ្ទះវិញ ។ លុះឃើញហឹង្សារបស់នាយផែង ដល់កំរិតធ្វើបាបរូបកាយប្រពន្ធកូនដូច្នោះ ទៅហើយ កម្មករទាំងឡាយនាំគ្នាបំបែកជួរអស់ទៅ ទុកអោយនាយផល បីនាំនាងវ៉ាន់មកដល់ខ្ទមកញ្ចាស់របស់នាយ នៅលើដីទួលកណ្តាលវាល ស្រែក្បែរបឹងឈូក ដែលនាយទើបតែសន្សំលុយទិញដីនោះបាន កាលពី ប៉ុន្មានខែមុនមកនេះ ។

កុមារវៃរអង្គុយត្របោមជង្គង់ សម្លឹងមុខនាយផលរុំរបួសឱ្យម្តាយរបស់ នាយដែលទើបនឹងដឹងស្មារតីមកវិញ រួចហើយសួរម្តាយថា :

- ម៉ែ! ហេតុអីក៏ពុកធ្វើបាបពួកយើងដូច្នេះ?
- ម៉ែមិនដឹងទេកូន.. ប្រហែលជាគាត់មានបញ្ហាក្នុងការរកស៊ីទេដឹង?
- ហើយចុះអង្កាល់ទៅទើបយើងអាចត្រលប់ទៅផ្ទះវិញបាន?
- ហ៊ឺ!... កូនប្រុសម៉ែ... ចាំមើលទាល់តែពុកកូនបាត់ខឹងហើយ ។

ចៃដន្យ អ្នកទាំងពីរមិនដែលមានឱកាសបានត្រលប់ទៅផ្ទះទេ ។ នៅ ពេលដែលមេឃុំផែងមួម៉ៅ គាត់តែងតែគំហកកំហែងកម្មករដោយសំដី អាក្រក់ៗ ម្ល៉ោះហើយគ្មាននរណាជួយធ្វើអន្តរាគមន៍ក្នុងរឿងក្រុមគ្រួសារ មេឃុំផែងឡើយ ។ ថ្វីបើនៅពេលនោះ មេឃុំដឹងខ្លួនថាបានជ្រុលជ្រួសទៅ លើកូនប្រពន្ធខ្លាំងពេកក៏ដោយ តែដោយគាត់ជាមនុស្សមានមោទនភាព ហួសហេតុចំពោះខ្លួនឯង គាត់ក៏ខ្មាស់មាត់ខ្មាសខ្លួន មិនហ៊ានទៅសូមទោស ភរិយា អង្វរអោយគេត្រលប់មកផ្ទះវិញ ។ គាត់នឹកគិតថាបំរុងចេញទៅ តាមនាងវ៉ាន់ជាប្រពន្ធជាច្រើនដង តែក៏គ្មានសេចក្តីក្លាហានគ្រប់គ្រាន់នឹង ទៅហៅនាងត្រលប់មកផ្ទះវិញដែរ ណាមួយបេះដូងរបស់មេឃុំក្មេងរបស់ យើង ក៏នៅសល់កំសួលចំហាយនៃក្តីប្រចណ្ឌ័ពេញខ្លួននៅឡើយ ជាពិសេស ពេលដែលគេសង្កេតឃើញថា បុរសសង្ហាក្មេងមួយរូបឈ្មោះផលនោះ នៅ តែបំរើផ្គាប់ផ្គុននាងវ៉ាន់មិនដែលលោះដដែល ។ ការពិត រវាងនាងវ៉ាន់និង ផល គេទាំងពីរមាននិស្ស័យចុះសម្រុងនឹងគ្នាច្រើន ដោយគេមិនចូលចិត្ត យកភាពកំហែងទល់កំហល់ ជាការដោះស្រាយរឿងកង្វល់នៅក្នុងចិត្ត ។ គេចូលចិត្តនិយាយអ្វីធ្វើអ្វី ប្រកបដោយក្តីមេត្តានិងសីលធម៌ ដែលមេឃុំ ផែងមិនអាចយកប្រៀបបាន ។ ថ្វីបើពេលនោះនាយផលក្រីក្របន្តិច តែ នាងវ៉ាន់និងកូនបានទទួលនូវសេចក្តីសុខគ្រប់គ្រាន់ មិនរងនូវការរកាំរកូស ព្រឹកល្ងាចដូចកាលរស់នៅជាមួយមេឃុំផែង ដែលអាងទ្រព្យ អាងបុណ្យ សព្វបែបយ៉ាងនោះទេ ។ រីឯផលនៅតែគោរពបំរើនាងវ៉ាន់ ដូចជា ចៅហ្វាយនាយដដែល មិនដែលផ្លាស់ប្តូរសោះឡើយ ។

មួយឆ្នាំក្រោយមក នាងវ៉ាន់ក៏ចែកឋានទៅដោយរោគចិត្ត ជាពិសេស បន្ទាប់ពីបានដឹងថា មេឃុំផែងបានទៅអួសនាងឆោមនីពីស្រុកថៃមករៀប ការជាប្រពន្ធថ្មី ហើយនាំឡើងមករស់នៅលើផ្ទះរបស់គាត់ យ៉ាងពេញមុខ ពេញមាត់ដើម្បីបញ្ឈឺចិត្តប្រពន្ធដើម ។ រីឯកុមារវៃក៏ត្រូវរស់នៅជាមួយ នាយផលជាឪពុកធម៌រហូតរៀងមក ។ ក្រោយៗមក គេក៏ឮដំណឹងថា មេឃុំផែងលែងលះប្រពន្ធ រៀបការប្រពន្ធ រួចលះលែង រួចរៀបការអស់ ជាច្រើនដង ត្បិតប្រពន្ធទាំងឡាយនោះ

មិនអាចស៊ូធន់នឹងភាពឆេវឆាវ អ៊ុងអាត់របស់គាត់បាន។ ក្រោយមក មេឃុំក៏បានមកជួបនឹងមីងផាវ រួច បានរៀបការរស់នៅជួបជុំគ្នារហូតតរៀងមក។

0000000000000000

0

# វគ្គទី៨
# សំនៀងស្នេហ៍កវី

ច្រើនឆ្នាំកន្លងទៅ...

ពូផលបាននាំចិញ្ចឹមកូនធម៌របស់គាត់ រហូតដល់ធំពេញវ័យហើយបាន ប្រលងជាប់ចូលរៀននៅវិទ្យាល័យនេតយ៉ង់ បាត់ដំបង។ គាត់បានដូរ ឈ្មោះថ្មីអោយនាយថា កវី ត្បិតនាយយើងចូលចិត្តតែងកាព្យតែងចំរៀង ច្រៀងលេងមិនឈប់សោះ ចំរៀងកំសត់ក៏មាន សប្បាយក៏មាន។ សំណាង របស់នាយមិនល្អ ឪពុកបង្កើតរបស់កវីបានបិទទ្វារមិនទទួលស្គាល់រូបនាយ ជាយូរឆ្នាំហើយ ហើយថែមទាំងស្រាស់របងចំការ មិនអោយមាននរណា អាចដើរឆ្លងរបងទៅរកដីភូមិរបស់ពូផលឡើយ ប្រហែលជាគាត់មិនដឹងថា មីងវ៉ាន់ជាប្រពន្ធដើមចែកឋានឫក៏យ៉ាងណាទេ។ កវីរស់នៅឯកាកណ្តោច កណ្តែងជាមួយឪពុកធម៌តែពីរនាក់ម៉ង់ៗ។ ក្រោយមកផលបានចេញទៅ រកស៊ីជីកត្បូងនៅប៉ៃលិន យូរៗមកផ្ទះមើលកូនម្តង។ កវីក៏ធំឡើងជា ក្មេងឯកោ មិនសូវមានសម្តីទេតែគេមានសីលធម៌នៅក្នុងខ្លួនណាស់ មិន ដែលធ្វើអ្វី ដែលនាំអោយពូផលត្រូវពិបាកដោយសារនាយម្តងណាឡើយ។ គេតែងតែចងចាំនូវបណ្តាំគ្រប់ម៉ាត់ដែលម្តាយនិយាយប្រាប់ មុនពេលគាត់ អនិច្ចកម្មទៅ ថែមទាំងគោរពពូផលហាក់បីដូចជាឪពុកបង្កើត។ នៅក្នុង ជំរៅដួងចិត្តរបស់នាយ មេឃុំផែងជាអ្នកផ្តល់កំណើត តែពូផលជាអ្នក ផ្តល់ជីវិត និងជាអ្នកត្រាយផ្លូវអនាគតអោយរូបនាយដើរដោយមិនបាច់ ធ្លាក់ផុងជាប់អន្លង់នៃភាពភ្លើតភ្លើនអន្ធពាលរបស់យុវវ័យ។ កវីជាក្មេង កតញ្ញូ មាននិស្ស័យសម្បទាយ៉ាងល្អដូចម្តាយរបស់គេ ដែលជាហេតុធ្វើ អោយពូផលស្រឡាញ់ កវីហាក់បីដូចជាឈាមរបស់គាត់ម្នាក់ដែរ។

នៅរដូវដកស្ទូងមួយ...

កុមារកវីមានវ័យប្រមាណ១៤ឆ្នាំហើយ។ ដោយសារពេលនេះជារដូវ វិស្សមកាល កវីត្រូវនៅផ្ទះមើលជ្រូកមាន់ទា ចំណែកឪពុករបស់នាយដែល មានដើមទុនខ្លះៗ ក្រោយពីទៅរកស៊ីត្បូងនៅប៉ៃលិន ក៏យកទៅជួលដីធ្វើ ស្រែប្រវាសជាមួយអ្នកជិតខាង។ ពេលឪពុកកំពុងតែរាស់ដីស្រែ កវីក៏ដើរ បាចត្រី ចាប់ខ្យងក្តាម ក្តិចត្រកួន បេះផ្កាស្នោ យកមកធ្វើម្ហូបអាហារ។ គេ ដើរស្ពាយត្រកបឬស្សីមួយ ឆ្លងពីស្រែមួយទៅស្រែមួយ រហូតមកដល់ដី

ថ្នាលសំណាបមួយដែលមានមនុស្សកំពុងឱនដកសំណាបបីបួននាក់ ។ ភ្លាម នោះ នាយយើងបានឮសំណើចរអីករបស់កុមារីម្នាក់អាយុប្រមាណ១១ឆ្នាំ កំពុងរត់លេងតាមភ្លឺស្រែ :

- ម៉ែ! ម៉ែ! មើលនែ៎... កូនចាប់បានកន្ទុំរុយមួយ មានពណ៌ស្អាតណាស់!

- អឺ.. ម៉ែដឹងហើយ... កូនលែងវាវិញទៅ កុំធ្វើបាបវាអី ទុកវាអោយវា រស់នៅសុខសប្បាយដូចយើងផងណា៎កូន ។

ស្ត្រីដែលកំពុងដកសំណាបម្នាក់ក៏ងើបមុខឆ្លើយឡើង ។

កវីឈរសម្លឹងក្មេងស្រីនោះទាំងញញឹម ។ នាងមានមុខមាត់ស្រស់ ស្អាតណាស់ មានថ្ពាល់ខួចហើយក្រងសក់យ៉ាងស្អាតទៀតផង ។ ពេលនោះ គេមានអារម្មណ៍ថា ហាក់ដូចជាមាននិស្ស័យជាមួយនាងតូចម្នាក់នោះ ណាស់ ។ បន្តិចមក កវីក៏ដើរទៅជិតកុមារី រួចស្រដីថា :

- នាងតូចចេះចាប់ត្រីទេ?

កុមារីងើបមើលមុខកវី រួចហើយក៏គ្រវីក្បាលឆ្លើយថា :

- អត់ចេះទេ ហើយចុះបងប្រុសចេះចាប់ត្រីមែនទេ?

- មែនហើយ! ប្អូនចង់ឃើញបងចាប់ត្រីទេ?

- ចង់! ទៅចាប់នៅឯណាដែរ?

- គឺនៅស្រែខាងណោះ.. នៅជិតនេះតើហ៍ ។

- អញ្ចឹង ខ្ញុំទៅសុំម៉ែសិនណា៎...

នាងតូចក៏កូកហៅម្តាយភ្លាម :

- ម៉ែ! កូនដើរទៅស្រែខាងនោះ ទៅមើលបងប្រុសម្នាក់នេះគាត់ចាប់ត្រី

- អឺទៅចុះ តែកុំទៅឆ្ងាយពេក ក្រែងវង្វេងណា៎កូន ។

- បន្តិចទៀតខ្ញុំជូនប្អូនមកវិញហើយណា៎មីង! (កវីកូកប្រាប់ម្តាយនាងតូច)

- អឺ! មើលប្អូនផងណា៎ក្មួយ យ៉ាងណាកុំអោយតែលង់ទឹកបានហើយ ។

ថាហើយ ស្ត្រីនោះក៏ឱនដកសំណាបវិញទៅជាមួយគូកនពីរបីនាក់ ។ កុមារីរត់តាមកវីមកដល់កាច់ជ្រុងស្រែមួយដែលមានទឹកជ្រៅគួរសម កវីក៏ ចុះទឹករាវមងដែលនាយបានចងរាយពីយប់មិញ ។ ថ្វីត្បិតតែមងនោះដាច បន្តិចមែន តែនៅពេលកវីលើកវាឡើងផុតពីទឹក ស្រាប់តែឃើញមានជាប់ត្រីស្រែបួនដប់បំរះលាន់ត្រុល១ ។ កុមារីឃើញហើយក៏ទះដៃហ៊ោរឡើង :

- ជយោ! ចាប់បានត្រីហើយៗ...!

កវីក៏សួរនាងថា :

- ប្អូនចង់បានខ្លះយកទៅធ្វើម្ហូបទេហ៎?

- ចា៎ស! មិនយកទេ ព្រោះខ្ញុំមិនទាន់ចេះដាំស្លនៅឡើយ ។

- យកទុកអោយម៉ែធ្វើម្ហូបទៅណា៎!...
- អញ្ចឹងក៏បាន! សុំពីរបីមក ។
 កវីស្រាវមងមួយសន្ទុះ ក៏បានត្រីជិតកន្លះផ្លូន ។ គេក៏បោចស្លឹដោតត្រី មួយត្រណោតអោយនាងតូច ។ បន្ទាប់មកក៏សួរថា :
- បងនេះឈ្មោះកវី ហើយចុះនាងតូចឈ្មោះអីដែរ?
- ឈ្មោះភារាណីចាំស!
- អីយ៉ា ប្អូនមានឈ្មោះពិរោះដូចកូនទេវតាអញ្ចឹង ។
- មិនមែនកូនទេវតាទេ ភារាណីជាកូនម៉ែ តែម៉ែខ្ញុំចិត្តល្អដូចទេវតាដែរ ។
 បន្តិចមក កវីក៏បោចផ្កាស្មៅក្រងជារង្វេលម្កុដយ៉ាងស្អាតមួយយកទៅ បំពាក់អោយកុមារី ថែមទាំងស្រដីថា :
- នាងតូចស្រស់ស្អាត សំដីពិរោះ ហើយមានឈ្មោះល្អទៀតផង ។ បងសូម យកម្កុដនេះបំពាក់អោយប្អូនមួយចុះ
នោះប្អូននឹងក្លាយជាទេពអប្សរដ៏
ស្រស់ស្អាតបំផុតក្នុងលោកនេះតែម្តង ។
 កុមារីឮកវីចំអន់លេងដូច្នោះ នាងក៏សើចរអឹកឡើង :
- បើភារាណីជាទេពអប្សរ តើបងកវីជាអ្វីដែរ?
- បងគឺជាកវី ដែលតែងចំរៀងស្ញើចសរសើររូបសម្រស់ដ៏ស្រស់ស្អាត របស់ ទេពអប្សរនោះអី !
 ឮដូច្នោះ នាងតូចក៏ញញឹមឡើងយ៉ាងស្រស់ត្រកាល ។ បន្តិចមក គេរត់ប្រលែងគ្នាតាមភ្លឺស្រែយ៉ាងសប្បាយ
ហាក់ដូចជាគ្មាននឹកគិតពីកង្វល់ អ្វីឡើយ ។ មួយស្របក់ក្រោយមក កវីក៏លានាងតូច ត្រលប់ទៅផ្ទះវិញ :
- អូនណី!.. បងត្រូវទៅសិនហើយណា៎..
- ហើយស្អែក បងកវីមកទៀតទេ?
- បងមក់... ចុះប្អូនវិញ មក៏ទៀតដែរទេ?
- ច្បាស់ជាមក៏ហើយ ព្រោះខ្ញុំតាមម៉ែមកដកស្ទូងរាល់ថ្ងៃ មិនចូលចិត្តនៅ ផ្ទះតែម្នាក់ឯងទេ ។
- អញ្ចឹង យើងជួបគ្នាស្អែកទៀតណា៎ ។
- ចាំស បងកវី!
 ទាំងពីរនាក់ ក៏លើកដៃលាគ្នាទៅទាំងអារម្មណ៏សប្បាយរីករាយ ដែល គេបានស្គាល់គ្នានៅពេលនោះ ។
 ចាប់តាំងពីថ្ងៃនោះមកអ្នកទាំងពីរតែងតែមកជួបគ្នារត់លេងសប្បាយ ចាប់ត្រី ចាប់ក្តាម បេះផ្កា ឃ្វាលគោក្របី
បេះផ្លែឈើព្រៃ ច្រៀងប្រលែង គ្នាលេងយ៉ាងសប្បាយ ។ មិនថារដូវស្ទូង ឬរដូវចម្រូតទេ គេតែងតែមក ជួបគ្នានៅទួលដើមចារ
រាល់ពេលណាដែលសាលាបិទទ្វារ ឈប់សំរាក ។ អ្នកទាំងពីរមាននិស្ស័យនឹងគ្នាណាស់ ត្រូវដងត្រូវផ្លែគ្នាបេះមិនដាច់ឡើយ
រួចហើយនៅរៀងរាល់ពេលដែលកវីមកជួប នាយតែងតែក្រងម្កុដផ្កាស្មៅ អោយនាងតូចពាក់ជានិច្ច
ព្រមទាំងដាក់ឈ្មោះអោយនាងតូចយើងថា ទេពអប្សរទួលចារ ទៀតផង ។

ពីរឆ្នាំក្រោយមក នៅរសៀលថ្ងៃមួយ...

កវីដើរកាត់ស្រែមករកភារាណីដូចរាល់ដង តែថ្ងៃនេះ ពេលគេមក ដល់ភ្លាម គេមិនបានប្រទះឃើញតរុណីមានទឹកមុខញញឹមរីករាយដូចរាល់ ដងនោះទេ។ ពេលនោះ ធិតាបានមកអង្គុយរង់ចាំកវី ត្របោមជង្គង់ ធ្វើ ទឹកមុខយ៉ាងក្រៀមក្រំបំផុត។ កវីដាក់ខ្លួនចុះក្បែរនាងហើយសួរថា :

- អូនណី! ថ្ងៃនេះ មានរឿងអ្វីមែនទេ?

ស្រាប់តែនាងតូចស្រវាអោបកកវីហើយយំហ៊ូតែម្តង។ កវីភ្ញាក់ព្រើត លើកដៃអង្អែលខ្នងរបស់នាងបន្ថើរ១ ព្រមទាំងស្រដីថា :

- អូនមានរឿងអ្វី នាងតូច? ប្រាប់បងមកមើល៍?

- គឺម៉ែខ្ញុំត្រូវផ្លាស់ផ្ទះ ទៅនៅជាមួយមេឃុំផែងហើយ! គាត់នឹងរៀបការ ពុកមេឃុំអាទិត្យក្រោយនេះឯង។

គ្រាន់តែឮសូរឈ្មោះនេះភ្លាម ស្រាប់តែកវីបើកភ្នែកធំ១។ បន្តិចមក កវីក៏បន្ធូរចិត្តវិញបាន រួចហើយស្រដីទៅកាន់នាងតូចបន្ថែមថា :

- បានទៅនៅផ្ទះមេឃុំហើយ ម្តេចប្អូនមិនត្រេកអរអញ្ចឹង?

- គឺ.. ខ្ញុំធ្លាប់ឮថា គាត់ជាមនុស្សកាច ហើយចូលចិត្តវ៉ាយកូនវ៉ាយដំ កូនប្រពន្ធណាស់! អូនណីខ្លាច...

- ប្រហែលជាលោកកាចចំពោះតែនរណាដែលធ្វើខុសទេដឹង..? អូនណីមិន ទាន់បានទៅរស់នៅជាមួយផង ធ្វើម៉េចនឹងដឹងកើតថាគាត់កាចចំពោះអូន ឬក៏យ៉ាងណា? ណាមួយអូនណីក៏ជាក្មេងស្រីជំទង់ហើយ ប្រហែលជាគាត់ លែងប្រើធមិវ៉ាយដំសំរាប់ប្រដៅកូនចៅហើយទេដឹង?

- តែអូនណីជួបគាត់កាលពីម្សិលហើយ... ឃើញទឹកមុខគាត់កាចណាស់។

- ណ្ហើយ! អូនរស់នៅជាមួយគាត់យូរ១ទៅ នឹងច្បាស់ជាស៊ាំហើយ ម្យ៉ាង ទៀត បើអូនគោរពតាមដំបូន្មានរបស់គាត់ អូនច្បាស់ជាសុខកាយសប្បាយ ចិត្តមិនខាន ជឿបងចុះ!

ដើម្បីលួងលោមកុំអោយធិតាយំខ្សឹកខ្សួលតទៅទៀត កវីក៏ឡើងដើម ចារ បេះផ្កាមួយដៃធំចុះមក :

- អូនមើលនេះ! ផ្កាស្អាតទេ?

- ចាំសស្អាតណាស់!

- តែ.. អូនណីស្រស់ស្អាតជាងហ្នឹងទៅទៀត។

ភ្លាមនោះ ធិតាតូចក៏ញញឹមឡើង ដោយមានទឹកភ្នែកនៅដក់ជាប់ផ្ទៃ មុខនៅឡើយ។ កវីក៏ហុចផ្កាទៅអោយនាងហើយពោលបន្តទៅទៀតថា :

- ណេះ! អូនណីយកផ្កានេះទៅ ព្រោះផ្កាដ៏ស្រស់ស្អាតនេះ នឹងនាំអោយ អូនសប្បាយចិត្តឡើងវិញមិនខាន។ អូហ៍ ពេលនេះ តើអូនណីចង់ស្តាប់បទ ចំរៀងមួយទេ? ចាំបងច្រៀងអោយស្តាប់ យ៉ាងម៉េចដែរ?

ភារាណីឮហើយយកដៃជូតទឹកភ្នែកហើយក៏ញញឹមឡើងភ្លាម :

- ចាស បើអញ្ជើងច្រៀងអោយពិរោះណាំបងកវី អូនណីចាំស្តាប់ !

ភ្លាមនោះ កវីក៏ច្រៀងបទមួយយ៉ាងពិរោះលួងលោមធិតាយើង ឱ្យ នាងភ្លេចអស់នូវក្តីកង្វល់ក្នុងចិត្តទាំងឡាយ ។

ស្រស់នោម

ស្រស់អើយស្រស់ស្អាតគួរបេតី ស្រស់តរុណីកែវវរមិត្រ
ញញឹមថ្នាល់ខួចលួចដួងចិត្ត អោយបងលង់ស្និទ្ធត្បិតពេញស្នេហ៍ ។
ស្រស់អើយស្រស់នោមកែវនិមល ស្រស់ល្អកាយកលភក្ត្រដូចខែ
កេសាវំសាយគួរថើបថៃ កែវភ្នែកមានស្នេហ៍សណ្តំអង្គ ។
ស្រស់អើយស្រស់ណាស់ម្ចាស់ទ័យា ស្រស់ស្រីពំងាល្អផូផង់
យល់ភក្ត្រស្រស់ភ្លាមហឫទ័យលង់ វិជ្ជលបេះដូងយោងកាមា ។
ស្រស់អើយស្រស់ស្រីទេពអប្សរ គន់យូរវិតល្អិតសោភា
រៀមលង់ស្នេហ៍ស្រស់អស់ទ័យា ភក្តីលុះគ្រាជីវិតបង់ ។

មួយស្របក់ក្រោយមក គេក៏បែកគ្នាទៅផ្ទះរៀងៗខ្លួន ។

ចំណងសម្ពន្ធ័ភាពរវាងអ្នកទាំងពីរក៏កាន់តែជិតស្និទ្ធឡើង កាន់តែរីក ចំរើនឡើង រហូតដល់ធិតាយើងចំរើនវ័យគំរប់១៦ឆ្នាំ ហើយត្រូវប្រលង បញ្ចប់មធ្យមសិក្សាផង ។ ចំណែកកវីវិញ មិនបានរៀនឆ្ងាយទេ ។ បន្ទាប់ពី ប្រលងជាប់បាក់ឌុបមក នាយក៏ចាប់ផ្តើមចេញរកស៊ី កាន់មុខជំនួញជំនួស ពូផលជាឪពុកធម៌រហូតមក ព្រោះគាត់មានជំងឺគ្រុនពោះវៀនហើយក៏ចូល អនិច្ចកម្មទៅ ចោលកវីអោយរស់នៅតែម្នាក់ឯង ។ ការពិត ចំណងទាក់ទង របស់នាយនិងភារាណីមិនមាននរណាដឹងច្រើនឡើយ ក្រៅតែពីមីងផាវជា ម្តាយប៉ុណ្ណោះដែលគាត់តែងតែស្រណោះអាណិតកវីតាំងពីគាត់ឃើញនាយ នៅថ្ងៃដំបូងមកម្ល៉េះ ។ ចំណែកអ្នកស្រុកដទៃ ហាក់ដូចជាត្រដរយកតែរស់ រៀងៗខ្លួន គ្មាននរណានឹកខ្វល់នឹងរឿងអ្វីដែលទាក់ទងនឹងកវីឡើយ ។ រីឯ សម្ពន្ធ័រវាងមេឃុំផែងនិងកវី ក៏ដាច់សូន្យ មិនមានទៅមកតាំងពីគេបែក ចេញពីមេឃុំទៅជាមួយម្តាយរបស់គេមកម្ល៉េះ ម្យ៉ាងដោយកវីខ្លាចមេឃុំ មិនហ៊ានទៅជិត ។ រីឯមេឃុំប្រកាន់ឫកជាឪពុក ក៏មិនព្រមស្រទន់ចិត្តខ្លះ អនុគ្រោះចំពោះកូន ម្ល៉ោះហើយ កូននិងឪពុកបង្កើតក៏ប្រែក្លាយជាអ្នកដទៃ ដោយស្វ័យប្រវត្តិ ។ ចំណែកភារាណី ដែលលួចចេញទៅមកជួបកវី ក៏ធ្វើ ឡើងដោយការលាក់ពីភ្នែកច្រមុះរបស់មេឃុំដែរ ត្បិតនៅម្តុំៗនោះ ចាស់ៗ ណាមួយក៏ដឹង ថាមេឃុំមានគំនុំប៉ុនណាចំពោះពូផលយើង ។ ដោយសារតែ ពាក្យចចាមអារាមដែលថា ពូផលបានលួចសហាយស្មន់នឹងមីងវ៉ាន់ ដែល ជាប្រពន្ធដើមរបស់មេឃុំផែង មនុស្សម្នាទាំងឡាយមិនសូវទៅមកនឹងពូ ផលទេ កាលពីគាត់នៅរស់ មិនដឹងថាជាគេស្អប់ពូផល ឬក៏គេខ្លាចបុណ្យ បារមីនិងភាពគំហកកំហែងរបស់មេឃុំឡើយ ។

នៅថ្ងៃមួយ...

ថ្ងៃនេះ កវីណាត់បបួលភារាណីទៅបណ្តែតប្រទីបនៅស្ទឹងសង្កែ។ គេ មិនបានដើរទៅជុំគ្នាទេ ព្បិតខ្លាចអ្នកស្រុកឃើញយកដំណឹងមកជំរាបមេឃុំ ផែង ម៉្លោះហើយក៏ណាត់ដើរផ្លូវផ្សេងគ្នា តែក៏ទៅជួបគ្នានៅមាត់ស្ទឹងតែ ម្តង។ ព្រលប់បន្តិច ភារាណីក៏បានមកដល់។ កាលបើប្រទះវត្តមានរបស់ ធិតាពេលណា កវីក៏ញញឹមឡើង :

- ភារាណី! ថ្ងៃនេះបងមានសេចក្តីសុខណាស់ ដែលបងបានមកបណ្តែត ប្រទីបជាមួយអូន។ អរគុណដែលអូនផ្តល់កិត្តិយសអោយបង។ ជាយូរមក ហើយដែលបងគិតថា លោកនេះធំធេងហើយរងាក្រៃលែង។ តែពេលនេះ បងមានអារម្មណ៍ថា ពិភពលោកមិនជារងាឯកាទេ កាលបើមានរូបអូន នៅក្បែរខ្លួនរបស់បង...

ធិតាក៏ញញឹមឡើងតបវិញ :

- ភារាណីក៏ដូចគ្នា។ ក្រៅតែពីម៉ែចេញ គ្មាននរណាយល់ចិត្តហើយថ្នាក់ថ្នម អូនអោយស្មើនឹងបងកវីរបស់ទេពអប្សរទួលចារនោះឡើយ។

ភ្លាមនោះ ធិតាក៏លូកដៃត្រកងប្រទីបដែលកវីបានតុបតែងធ្វើឡើង ដោយដៃនាយផ្ទាល់យ៉ាងស្រស់ប្រណិតនោះ រួចហើយក៏ស្រដីថា :

- ថ្ងៃនេះ យើងសូមផ្សងសច្ចាជាមួយគ្នា ព្រមគ្នាថា យើងទាំងពីរមិន បោះបង់ចោលគ្នាជាដាច់ខាត ទោះបីជានៅក្នុងកាលៈទេសៈណាក៏ដោយ។

- មែនហើយ! បងកវីសូមសច្ចាដូចគ្នាដែរថា បងមិនចោលភារាណីជា ដាច់ខាត មិនថាកាលៈទេសៈណាក៏ដោយ បងកវីនៅតែជាកវីរបស់ទេព អប្សរទួលចារជានិច្ច រហូតតរៀងទៅ...

បួងសួងចប់ អ្នកទាំងពីរក៏អោនបន្ទាបប្រទីបបណ្តែតទៅលើទឹកស្ទឹង ដែលកំពុងហូរទៅយ៉ាងខ្ជួលខ្ជាញ់ រួចហើយក៏ពោលព្រមគ្នាថា :

- សូមអោយយើងទាំងពីរបានជួបគ្នាជាគូគាប់ រួមរស់ប្រកបដោយសុភ មង្គលលុះអវសាននៃជីវិតរបស់យើង។

បន្ទាប់មក គេទាំងពីរក៏អង្គុយសម្លឹងតាមប្រទីបដែលអណ្តែតតាមខ្សែ ទឹកឆ្ងាយទៅៗ ទាំងទឹកមុខញញឹមបំព្រងហាក់ដូចជាកំពុងទទួលនូវសេចក្តី សុខយ៉ាងធំធេង។

មួយស្របក់ក្រោយមក កវីសួរធិតាយើងថា :

- អូនណី..! ពេលប្រលងជាប់បាក់ឌុបហើយ តើអូនបំរុងធ្វើអ្វីដែរ។

- ពុកម៉ែគាត់ថានឹងបញ្ជូនអូនអោយទៅរៀនបន្តនៅភ្នំពេញទៀត។

- ហ៊ឺ! បងច្បាស់ជានឹកអូនស្លាប់ហើយ។

- បងកុំព្រួយអី! ចាំអូនសរសេរសំបុត្រមកលេងបងអោយបានញឹកញាប់!

- ប៉ុន្តែ.. ទោះជាយ៉ាងណាក៏បងនៅតែនឹកអូនដដែលហ្នឹង។

- នៅសល់ច្រើនខែទៀតឯណោះ ទើបអូនចេញទៅភ្នំពេញ។ បងចាំបាច់ គេងខ្វល់អីនៅថ្ងៃនេះ នាំតែល្អក់អារម្មណ៍ទទេៗ។ ម៉ោះ! ច្រៀងអោយ អូន ស្តាប់វិញបានទេ? អូនចង់ស្តាប់សំនៀងបងណាស់...!

ពួសំដីប្រកបដោយមង្គលរបស់កល្យាណី កវីក៏ញញឹមឡើងហើយក៏ ស្រវាកាយធិតាអោយមកកើយលើស្មារបស់ខ្លួន រួចក៏បន្លឺសំនៀងយ៉ាង ក្រអូនឡើង ថ្នាក់ថ្នមគួស្នេហ៍ អោយវង្វេងនឹងភាពក្សេមក្សាន្តក្នុងដួងចិត្ត និងអារម្មណ៍។

រាត្រីក្សេមក្សាន្តចិត្ត

| | |
|---|---|
| ស្តាប់សៀងទឹកហូររលេញឆ្ងាយទៅ | សពសត្វច្រៀងនៅក្បៀកកើយគូវា |
| ហាក់តួរឿតន្ត្រីកំដរទ័យា | រៀមនិងពំងាស្នេហាបរិសុទ្ធ។ |
| ក្លិនផ្កាក្រអូបសាយជាប់នាសា | សុរិយ៉ាត្រាយាងអស្តង្គត |
| រីស្បៃអន្ធការលាតក្រាលដណ្តប់ | តែស្នេហ៍បរិសុទ្ធនៅភ្លឺត្រចង់។ |
| ជំនោរត្រជាក់ធ្លាក់មកពីជើង | កំដរស្នេហ៍យើងត្រកាលផូផង់ |
| ពពករសាត់កាត់មេឃថ្លាយង់ | ចន្ទ្រាពេញវង់យាងលោមលោកា។ |
| សន្សើមរោយស្បៃដណ្តប់ប្រថពី | គូគាប់នារីថ្នាក់ថ្នមកាយា |
| ញញឹមទទួលពរសាធុការ | រាត្រីសន្ធិយាពេញដោយមង្គល។ |

គេនៅអង្គុយសន្ទនាគ្នានូវភាសាដួងចិត្តយ៉ាងយូរ ទើបនាំគ្នាងើបដើរ ឡើងច្រាំងសំដៅទៅផ្ទះវិញ។ តែកវីមិនអស់ចិត្តសោះ ដែលនឹងត្រូវបែក ឃ្លាតពីគូសង្សារបណ្តូលចិត្តរបស់គេ។ ភ្លាមនោះ គេសុំដើរទៅជាមួយ ជូន ដំណើរធិតារហូតដល់មាត់របងផ្ទះ។ គ្រាន់តែដើរមកដល់ក្បែរមាត់របង ពេលណា ស្រាប់តែអ្នកទាំងបីបានឮសម្លេងមួយគំហកមកថា :

- នាងណើមកពីណាទាំងយប់ព្រលប់? ហើយចុះអាកម្លោះម្នាក់នេះ តើជា

នរណាដែរ?

កវីឮសំដីនៅភ្លាម ក៏ភ្ញាក់ភ័យប្រហោងពោះធ្លុងតែម្តង។ គេក៏លួច ខ្សិបទៅភារាណីតិចៗថា :

- ណើ! បងលាទៅវិញសិនហើយណា៎!

ថាហើយនាយក៏បោះជំហានចេញទៅយ៉ាងរហ័ស ស្រាប់តែ :

- នែ៎ អាអន្ទិតកម្លោះ! កុំអាលទៅណា! មកណេះសិន!

មាណពកម្លោះទុចង៉ក់ កាលបើឮពាក្យហៅឃាត់ តែក៏ភិតភ័យបែក ញើសជោគខ្នងតែម្តង។ ឃើញស្ថានការណ៍មិនស្រួល ភារាណីគេចចូលទៅ ក្នុងផ្ទះបាត់ទៅ ទុកអោយកវីនៅឈរទ្រឹងម្នាក់ឯងក្រៅរបង។ រំពេចនោះ មនុស្សចាស់ម្នាក់ក៏ដើរមកដល់។ ក្រោមពន្លឺភ្លើងអំពូលម៉ែត្រ មុខផ្ទះ កវីក៏ដឹងស្រេចហើយ ថាគាត់ជាមេឃុំផែង មិនអាចលាក់បាំងបានឡើយ។

កាលបើក្រលេកឃើញនាយកវី មេឃុំបើកភ្នែកធំៗ សួរថា :

- តើឯងជានរណា?

កវីឈ្ងោកមុខនៅស្ងៀមមិនហ៊ានស្រដីតបសោះ។ មេឃុំផែងក៏គំហក ថែមទៀតថា :

- ឯង គ ឬអ្វី បានជាមិនឮយើងសួរ?

- គឺ... គឺ.. ខ្ញុំ... គឺ...

- និយាយមិនរួចយ៉ាងនេះ ប្រាកដជាឯងធ្វើអីខុសហើយ!

- អត់ទេ.. គឺ... គឺ..

- ឯងឆ្លើយប្រាប់យើងមក៏ ថាឯងជានរណា? ហើយហេតុអ្វីបានជាស្គាល់ នាងភារាណីកូនស្រីរបស់យើង? តើឯងជាអ្នកភូមិម៉្លុំនេះដែរទេ? កូនចៅ អ្នកណាដែរ? ហេតុអ្វីបានជានាំគ្នាដើរយប់ព្រលប់ ដោយមិនខ្លាចចិត្តខ្លាច ថ្លើមមនុស្សចាស់យ៉ាងនេះ?

ឮមេឃុំសួររន្ថើនយ៉ាងនោះ កវី រិតតែភ័យខ្លាំងឡើងរហូតលែងហ៊ាន ឆ្លើយថាយ៉ាងម៉េច ។ ឃើញដូច្នោះ មេឃុំរិតតែស្រងាកចិត្តឡើងដែលគាត់ មិនអាចសម្លុតនាយ ឱ្យទំលាយការណ៍ប្រាប់អ្វីគាត់មួយម៉ាត់បានសោះ ។ បន្ទាប់មក គាត់ក៏យកដៃច្រានទ្រូងរបស់កវីសឹងផ្ងាកក្រោយ :

- នែ៎ យើងប្រាប់ឯងមុនចុះណា៎ ថា លើកក្រោយកុំអោយយើងឃើញឯង មករញ៉ីរញ៉ៃនឹងកូនស្រីរបស់យើងទៀត បើមិនដូច្នេះទេ ឯងប្រាកដជាឈឺ ខ្លួនហើយ!!

កវីឈ្ងោកមុខ អោនសំពះមេឃុំផែង ជំរាបលាលោកដើរចេញទៅវិញ យ៉ាងរហ័ស ។ មេឃុំផែងសម្លឹងមើលនាយតាមពីក្រោយ ហាក់ដូចមិនអស់ ចិត្តសោះឡើយ ដែលនាយមិនព្រមហើបមាត់អីមួយម៉ាត់ជាមួយមេឃុំ ។

យូរថ្ងៃកន្លងទៅ កវីតែងតែមករង់ចាំភារាណីនៅក្រោមដើមចារមួយ ដែលគេតែងណាត់ជួបគ្នារាល់ថ្ងៃអស់ជាយូរឆ្នាំមកហើយតែក៏មិនដែលបាន ឃើញនាងត្រលប់មកម្តងណាទៀតឡើយ តាំងពីថ្ងៃបណ្តែតប្រទីបជុំគ្នាជា មួយកល្យាណីនោះមក ។ ពេលនោះ មាណពគិតថា ប្រហែលជាមេឃុំរៀប ជើងព្រួល យាមធិតាយើងមិនអោយចេញទៅណាមកណាទៀតហើយ ទើបបានជាមិនឃើញនាងចេញមកជួបនាយដូចកាលពីដើម ។ តែ...ទោះបី ជាយ៉ាងណាក៏ដោយ ក៏យុវជនយើងនៅតែត្រលប់មកអង្គុយរង់ចាំធិតា របស់គេរាល់ថ្ងៃជានិច្ច នៅក្រោមដើមចារលើទួលកណ្តាលស្រែ តាមការ ដង្ហោយ ក្នុងបេះដូងរបស់គេមិនមានលោះមួយថ្ងៃណាឡើយ...

រង់ចាំ

| | |
|---|---|
| រង់ចាំ រង់ចាំ ស្រអាំស្រី | រង់ចាំគ្រាថ្មីអូនវិលវិញ |
| រង់ចាំទាំងចិត្តសោកទោម្នេញ | បេះដូងពោរពេញដោយកង្វល់ ។ |
| រង់ចាំ រង់ចាំ រាប់ឆ្នាំខែ | រង់ចាំមាសស្នេហ៍កែវនិមល |
| រង់ចាំដំណឹងទាំងអំពល់ | ទ្រូងអើយខ្វាយខ្វល់នឹកម្ចាស់ចិត្ត ។ |
| រង់ចាំ រង់ចាំ តាមសន្យា | ចាំមុំធិតាស្រស់វរមិត្រ |

រង់ចាំទាំងទ្រូងលង់វិបរិត ចាំម្ចាស់ជីវិតអូនវិលវៃ ។
រង់ចាំ រង់ចាំ ស្ងាត់ដំណឹង តើពៅព្រលឹងវិលទៅថ្ងៃ
រង់ចាំជានិច្ចណាំចរណៃ លុះជីវិតក្ស័យក៏នៅតែចាំ...

000000000000000

00000

0

# វគ្គទី៩
# ទ្រុស្តមិត្ត

រសៀលថ្ងៃអាទិត្យមួយ...

កវីនៅអង្គុយក្រោមដើមចារលើជីទួល ដែលនាយតែងណាត់ជួបគ្នាជា មួយភារាណី នៅដៃមានកាន់ប៉ាកកាសៀវភៅទំនងកំពុងសរសេរនិពន្ធបទ អ្វីមួយតែម្នាក់ឯង ស្រាប់តែនាយយើងឮសូរសម្រិបជើងមកដល់ជិតខ្លួន។ មាណពងើបមុខឡើងងើយមើលទៅ ក៏ប្រទះនឹងវត្តមានរបស់ទេពអប្សរ ម្ចាស់ចិត្ត ដែលគេកំពុងរង់ចាំច្រើនអាទិត្យមកហើយ។

- អូនណី!

កវីហក់ស្ទុះទៅស្រវាអោបកាយរបស់នាងដោយក្តីនឹករលឹកឥតឧបមា រកវាចាថ្លែងមិនត្រូវឡើយ។ ភារាណីក៏ស្រវាអោបនាយវិញ សម្រក់ទឹក ភ្នែកយំខ្សឹកខ្សួលឡើងយ៉ាងសង្វេគ :

- អូនណី.. មានរឿងអីហ្នឹងអូន?

ធិតាក៏ស្រវាទាញក្រមាដែលនាងទទូរចេញពីក្បាលភ្លាម ស្រាប់តែកវីប្រទះឃើញស្នាមជាំនៅលើថ្ពាល់ទាំងសងខាងរបស់ធិតា។ នាយយើងភ្ញាក់ ក្រញាង រួចឧទានថា :

- ស្លាប់ហើយ! តើនរណាចិត្តអាក្រក់ធ្វើបាបអូនដល់ម្លឹង?

ភារាណីល្ញោកមុខក្រាបនៅលើដើមទ្រូងរបស់កវី យំខ្សឹកខ្សួលសាជា ថ្មី។ ភ្លាមនោះកវីក៏សង្កេតឃើញស្នាមជាំលើដៃរបស់នាងពីរបីកន្លែងទៀត ម្តងនេះ នាយទ្រាំលែងបានហើយ។ នាយក៏សួរនាងយ៉ាងរន្ធើនថា :

- អូនណី! ប្រាប់បងមក៏ ថានរណាមានចិត្តយង់ឃ្នងធ្វើបាបរូបអូន? ប្រាប់ បងមក៏... នរណាគេទះកំផ្លៀងអូន?

ធិតាងើបមុខឡើងហើយឆ្លើយទាំងអណ្តឹតអណ្តក់ ថា:

- គឺ.. ខ្ញុំលួចចេញមកក្រៅ ដើម្បីមករកបងកវី តែត្រូវពុកគាត់ចាប់ទាន់ហើយអូនក៏ត្រូវទណ្ឌកម្មដែលអូនមិនគោរពតាមបញ្ជារបស់គាត់...

កវីសម្លឹងមុខធិតា សម្តែងការឈឺចាប់ជំនួសមាណវីដ៏តូចច្រឡឹងមួយ
រូបដែលត្រូវរងអំពើហឹង្សាកំហែងកំហល់របស់មេឃុំផែង។ គេញាប់ញ័រ ក្នុងចិត្តនឹកអាណិតរូបនាងរហូតដល់រលីងរលោងទឹកភ្នែក។ ភ្លាមនោះ គេក៏សួរនាងទៀតថា :

- ចុះ ម្តាយរបស់អូន.. ហេតុអីមិនជួយឃាត់គាត់ផង?

- ម៉ែប្រឹងឃាត់រហូតត្រូវកំភ្លៀងយ៉ាងធ្ងន់ដូចគ្នា ហើយគាត់ក៏នាំខ្ញុំទៅជ្រក នៅឯវត្តជាមួយដូនជី ដើម្បីចៀសអំពើហឹង្សានេះ។

- ពុទ្ធោ! អូនណីព្រលឹងមាសបង! ហេតុអ្វីក៏ជីវិតអូនត្រូវមករងគ្រោះបែប
នេះផង? បងមិនសុខចិត្តទេ.. បងមិនសុខចិត្តអោយនរណាធ្វើបាបអូន យ៉ាងនេះទេ... ម៉ោះ! អូនទៅជាមួយបង
បងនឹងតវ៉ាអោយដឹងសាច់រឿង នឹងគ្នាម្តង។

ថាហើយ មាណពក៏អូសដៃភារាណីរឹងទៅយ៉ាងលឿន។

- បងអូសដៃខ្ញុំទៅណាហ្នឹង? ( ធិតាយើងសួរទាំងភន្ត័ភាំង )

- ទៅតវ៉ានឹងមេឃុំដែលមានចិត្តព្រៃផ្សៃម្នាក់នោះ!

- អត់ទេ! អូនមិនទៅទេ.. អូនមិនទៅជាដាច់ខាត... អូនខ្លាច អូនមិនទៅ ទេ បងកវី...

- មានបងហើយ.. អូនកុំខ្លាចអី.. បងហ៊ានប្តូរជីវិតដើម្បីរកយុត្តិធម៌អោយ អូនណាំភារាណី!

កវីស្រដីផង អូសដៃភារាណីផង រហូតដល់មុខផ្ទះមេឃុំផែង។ រំពេច នោះ មេឃុំក៏ដើរចេញមកដល់។
លុះឃើញវត្តមានអ្នកទាំងពីរកាលណា គាត់ក៏ស្រែកឡើងខ្លាំងៗថា :

- មកហើយឬ នាយមេភ្លើង? ឯងពិតជាភ្លើង ដែលដុតរោលក្នុងគ្រួសារ របស់យើងអោយរលាកគ្រប់គ្នាមែន!!

កវីសម្លឹងមុខមេឃុំផែងជាលើកដំបូង តាំងពីនាយបោះជំហានពីផ្ទះ នេះទៅកាលពីជាងដប់ឆ្នាំមុន រួចហើយក៏ស្រដីតបវិញថា :

- ពុកមេឃុំមានប្រសាសន៍ខុសហើយ.. ភ្លើងដែលកំពុងដុតរោលក្នុង គ្រួសាររបស់ពុកមេឃុំ  មិនមែនមានប្រភពមកពីខ្ញុំទេ។ ពុកក៏ជ្រាបរឿង
នេះស្រេចទៅហើយ ថាភ្លើងនោះមានប្រភពនៅត្រង់ណា មិនមែនទេ?

- នរណាជាពុករបស់ឯង នាយមេភ្លើង? ម៉េច? ឃើញយើងមានកូនស្រី ស្រស់ស្អាត បន្លំហៅយើងថាពុកផងហ្អែស? ថ្លើមធំណាស់! ហ៊ានផ្តើនចិត្ត យើងដោយមិនខ្លាចរអា...!

- ពុកមេឃុំមានពិរោធខ្លាំងណាស់ រហូតដល់ពុកលែងស្គាល់កូនចៅខ្លួនឯង អស់ហើយ... ហេតុអ្វីបានពុកយកអំពើហឹង្សាជាត្រីមុខ សំរាប់ប្រដៅកូន ចៅរបស់ពុកយ៉ាងនេះ?

- ឯងចង់ប្រដៅយើងផង អាច្រមក់មិនទាន់ជ្រុះពន្លៃពីក្បាល?

ផាំង! មេឃុំផែងលើកដៃទះកំភ្លៀងមាណព។

- មនុស្សព្រហើនដូចឯងមិនសមនឹងធ្វើកូនចៅយើងទេ.. កុំហៅយើងថា ពុកទៀត! ( មេឃុំគំហក)

- មែនហើយ.. មិនអោយខ្ញុំហៅថាពុកក៏បាន វាយដំរូបខ្ញុំយ៉ាងណាក៏បាន.. ប៉ុន្តែ... អោយខ្ញុំសុំរឿងមួយបានទេ? គឺពុកមិនត្រូវយារដៃធ្វើបាបកូនស្រី របស់ពុកដ៏ទន់ខ្សោយម្នាក់នេះទេ...

- យ៉ស! ចេញមុខការពារគ្នាផងហ្អែស?.. សារភាពហើយមែនទេ ថាឯង ពិតជាលួចលូកថ្លើមយើងពីក្រោយខ្នង..?

ផាំង! មេឃុំទះកំភ្លៀងកវីមួយដៃទៀតយ៉ាងអស់ទំហឹង ។

- នេះនែ៎ អោយសមមុខអាក្មេងមុខរឹង សំដីរឹង! (មេឃុំគំហកបន្ថែម)

មាណពយើងដួលទៅដីប្រូស ហូរឈាមពីមាត់រឹម១ ។ ភារាណីឃើញ ហើយក៏ស្ទុះទៅទាញដៃឪពុក ឃាត់មិនអោយគាត់សំដែងកិរិយាកាចយង់ឃ្នងតទៅទៀត :

- ពុក! អោយកូនសូមអង្វរចុះ.. ប៉ុណ្ណឹងបានហើយ! កុំវាយដំគេអី..!

- នែ៎ ចៀសចេញកូនចង្រៃមិនស្តាប់ម៉ែឪ!

មេឃុំយកជើងកៀសភារាណីអោយដួលទៅម្ខាង ហើយក៏ស្រវាចាប់ សក់នាយកវីភ្ញើយមុខឡើង ថែមទាំងស្រដីថា :

- មួយជីវិតយើងនេះ មិនដែលមាននរណាហ៊ានចេញមុខតវ៉ាសំដីធំតូចជា មួយយើង ដូចរូបឯងនេះឡើយ ។ ដឹងទេ ថាយើងគួរដាក់ទោសឯងយ៉ាង ណា អាក្មេងមិនស្គាល់ចាស់?

មេឃុំផែងក៏ទាត់មាណពពីរបីជើងថែមទៀត ស្ទើរតែទ្រោមខ្លួនស្លាប់ ស្រាប់តែមាណពងើបឡើង ញញឹមសម្លឹងមុខមេឃុំហើយស្រដីថា :

- ខ្ញុំអាចទទួលរងទណ្ឌកម្មពីពុកមេឃុំប៉ុនណាក៏បានដែរ... ខ្ញុំយល់ព្រម! តែសូមពុកត្រូវសន្យានឹងខ្ញុំសិនមក៏.. ថាពុកមេឃុំនឹងឈប់ប្រើហឹង្សាទៅ លើ ភារាណីកូនស្រីរបស់ពុកតទៅទៀត...

- អឺ.. យើងសន្យាក៏បាន... តែឯងត្រូវតែសន្យាដែរ.. ថាឯងឈប់មករញ៉ិ រញ៉ៃនឹងកូនស្រីយើងតទៅទៀតដូចគ្នា ។ គេជាកូនស្រីដែលមានកិត្តិយស មានត្រកូល ត្រូវរក្សាការររៀនសូត្រដើម្បីអនាគតល្អ.. ឯងមិនត្រូវនាំគេ ធ្លាក់ភក់ធ្លាក់ជ្រាំជាមួយជីវិតក្រីក្ររបស់ឯងនោះឡើយ...

កវីបែរមើលទៅភារាណីមួយស្របក់ក៏ពោលថា :

- ដើម្បីសេចក្តីសុខនិងសុវត្ថិភាពរបស់នាង.. កវីសូមសន្យាជូនពុកមេឃុំ ថ្ងៃនេះ ថាមិននាំភារាណីអោយធ្លាក់ភក់ធ្លាក់ជ្រាំក្នុងជីវិតឡើយ!

ថាហើយ កវីក៏ក្រាបក្បាលដល់ដីសំពះមេឃុំផែង ធ្វើអោយមេឃុំភ្ញាក់ ក្រញាងដែលនាយធ្វើដូច្នោះ ។ ភារាណីរន្ធត់ចិត្តណាស់ដែលនាងឃើញកវី សុខចិត្តលះបង់រូបនាងអោយត្រលប់មកក្រុមគ្រួសារវិញ ដើម្បីរក្សាសុវត្ថិ ភាពនិងសេចក្តីសុខអោយនាង ។ កល្យាណីយើងស្ទុះទៅជិតស្រវាអោបកវី ហើយស្រដីថា :

- បងកវី.. បងមិនបាច់ធ្វើដល់ម្លឹងទេ.. បើធ្វើយ៉ាងនេះ គឺមានន័យថា បង កាត់ផ្តាច់និស្ស័យរវាងបងនិងភារាណីហើយ! អូនមិនព្រមទេ.. មិនព្រម បាត់បង់រូបបងទេ.. បងកវី...

- ថយចេញនាងណើ!

ពុកមេឃុំគំហកផង យកដៃទាញភារាណើពីមាណពយើងផង :

- នាងណើ! បើមិនចង់ឈឺខ្លួន... ឆាប់ឡើងទៅលើផ្ទះភ្លាម ឮហើយនៅ?

កាលបើឃើញមេឃុំផែងគំហកកំហែងភារាណើ មាណពក៏ក្រោកឈរ ឡើងហើយស្រដីថា :

- ពុកមេឃុំបានសន្យានឹងខ្ញុំហើយថា នឹងឈប់ធ្វើទារុណកម្មអូនណើ នៅ ពេលណាដែលខ្ញុំដើរចេញពីជីវិតរបស់នាង។ ឥលូវនេះ ខ្ញុំសូមធ្វើតាម សន្យាជូនពុកមេឃុំពេលឥលូវនេះ។ សូមមេត្តាដោះលែងអូនណើតាម សន្យារបស់ពុកផង!

ថាហើយ មាណពក៏លើកដៃសំពះលាមេឃុំផែង ហើយឈ្ងោកមុខដើរ ចេញទៅ ទាំងទុរន់ទុរាកាយា។ ភារាណើសម្លឹងមើលកម្លោះយើងពីក្រោយ ទាំងឱរាខ្សឹកខ្សួលក្រៃលែង។ ចំណែកពូមេឃុំវិញ មុនដំបូងហាក់ដូចជា មានអារម្មណ៍ល្អ ដែលគាត់សម្លុតក្មេងអោយធ្វើតាមបញ្ជាបានយ៉ាងជោគ ជ័យ រួចស្រាប់តែមានអារម្មណ៍ថា បេះដូងរបស់គាត់បានទទួលអារម្មណ៍ ឈឺចាប់យ៉ាងចម្លែកយ៉ាងណាមិនដឹង កាលបើឃើញមាណពឈានដើរ ចេញទៅទាំងឈាមមាត់ ទុរន់ទុរាកាយ។ មែនហើយ ហេតុដូចម្តេច ដែលពីដើមមិញ មេឃុំធ្លាប់តែមានសន្តានចិត្តចំពោះញាតិទាំងឡាយ ឥលូវ គាត់បែរជាមិនអត់អោនអោយ សូម្បីតែក្មេងប្រុសកម្លោះម្នាក់ ដែលមិន ទាន់បានធ្វើអ្វីខុសសោះ ក្រៅតែពីគេមិនមាត់មិនកឆ្លើយតបមករកគាត់ កាលពីថ្ងៃមុននោះ ពេលគាត់ឃើញគេដើរជជែកគ្នាជាមួយកូនស្រី? តើ ទោសប៉ុនហ្នឹងល្មមដល់ថ្នាក់ប្រើហឹង្សា វាយដំដូចដែលមេឃុំធ្វើថ្ងៃនេះដែរ ទេ? មើលទៅក្មេងម្នាក់នោះ ក៏ហាក់ដូចជាគ្មានពិសពុលអ្វីគួរអោយបារម្ភ ដែរ។ តែហេតុដូចម្តេចបានជាគាត់ប្រើហឹង្សាទៅលើគេ.. ដើម្បីយកឈ្នះ? ប៉ុន្តែ គាត់យកឈ្នះដើម្បីអ្វី?

នៅរាត្រីនោះ មេឃុំផែងសំរាន្តគងថ្ងាសមួយយប់ទាល់ភ្លឺ នឹកពីភាល់ ក្នុងចិត្តមិនអស់មិនហើយ ហើយនឹកមិនយល់សោះ ថាហេតុអ្វីបានជាគាត់ ត្រូវមកជំពាក់ចិត្ត ជំពាក់អារម្មណ៍គិតដល់ក្មេងប្រុសកំលោះម្នាក់នេះម្ល៉េះ? ច្រើនថ្ងៃកន្លងទៅ... ភារាណើក៏សង្កេតឃើញថា មេឃុំផែងហាក់ដូចជាមាន កិរិយាស្ងាត់ស្ងៀមចម្លែកខុសធម្មតា។ មិនតែប៉ុណ្ណោះ គាត់ក៏បានទៅវត្ត អង្វរហៅមីងផាវអោយត្រលប់មកផ្ទះទៀតផង ចៃដន្យ មុននឹងមីងស្មគ្រ័ ចិត្តត្រលប់មកផ្ទះវិញ គាត់បានដាក់កំហិតអោយមេឃុំផែងស្បថស្បែនៅ មុខព្រះពុទ្ធបដិមារ ថាគាត់ឈប់ប្រើអំពើហឹង្សាលើប្រពន្ធកូនតទៅទៀត។ ដោយក្តីទាល់ច្រក ណាមួយកំពុងតែលង់ ក្នុងភាពកណ្តោចកណ្តែងក្នុងចិត្ត យ៉ាងណាមិនដឹង មេឃុំផែងក៏សុខចិត្តអុជធូបស្បថបំពេញកិច្ចជូនមីងផាវ ដើម្បីអោយគាត់ត្រលប់មកផ្ទះរស់នៅជាក្រុមគ្រួសារដូចធម្មតាវិញ។

ថ្ងៃខែចេះតែកន្លងទៅ...

ភារាណើខ្លាចឪពុកតាមធ្វើទារុណកម្មចំពោះកវី ក៏សំរេចចិត្តមិនទៅជួប កវីទៀតដូចកាលពីមុនឡើយ ថ្វីបើនាងកំពុងតែរងសេចក្តីនឹករលឹកក្នុងចិត្ត ចំពោះនាយយ៉ាងណាក៏ដោយ។ មីងផាវឃើញកូនស្រីចេះតែស្គមទៅៗ ដោយការព្រួយចិត្តនឹករលឹកកវី ក៏តែងតែបន្ទើបន្ទប់នាងដោយប្រការ ផ្សេងៗ ប៉ុន្តែ..

ទោះជាយ៉ាងណាក៏ធិតានៅតែស្រពាប់ស្រពោនដដែល ។ ក្រោយមក មីងផាវក៏បែកប្រាជ្ញអោយរតនានិងដាវ៉ាន់ជាមិត្តនាំធិតាចេញទៅដើរកំសាន្តអារម្មណ៍ក្រៅផ្ទះម្តងម្កាល ដើម្បីកុំអោយនាងគេងអោប ទុក្ខព្រួយច្រើនពេក ។

ថ្ងៃមួយ...

រតនាបានសូមភារាណីអោយមកឌុបនាងទៅរៀនរាល់ថ្ងៃ ត្បិតអីម៉ូតូ របស់នាងខូចមិនទាន់ជួលជុល ។ ថ្ងៃនេះចេញពីសាលា ភារាណីក៏ឌុបរតនា ត្រលប់ទៅផ្ទះដូចធម្មតា ស្រាប់តែមានសិស្សប្រុសកម្លោះពីរនាក់ជិះម៉ូតូថ្មី ស្រឡាងយ៉ាងសង្ហាមួយចេញពីច្រកទ្វារសាលាមកដល់ទន្ទឹមនឹងធិតាទាំង ពីរនាក់ ។ សិស្សកម្លោះដែលនៅជិះពីក្រោយ បានយកដៃទៅទះហើយ អង្អែលត្រគាករបស់រតនាដែលនៅជិះពីក្រោយភារាណី រួចហើយសើច ក្អាកក្អាយយ៉ាងព្រហើន ធ្វើអោយរតនាខឹងឡើងស្រក់ទឹកភ្នែកតែម្តង ។ បន្ទាប់មកគេក៏បរម៉ូតូចេញទៅយ៉ាងលឿន ថែមទាំងធ្វើមុខធ្វើមាត់ដូច ស្វាដាក់ទៅរតនានឹងភារាណីផង ។

- រតនា! ចាំយើងទៅប្តឹងលោកគ្រូអោយណា៎! ខ្ញុំអាចធ្វើជាសាក្សីបាន!

រតនាយកដៃជូតទឹកភ្នែកហើយឆ្លើយថា :

- ជារឿងអាស្រូវបែបនេះ ប្តឹងយ៉ាងម៉េច.. អ្នកស្រុកគេមិនសើចយំយើង ទៅហើយទេ?

- ម៉េចបានជាខ្លាចការសើចយំផង កាលបើយើងជាជនរងគ្រោះ? បុគ្គល ដែលគួរអោយសង្គមសើចចំអកហើយដាក់ទោសនោះ ជាពួកវាតើហ៎ គឺពួកដែលប្រព្រឹត្តអាស្រូវលើគេលើឯងនេះអី ។ ព្រោះតែឯងមានគំនិត យ៉ាងដូច្នេះហើយ បានជាពពួកជនពាលាបែបនោះវាបានចិត្តត្បិតវាគិតថា អ្នករងគ្រោះមិនហ៊ានចេញមុខបកអាក្រាតអំពើពាលរបស់វា ។

- ណ្ហើយ ចាំដល់រឿងអាស្រូវវាកើតចំពោះឯង ចាំឯងទៅបកអាក្រាតវា ទៅ ។ ចំពោះខ្ញុំ.. ខ្ញុំមិនមានសេចក្តីក្លាហានដូចឯងទេ ។

ភារាណីគ្រវីក្បាលហួសចិត្តចំពោះមិត្តរបស់ខ្លួនដែលមានចិត្តយ៉ាងទន់ ខ្សោយ ។ នាងក៏ឆ្លើយថា :

- មែនហើយ! បើសិនរូបខ្ញុំជាឯងវិញ គ្នាច្បាស់ជាមិនទុកបណ្តោយអោយ ជនពាលវារួចខ្លួនងាយៗទេ ។

ច្រើនថ្ងៃកន្លងទៅ...

ពេលវេលានោះជារដូវចម្រូត ។ ថ្ងៃនេះជាថ្ងៃអាទិត្យ ភារាណីអផ្សុក ពេកក៏បបួលរតនាទៅលេងស្រែ មើលអ្នកស្រុកច្រូតស្រូវ ហើយក៏ចុះទៅ ជួយគេមួយដៃមួយជើងដែរទៅដើម្បីកំដរបរិយាកាស ។កំពុងតែឱនងើបៗ នៅក្នុងស្រែ ស្រាប់តែរតនាដាក់ភ្នែកទៅកូនខ្ទមមួយ ដែលនៅឯវាលមាត់ បឹងមិនឆ្ងាយពីស្រែនោះប៉ុន្មាន ក៏ប្រទះនឹងមាណពរូបសង្ហាមួយរូបអង្គុយ កាន់មុងដផ្កាស្មៅមួយ លួចសម្លឹងមកម្តុំស្រែដែលអ្នកទាំងពីរកំពុងច្រូតនេះ ។ រតនាហាក់ដូចជាចាប់អារម្មណ៍ចំពោះភាពសង្ហារបស់គេណាស់ ថ្វីត្បិតតែ គេស្លៀកពាក់របៀបអ្នកភូមិសាមញ្ញធម្មតាៗក៏ដោយ ។ នៅរៀងរាល់ដង ដែលនាងលួចដាក់ភ្នែកសម្លឹងមើលទៅ ឃើញតែក្រសែភ្នែករបស់នាយ សម្លឹងត្រលប់មកវិញដូចគ្នា ក៏នឹកក្នុងចិត្តថាប្រហែលជាមាណពសម្លឹងនាង ហើយ ។ បន្តិចមក នាងក៏យកលេសថាចង់សម្រាកបន្តិច ហើយក៏ដើរឡើង ពីស្រែ សំដៅទៅខ្ទមស្រែមួយនោះ ។ ចៃដន្យ ពេលនាងដើរទៅដល់

មាណពបានដើរចេញពីខ្ទមនោះទៅហើយថែមទាំងទុកចោលនូវម្កុដផ្កាស្មៅ មួយនៅលើរនាបឫស្សី ក្នុងខ្ទមនោះទៀតផង។ មួយស្របក់ក្រោយមក

ភារាណីក៏ឡើងពីស្រែមកតាមរតនាហួតដល់ខ្ទម ហើយវាចាទៅនាងថា:

- រតនា! មកអង្គុយភ្លឹកអារម្មណ៍អីនៅទីនេះ? ម៉េចហើយ សប្បាយចិត្ត នឹងទេសភាពស្រុកស្រែរហូតភ្លេចដកជង្ហើមហើយមែនទេ?

ពួសំដីរបស់ភារាណីភ្លាម រតនាក៏ភ្ញាក់ព្រើត ឆ្លើយវិញថា :

- អូហ៎ អត់ទេ... មកពីគ្នាហេវបាយតើហ៎...

រតនាស្រដីតិច១ មិនហ៊ានទំលាយអារម្មណ៍ផ្ទាល់របស់ខ្លួនអោយមិត្ត នាងបានដឹងទេ។ ភ្លាមនោះ រតនាដើរទៅស្រវាយកដៃស្រវាចាប់ម្កុដផ្កា ស្មៅនោះឡើងមកមើល ស្រាប់តែភារាណីលាន់មាត់ថា :

- បងកវី?

រួចហើយភារាណីក៏ស្ទុះទៅទាញយកម្កុដផ្កាស្មៅពីដៃរតនា ហើយរត់ ចេញពីខ្ទមរកមើលកវីនៅម្តុំ១នោះ តែកវីបានចេញទៅបាត់ស្រមោលទៅ ហើយ មិនឃើញនាយនៅជិត១នោះទៀតទេ។ មែនហើយ! អាល័យតែ ច្រូតផង ជជែកលេងជាមួយអ្នកស្រុកផង ធិតាយើងមិនបានចាប់ភ្លឹកនឹង វត្តមានរបស់កវីកំពូលដួងចិត្តរបស់នាងនៅម្តុំ១នោះទេ។ ភ្លាមនោះមាណវី ក៏លើកម្កុដផ្កាស្មៅនោះឡើងសម្លឹងមើលទាំងទឹកភ្នែករលីងរលោង។ កាល បើឃើញកិរិយាដ៏ចម្លែករបស់មិត្ត រតនាក៏សួរឡើងថា :

- អេហ៎ ណី.. ឯងមានរឿងអ្វីហ្នឹង បានជាស្រក់ទឹកភ្នែក?

តែភារាណីមិនឆ្លើយទេ បែរជាដាក់ខ្លួនអង្គុយឈ្ងោកមុខធ្វើមុខ ស្រងូត លែងរីករាយដូចកាលពីព្រឹកមិញទៀតឡើយ។ រតនាមិនអស់ចិត្ត គេក៏សួរនាងបន្ថែមថា :

- បុរសសង្ហាម្នាក់នោះជាសង្សាររបស់ឯងមែនទេហ៎?

ស្រាប់តែភារាណីងើបឡើងសួរវិញយ៉ាងរហ័ស :

- ឯងឃើញគេនៅទីនេះមែនទេ?

- មែន... តែគ្នាឃើញគេដើរចេញទៅតាំងពីយូរមកហើយ!

ភារាណីក៏ឈ្ងោកមុខស្រងូតស្រងាត់សាជាថ្មីម្តងទៀត។ រតនាក៏លែង ហ៊ានមាត់ហ៊ានស្តីតទៅទៀត ឡិតខ្លាចនាំអោយមិត្តរបស់ខ្លួនមានអារម្មណ៍ កាន់តែយ៉ាប់ថែមទៀត។ បន្តិចមក អ្នកទាំងពីរក៏ដើរត្រលប់សំដៅទៅផ្ទះ វិញ ដោយស្ងៀមស្ងាត់មិនឃើញស្រដីសន្ទនាគ្នាអ្វីតទៅទៀតឡើយ។

ព្រឹកស្អែកឡើង...

នៅវិទ្យាល័យនេតយ៉ង់...

រតនានិងភារាណីដើរដឹកដៃគ្នាឡើងកាំជណ្ដើរទៅថ្នាក់រៀន ស្រាប់តែ សិស្សកម្លោះពីរនាក់ដែលគេជួបពីថ្ងៃមុន នាំគ្នាមកដើរប្រជែងប្រជ្រៀត អ្នកទាំងពីរ យកខ្លួនគេមកត្រដុសរាងកាយរបស់សិស្សនារីយើង ធ្វើអោយ នារីទឹកខឹងខកចិត្តយ៉ាងខ្លាំង ។ បន្ទាប់មក សិស្សយុវជនពីររូបនេះ ដើរធ្វើ ឆីយចេញទៅទាំងមុខខ្ញាញ់ ។ រតនាលាន់មាត់ឡើង :

- នាយហារិន! នាយអរុណ! អោយល្មម១បានហើយ! ទីនេះជាសាលា រៀនណា៎ មិនមែនកន្លែងរកស៊ីផ្ដេសផ្ដាសទេ ។ ល្មមស្គាល់កាលៈទេសៈផង!

តែក្មេងកំលោះទាំងពីរនោះ នៅតែមុខខ្ញាញ់ដដែល ។ ឃើញដូច្នោះ ភារាណីរត់រឹងសំដៅទៅការិយាល័យសាលាជំរាបគ្រូភ្លាម ។ លុះលោកគ្រូ អនុរក្សមួយរូបមកដល់ អ្នកទាំងបីបានបំបែកជួរអស់ទៅហើយ ។ ថ្ងៃត្រង់ ចេញពីសាលា នាយហារិននិងនាយអារុណដើរជើងម៉ូតូប្រឆាបក្បែររតនា ដែលកំពុងដើរដឹកម៉ូត ឱ្យភារាណីដើរពីក្រោយចេញពីបរិវេណសាលា :

- ស្រស់ស្អាតយ៉ាងនេះ មិនគួរថ្លើមធំ ប្ដឹងគ្នាឯងសោះ (នាយហារិនហើប មាត់និយាយបញ្ឆោះអោយភារាណី) យើងរៀនជាមួយគ្នា គួរណាស់តែ ស្គាល់ចិត្តគ្នា បែរជាតាំងខ្លួនជាសត្រូវទៅវិញ ។

- នរណាជាមិត្តរបស់ឯង ហារិន? (រតនាគំហក)

- គឺអូនទាំងពីរហ្នឹងណា៎ បើមិនមែនជាមិត្ត តើជាអ្វីទៅវិញ? ជាសង្សារឬ? ណ្ហើយ!... ជាសង្សារក៏បានដែរ បងព្រម!

- តែផ្ដាស! កុំនិយាយឈ្លើយយ៉ាងនេះ ហារិន!

- យី! គេខំស្រលាញ់ខ្លួនយ៉ាងនេះទៅហើយ នៅមើលងាយទៀត តិចចាប់ ថើបកណ្ដាលផ្លូវតែលូវហ្នឹង..!

ហារិនថាផង យកដៃលូកបិចថ្ពាល់រតនាផង ។ ស្រាប់តែភារណីចាប់ ដៃនាយជាប់ ហើយមួលដៃនាយកាច់ទៅក្រោយ ព្រមទាំងស្រដីថា :

- មាត់និយាយបាន តែដៃកុំលូក ប្រយត្ន័យើងមួលដាច់ខានប្រើ!

ហារិនឈឺណាស់ ត្បិតមិនបានប្រុងខ្លួនត្រូវភារាណីបំបាក់មុខបានយ៉ាង នោះ ។ ភ្លាមនោះ គេខំប្រឹងរលាស់ដកដៃវិញយ៉ាងខ្លាំង :

- នាងភារាណី! ចេះហៃហៃស៊ីដែរ? យើងមិនបានញ៉ៃនាងឯណា?

- តែក៏ឯងមានកិរិយាមិនសមរម្យលើសិស្សនារីក្នុងរង្វង់ជីសាលា!

- វាស្រេចតែក្បាលរបស់យើង.. ចេះដឹងអីដែរ?

- ចឹមិនចេះ បើរតនាជាមិត្តរបស់យើង!

- អឺ.. ការពារគ្នាទៅ... ថ្ងៃក្រោយនាងគង់ដឹងទេ តិចថាយើងមិនប្រាប់!

ថាហើយ នាយហារិនហក់ឡើងម៉ូតូជាមួយពួកម៉ាកទៅបាត់ ។ រតនាក៏ បែរមកប្រាប់មិត្តថា :

- ណីឯង! កុំសូវលូកដៃលូកជើងជាមួយពួកហ្នឹងពេក ប្រយត្ន័ពួកវាតាម សងសឹកណា៎! ម្យ៉ាងទៀតពួកវាជាកូនចៅរបស់មន្ត្រីជាន់ខ្ពស់ ហើយខ្ញុំធ្លាប់ ឮថាពួក វាទទួលថ្នាំញៀនផង តិចលោវា...

- អេហ៏.. រតនា! កុំគិតអ្វីអពមង្គលពេកមើល..! តោះទៅផ្ទះ ។

ថាហើយ ភារាណីក៏ស្រវាចាប់ម៉ូតូបញ្ឆេះ ទុកអោយរតនាឡើងជិះពីក្រោយវិញម្តង ។

នៅអាទិត្យបន្ទាប់ៗមក....

រៀងរាល់ថ្ងៃអាទិត្យ ភារាណីតែងទទូចអោយរតនាមកលេងនាងរួច ហើយនាំគ្នាទៅស្រែមើលអ្នកស្រុកច្រូតស្រូវ ។ ពេលនោះ រតនាដឹងក្នុងចិត្ត ស្រេចហើយថា ភារាណីកំពុងរកលេសទៅជួបម្ចាស់ចិត្តរបស់គេ ។ នាងក៏ សង្កេតឃើញដែរថា មេឃុំផែងក៏ហួងហែងភារាណីណាស់ដែរ មិនងាយឱ្យ ចេញទៅណាមកណាទេ តែដោយឃើញរតនាតែងទៅណាមកណាជាមួយ ភារាណីជានិច្ច មេឃុំក៏ចេះតែបណ្តោយៗនាងខ្លះៗទៅ ។

ភារាណីបាននាំរតនាមកដល់ទួលចារ ដែលនាងតែងតែណាត់ស្កាត់ជួប កវីតាំងពីក្មេងរហូតដល់ពេញវ័យរៀងខ្លួន ។ ប៉ុន្តែ គួរអាណិតធិតាណាស់ នៅរៀងរាល់ដងដែលនាងនាំរតនាទៅដល់... កល្យាណីមិនដែលបានប្រទះ មាណពម្ចាស់ដួងចិត្តរបស់នាងម្តងណាឡើយ... ឃើញតែគំនរម្ដុជផ្កាស្មៅ ក្រៀមដាក់គរលើគ្នាក្រោមដើមចារជាច្រើន... ទំនងហាក់ដូចជានាយក្រង ទុកផ្ញើធិតាយើងរាល់ថ្ងៃអញ្ជឹង ។ ភារាណីអង្គុយស្រក់ទឹកភ្នែកសង្វេគ ក្នុង បេះដូងនិយាយមិនចេញ ត្បិតមិនដឹងថា នាងត្រូវធ្វើយ៉ាងណា បើមេឃុំ ផែងមិនស្រណោះអាណិតចិត្តកូនចៅយ៉ាងដូច្នោះ ។

ថ្ងៃមួយ...

ភារាណីកំពុងតែឱនច្រូតស្រូវជាមួយអ្នកស្រុក ស្រាប់តែឮសំនៀងដ៏ គ្រលួចមួយរសាត់រវើយៗមកពីស្រែម្ខាង... ធ្វើអោយមាណវីភ្ញាក់ព្រើត ហើយក៏រន្ធត់ញាប់ញ័រក្នុងចិត្តយ៉ាងចម្លែករកថាមិនត្រូវ ។ នាងក៏ងើបភក្ត្រ័ ឡើងបែរមើលរកម្ចាស់សំនៀង រួចហើយបញ្ចេញទឹកមុខញញឹមយ៉ាង បំព្រង ។ នោះគឺជាភាពញញឹមមួយដែលបានបាត់ពីភក្ត្រ័របស់នាងជាច្រើន អាទិត្យមកហើយ ។

## សំនៀងស្នេហ៍កវី

១. ក្រោមជំនោរ ទឹកហូររលេញរីមៗ តំណក់សន្សើមព្រលឹម ញញឹមទទួលក្លិនផ្កា បទុមរមណីក្រពុំរេរាំកាយា យោលយោគតាមវាតា សោភាគួរភិសម័យ ។

២. ក្លិនម្ទមស្រែ បំពេរបេះដូងកំព្រា កវីឯកា រងា ប្រាថ្នាហត្ថាថ្នមកាយ សំលឹងវេហាស៍ចិន្តាគួចគិតស្រម័យ វង់ភក្ត្រាប្រឹមប្រិយកល្យាណីម្ចាស់ស្នេហា ។

បន្ទរ. ម្លប់ដើមក្រសាំង នោមយង់ធ្លាប់ចូលជ្រក រៀមស្នេហ៍ពន្លក តាំងពីនៅកុមារ ឆ្នាំនេះពេញវ័យស្រីស្អាតដូចសួគ៌ធិតា កវីញាប់ញ័រឱរាលង់ស្នេហាពាលពៅ ។

៣. ខ្ទមមាត់ទឹក រាល់ព្រឹកបងស្កាត់លួចឃ្លាំ គន់មើលស្រីមុំស្រងាំ អូននាង ចុះស្រែច្រូតស្រូវ បានយល់ភក្ត្រ័ស្រី ហឫទ័យស្បើយអស់ហ្មងសៅ ជាតិនេះជាតិណាតទៅ ផ្សងជួបតែពៅជាគូអើយ...

(ចំរៀងដកស្រង់ពីឌីវីឌីខារ៉ាអូខេរបស់ផលិតកម្មផ្កាយព្រះចន្ទ័លេខ៣០)

- បងកវី...!

ភារាណីលាន់មាត់ខ្សិបទាំងចិត្តរំភើបត្រេកអរ កាលបើយល់រូបរបស់
នាយពិចម្ខាយដែលអង្គុយនៅក្នុងម្លប់ខ្ទមចាំស្រែមួយនោះ ។ នាងងើបមុខ ឡើងសម្លឹងមើលមាណពធ្វើភាំង
ហាក់ដូចជាមិនចាប់ភ្លឹកថា នរណាឃើញ កិរិយារបស់នាងខ្លះទេ ។ ធិតាក៏ងើបស្ទុះដើរសំដៅទៅរកនាយយើងភ្លាម
ស្រាប់តែនាយងើបដើរគេចចេញទៅយ៉ាងរហ័ស ហាក់ដូចជា កំពុងតែខ្លាច នរណាម្នាក់ឃើញនាយមកដល់ទីនោះដូច្នោះឯង
ធ្វើឱ្យភារាណីនឹកខកចិត្ត ក្រៃលែង ។ លុះនាងដើរមកដល់ខ្ទម នាងក៏ឃើញម្កុដផ្កាស្មៅដែលទើបតែ ក្រងហើយថ្មីៗ
ដាក់ចោលនៅលើរនាបគ្រែក្នុងខ្ទម ព្រមទាំងកូនចំណារតូច មួយដែលសរសេរថា :

- ចំពោះទេបអប្សរតែមួយរបស់កវី!! នឹកណាស់!!

គ្រាន់តែអានចប់ ភារាណីស្រក់ទឹកភ្នែករលីងរលោងតែម្តង ។ ពេល នោះ
នាងយល់ហើយថាហេតុអ្វីមាណពដើរគេចពីនាងទៅ ។ ការពិតគឺកវី គោរពតាមសន្យាចំពោះមេឃុំដើម្បីរក្សាសុវត្ថិភាពរបស់នាង ។
ធិតាយើង ក៏លើកម្កុដឡើងពាក់លើកេសាហើយស្រដីខ្សិបៗតែម្នាក់ឯងថា :

- ទេពអប្សរក៏នឹកបងកវីដូចគ្នាដែរ..!

ធិតានៅអង្គុយច្រងុកក្នុងខ្ទម លែងមានកំលាំងចិត្តនឹងធ្វើអ្វីទាំងអស់
ក្រៅតែពីការបន់ស្រន់អោយនាងបានជួបកវីវិញតែប៉ុណ្ណោះ :

- ឱ! បារមីវត្ថុសក្តិសិទ្ធទាំងឡាយ.. សូមជួយអោយយើងទាំងពីរបានជួប គ្នាវិញឆាប់ៗនេះផង ។

បន្តិចក្រោយមក រតនាក៏បបួលនាងត្រលប់ទៅផ្ទះវិញ ។

ពីរបីថ្ងៃកន្លងទៅ...

ប៉ុន្មានថ្ងៃនេះ គេមិនឃើញហារិននិងនាយអរុណមករៀនទេ ។ រតនា និងភារាណីនឹកត្រេកអរក្នុងចិត្តណាស់ត្បិតពេលនេះ
ផ្លូវចេញចូលសាលា ហាក់ដូចជាស្រលះឥតមានបន្លាស្រាស់អ្វីសោះ ។ ដឹងអី ពេលគេបរម៉ូតូ ចេញពីរៀនថ្ងៃរសៀល
ឆ្លងស្ពានថ្មមុខសាលាខេត្តបាត់ដំបងបត់ហួសទៅ ខាងផ្សារលើបន្តិច ស្រាប់តែឃើញទាំងពីរនាក់នោះ នៅឈរស្ទាក់ចាំទីនោះ
ស្រេច ។ ហារិនស្ទុះមកចាប់ដៃម៉ូតូរកផ្លូលនារីយើងទៅដី ស្រាប់តែ ភារាណីឈប់ង៉ក់ទប់ម៉ូតូជាប់ ។ ហារិនក៏ស្រដីថា :

- អេហ៍ ឈប់សិនស្រីស្រស់! នឹកបងខ្លះទេ ប៉ុន្មានថ្ងៃនេះ?

រតនាគិតក្នុងចិត្តហាក់មានប្រផ្នូលអ្វីមិនស្រួលហើយ :

- នៅកណ្តាលថ្ងៃសោះ ពួកវាព្រហើនប៉ុនហ្នឹងទៅហើយ ចុះទម្រាំបើស្ងាត់ គ្មានមនុស្ស តើយ៉ាងណាទៅវិញ?

រំពេចនោះហារិនស្រដីបន្តថា :

- នែ៎ យើងមានគ្នាពីរគូ.. បើយើងអោយប្រុសៗជាអ្នកឌុប ហើយស្រីៗជា តែជិះពីក្រោយ ប្រហែលជាមានសុវត្ថិភាពជាជាងណាំ!

តែភារាណីធ្វើមិនដឹង ប្រឹងតែកាច់ម៉ូតូប្រុងបរគេចទៅ តែក៏គេចមិន
រួចដោយប្រុសកម្លោះទាំងពីរបានប្រុងជើងការស្រេចជាមុនថា មកបំបាក់ មុខនាងទាំងពីរនាក់ទៅហើយ ។

- ហារិន! លែងពួកយើងទៅ! ពុកម៉ែយើងកំពុងចាំបាយហើយ ។ ចាំថ្ងៃ ក្រោយ យើងជជែកគ្នាទៀតបានទេ? (ភារាណីស្រដី)

- មិនបាន! អូនបានធ្វើអោយបងឈឺខ្លួន មិនទាន់សូមទោសបងផង តើធ្វើ ម្ដេចនឹងបងព្រលែងអូនអោយទៅស្រួល១ម៉េចកើត?

- អញ្ចឹង! ហារិនសូមទោសពួកយើងមុនមក៏ ថាឈប់ព្រហើនដាក់យើង ទៀត នោះយើងនឹងសូមទោសវិញថា ឈប់លេងឈឺ១ទៀតហើយ ។

- តែថ្ងៃនេះ បងចង់លេងឈឺ១ជាមួយអូនម្ដងទៀត ។

ភ្លាមនោះ ស្រាប់តែនាយយើងស្រវាកញ្ឆក់អូសភារាណីសំដៅរថយន្ត របស់នាយដែលចតចោលក្បែរនោះ ហើយស្រែកថា :

- វ៉ឺយ! អរុណ! ឯងចាត់ការនាងរតនាទៅ! ទុកអោយយើងចាត់ការនាង ល្អនេះ ព្រោះវាមាត់បានណាស់ ។

ហារិននិងភារាណីប្រវាយប្រតប់គ្នាពេញថ្នល់ ។ ទីបំផុតហារិនក៏ដាក់ មួយដៃចំកណ្ដាលពោះធិតា ធ្វើអោយនាងដួលគ្រេងសន្លប់បាត់មាត់តែម្ដង ភ្លាមនោះអ្នកស្រុករត់មកដល់ឈូឆរ ។ ហារិនក៏អូសភារាណីដាក់ឡានបរ ចេញទៅយ៉ាងលឿនស្លេវ ។ ចំណែកនាយអរុណក៏ស្រវាអោបរតនាដាក់ ម៉ូតូបរចេញទិសមួយទៀត ដើម្បីបំបែកហ្វូងអ្នកស្រុកកុំអោយតាមទាន់ ហើយក៏គេចបាត់ស្រមោលទៅដែរ ។

0000000000000000

00000

0

# វគ្គទី១០
# ខឹងគោវាយរទេះ

មួយថ្ងៃមួយយប់កន្លងទៅ...

មីងផាវនិងមេឃុំផែងចាំមើលផ្លូវកូនស្រីផ្សាភ្អែក នៅតែមិនឃើញ នាងត្រលប់មកផ្ទះសោះ ក៏ចាត់មនុស្សអោយតាមរកគ្រប់ទីកន្លែងតាំងពី សាលាដល់ផ្ទះរតនា តែគ្មាននរណារកអ្នកទាំងពីរឃើញសោះ ។ មីងផាវ បានលួចទៅរកនាយករឹងទូលចារ ដែលនាយចំណាំមកអង្គុយលេងជាមួយ កូនស្រីរបស់គាត់តាំងពីកុមារភាព តែក៏មិនបានប្រទះនាយសោះ ។ លុះ គាត់ដើរទៅដល់ដីភូមិរបស់នាយករី ក៏ឃើញផ្ទះចាក់សោរស្ងាត់ច្រៀប គ្មាននរណានៅ ។ មីងផាវក៏ត្រលប់មកវិញទាំងក្រៀមក្រំចិត្ត ។ លុះគាត់ ត្រលប់មកដល់ផ្ទះវិញ ស្រាប់តែបានទទួលដំណឹងពីឪពុកម្តាយរបស់រតនា ថានាងបានរងគ្រោះថ្នាក់ម៉ូតូជាទម្ងន់ ហើយក្មេងកម្លោះអ្នកបរម៉ូតូនោះ បានទទួលមរណភាពនៅនឹងកន្លែងដោយបុព្វហេតុបើកបុកគល់ឈើ ម្តុំខាង មុខទក្ខិណសាលា ។ ឮដំណឹងនោះហើយ ទាំងមីងផាវ ទាំងមេឃុំមានការ ខ្វល់ខ្វាយណាស់ត្បិតមិនដឹងថា មានអ្វីកើតឡើងចំពោះភារាណីឡើយ ។

នៅព្រឹកព្រហាមថ្ងៃបន្ទាប់...

មីងផាវភ្ញាក់ពីដំណេក ឃើញស្រមោលមនុស្សឈរទ្រោបខ្លួននៅលើ ទ្វាររបងមុខផ្ទះ ក៏លាន់មាត់ឡើង :

- កូនណី!

មីងស្ទុះហក់រឹងសឹងបាក់ក ចុះតាមកាំជណ្តើរសំដៅទៅរកកូនស្រី :

- ស្លាប់ហើយ កូនម្តាយ! ហេតុអ្វីក៏កូនទុរន់ទុរាយ៉ាងនេះ? មានរឿងអ្វី ហ្នឹងកូន?... ណី... កូន!

មែនហើយ... នោះគឺជាមាណវីរបស់យើងមែន តែសភាពរូបកាយ របស់នាងទ្រុឌទ្រោមពិបាកមើលណាស់ ។ គ្រាន់តែបានមកដល់រង្វង់ដៃ របស់ម្តាយភ្លាម នាងក៏ដួលប្រូសសន្លប់បាត់ស្មារតី ។ នៅលើខ្លួនរបស់នាង មានស្នាមជាំជាច់ស្បែកជាច្រើនកន្លែង ទំនងជាត្រូវរងគ្រោះថ្នាក់ដោយ អំពើហឹង្សាណាមួយហើយ ។ មីងផាវភិតភ័យណាស់ក៏កូកហៅមេឃុំនិង កម្មករអោយមកជួយគាត់យ៉ាងលឿន ។

មេឃុំដើរទៅដើរមក ក្បែរគ្រែរបស់ភារាណី ដោយកិរិយាក្រហល់ ក្រហាយ ។ នៅលើគ្រែវិញ ធិតាយើងគេងដណ្តប់ភួយសម្ងំស្វែងរកភាព ស្ងប់ស្ងៀមនៅក្នុងចិត្តយ៉ាងលំបាក ។ ពេលនេះ នាងមិនមានអារម្មណ៍ថា ឈឺចាប់ខាងផ្លូវកាយឡើយ ។ អ្វីដែលឈឺចាប់បំផុត គឺចាញ់ចិត្តទ្រុស្តមិត្ត ដែលអាចយកឈ្នះលើរូបនាង ដែលជាភេទទន់ខ្សោយ ដោយការប្រើ កម្លាំងបាយ ដោយកម្លាំងចំហាយអំណាចពីឪពុកម្តាយ និងដោយកលល្បិច ដ៏ទុរយសក្រៃលែង ។ ភ្លាមនេះ មេឃុំផែងក៏គំហកសួរនាងថា :

- នាងណី! កូនប្រាប់ពុកមក៏ ថាបុរសណាមួយដែលថ្លើមធំ ហ៊ានធ្វើបាប កូន ដល់ថ្នាក់នេះ... ប្រាប់មក៏ ចាំពុកចេញទៅប្រដៅវាអោយ ។

តែកល្យាណីយើងមិនស្រដីមួយម៉ាត់ជំរាបគាត់ទេ ម្យ៉ាងដោយសារ នាងនៅរន្ធត់ស្មារតីភិតភ័យមិនទាន់បាត់ចំពោះហេតុការណ៍ដែលកើតឡើង ចំពោះនាងកាលពីយប់ម្សិល ម្យ៉ាងដោយសារភាពឆេវឆាវរបស់មេឃុំ ខ្លាចគាត់ច្រលោតខុសរឿង នាំភ្លើងដុតរោលពេញណាពេញណី ម្យ៉ាងក៏ ដោយសារនាងកំពុងតែច្របូកច្របល់ក្នុងចិត្តថា នឹងត្រូវរកមធ្យោបាយ ណាដែលអាចយកឈ្នះជនទុរយសនោះបានដោយយុត្តិធម៌ ដើម្បីអោយគេ បានទទួលទោស អោយសមនឹងការប្រព្រឹត្តរបស់គេ ។

ឃើញកូនស្រីមិនមាត់មិនក មេឃុំរិតតែខឹងឡើង :

- នែ៎... នាងណី! និយាយខ្លះបានទេ.. ថាមានរឿងអ្វី? ហើយនរណាគេធ្វើ បាបកូន? ប្រាប់ពុកភ្លាមមក៏!

ភ្លាមនោះ មីងផាវទាញដៃគាត់អោយអង្គុយចុះ ហើយមានប្រសាសន៍ ទៅកាន់គាត់ដោយសំដីថ្នម១ថា :

- ពុកវ៉ា! កូនវាកំពុងតែមានអារម្មណ៍ភិតភ័យតក់ស្លុតចំពោះអ្វីដែលទើប នឹងកើតឡើងចំពោះនាងថ្មី១... កុំសម្លុតគេអោយលោះព្រលឹងអញ្ជឹងណា៎!

មេឃុំដាក់ខ្លួនអង្គុយប៉ុកទាំងចិត្តអន្ទះសា ។

ច្រើនអាទិត្យកន្លងទៅ...

មីងផាវបានអញ្ជើញអ្នកគ្រូពេទ្យដែលគាត់ស្គាល់ជិតស្និទ្ធម្នាក់ អោយ មកជួយព្យាបាលមើលជំងឺភារាណីនៅផ្ទះ ត្បិតនាងបានទទួលរងគ្រោះថ្នាក់ ផ្លូវភេទជាទម្ងន់ មិនចង់អោយបែកការណ៍ទៅក្រៅ ។ ដោយសារតែដើម បុព្វហេតុបែបនេះហើយ ទើបមីងមិនចង់អោយលេចឮរឿងអ្វីទៅក្រៅ ម្យ៉ាងទៀត ខ្លាចនារីយើងឆ្លងរោគអេដស៍ពីបុគ្គលដែលធ្វើបាបនាងផង ។ ការពិត ភារាណីបានរងគ្រោះថ្នាក់ធ្ងន់ជាងយើងគិតទៅទៀត ។ ដោយសារ ការប្រវាយរើបំរះគេចពីការវាយដំរបស់នាយហារិន ធិតាយើងបានទទួល រងគ្រោះ បាក់ឆ្អឹងកំភួនដៃឆ្វេង និងបាក់ឆ្អឹងស្មា ថែមទាំងមានរបួសដាច់ ស្បែកពាសខ្លួនត្រូវដេរជាច្រើនសិបថ្នេរ ។

ថ្វីបើម្នាក់១ខំប្រឹងបំបិទរឿងនេះជិតមិនអោយនរណាដឹងក៏ដោយ ក៏ បុព្វហេតុចម្លែកអោយអ្នកស្រុកសង្ស័យក៏ចេះតែមាន គឺភារាណីលែងចេញ ក្រៅផ្ទះ លែងទៅសាលា លែងចេញទៅស្រែច្រូតស្រូវជាមួយកម្មករឬអ្នក ភូមិដែលប្រវាសដៃជាមួយមេឃុំដូចធម្មតា១សព្វដង ។ ករីបាត់ដំណឹងធិតា យូរ ចេះតែមកលួចលបមើលពីក្រៅរបងជាញឹកញាប់

តែក៏មិនហ៊ាននៅ យូរត្បិតខ្លាចមេឃុំផែងចាប់បាន។ គេនឹកទេពអប្សរកំពូលដួងចិត្តរបស់គេ ណាស់ ហើយគេក៏មិនដឹងថានាងឈឺអ្វីដែរ ដែលត្រូវលាក់ខ្លួនក្នុងផ្ទះ មិន ចេញក្រៅរាប់អាទិត្យមកហើយ។

នៅព្រលប់ថ្ងៃមួយ...

កវីលួចដើរទៅពីខាងក្រោយដីចំការរបស់មេឃុំ ជួបនឹងពូសេតដែល កំពុងប្រមូលប្រដាប់ប្រដាពីក្នុងចំការយកទៅទុកដាក់ ហើយសួរថា :

- ពូ!.. អូនណីសុខសប្បាយទេ?

ពូសេតជាមនុស្សដែលទើបចូលធ្វើការថ្មីនៅចំការ មិនស្គាល់កវីថាជា នរណាទេ តែលុះឃើញរូបរាងនាយហាក់ដូចជាមនុស្សល្អ គាត់ក៏ឆ្លើយថា :

- អូហ៎.. នាងតូចឈឺយូរខែហើយ.. មិនដែលចេញទៅណាទេ ហើយចុះអា នាងឯងជានរណាដែរ?

- ខ្ញុំជាមិត្តធ្លាប់ស្គាល់ធ្វើស្រែប្រវាសជាមួយគ្នា បាត់នាងយូរបានជាមកសួរ សុខទុក្ខ...

ស្រាប់តែពូសេតឆ្លើយខ្សិបៗដាក់នាយថា :

- អានាងអើយ... ឯងពេញចិត្តកូនស្រីនរណាបានដែរ តែកុំប៉ះកូនមេឃុំ ផែងឱ្យសោះ ប្រយត្ន័ឈឺខ្លួនរ៉ឺយ តិចថាពូមិនប្រាប់!

កវីមិនទាន់ឆ្លើយថាម៉េចផង ស្រាប់តែមានសម្លេងមួយស្រែកកាត់ការ សន្ទនារបស់អ្នកទាំងពីរភ្លាម :

- អាសេត! ឯងឈរនិយាយជាមួយនរណាហ្នឹង?

ពូសេតបែរក្រោយឃើញមេឃុំផែងឈរច្រត់ចង្កេះធ្វើមុខមាំ ក៏ហក់ ប្រូចផាយជើងប្រាំចេញបាត់ទៅយ៉ាងរហ័ស។ កវីក្រលេកឃើញមេឃុំភ្លាម ក៏ស្លុតស្មារតីភ្លេតតែម្តង។ កាលបើប្រទះឃើញមាណពយើង មេឃុំផែងក៏ លាន់មាត់ឡើងថា :

- គឺឯងទេហ៎ អាក្មេងក្បាលខូច..? មកណេះ! មកជិតយើងម៉ាភ្លែត !

កវីឮហើយ ក៏ឈ្ងោកមុខដើរឱនៗទៅជិតមេឃុំ ស្រាប់តែ.. ផាំង! មេ ឃុំលើកជើងធាក់នាយមួយទំហឹងផ្ទារពោះអុកគូថទៅដីយ៉ាងខ្លាំង :

- យើងកំពុងរកមុខឯងយូរអាទិត្យហើយ.. ! តែយើងមិនដឹងថាឯងនៅឯ ណា... ថ្ងៃនេះ ព្រះបណ្តាលអោយឯងមកដល់ទីនេះស្រេច មិនបាច់យើង តាមរកដូច្នេះល្អណាស់ នឹងអាលយើងដាក់ទោសឯងឱ្យសមនឹងអំពើដែល ឯងបានប្រព្រឹត្តយង់ឃ្នងមកលើកូនស្រីរបស់យើង រហូតនាងមានជំងឺជា ទម្ងន់តាំងពីច្រើនអាទិត្យកន្លងមកហើយ!

កវីឮមេឃុំមានប្រសាសន៍ដូច្នោះ នាយបើកភ្នែកធំៗឡើង ភ្លេចអស់ ការឈឺចាប់ដែលត្រូវមួយជើងយ៉ាងធ្ងន់ពីមេឃុំយើងអស់រលីង រួចនាយក៏ សួរគាត់ថា:

- ភារាណីឈឺធ្ងន់?

- មែន! គឺមកពីស្នាដៃឯងហ្នឹង អាក្មេងព្រហើន! ឯងថ្លើមធំណាស់ដែល ឯងហ៊ានបំពានសន្យាជាមួយយើង។

ថាហើយ មេឃុំក៏ទាត់នាយពីរបីជើងថែមទៀតយ៉ាងធ្ងន់។ មាណព យើងក៏ច្រលោតដួលបីបួនត្រលប់។ រំពេចនោះ ភារាណីនិងមីងផាវក៏រត់ មកដល់កន្លែងកើតហេតុព្រមៗគ្នា។

- ពុកវា! មានរឿងអីហ្នឹង? ហេតុអ្វីប្រើកម្លាំងបាយទៀតហើយ?

មីងផាវស្ទុះទៅឃាត់ តែមេឃុំស្រែករាំងឡើងថា :

- មកពីយើងទ្រាំមិនបាននឹងអាក្មេងខូចវាប្រព្រឹត្តផ្តេសផ្តាស...!

ភារាណីក្រលេកឃើញមាណពហូរឈាមពីមាត់ក៏ស្ទុះយកខ្លួនទៅពាំង ហើយឃាត់ឪពុកនាងថា :

- ពុក! កុំធ្វើបាបគាត់អី!..

- យើស៎! គ្រាន់តែសះខ្លួនមិនទាន់ លង់ស្នេហ៍វាជាថ្មីទៀតហើយហ្អែស?

- ពុក... ស្តាប់កូនសិន! ពុកធ្វើទោសខុសមនុស្សហើយ!

- ថយចេញ នាងណី! ប្រយ័ត្នយើងវាយឯងដាក់ទោសជាមួយគ្នាទាំងពីរ នាក់តែម្តងទៅ!

- អត់ទេ.. ណីមិនថយទេ! សុខចិត្តអោយពុកវាយកូន តែកូនមិនបណ្តោយ អោយពុកវាយគាត់ទេ។ ហេតុអី? ហេតុអីទៅពុក ដែលពុកត្រូវស្អប់គេ យ៉ាងនេះផង?

- គឺមកពីវាមិនស្តាប់យើង ហើយវាក៏ធ្លាប់បំពានធ្វើបាបឯង... ទុកអោយ ពុកវាយវាដាក់ទោសចុះ កុំអោយវាធ្វើដូច្នេះទៀត

- ពុក! គាត់មិនមែនជាមនុស្សទុរយសម្នាក់នោះទេ។

- កុំលាក់!.. ហេតុអីចាំឯងកាន់ជើងវាផង? យើងមិនជឿសំដីបត់បែន របស់ឯងទេ.. ត្រលប់ទៅផ្ទះវិញឱ្យឆាប់ ឮទៅ?

មេឃុំក៏ស្រវាអូសដៃភារាណីចេញពីកវី តែនាងស្រវាអោបនាយជាប់ ហើយកវីក៏ស្រវាអោបនាងវិញដែរ។ ការពិត គេរលឹកគ្នាណាស់ ស្រលាញ់ គ្នាណាស់ ហួសពីការស្មានរបស់មេឃុំទៅទៀត។ កាលបើឃើញមេឃុំផែង ដៃធ្ងន់ចំពោះភារាណី កវីក៏ងើបឡើងយកខ្លួនពាំងហើយមិនអោយគាត់ អូសនាងទាំងកំហល់ ហើយស្រដីថា :

- ពុកបានសន្យាហើយថាឈប់វាយនាង! បើពុកចង់ដាក់ទោសនាង ដាក់ ទោសខ្ញុំជំនួសទៅ! ពេលនេះ ខ្ញុំពិតទ្រាំមិនបានទេ កាលបើភារាណីត្រូវរង
ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរពីពុកយ៉ាងនេះ!

ផាំង! មេឃុំទះកំភ្លៀងនាងមួយទំហឹងដៃយ៉ាងធ្ងន់ :

- នេះយកទៅ! សំរាប់អាក្មេងព្រហើនហ៊ានតវ៉ានឹងយើង!

- បងកវី...

ភារាណីស្រែកភ្លាត់សំលេង ហើយស្ទុះទៅស្រវាអោបជើងឪពុកឃាត់ គាត់មិនអោយវាយកវី
ស្រាប់តែត្រូវមេឃុំរលាស់ជើងអោយនាងដួល បោកខ្លួនទៅម្ខាង សន្លប់បាត់មាត់តែម្តង។ កវីភិតភ័យណាស់ក៏លើកត្រកង បីនាងឡើងមក ហើយបែរសម្លឹងមេឃុំផែងដោយក្រសែភ្នែកយ៉ាងមុត ព្រមទាំងស្រដីថា :

- ខ្ញុំពិតជាខកចិត្តចំពោះពុកមេឃុំណាស់! ពុកមើលឃើញតែភាពយង់ឃ្នង របស់អ្នកដទៃ
តែពុកភ្លេចបែរមើលការប្រព្រឹត្តរបស់ពុកផ្ទាល់ទៅវិញ... ថា តើសាហាវឃោរឃៅប៉ុនណាដែរ?

កវីក៏បីធិតាយើងរត់ជើងប្រាំយ៉ាងរហ័ស ដោយមានមីងផាវនាំមុខ សំដៅទៅបន្ទប់របស់ភារាណី ទុកអោយមេឃុំផែងឈរសម្លឹងមើលពី ក្រោយទាំងចាញ់ចិត្ត ត្បិតរកនឹកមិនឃើញចម្លើយចំពោះមួយសំនួរក្រោយរបស់នាយយើង ។

បន្តិចមក អ្នកគ្រូពេទ្យដែលតែងតែមកពិនិត្យភារាណីរាល់ថ្ងៃក៏បាន មកដល់ជាប្រញាប់ ដោយមានពូសេតជាអ្នករត់ទៅតាមមក ។ បន្ទាប់ពី ពិនិត្យអាការៈរបស់មាណវីយ៉ាងយូរ ទើបគាត់មានប្រសាសន៍ជំរាបមីង ផាវថា :

- កូនស្រីរបស់មីងកំពុងតែមានផ្ទៃពោះហើយ!

មីងផាវភ្ញាក់ដូចគេចាប់គ្រវែង កាលបើទទួលដំណឹងនេះ មិនខុសពី កវីដែលឈរក្បែរនោះ ក៏ភ្ញាក់ផ្អើលស្ទើរតែគាំងបេះដូងស្លាប់ ។ ភ្លាមនោះ នាយក៏ស្ទុះទៅជិតភារាណីហើយឧទានឡើង :

- ណី! បងមិនជឿទេ ថាអូនជាមនុស្សរាយមាយ... អូនប្រាប់បងមក៍.. តើអ្នកណាធ្វើបាបអូន... ភារាណី..? តើគេនោះជានរណា?

ព្ធមាណពស្រដីដូច្នោះ នាងក៏រលីងរលោងទឹកភ្នែកហើយលើកដៃទៅ ចាប់ដៃមាណពមកកាន់ទាំងឱរាញាប់ញ័រហើយក៏ឆ្លើយថា :

- មានផ្ទៃពោះក៏ល្អហើយ ព្រោះអូននឹងមានភស្តុតាងសំរាប់ចាប់ជនពាល មួយរូបនោះ...

- តែគេជានរណា.. ប្រាប់បងមក៏..បងនឹងទៅប្រដៅវា...

- កុំអី.. គេជាមនុស្សមានអំណាច.. បងមិនអាចធ្វើអ្វីគេបានទេ?

- មនុស្សមានអំណាច?.. នរណាទៅ? ឬក៏...

ស្រាប់តែនាយបើកភ្នែកធំៗ ហាក់ដូចជានឹកភ្ញកឃើញរឿងមួយ ។ គេ ស្ទុះហក់រឹងយ៉ាងលឿនសំដៅមេឃុំផែង ដែលកំពុងឈរធ្វើមុខស្ញើកនៅ ចំហៀងផ្ទះ ហើយសួរគាត់យ៉ាងរន្ធើនថា :

- គឺពុកមែនទេ ដែលជាអ្នករំលោភធ្វើបាបអូនភារាណីអោយនាងមានផ្ទៃ ពោះ?... គឺពុកមែនទេ?

- ហ្អាស? ថាម៉េច? នាងណីមានផ្ទៃពោះ? (មេឃុំលាន់មាត់)

- ពុកឆ្លើយមក៏! ទារកដែលនៅក្នុងផ្ទៃរបស់នាងជាឈាមរបស់ពុកមែនទេ
 មែនទេ?

- តែផ្ដាស! ឯងនិយាយអ្វីឆ្កួតៗយ៉ាងនេះហ្អាស?

- បើមិនមែន ម៉េចបានជាពុកសម្ដែងកិរិយាហាក់ដូចជាហួងហែងនាងខុស ធម្មតាយ៉ាងនេះ? ពុកមានចំណុចខ្សោយ.. ពុកប្រាកដជាប្រព្រឹត្តអ្វីខុសឆ្គង មិនខាន! ពុកជាមនុស្សដែលធ្វើបាបអូនណី... មែនទេ? សារភាពមក៏...! ពុកសារភាពមក៏...

កវីសួរមេឃុំរន្ធើនព្រោះតែនាយអាណិតភារាណីស្ទើរតែស្រក់ទឹកភ្នែក ស្រាប់តែ.. :

- នាយចំកួតអើយ.. ឯងពិតជាកំពុងវង្វេងបល់បាយហើយ ដែលឯងមក ចោទយើងផ្ដេសផ្ដាស.. (មេឃុំគំហកវិញ)

- ទោះជាយ៉ាងណាក៏ខ្ញុំលែងទុកចិត្តពុកទៀតហើយ...

កវីស្ទុះរឹងឡើងទៅលើផ្ទះ លើកដៃក្រាបសំពះមីងផៃដល់ក្ដារបីដង ធ្វើអោយគាត់ភ្ញាក់ក្រញាងមិនដឹងថានាយចង់ធ្វើអ្វីទេ។ បន្ទាប់មក នាយក៏ ស្ទុះលើកត្រកងបីភារាណី ដែលកំពុងធ្ងេចដោយការអស់កម្លាំងធឹងធោង នោះឡើង ហើយដើរចេញទៅក្រៅ ព្រមពេលដែលមេឃុំឡើងមកដល់ លើផ្ទះល្មម:

- ឯងចង់យកនាងណីទៅណា? (មេឃុំគំហកសួរ)

- ទៅកន្លែងដែលមានសុវត្ថិភាពសំរាប់នាង... (កវីឆ្លើយ)

- មុខដូចឯងមានសមត្ថភាពនឹងរក្សានាងអោយមានសុវត្ថិភាពដែរ?

- ហើយចុះពុកមេឃុំវិញ  ការពារអូនណីបានសុខសប្បាយ ប៉ុនណាដែរ? ពុកមានឃើញស្ថានភាពផ្លូវកាយផ្លូវចិត្តរបស់ភារាណីពេលនេះទេ? នេះឬ ដែលថា ពុកមានសមត្ថភាពគ្រប់គ្រាន់នឹងការពារនាងឱ្យមានសុវត្ថិភាព នោះ?

ពេលនេះ មេឃុំផែងបិទមាត់ដូចគេចុកឆ្លើយមិនរួចតែម្ដង។ រីឯមីង ផាវក៏មិនព្រឃាត់អ្វីដែរ មើលទៅប្រហែលជាមីងមិនអាចទ្រាំនឹងមើលភាព កំហែងកំហល់របស់មេឃុំចំពោះកូនស្រីរបស់គាត់ នៅនឹងភ្នែកតទៅទៀត ដែរបានជាគាត់បណ្ដោយអោយកវីបីនាងដើរចេញទៅតាមសម្រួល។ ទាំង មេឃុំផែង ទាំងមីងផាវ សម្លឹងមើលតាមមាណពរហូតដល់គេចេញបាត់ពី របងផ្ទះដោយមិនព្រស្រដីអ្វីមួយម៉ាត់តទៅទៀតឡើយ។

កវីដើរបីភារាណីរហូតដល់ផ្ទះរបស់នាយ។ មិនដឹងហេតុអ្វីទេ ថ្ងៃនេះ គេបែរជាមានភាពក្លាហានខុសធម្មតា ហ៊ានប្រឈមមុខតវ៉ាចំពោះមេឃុំ វិញថែមទាំងហ៊ានបីកូនស្រីគេចេញពីផ្ទះ នៅចំពោះឪពុកម្ដាយទាំងពីរនាក់ ដោយឥតក្រែងរអែងចិត្តអ្វីបន្តិចសោះ ប្រហែលជាគេបារម្ភពីនារីយើងដល់ ក៏រិតហើយ បានជាលែងខ្លាចចិត្ត ខ្លាចគ្រោះថ្នាក់អ្វីទាំងអស់ យ៉ាងនេះ។

មកដល់លើផ្ទះភ្លាម កវីក៏ដាក់ធិតាផ្ដេកចុះទៅលើគ្រែដោយថ្នម។ :

- ភារាណី! ចាប់ពីថ្ងៃនេះតទៅ.. បងមិនបណ្ដោយអោយនរណាម្នាក់ធ្វើ បាបអូនទៀតបានឡើយ។ បងនឹងការពារអូនដោយជីវិតរបស់បង!.. អូន ណីត្រូវតែចាកផុតពីការរងគ្រោះពីអំពើហឹង្សាទាំងឡាយ។

ធិតាយកដៃអង្អែលថ្ពាល់កវីហើយស្រដីទាំងអួលដើមកថា :

- អរគុណណាស់ បងកវី... ដែលបងមិនគិតថាអូនមានចិត្តរាយមាយ...

- អូនណី! បងស្គាល់អូនតាំងពីតូចមកម្ល៉េះ រឿងអ្វីដែលបងមិនដឹងថាអូន ជាមនុស្សយ៉ាងណានោះ?

ឮសំដីនេះភ្លាម ភារាណីក៏ងើបឡើងពីគ្រែ ស្រវាអោបកវីយំហ៊ូមួយ រំពេច ត្បិតនឹកអាណិតខ្លួនដែលត្រូវមករងគ្រោះចង្រៃ ទាំងវ័យក្មេងខ្ចីមិន ទាន់ចប់ការសិក្សានៅឡើយ។ កវីអង្អែលខ្នងនាងថ្នម១លួងលោមចិត្តឱ្យ នាងបានធូរស្រាលក្នុងចិត្ត :

- អូនឈប់បារម្ភទៀតទៅ! ពិតមែនតែផ្ទះបងតូចចង្អៀត មិនមានអ្វីស្អាត ល្អដូចផ្ទះពុកមេឃុំ តែបងសូមធានាថា បងនឹងរក្សាអូនអោយមានសេចក្ដី សុខ គ្មានការយាយីលើផ្លូវកាយទៀតឡើយ ណា៎អូន!!

ភារាណីញញឹមឡើងទាំងទឹកភ្នែក... ទឹកភ្នែកដោយការរំភើបរំជើប រំជួលក្នុងចិត្ត ត្បិតករីនៅតែអាណិតស្រឡាញ់រូបនាងដដែល ឥតផ្លាស់ប្តូរ ឡើយ ថ្វីបើពេលនេះ នាងបានក្លាយជាផ្កាបាក់មែក តែករីនៅតែបង្ហាញ សមានចិត្តយ៉ាងល្អចំពោះនាង ថែមទាំងចេញមុខការពារនាងដោយម៉ឺង ម៉ាត់ទៀតផង ។ ចំពោះករីវិញ... គេក៏ឈឺចាប់មិនតិចជាមាណវីយើង ប៉ុន្មានឡើយ ។ បេះដូងរបស់គេហាក់ដូចជាកំពុងត្រូវគេច្របាច់ខ្ទេចខ្ទាំ កាលបើគេបានយល់នារីកំពូលដួងចិត្តត្រូវទទួលរងគ្រោះ ពីសំណាក់មនុស្ស ដែលមានចិត្តទ្រុស្តពាលា...

ច្រើនអាទិត្យបានកន្លងទៅ...

ភារាណីមានអារម្មណ៍ស្ងប់ស្ងៀមជាងមុនច្រើន តាំងពីបានមកស្នាក់ នៅផ្ទះរបស់ករី ដែលរស់នៅដាច់តែឯង គ្មានញាតិទៅមកអ៊ូអរដូចនៅផ្ទះ មេឃុំផែងទេ ។ សុខភាពផ្លូវកាយក៏បានប្រសើរជាងមុនច្រើនដែរ ។ ម្យ៉ាង ទៀត ករីបានថែរក្សានាងដោយយកចិត្តទុកដាក់បំផុត មិនដែលអោយ ឃ្មើសចិត្តរឿងអ្វីទេ ។ ប៉ុន្តែអ្វីដែលចម្លែកនោះ គឺមេឃុំផែងនិងម្តាយរបស់ នាង.. មិនឃើញមាននរណាមួយតាមរកនាងសោះ មិនដឹងថា គាត់កំពុង គិតពីអ្វីទេ ប៉ុន្មានអាទិត្យមកនេះ ។

នៅលើស្ពានឈើមាត់ស្រះឈូក ចំហៀងផ្ទះ ភារាណីអង្គុយយកជើង លេងទឹកតែម្នាក់ឯងស្ងាត់ស្ងៀម រង់ចាំករីត្រលប់មកពីស្រែវិញ ។ នាងនឹក ស្តាយចំពោះខ្លួននាងដែលត្រូវខកសាលារៀនមិនចប់ នឹកខ្វល់ខ្វាយត្បិត តាំងពីបែកពីរតនាមក មិនដឹងថា មិត្តនាងមានសុខទុក្ខយ៉ាងណា នឹកមួយ ទៀតគឺនាយហារិនដែលបានបំផ្លាញអនាគតនាង ។ ធិតាគិតថា ថ្ងៃណាមួយ នាងនឹងវិលត្រលប់មកដាក់ទោសនាយវិញ អោយសមនឹងកំហុសដែល នាយបានប្រព្រឹត្តមកលើនាង ។ ប៉ុន្តែ តើនាងត្រូវរកមធ្យោបាយយ៉ាងណា ដើម្បីដាក់ទោសគេបានទៅ បើគេជាកូនចៅរបស់មន្ត្រីជាន់ខ្ពស់មានអំណាច យ៉ាងធំធេង? កំពុងតែគិតលង់ស្មារតី ស្រាប់តែ...

- អូនណី! កំពុងគិតអីហ្នឹង?
- អុះ! បងករី! មកដល់ពីអង្កាល់ហ្នឹង?
- មកដល់មួយសន្ទុះមុននេះឯង ម៉ោះ! ទៅបរិភោគបាយជុំគ្នា ។ បងបាន ដាំស្លធ្និនហើយ ។

ថាហើយ ករីក៏អូសដៃនាងអោយក្រោកឡើង ដើរត្រលប់ទៅផ្ទះវិញ ដោយរីករាយ ។ នៅរាត្រីនោះ ករីសួរនាងថា :

- អូនណី! ជាស្រួលបួលហើយនៅ?
- ខ្ញុំស្រួលហើយ.. កុំបារម្ភអី! ខ្ញុំអាចជួយខ្លួនឯងបាន ពេលបងមិននៅ ។
- ទោះយ៉ាងណាក៏បងនៅតែបារម្ភពីអូនមិនបាត់ទេ.. ខ្លាចពុកមេឃុំ...

ឮឈ្មោះនេះភ្លាម ធិតាភ្ញាក់ព្រើត ស្រាប់តែស្រដីថា :

- ខ្ញុំសង្ឃឹមថា គាត់មិនតាមរំខានយើងទាំងពីរទៀតទេ...
- ម៉េចក៏អូនមានជំនឿម្ល៉េះ?
- ព្រោះគាត់មិនមែនជាអ្នកប្រព្រឹត្តអាស្រូវលើរូបអូននោះឡើយ...

- ថាម៉េច?.. (កវីឆ្លើយទាំងភ្ញាក់) មិនមែនគាត់ទេ? ហើយចុះ តើជា..

- បងមិនស្គាល់គេទេ.. ប៉ុន្តែនៅថ្ងៃណាមួយ អូននឹងរកមធ្យោបាយអោយ គេទទួលកំហុសនោះអោយទាល់តែបាន។

កវីនៅស្ងៀម បន្តិចមកទើបស្រដីបន្តថា :

- មិនថាពេលវេលាផ្លាស់ប្តូរជីវិតរបស់យើងយ៉ាងណាទេ...ភារាណី! បង ចង់អោយអូនដឹងថា កវីនៅតែស្រឡាញ់អូនជានិច្ច តរៀងទៅ...ហើយបង នឹងទទួលចិញ្ចឹមទារកដែលជាកូនរបស់អូនឱ្យគេមានសេចក្តីសុខបំផុត!

ព្ញវាចារបស់មាណពដូច្នោះ ភារាណីក៏ញញឹមឡើង :

- អរគុណណាស់ បងកវី! អូនពិតជាមោទនភាពណាស់ដែលអូនមានរូប បងជាបង្អែកជីវិត។

បង្អែកជីវិត

| | |
|---|---|
| បងជាបង្អែកដ៏កក់ក្តៅ | គ្រប់គ្រងពាលពៅផុតសង្ការ |
| ជីវិតអូនមួយរស់ខ្លោចផ្សា | ក្នុងដៃជីវ៉ាអូនក្សេមក្សាន្ត។ |
| បងជាបង្គោលមានលំនឹង | ថៃពៅព្រលឹងស្រស់កល្យាណ |
| រស់នៅផុតសោកផុតរំខាន | ស្គាល់តែសុខសាន្តមានមង្គល។ |
| បងជាទ្រនំជាសំបុក | សាងសេចក្តីសុខផុតអំពល់ |
| ជាម្លប់កក់ក្តៅដ៏និមល | ស្រាន្តស្រួលកាយកល់យល់សួគ៌ា។ |
| បងជាអ្វីៗសំរាប់អូន | លុះជីវិតសូន្យសូមសច្ចា |
| សូមជួបតែបងគូស្នេហា | កសាងគ្រួសារមង្គលអើយ។ |

តាំងពីថ្ងៃនោះមក កវីបានថែទាំគ្រប់គ្រងភារាណីដោយហ្មត់ចត់រហូត ដល់នាងសម្រាលបានកូនស្រីមួយ ដែលកវីបានដាក់ឈ្មោះឱ្យថាសោភា។ រាល់ថ្ងៃកវីចេញទៅប្រកបការងារ ទុកអោយភារាណីនៅផ្ទះរក្សាទុកដាក់ ផ្ទះសំបែង។ បើមើលពីក្រៅទៅមិនខុសពីប្តីប្រពន្ធមួយគូដែលស្រឡាញ់គ្នា យ៉ាងស្មោះស្ម័គ្រនោះឡើយ ។ យូរៗម្តង... មីងផាវលួចស្កាត់មកជួបកូន ស្រីរបស់គាត់នៅឯខ្ទមចាំស្រែដើម្បីសួរសុខទុក្ខនាង តែគាត់មិនដែលហ៊ាន មកជួបកូនរហូតដល់ផ្ទះនាយកវីទេ ត្បិតមិនចង់ឱ្យមេឃុំស្គាល់ ខ្លាចគាត់ តាមឆានៅរំខានធ្វើបាបកូនដោយសារភាពមានះ ហឹង្សា និងការដែលខ្លួន គាត់គិតថាគាត់ជាមនុស្សត្រូវរហូត។

ថ្ងៃដន្យ សំណាងមិនល្អ ពេលភារាណី ប្រសូត្របុត្រីបានមួយខែ ស្រាប់តែនាងមានជំងឺទាស់មើលមិនជា រហូតដល់កវីយកជ្រូកទាមាន់គោ ក្របីទៅលក់អោយហើយក៏មើលមិនជា។ នាយក៏ដាច់ចិត្តស្កាត់ទៅលួចជួប មីងផាវដើម្បីជំរាបដំណឹង។ កាលបើឮដំណឹងនេះភ្លាម មីងផាវក៏រួសរាន់ មករកជួបកូនស្រី ឃើញនាងគេងឈឺស្គាំងស្គមលើកន្ទេល :

- ណីកូនម្តាយ! យ៉ាងម៉េចហ្នឹងកូន?

- គឺគេចាប់ផ្ដើមគ្រុនក្ដៅរីងរៃជិតមួយខែហើយម៉ែ! (កវីជំរាបគាត់វិញ)
ខ្ញុំបានលក់គោក្របីមើលជំងឺនាងយ៉ាងអស់សមត្ថភាពតែនាង នៅតែមិន បានគ្រាន់បើទាល់តែសោះ ពេលនេះ ខ្ញុំចាញ់ចេះហើយ ។
- ហើយចុះកូនស្រីរបស់ឯង គេមិនអីទេ?
- នាងមិនអីទេ! ខ្ញុំបានទិញទឹកដោះគោឆុងបំបៅនាងជំនួស ត្បិតអូនណើ មិនអាចផ្ដល់ទឹកដោះដល់នាងតូចបាន ។
ដោយឃើញសុខភាពរបស់កូនយ៉ាប់យ៉ឺនពេក មីងផាវក៏សំរេចចិត្ត យកភារាណើទៅព្យាបាលនៅមន្ទីរពេទ្យឯបាត់ដំបង ។
ជាច្រើនថ្ងៃកន្លងទៅ...
មេឃុំផែងសង្កេតឃើញមីងផាវចេញទៅផ្សារធំរាល់ព្រឹក ហាក់ដូចជា ចាប់មានការសង្ស័យក៏លួចធ្វើដំណើរទៅតាម ស្រាប់តែគាត់ប្រទះឃើញ មីងផាវមកមើលថែទាំភារាណើឯមន្ទីរពេទ្យ ហើយក៏ប្រទះនាងកវីនៅបំរើ ធិតាយើងទីនោះដែរ :
- យ៉ាងម៉េចហើយ អាល្អិត? នេះឬដែលឯងថា ឯងនឹងថែទាំនាងណើ អោយបានល្អបំផុត? ឥលូវឃើញទេ? នាងណើវាយ៉ាងម៉េចដែរ? មុខដូច ឯង មានសមត្ថភាពអីនឹងរក្សានរណាបានទៅ?
មេឃុំស្រដីចំអកអោយទៅកវី ។ មាណពព្រួសំដីនេះហើយឈ្ងោកមុខ នៅស្ងៀម មិនតវ៉ាអ្វីទេ ត្បិតពេលនោះ នាយគ្មានកម្លាំងតតាំងនឹងនរណា ឡើយ ក្រៅតែពីការព្រួយបារម្ភចំពោះសុខទុក្ខរបស់ភារាណើតែម្យ៉ាង ។ គេ នៅបីទារកធ្វើមុខស្លូតក្រៀមក្រំក្បែរចុងជើងរបស់ទេពអប្សរកំពូលដួងចិត្ត របស់គេ ។ បន្តិចមក មេឃុំក៏ហៅលោកគ្រូពេទ្យមកសាកសួរដំណឹង ។ មែនហើយ! ថ្វីបើគាត់មាត់អាក្រក់បន្តិចមែន ប៉ុន្ដែមើលទៅកិរិយារបស់ គាត់ ពេលនេះក៏ហាក់ដូចជាបារម្ភពីភារាណើណាស់ដែរ ។ លោកគ្រូពេទ្យ បានជំរាបថា នាងមានជំងឺដុះសាច់ក្នុងក្រពះ ត្រូវទៅធ្វើការព្យាបាលជា ពិសេសនៅមន្ទីរពេទ្យឯភ្នំពេញជាប្រញាប់ បើមិនដូច្នេះទេ នាងប្រាកដជា ចៀសមិនរួចពីសេចក្ដីស្លាប់ឡើយ ។
នៅខាងក្រៅមន្ទីរពេទ្យ មេឃុំផែងបានហៅនាយកវីអោយមកជួប ដោយទុកអោយមីងផាវនៅមើលថែកូនស្រីនៅខាងក្នុងតែពីរនាក់ :
- យើងចង់សុំឯងរឿងមួយបានទេ?
- បាទ! ពុកមេឃុំមានការអ្វីដែរទៅ?
- គឺយើងនឹងយកភារាណើទៅព្យាបាលនៅមន្ទីរពេទ្យជំនាញឯភ្នំពេញ ត្បិត ជំងឺរបស់នាងធ្ងន់ធ្ងរមិនអាចអែអង់បានឡើយ ។
- ស្រេចតែពុកមេឃុំចុះ បាទ!
- មិនងាយដល់ម្លឹងទេ នាយអើយ! គឺយើងនៅមានរឿងមួយទៀត គឺថា បើយើងព្យាបាលនាងជាសះស្បើយ យើងទុកអោយនាងរៀននៅទីនោះ ដើម្បីបញ្ចប់ការសិក្សា ហើយឯងត្រូវសន្យាថាមិនត្រូវទៅរំខានជីវិតរបស់ នាងនៅទីនោះជាដាច់ខាត រហូតដល់គេរៀនចប់ ។
- ហេតុអ្វីពុកចាំបាច់ធ្វើដល់ម្លឹង? ហើយចុះកូនតូចរបស់នាងនោះ មិនត្រូវ បែកកូនបែកម្ដាយហើយទេហ៎?
- ឯងជាឪពុក ឯងមើលវាទៅ! ឃើញទេ? ដោយសារតែភាពក្រីក្រអវិជ្ជា

អត្តខាត់នេះហើយ ដែលធ្វើអោយឯងទាល់ច្រក ដោះស្រាយបញ្ហាជីវិត គ្រួសារយ៉ាងវេទនាខ្វះមុខខ្វះក្រោយ ។ នាងណើមិនត្រូវមកលលង់ភក់ជ្រាំក្នុង ជីវិតដ៏កំសត់ជាមួយឯងទេ ។ គេត្រូវតែមានអនាគតល្អ ហើយអនាគត នោះត្រូវតែចាប់ផ្តើមសាងពីឥលូវនេះទៅ ទាន់គេនៅក្មេង គេនៅមាន ឱកាស បើមិនដូច្នោះទេ ឱកាសនឹងរត់ចោលគេហើយ ហើយនាងក៏នឹងមាន ជីវិតលិចលង់ដូចឯងសព្វថ្ងៃនេះអញ្ចឹង ។

- ពុកមេឃុំ! នេះមិនខុសពីការចាប់ពង្រាត់កូនចៅបំបែកគ្នាទេ...

- ទោះជាយ៉ាងណា ក៏ឯងនៅតែព្រាត់ភារាណើដូចតែគ្នាហ្នឹង! បើឯងមិន ស្តាប់យើង យើងនឹងបញ្ឈេរភ្នែកមើលនាងណើរហូតឈឺស្លាប់នៅពេទ្យនេះ តែម្តង! ពេលនោះ ឯងនឹងព្រាត់នាងរហូតគ្មានថ្ងៃណានឹងជួបវិញឡើយ ។ តែបើឯងស្តាប់យើង នាងនឹងមានឱកាសរស់រានមានជីវិតសាជាថ្មីមកវិញ ម្តងទៀត ។ ឥលូវនេះ ឯងសំរេចចិត្តទៅ ថាឯងជ្រើសរើសផ្លូវណា? ចង់ឱ្យ ភារាណើស្លាប់ឬចង់អោយនាងរស់រានមានជីវិត?

កវីឈ្ងោកមុខនិយាយលែងចេញ ។ ទឹកភ្នែកពីរតំណក់បានហូរស្រក់ចុះ ពីកែវភ្នែកមាណពយើងយ៉ាងស្ងៀមស្ងាត់ ។ មែនហើយ ពេលនេះ កវីមាន អារម្មណ៍ថា បេះដូងរបស់នាយកំពុងត្រូវគេមួលផ្តាច់ពីដើមទ្រូងរបស់នាយ ហើយ ។ គេឈឺចាប់ណាស់ តែគេក៏បារម្ភពីសុខទុក្ខរបស់ភារាណើខ្លាំងណាស់ ដែរ ។ គេឈ្ងោកមុខសម្លឹងទារកតូចរបស់នាង ដែលគេបីនៅក្នុងដៃ ព្រឹក ល្ងាច១ តាំងពីនាងប្រសូត្រមក ដោយអារម្មណ៍ឈឺផ្សារកទីបំផុតគ្មាន... តើ អោយគេសំរេចចិត្តយ៉ាងណា? តើគេត្រូវជ្រើសរើសយក ព្រាត់ស្លាប់ ឬក៏ព្រាត់រស់?... មួយស្របក់ក្រោយមក គេក៏លើកទារិកាមកផ្ទាប់នឹង ថ្ពាល់របស់គេហើយស្រដីខ្សិប១ទៅនាងថា :

- អោយពុកសូមទោសណាកូនណា! ពុកមានចំលើយតែមួយទេ ជូនលោក តារបស់កូន.. នោះគឺ ពុកត្រូវតែសំរេចចិត្តជូនម៉ែណើទៅលោកតាវិញហើយ ធ្វើបែបនេះ... កូននឹងព្រាត់ពីម្តាយរបស់កូនមែន.. តែថ្ងៃណាមួយ កូននឹង មានឱកាសជួបម៉ែវិញមិនខាន... ពុកមិនចង់អោយកូនត្រូវព្រាត់ម៉ែមួយ ជីវិតទេ... កូនត្រូវតែមានម៉ែហៅដូចគេដូចឯង...!!

កវីអោបទារកផ្ទាប់នឹងដើមទ្រូងដោយដួងចិត្តអាណិតអាសូរ...!!

នៅទីបំផុត ភារាណើក៏ត្រូវឃ្លាតចេញពីមាណពនិងកូនស្រីរបស់នាង ដោយមិនបានលាគ្នាមួយម៉ាត់ ត្បិតនៅគ្រានោះ ធិតារបស់យើងឈឺធ្ងន់ រហូតដល់បាត់ស្មារតីទៅហើយ ។ កវីបីកូនសម្លឹងតាមមើលរថយន្តដែលផ្ទុក មាណវីចេញឆ្ងាយទៅ១ រហូតដល់ដាច់កន្ទុយភ្នែក... :

- សូមព្រះជាម្ចាស់ជួយតាមថែរក្សាអូនណើផង!... សូមអោយអូនឆាប់បាន ជាសះស្បើយណាកំពូលដួងចិត្តរបស់បង..!

ព្រាត់ដើម្បីជួប...

ស៊ូលះបង់ចិត្តត្បិតសង្ឃឹម ថ្ងៃក្រោយញញឹមឃើញអូនទៀត
សុខចិត្តបូជាមិនចង្អៀត ដើម្បីស្រីនាថជាសះស្បើយ ។
សូវយើងព្រាត់រស់មិនអោយស្លាប់ ព្រាត់ព្រោះវិបត្តិមិនអាចស្រាយ
ព្រាត់ព្រោះបងក្រ បងសែនស្តាយ នោមឆាយអភ័យផងណាអូន ។
សុខចិត្តព្រលែងអោយអូនទៅ ទោះចិត្តបងនៅក្រៀមស្រពោន

ហឫទ័យព្រួយណាស់កែវនឹមនួន ទ្រូងស្មើរប្រេះសូន្យនឹកអូនម្នាក់ ។
សូមសះស្បើយឆាប់ណាំអូនណាំ បងចាំធិតាកែវវរលក្ខណ៍
ស្រស់ទេពអប្សរដែលបងស្នេហ៍ ដីបែកមេឃបាក់ក៏ស៊ូចាំ...

ចាប់តាំងពីថ្ងៃនោះមក កវីក៏លែងបានទទួលដំណឹងអ្វីទាំងអស់ពីធិតា យើងឡើយ ។
គេក៏រស់នៅស្ងៀមស្ងាត់ជាមួយនឹងកូនស្រីតូចតែពីរនាក់ យ៉ាងកំសត់ ប៉ុន្តែ... គេមិនបានលះបង់នូវក្តីសង្ឃឹមក្នុងការរង់ចាំទេពអប្សរ ភារាណីរបស់គេឡើយ ត្បិតគេជឿជាក់ក្នុងចិត្តយ៉ាងមុតមាំថា ថ្ងៃណាមួយ ឆវីនឹងវិលមករកកូនស្រីរបស់នាងជាមិនខាន ។

រីឯភារាណីវិញក៏ដូចគ្នាដែរ ។ ៣ខែក្រោយពីព្យាបាលជំងឺបានជាសះ ស្បើយមក
នាងក៏ត្រូវពុកមេឃុំបង្ខំអោយស្នាក់នៅភ្នំពេញរៀនសូត្រសា ជាថ្មី ក្នុងគោលបំណងអោយនាងស្វែងរកអនាគតថ្មី ដែលប្រសើររុងរឿង ជាងជីវិតដ៏យ៉ាប់យ៉ឺនរបស់នាងឯស្រុកស្រែជាមួយនាយកវី ដែលមេឃុំ មិនស្គាល់ ឬក៏ស្គាល់យ៉ាងស្រពិចស្រពិលបំផុតនោះ ។

0000000000000000000

00000

0

# វគ្គទី១១
# ពិរុទ្ធជន

នៅក្នុងគេហដ្ឋានរបស់កវី...

មេឃុំផែងធ្វើទឹកមុខស្ងួត កាលបើបានស្តាប់នូវប្រវត្តិទាំងឡាយដែល កវីរៀបរាប់កន្លងមក ។ ភ្លាមនោះ ស្រាប់តែគាត់មានទឹកភ្នែករលីងរលោង ឡើង... ។ ទាំងមីងផាវ ទាំងភារាណី ទាំងកវី មានការភ្ញាក់ផ្អើលក្នុងចិត្ត ណាស់ ដែលឃើញកិរិយារបស់មេឃុំប្រែប្រួលយ៉ាងចម្លែកបំផុត ត្បិតគេ មិនដែលឃើញគាត់បង្ហាញនូវភាពទន់ភ្លន់របស់គាត់ចំពោះនរណា ម្តងណា ឡើយ ។ នេះជាលើកដំបូងហើយ ដែលគាត់បានបង្ហាញចេញមកនៅចំពោះ វត្តមានរបស់អ្នកទាំងបីរូប ។ មេឃុំផែងនៅស្ងៀមស្ងាត់មួយសន្ទុះធំ ទើប មានប្រសាសន៍ថា :

- កវី!... មកជិតយើងបន្តិចមក៍..!

កវីលូនទៅជិតមេឃុំ អង្គុយបត់ជើងឈ្ងោកមុខនៅស្ងៀម ។ មេឃុំក៏ លូកដៃទៅអង្អែលក្បាលកូនប្រុស រួចហើយក៏សំរក់ទឹកភ្នែកច្រោក :

- កវី! អោយពុកសូមទោសកូនផង.. ដែលពុកចំណាំកូនមិនបាន ព្រោះអី កាលនោះពុកគ្រាន់តែនឹកសង្ស័យប៉ុណ្ណោះថាជាកូន តែដោយពុកជាមនុស្ស ជោរនឹងមោទនភាពរបស់ខ្លួនឯង ពុកក៏ពើមិនសួរកូនអោយដឹងការពិត រហូតមក ។ ឥលូវនេះ ពុកស្តាយក្រោយណាស់ ដែលពុកមិនបានចិញ្ចឹម បីបាច់ថែរក្សាកូនអ្វីសោះ តែកូននៅតែស្គាល់ នៅតែគោរពពុកជាពុក ដដែល ។ ពេលនេះ ពុកពិតជាមានវិប្បដិសារីខ្លាំងណាស់ ដែលពុកបានធ្វើ បាបសាច់ឈាមរបស់ខ្លួន អស់រយៈពេលជាយូរ...

កវីអោនក្បាលនៅស្ងៀម មិននិយាយតបអ្វីវិញទេ ។ មីងផាវឃើញ បរិយាកាសហាក់ដូចជាក្រៀមក្រំពេកទើបពោលឡើងថា :

- ណ្ហើយចុះ! ទោះបីជាយ៉ាងណា ក៏ពុកវាត្រូវតែត្រេកអរហើយត្រូវមាន មោទនភាពចំពោះគេដែរ ដែលគេបានសាងខ្លួនមកជាមនុស្សល្អ ស្គាល់ខុស ត្រូវហើយមិនអកតញ្ញូចំពោះអ្នកអោយកំណើត ថ្វីបើគាត់មិនបានផ្តល់ការ កក់ក្តៅក្នុងជីវិតក៏ដោយចុះ ។ ពុកវាឃើញទេ? ដោយសារតែភាពកតញ្ញូ របស់គេនោះហើយ ដែលជាហេតុនាំអោយគេរត់មកជួយពុកវានៅពេល មានគ្រោះភ័យ ។ នេះបើសិនគេជាអ្នកមើលបំណាំ ម៉្លេះសម.. ហ៊ឺ...

មែនហើយ... បេះដូងរបស់មេឃុំពេលនេះកំពុងទទួលទណ្ឌកម្មវិញ ហើយ..
នោះគឺវិប្បដិសារីដែលគាត់ធ្លាប់ជាមនុស្សឆេវឆាវយកអំពើហឹង្សា ជាគោលដោះស្រាយរឿងរ៉ាវក្នុងជីវិត ទីបំផុត គឺខ្លួនគាត់ទេតើដែលត្រូវ ទទួលការឈឺចាប់ជាលទ្ធផល ។ មិនតែប៉ុណ្ណោះ សមាជិកក្រុមគ្រួសារដែល នៅក្រោមការគ្រប់គ្រងរបស់គាត់ក៏គ្មានសេចក្តីសុខក្នុងជីវិតដែរ ។ យប់ នេះ
មេឃុំផែងចេះស្រក់ទឹកភ្នែកជាលើកដំបូងបង្អស់ក្នុងជីវិត ។ សូម្បីតែ ក្នុងសម័យកាលជំនាន់កម្មុយនិស្ត ១៩៧៥-១៩៧៩ ស្លាប់បងស្លាប់ប្អូន ស្លាប់ឳពុកម្តាយ ក៏មេឃុំផែងមិនដែលស្រក់ទឹកភ្នែកមួយដំណក់ផង ។ ប៉ុន្តែ ថ្ងៃនេះ
គាត់ក៏បានក្លាយជាមនុស្សទន់ជ្រាយបំផុត ទន់ជ្រាយព្រោះតែគាត់ បានទទួលលទ្ធផលគួរអាមាសពីការប្រព្រឹត្តទាំងឡាយរបស់គាត់ ដែលសុទ្ធ តែកើតឡើងដោយការខ្វះសតិ ការប្រកាន់ភាពមានរឹងត្អឹងយកតែពីឈ្នះ ដោយមិនគិតពីចិត្តពីអារម្មណ៍របស់អ្នកដទៃ ហើយមិនព្រមពិចារណា វែក ញែកហេតុផលឱ្យច្បាស់លាស់ ។ តើហេតុអីទៅ ដែលធ្វើអោយមេឃុំផែង ក្លាយជាបុគ្គលបែបនេះ បើកាលដើមឡើយ គាត់ក៏ជាមនុស្សដ៏ល្អមួយរូប នឹងគេដែរ?

ការពិត មេឃុំមានជំងឺពិរោធក្នុងចិត្តដោយសារការកៀបសង្កត់ផ្លូវចិត្ត ក្នុងរបបកុម្មុយនិស្ត
មានការឈឺចាប់ក្នុងចិត្តជាច្រើនដែលគាត់និយាយមិន ចេញ... ការឈឺចាប់ដែលគាត់ត្រូវព្រាត់សាច់ឈាមអស់រលីងហើយក៏មិន ដឹងថាគេព្រាត់ស្លាប់នៅទីណា ឫព្រាត់រស់នៅទីណា... ជាពិសេសចំពោះ បងប្អូនដែលព្រាត់គ្នាឥតដំណឹង
មិនដឹងថាគេស្លាប់ឫគេរស់ ។ ក្រោយមក ការរកស៊ីជួញដូរជាអ្នករត់ពន្ធ ក៏បាននាំអោយគាត់ទទួលរងការធ្វើបាប ព្រៃផ្សៃពីពួកចោរព្រៃនិងការប្រយុទ្ធគ្នានៅទល់ដែនខ្មែរថៃ ។ ភាពសាហាវ យង់ឃ្នងទាំងឡាយដែលគាត់បានជួបប្រទះ គឺនៅមានជីវិតរស់រវើកក្នុង អារម្មណ៍របស់គាត់ជានិច្ច ។ តែដោយមីងវ៉ាន់ជាប្រពន្ធជាមនុស្សមិនសូវ មាត់ក
មេឃុំក៏មិនសូវបានរំខាននាំគ្នាជជែកពីអ្វី ដើម្បីបន្ធូរអារម្មណ៍ ម៉ូម៉ៅទេ ទើបពូផែងចេះតែរកផ្លូវចេញទៅក្រៅ
រកវិធីបន្ធូរអារម្មណ៍ពី មនោរម្មណ៍វិបត្តិដែលតែងតែដុតរោលក្នុងទ្រូងរបស់គាត់ជាប្រចាំ ។ លុះ ក្រោយៗមក
គាត់ក៏ចេះតែលង់ខ្លួនទៅៗ ក្នុងភាពរាយមាយក្នុងជីវិត រហូតដល់ថ្ងៃមួយ ភាពឆេវឆាវរបស់គាត់បានជំរុញឱ្យកូនប្រពន្ធឃ្លាតចេញ ពីជីវិតរបស់គាត់ទៅទៀតយ៉ាងទាន់ហន់ ។ ពេលនោះ មេឃុំបានក្លាយជា មនុស្សក្រោមអនុភាពរបស់ស្រាស្រីល្បែងអស់ជាយូរឆ្នាំ ទម្រាំតែគាត់បាន មកជួបមីងផាវដែលជាអ្នកស្រុកក្បែរភូមិគ្នា ។ នោះក៏ដោយសារមីងផាវ ជាស្រីមេម៉ាយប្តីស្លាប់
ជាមនុស្សមានទឹកចិត្តល្អ ធ្លាប់ជួយធ្វើអន្តរាគមន៍ ជាច្រើនដង ពេលមេឃុំឃ្លាតចាកសតិ រហូតដល់នាំគាត់ចូលវត្តវ៉ា ផ្តាច់ជំងឺ ញៀនបីយ៉ាង ស្រីស្រាល្បែងអស់ពីខ្លួនមេឃុំម្តងបន្តិចៗ ។ ប៉ុន្តែ ជំងឺ ឆេវឆាវមិនព្រមមានល្បឿនស្រកស្រុតថមថយ
អោយសមចិត្តអ្នកដែល រស់នៅជុំវិញមេឃុំសោះ គឺគាត់នៅមានសល់ ភាពគំហកកំហែងបន្តិចបន្តួច រហូតមកដល់សព្វថ្ងៃនេះ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏គាត់មិនមានស្ពាយ ពិរោធដូចកាលពីមុនទៀតឡើយ ។ ម្យ៉ាងទៀត តាំងពីមីងផាវនិមន្តព្រះ ចៅអធិការវត្តមកបិណ្ឌបាត្រទោសៈពីមេឃុំដល់ផ្ទះគាត់ម្តងមក មេឃុំ ហាក់ដូចជាថ្នមចិត្តខ្លួនមិនទោសៈដូចពីដើមទៀតឡើយ ។

នៅចំពោះមុខលោកតាមេឃុំនិងយាយផាវ កុមារីសោភានិងសាវេត បានលុតជង្គង់ ថ្វាយបង្គំជីតាជីដូន
ទទួលនូវពរជ័យពីគាត់យ៉ាងប្រសើរ :

- ចៅស្រី! ចៅប្រុសអើយ! តាពិតជារំភើបចិត្តណាស់ ពេលដែលតាឃើញ

ចៅទាំងពីជាក្មេងល្អ គួរអោយសរសើរ (មេឃុំផែងស្រដីទាំងអួលដើមក)

ពុករបស់ឯងពិតជាអប់រំចៅបានល្អត្រឹមត្រូវជាងតាឆ្ងាយណាស់...

មានប្រសាសន៍ហើយ គាត់ក៏ស្រវាអោបចៅទាំងពីររូបដោយដួងចិត្ត អាណិតអាសូរ ។ បន្ទាប់មក

កវីក៏នាំមេឃុំមកបង្ហាញនូវហ៊ឹងតម្កល់ធាតុ របស់មីងវ៉ាន់ និងពូផល ។

- វ៉ាន់អើយ! អហោសិកម្មអោយបងផងណា៎ ដែលបងមានអគតិចំពោះ អូននិងកូន

ធ្វើអោយវ៉ាន់ត្រូវឈឺចិត្តរហូតដល់ស្លាប់បាត់បង់ជីវិត ។ ពេល នេះ ពិតមែនតែជីវិតរបស់បងកាន់តែខ្លីទៅមែន

តែបងសន្យាថានឹងថែកូន ចៅរបស់វ៉ាន់អោយបានល្អបំផុត មិនឱ្យវិញ្ញាណក្ខន្ធ័របស់វ៉ាន់នៅវិលវល់

វង្វេងដោយការបារម្ភពីពួកគេឡើយ ។ សូមអោយវិញ្ញានក្ខន្ធ័របស់អូនបាន ឆ្លងទៅដល់សុគតិភពផងចុះ...

រួចហើយ មេឃុំក៏បែរសម្លឹងទៅកូនប្រុសដែលអង្គុយនៅពីក្រោយខ្នង ទើបមានប្រសាសន៍បន្តទៀតថា :

- ផលអើយ! ផែងមកសូមទោសឯងហើយ សូមអហោសិកម្មអោយផង យើងផងណា៎

ដែលយើងមិនដែលនឹកគិតអំពីសេចក្តីល្អរបស់ឯងដែលមាន ចំពោះយើង នាងវ៉ាន់ និងកូនវៃ ។ ពេលនេះ

យើងមកសុំខមាទោសហើយ! សូមអោយព្រលឹងឯងបានទទួលដឹងឮនូវការទទួលទោសកំហុសពីយើង រួច

សូមអោយព្រលឹងឯងបានស្ងប់សុខឯស្ថានសុគតិភពផងដូចគ្នា!

មានប្រសាសន៍ចប់ មេឃុំក៏អោនថ្វាយបង្គំបីដងដោយដួងចិត្តជ្រះ ស្រឡះអំពីភាពសង្ស័យនិងពិរោធ

ដែលធ្លាប់មានទាំងអំបាលម៉ាលពីអតីត កាល ។ ចំណែកមីងផាវិញ ក៏ហាក់ដូចជាមានអារម្មណ៍ថាធូរស្រាលក្នុង ចិត្តច្រើនណាស់

កាលបើឃើញមេឃុំបន្ទន់តិរិយាយ៉ាងដូច្នោះ ។ ពេលនោះ គាត់គិតថា ថ្ងៃនេះជាថ្ងៃដែលក្រុមគ្រួសាររបស់គាត់ មានសុភមង្គលយ៉ាង

ធំធេងបំផុត ។

ថ្ងៃមួយ...

កវីបើកម៉ូតូត្រលប់មកពីត្រើយម្ខាងស្ទឹងមកវិញ ស្រាប់តែប្រទះនឹង ភារាណីដែលកំពុងរៀបចំខ្លួនចេញទៅក្រៅ :

- អូនណី! បំរុងទៅណាហ្នឹង?

- បងកវី! សូមផ្ញើកូននិងពុកម៉ែផង! ខ្ញុំទៅក្រុងបាត់ដំបងម៉ាភ្លែត?

- ជាកិច្ចការទាក់ទងនឹងសាលាមែនទេ អូនណី?

នាយសួរដូច្នេះ ត្បិតយល់ថាជិតដល់ពេលបវេសនកាលវិញហើយ ។ ស្រាប់តែភារាណីស្រដីថា :

- អត់ទេ! ជាកិច្ចការផ្ទាល់ខ្លួនបន្តិចបន្តួច ។

- អញ្ចឹងបងជូនអូនទៅណា៎!

ស្រាប់តែធិតាយើងបែរសម្លឹងមុខនាយ មួយស្របក់ទើបស្រដីថា :

- បើដូច្នោះ បងសន្យានឹងអូនមួយសិនមក៏!

- សន្យាអីទៅ?

- គឺរក្សាចិត្តអោយត្រជាក់ មិនឆេវឆាវ!

ករីញញឹមហើយក៏ញញឹមឡើង :

- ស្លាប់ហើយ! អូនណើឃើញបងជាមនុស្សឆេវឆាវតាំងពីអង្កាល់ហ្នឹង?

- គឺ ណើសុំការពារទុកមុនណា៎។

- កំពុងមានរឿងអ្វីហ្នឹង អូនណើ? (ករីសួរដោយមិនអស់ចិត្ត)

- បន្តិចបងនឹងដឹងហើយ។

ប្រហែល២០នាទីក្រោយមក អ្នកទាំងពីរក៏បានមកដល់មុខការិយា ល័យរបស់លោកហារ៉ាន់ ដោយមានអ្នកកាសែតឈរចាំអ៊ូអរ ថៃមទាំង មានអេក្រង់សំពត់ស សម្រាប់បញ្ចាំងកុន លើកតម្លើងនៅលើជញ្ជាំងរថយន្តដ៏ធំមួយដែលចតនៅខាងស្តាំថ្នល់។ ពេលនោះ ករីមិនយល់ទេ ថាថ្ងៃ នោះមានព្រឹត្តការណ៍អ្វី។ នាយក៏ខ្សិបសួរទៅមាណវីថា :

- គេធ្វើកូដកម្ម ឬបាតុកម្មអហឹង្សាអីប្រឆាំងនឹងក្រសួងមួយនេះមែនទេ បានជាមនុស្សមកឈរណែនអ៊ូអរយ៉ាងនេះ?

- គឺជារឿងសំខាន់ដែលទាក់ទងនឹងផ្ទះរបស់យើងណា៎បង! បងតាមអូន មក៏ ហើយសូមបងធ្វើជាបង្អែកផ្លូវចិត្តអោយភារាណើផង!

ភ្លាមនោះ ធិតាក៏ដើរចូលទៅរកលោកហារ៉ាន់ដែលកំពុងឈរនៅចាំ មុខការិយាល័យស្រេចដោយមានអង្គរក្ស និងក្រុមតម្រួតឯកសណ្ឋានជា ច្រើននាក់ទៀតនៅហែហមទីនោះផង។

- មកដល់ទាន់ពេលវេលាដូចការណាត់មែន ភារាណើ!

- ចាំសមែនហើយ ហើយសង្ឃឹមថា ថ្ងៃនេះ លោកនឹងជួយរក្សាភាពត្រឹម ត្រូវយុត្តិធមិដល់យើងដែរ។

រួចហើយនាងបែរមើលជុំវិញខ្លួន ធ្វើទឹកមុខងឿងឆ្ងល់ហើយសួរថា :

- ចុះឯណាមិនឃើញវត្តមានរបស់ហារិន?

- គេមិននៅទេ ទៅបរទេសយូរថ្ងៃហើយ...

- ទៅបរទេសយូរថ្ងៃហើយ? នេះគឺបំពានសន្យាអោយច្បាស់ទែងតែម្តង!

- មិនបានបំពានទេ.. គឺគេមានការបន្ទាន់ មិនអាចរង់ចាំបាន...

- មានការផ្ទាល់ខ្លួន ឬកំពុងតែគេចខ្លួន ពីការកាត់ទោសកំហុសនៅចំពោះ មុខពលរដ្ឋសាធារណៈ?

- កុំចេះតែថា! កូនប្រុសរបស់យើងមិនបានគេចខ្លួនទេ!

- បើគេមិនបានគេចខ្លួនទេ ឥចឹងមានតែលោកជាអ្នកជន្លៀសគេចេញពីទី នេះ? ហើយធ្វើដើម្បីអ្វី? ដើម្បីបិទបាំងក្តីអាមាសរបស់គ្រួសារដោយសារ កូនបានប្រព្រឹត្តអ្វីខុសនោះមែនទេ? ហើយបើមិនមានចំណុចខ្សោយទេ ហេតុអ្វីបានជាគេគេចខ្លួនមិនហ៊ានប្រឈមនឹងការពិត នៅពេលនេះផង?

- នែ៎ យើងជាមន្ត្រីថ្នាក់ឧត្តមសេនីយ និយាយអ្វីអោយគិតមុខគិតក្រោយ ផង នាងច្រមក់! កុំឆ្លៀតផ្ទៃផ្កាប្រមាថយើង.. តិចលោថាយើងមិនប្រាប់!!

- អូហ៏! លោកមានឋានន្តរសក្តិដល់ឧត្តមសេនីយផងហ្អែស? យី! ធ្វើធំ ដល់ថ្នាក់ហ្នឹងហើយ ហេតុអ្វីយាមកូនមិនបាន
បណ្តោយឱ្យគេបំពានការ ណាត់ ដោយលួចរត់គេចខ្លួនទៅបរទេសដូច្នេះបាន? ធ្វើឧត្តមសេនីយ៍ធ្វើស្អី
បើប្រដៅកូនចៅរបស់ខ្លួនមិនស្តាប់ផង?
- ឈប់ភ្លាម! នាងភារាណី!
- មិនឈប់! ដរាបណាដែលនាយហារិនគេចខ្លួន មិនហ៊ានបង្ហាញមុខនៅ ពេលជំរះបញ្ជី វែកញែករកខុសរកត្រូវ គេគឺជាអ្នកចាញ់
គេគឺជាអ្នកដែល កំពុងលាក់ចំណុចខ្សោយ ហើយឪពុករបស់គេ ក៏ខ្វះសេចក្តីក្លាហានគ្រប់
គ្រាន់ នឹងទទួលការពិតដែលទាក់ទងនឹងអំពើស្មោកគ្រោករបស់កូន!!
- យើងថាអោយឈប់មាត់!
- នេះលោកបំរុងបំបិទមាត់ខ្ញុំ ដើម្បីលាក់ចំណុចខ្សោយរបស់កូនមែនទេ? តែភារាណីសូមបញ្ជាក់ប្រាប់ទៅចុះថា ពេលនេះ
ទោះបីជាលោកសម្លាប់ខ្ញុំ បំបិទមាត់ក៏យឺតពេលដែរ ត្បិតភស្តុតាងទាំងឡាយដែលខ្ញុំមាន បានធ្លាក់
ទៅក្នុងដៃសាធារណជនអស់ហើយ ហើយគេនឹងជួយថ្កោលទោសកូនប្រុស របស់លោកជំនួសខ្ញុំគ្រប់ៗគ្នា... លោកហារ៉ាន់
ត្រៀមខ្លួនហើយឬនៅ?

ពេលនោះ លោកហារ៉ាន់បិទមាត់ដូចគេចុក ត្បិតដឹងថា មាណវីបាន រៀបជើងព្រួលការពារខ្លួនរបស់នាងជាមុនស្រេច។
បន្តិចមក នាងក៏ស្រដី បន្តថា :
- ល្ហើយចុះ! ខ្ញុំសូមទុកឱកាសជូនលោកកែសម្រួលសាច់រឿងបន្តិច គឺខ្ញុំ មានសំណូមពរពីរយ៉ាងជូនលោកជ្រើសរើស។ មួយគឺ
លោកអាចលាក់រូប ហារិនជាកូនប្រុសតទៅទៀត ដោយមិនបាច់អោយគេមកទទួលកំហុស
ចំពោះការប្រព្រឹត្តដ៏អប្រិយរបស់គេក៏បានដែរ តែលោកត្រូវរងទទួលការ
ថ្កោលទោសជំនួសហារិនពីបទឃុបឃិតលាក់ខ្លួនជនឧក្រិដ្ឋ។ ទីពីរ គឺ ក្នុង
ឱកាសដែលលោកស្ថិតនៅក្នុងឯកសណ្ឋានបំរើជាតិនិងពលរដ្ឋ លោកត្រូវ ប្រកាន់ខ្ជាប់នូវគតិយុត្តិធមិ
ហ៊ានថ្កោលទោសជនណាដែលប្រព្រឹត្តល្មើស ច្បាប់ដោយឥតលំអៀង។ ពេលនេះសូមលោកជ្រើសរើសមួយទៅ! ម្យ៉ាង ទៀត
អ្នកកាសែតសារពតិមាននឹងអ្នកការីទូរទស្សន៍ជាតិក៏បានមកដល់ទី នេះជាច្រើននាក់
ដើម្បីស្រង់យកព្រឹត្តការណ៍សំខាន់ថ្ងៃនេះផ្សាយជាគំរូដល់
បុគ្គលបំរើជាតិទាំងឡាយផង។

មែនហើយ... មើលទៅ ភារាណីក្លាហាន ហើយមានវេហារប្រកប
ដោយការគិតរាក់ជ្រៅ ល្មមធ្វើអោយលោកហារ៉ាន់ញ្ញោចស្មាញ៉ូរទ្រូងបន្តិច ដែរ
ដែលត្រូវគាំងសតិរកនឹកឆ្លើយនាងវិញសឹងតែមិនរួច។ ក្រលេកទៅ ធ្លាខាងមុខការិយាល័យវិញ អ្នកកាសែតឈរត្រៀបត្រា
មានប្រដាប់ថត សម្លេង មានទាំងកាម៉ារាតូចធំ កាម៉ារ៉ាទូរទស្សន៍បញ្ឈរចាំស្រេច។ ដោយ

ការទើសទាល់លោកក៏បែរខ្សិបទៅអង្គរក្ស័មួយរូប រួចហើយគេឃើញ បុរសនោះដើរចូលទៅក្នុងការិយាល័យ
រួចអូសដៃនាយហារិនចេញមក៍ :
- លោកប៉ា! មានការអីហ្នឹង? (ហារិនស្រែកឡើង)
- ឈប់មាត់រួចរក្សារបៀបរៀបរយបន្តិច ត្បិតឯងមិនមែនជាក្មេងបៀម
ដៃអោយប៉ាទទួលខុសត្រូវជីវិតរបស់ឯងរហូតតទៅទៀតនោះទេ។ ថ្ងៃនេះ
ប្រហែលជាឯងត្រូវរៀនធ្វើមនុស្សធំអោយសមវ័យឯងវិញហើយ!

គ្រាន់តែក្រលេកឃើញវត្តមានហារិនពេលណា ភារាណើក៏ញញឹមឡើង ចៃដន្យហារិនមិនបានញញឹមតបវិញឡើយ.. គឺគេកំពុងតែសម្លក់នារីយើង សឹងតែស៊ីសាច់ទាំងរស់តែម្តង។ ប៉ុន្តែមាណវីឈរធ្វើមិនដឹង រួចហើយក៏បែរទៅក្រោយសម្លឹងអ្នកកាសែតហើយក៏ពោលឡើងថា :

- ពេលនេះ សូមអញ្ជើញមិត្តការីចាក់បញ្ចាំងកាសែតវិដេអូមួយនោះ!

ភ្លាមនោះ ផ្ទាំងសំពត់សដែលចងនៅលើជញ្ជាំងរថយន្តក៏បង្ហាញរូប ភាពយ៉ាងភ្លឺច្បាស់ នូវសកម្មភាពមួយដែលមានមនុស្សបួននាក់ចូលរួម។ បី នាក់ពាក់អាវពណ៌ប្រផេះខ្លះ ខៀវខ្លះ តែម្នាក់ខុសគេពាក់អាវពណ៌លឿង។ នោះគឺជារូបភាពវីដេអូដែលមិនមានកាត់ត និងថតដោយការីដែលមិនទាន់ មានការប៉ិនប្រសព្វ តែក៏យិតបានរង្វង់មុខបុរសម្នាក់ៗ យ៉ាងច្បាស់ទែង ថែមទាំងមានការពង្រីកនៅលើក្រណាត់សផង ធ្វើអោយអ្នកដែលឈរ មើលនៅទីនោះទាំងប៉ុន្មានស្គាល់ច្បាស់ថាជានរណា។ រីឯលោកហារ៉ាន់វិញ លុះក្រលេកឃើញមុខជនពាក់អាវពណ៌លឿងនៅក្នុងវីដេអូភ្លាមក៏ឧទាន ឡើងថា :

- នាយហារិន?... ហើយចុះឯងទៅធ្វើស្អីហ្នឹងកណ្តាលយប់អាធ្រាត កៀន ផ្ទះនរណាមិនដឹង?...

ភ្លាមនោះ គេឃើញហារិននិងគូកនកំពុងលើកធុងចាក់សាំងទៅលើ ជើងសសរ និងជញ្ជាំងផ្ទះ រួចហើយក៏ស្រវាឈើគូសពីបុរសម្នាក់ទៀត បញ្ឆេះឡើង ហើយបោះទៅលើប្រេងសាំងដែលហូរពាសពេញដីជុំវិញផ្ទះ។ អណ្តាតភ្លើងក៏ឆាបឆេះសន្ធៅឡើង រួចមកក៏ឃើញនាយហាក់ប្រួចជាមួយ គូកនចេញតាមដីចំហៀងផ្ទះបាត់ស្រមោលក្នុងភាពងងិតមួយ។ បន្តិចមក គេឃើញមនុស្សរត់ប្រសេចប្រសាចមកជួយពន្លត់ ហើយក៏ឃើញបុរសម្នាក់ ទទូរបាវទទឹកទៅអូសយកមនុស្សពីក្នុងអណ្តាតភ្លើងមក.. នោះគឺជាមេឃុំ ផែងរបស់យើង.. បន្តិចមក តួផ្ទះទាំងមូលក៏រលំដួលដល់ដី...

ទាំងអ្នកស្រុកដែលមកឈរមើលអ៊ូអរ ទាំងអ្នកកាសែត ទាំងលោក ហារ៉ាន់ សុទ្ធតែភ្ញាក់ផ្អើលនឹងទិដ្ឋភាព ដែលគេបានឃើញក្នុងការបញ្ចាំង វីដេអូអំបាញ់មិញនេះណាស់។ ភ្លាមនោះ លោកហារ៉ាន់ដែលភ្ញាក់ផ្អើល ជាងគេ ក៏បែរទៅសួរកូនប្រុសថា :

- មានអីដោះសារទេ ហារិន?

ហារិនធ្វើអេះអុញមួយភ្លែតក៏ឆ្លើយថា :

- នេះគឺជាវិដេអូកាត់ត!! សម័យនេះ នរណាក៏បង្កើតបានដែរ! ពួកវាមាន គំរោងផ្កាញ់ផ្កាលបំបាក់មុខខ្ញុំ.. ទើបគេលែងល្បិចបន្លំ អោយខ្ញុំក្លាយជា ជនដែលជាប់ទោសនៅក្នុងគម្រោងអាក្រក់របស់វា...

- ប្រហែលជាវិដេអូបង្កើតរូបភាពបានមែន តែវីដេអូប្រហែលជាមិនទាន់ អាចផ្តល់កំណើតមនុស្សបាននៅឡើយទេ មែនទេហារិន? (ភារាណីសួរ)

ហារិនព្រហើយនៅស្ងៀម មិនហ៊ានមាត់តបទេ។ មាណវីក៏សួរបន្តថា:

- ចំពោះបញ្ហារឿងជីវិតមនុស្ស និងការបង្កអោយមានភាពអាមាសក្នុង គ្រួសារដោយសារទង្វើដ៏ថោកទាបរបស់កូនប្រុស.. តើហារិនត្រៀមខ្លួន ហើយឬនៅ?

ភ្លាមនោះ ធិតាយើងក៏បែរមកលោកហារ៉ាន់ ហើយពោលទៅកាន់ លោកថា :

- លោកចាញ់ខ្ញុំមួយហើយលោកហារ៉ាន់! លោកបានសន្យាថារក្សាសុវត្ថិ ភាពអោយក្មេងស្រីរងគ្រោះ និងអោយរូបនាងខ្ញុំដែលជាសាក្សី តែលោក ធ្វើមិនបាន ដោយលោកបណ្តោយអោយកូនប្រុសរបស់លោកនាំគូកនទៅ ដុតផ្ទះរបស់នាងខ្ញុំចោល។ សំណាងល្អទេវតាលោកជួយជនរងគ្រោះដូចជា ពួកយើង.. ទើបខ្ញុំថតឧប្បដិហេតុថ្ងៃនោះបានដោយចៃដន្យពេលខ្ញុំសាក រៀនប្រើកាម៉ារ៉ាលេងលើកដំបូង។ ពេលនេះ ខ្ញុំនិងក្រុមគ្រួសារបានក្លាយ ទៅជាជនឥតទីជំរក ដោយសារតែអំពើឃ្នានិះរបស់ហារិន កូនប្រុសរបស់ លោកតែម្តង។ ពេលនេះ លោកយល់ហើយមែនទេ ថា សូម្បីតែកូនប្រុស ម្នាក់ លោកប្រដៅអោយគេដើរផ្លូវត្រូវមិនបាន តើលោកនឹងប្រដៅមនុស្ស ក្នុងសង្គម អោយដើរផ្លូវសុចរិតធ្វើម៉េចនឹងមានប្រសិទ្ធិភាពទៅ?

ពេលនោះ លោកហារ៉ាន់ស្លាក់កឆ្លើយនឹងសំនួរនារីលែងចេញ ត្បិតអី ពេលនោះ មានសាក្សីច្រើនណាស់ដែលនៅឈរជ្រងោៗ... លោកត្រូវតែ សម្រួលឥរិយាបថហើយ។

បន្ទាប់មក ធិតាយើងក៏បក់ដៃហៅអ្នកគ្រូពេទ្យ ដែលបានបូមយក ឈាមពីហារិនថ្ងៃមុនយកទៅវិភាគ ហើយអ្នកគ្រូពេទ្យក៏បានទៅដោះ ឈាមក្មេងម្នាក់នោះយកមកវិភាគដូចគ្នា ហើយនៅក្នុងការបូមឈាម វិភាគនោះទៀតសោត គេបានថតជាវីដេអូ ដោយមានសាក្សីជាអ្នក កាសែតចំនួនច្រើនទាក់ទៅជាមួយផង។ ថ្វីបើវីដេអូនោះបានកោសលប់ បំបាត់រង្វង់មុខក្មេងស្រីម្នាក់នោះ មិនអោយអ្នកស្រុកស្គាល់ថាជានរណា តែកវីដែលឈរនៅពីក្រោយខ្នងរបស់ភារាណី មិនមាត់មិនកយូរហើយ អាចចំណាំបានយ៉ាងច្បាស់ថានោះជាកុមារីសោភា របស់នាយតែម្តង។

ភារាណីក៏សួរទៅអ្នកគ្រូពេទ្យថា :

- តើអ្នកគ្រូអាចជំរាបបានទេថាការស្រាវជ្រាវរបស់អ្នកគ្រូយ៉ាងណាដែរ?

- គឺយើងធ្វើការនេះដោយយុត្តិធម៌ ដោយគ្មានសមាជិកទាំងសងខាងចូល រួមទេ គឺយើងធ្វើការវិភាគដោយឯករាជ្យ ដោយមានក្រុមអ្នកកាសែតគាំ ទ្រជាសាក្សីកណ្តាល។ យើងបានយកឈាមមកទាំងសងខាងពិនិត្យយ៉ាង ហ្មត់ចត់ ទើបបានទទួលលទ្ធផលថា លោកហារិនបានផ្តល់កំណើតទៅកុមារី

ម្នាក់ដែលសព្វថ្ងៃមានអាយុ៦ឆ្នាំហើយ ។

- តែផ្តាស! យើងមិនដែលរញ៉េរញ៉ៃនឹងស្រីណាទេ.. កុំចោទយើងទាំងទទឹង

ទិសយ៉ាងនេះ!

ហារិនងើបឡើង គំហកខ្លាំងៗកាត់ប្រសាសន៍អ្នកគ្រូពេទ្យ ធ្វើអោយ គេទាំងឡាយទីនោះចាប់អារម្មណ៍ចម្លែក ។ លោកហារ៉ាន់ឃើញដូច្នោះក៏ ទាញអោយនាយអង្គុយចុះហើយសួរអ្នកគ្រូពេទ្យតទៅទៀតថា :

- ហើយធ្វើម៉េចនឹងអោយពួកយើងជឿជាក់បានថានោះជាការវិភាគឈាម ដ៏មានសុក្រឹតភាព?

- ចាំស! បាន! លោកអាចពិសោធន៍សាថ្មីម្តងទៀត បើសិនជាលោកមាន អ្នកឯកទេសខាងវិភាគឈាមមកពិសោធន៍ ហើយយើងទាំងអស់នឹងចូល រួចជាសាក្សីដែរថា អ្នកឯកទេសរបស់លោកមិនលួចប្តូរឈាម ។ លោកសុខ ចិត្តទេ?

- រួចចុះហេតុអ្វីអ្នកគ្រូពេទ្យមានសទ្ធាមកជួយធ្វើការអោយនារីម្នាក់នេះ? ( លោកហារ៉ាន់ដៀងមើលទៅភារាណី រួចហើយក៏មានប្រសាសន៍បន្ត) តើ អ្នកគ្រូបានទាញទទួលប្រយោជន៍អ្វីដែរ ពីការវិភាគថ្ងៃនេះ?

- គឺខ្ញុំអាចទាញប្រយោជន៍ច្រើនយ៉ាង ដែលមិនមែនជាលុយ ។ ទីមួយគឺធ្វើ ឱ្យបុរសទទួលខុសត្រូវជីវិតកូនចៅរបស់ខ្លួន ដែលគេបានឱ្យកំណើតវាយ មាយខ្វះសតិ ។ ទីពីរគឺអោយគេទទួលទោសកំហុស បើសិនកំណើតកុមារ កើតឡើងដោយការរំលោភផ្លូវភេទ ។ ទីបី គឺជាមេរៀនដល់ តាយាយនិង សាច់ញាតិជិតដិត ឱ្យជួយទទួលខុសត្រូវជីវិតកុមារដែលកើតមក មិនថា ដោយការរំលោភឬដោយការស្មគ្រ័ចិត្តនោះទេ ។ ទីបួន គឺយើងចង់ឱ្យក្មេង មានអារម្មណ៍ថា គេមិនមែនជាជនដែលមានកំហុសទេ... អ្នកដែលមាន កំហុសគឺអ្នកដែលអោយកំណើតគេហើយមិនទទួលខុសត្រូវ.. ទីប្រាំគឺយើង ចង់បង្វែរការថ្កោលទោសរបស់សង្គម ដែលធ្លាប់តែសើចចំអកស្ត្រីរងគ្រោះ អោយទៅថ្កោលទោសបុរសដែលខ្វះសតិទទួលខុសត្រូវនោះវិញ ។

លោកហារ៉ាន់ឮដូច្នោះក៏បាត់មាត់ឈឹងតែម្តង រួចហើយក៏បែរទៅរក កូនប្រុសរបស់លោកវិញ :

- ហារិន! នេះប៉ាចង់ឮពីមាត់កូនផ្ទាល់ ថាឯងបានប្រព្រឹត្តស្អី ទៅលើនរណា ខ្លះ? ដឹងទេ ថាថ្ងៃនេះ ឯងនាំអាមាសដល់ប៉ាធំធេងណាស់! តើប៉ាគួរដាក់ ទោសកូនរបស់ប៉ាយ៉ាងណា? ហេតុអ្វីបានជាហារិនដែលជាកូនប្រុសទោល របស់លោកឧត្តមសេនីយ ជាអភិជន ជាមន្ត្រីជាន់ខ្ពស់ តែប្រព្រឹត្តខ្លួនថោក ទាបដូចមនុស្សដែលខ្វះឪពុកម្តាយអប់រំទៅវិញ? ឯងឆ្លើយមក..! ហារិន!

- កូនមិនបានប្រព្រឹត្តទេ... គឺប៉ាកំពុងតែចាញ់ឧបាយកលគេហើយ!

- ឈប់មាត់! បើឯងនៅតែប្រកែកទៀត យើងនឹងវាយឯងដោយដៃយើង ចំពោះមុខសាធារណជនពេលនេះ ។ ឯងជាមនុស្សធំពេញវ័យ រៀនក៏បាន ច្រើនគួរសម តើវាគួរអោយអាមាសទេដែលថាឯងចាញ់ឧបាយកលគេ? តើឧបាយកលរបស់នរណាទៅដែលបោកអោយមនុស្សទៅដុតផ្ទះរបស់ខ្លួន ឯងយ៉ាងនេះ? ហារិន.. ឯងកុំនិយាយចេញមកល្អជាង ត្បិតបើឯងកាន់តែ ប្រកែក វាកាន់តែបង្ហាញនូវភាពភ្លីភ្លើរបស់ឯងកាន់តែខ្លាំងដែរហើយ ។

ឮសំដីខ្លាំងៗរបស់ឪពុក ហារិនស្ងាត់មាត់ដូចគេចុក ។ បន្តិចមក លោក

ហារ៉ាន់ក៏សួរទៅភារាណីថា ៖

- ហើយចុះនាងតូចដែលជាចៅរបស់ខ្ញុំនោះនៅឯណា? អោយខ្ញុំស្គាល់ផង បានទេហ៎?

ភារាណីសម្លឹងមុខលោកហារ៉ាន់ តបថា ៖

- លោកច្បាស់ក្នុងចិត្តហើយឬនៅ ថាគេពិតជាសាច់ឈាមរបស់លោកពិត ប្រាកដមែន? តើលោកព្រមទទួលស្គាល់គេដែរទេ?

លោកហារ៉ាន់បែរមើលទៅអ្នកកាសែត និងសាធារណជនទាំងឡាយ ដែលកំពុងឈរមើលនៅទីនោះ ហើយក៏មានប្រសាសន៍ថា ៖

- នាងមានជំនឿជឿជាក់រហូតអូសនាំមនុស្សរាប់រយមកធ្វើជាសាក្សីយ៉ាង នេះទៅហើយ បើមិនជឿនាងក៏មិនកើតដែរ។ ពេលនេះខ្ញុំចង់ជួបចៅ... តើគេយ៉ាងម៉េចទៅហើយ..?

ស្រាប់តែ ភារាណីបែរមើលទៅហារិនហើយសួរទៅលោកហារ៉ាន់ថា៖

- មើលទៅ លោកភ្លេចដាក់ទោសជនឧក្រិដ្ឋហើយ.. បើលោកហ៊ានទទួល ការពិតហើយ.. ម្តេចមិនដាក់ទោសអ្នកដែលគួរទទួលទោសសិនទៅ?

- អត់ទេ! លោកប៉ា! គឺកូនមិនបានរំលោភគេទេ.. ការដែលយើងមានអ្វីៗ នឹងគ្នានោះ គឺជាការយល់ព្រមទាំងសងខាងតើហ៎!

(ហារិនឆ្លើយកាត់)

- អូហ៎! សារភាពហើយមែនទេថាឯងរញ៉ីរញ៉ៃនឹងស្រីៗមែន?

លោកហារ៉ាន់សួរផ្ទាន់ជាន់កែង។

- គឺ... ស្រីហ្នឹងវាអោយដៃខ្ញុំនោះអី...

ផាំង! លោកហារ៉ាន់ទះកំភ្លៀងកូនប្រុសរបស់លោកមួយដៃនៅចំពោះ មុខសាធារណជនតែម្តង ថែមទាំងគំហកថា ៖

- ថ្ងៃនេះហើយនៅមិនព្រមភ្ញាក់ស្មារតីទៀតឬហារិន?

ហារិនភ្ញាក់ព្រើត ដែលឪពុកនាយធ្វើដូច្នោះ ៖

- លោកប៉ា!...

- ឈប់ហៅយើងថាប៉ាទៀត...!

- លោកប៉ា... គឺជាការពិតណាំ.. គឺកូនមិនដែលបង្ខំចិត្តទេ.. គឺយើងមាន ការយល់ព្រមនឹងគ្នាទៅវិញទៅមក ទើបកំណើតក្មេងវាកើតមាន...

ភារាណីទ្រាំមិនបានក៏ឆ្លើយឡើងថា ៖

- បើមានការយល់ព្រមទាំងសងខាង.. ដូច្នេះ យ៉ាងហោចណាស់ក៏អ្នកត្រូវ បង្ហាញភាពទទួលខុសត្រូវ៥០ភាគរយដែរ មែនទេ? ហើយចុះ៧ឆ្នាំកន្លង មកនេះ តើអ្នកបានបង្ហាញនូវភាពទទួលខុសត្រូវ៥០ភាគរយនោះដែរទេ? ម្យ៉ាងទៀត

អ្នកតែងតែប្រកែកថាមិនដែលប្រព្រឹត្តរឿងអាស្រូវរហូតមក រួចមកទល់នឹងពេលដែលអ្នកត្រូវភស្តុតាងចាប់ច្របាច់កជាប់ហើយ អ្នកនៅ តែទំលាក់កំហុសអោយភាគខាងស្ត្រីរហូត.. រួចចុះឯណា? ឯណាភាគ ទទួលខុសត្រូវខាងបុរស? អ្នកធ្វើបែបនេះ វាសមរម្យនឹងកិត្តិយសរបស់ អ្នក របស់លោកហារ៉ាន់ដែលជាឪពុក ឬឋានៈគ្រួសារលោកទេ? ហារិន! អ្នកដឹងខ្លួនទេ ថាអ្នកសព្វថ្ងៃមានទ្រព្យធន មានឋានន្តរសក្តិ មានមុខមាត់ តែខ្វះសេចក្តីថ្លៃថ្នូរនិងកិត្តិយសជាបុរស? ដឹងទេ ថាខ្លួនអ្នកអាប់យសដល់ កំរិតណាដែរ?

កាលបើឃើញភារាណីនិយាយប៉ះចំចំណុចខ្សោយរបស់គ្រួសារលោក លោកហារ៉ាន់ក៏ឃាត់ឡើង :

- ណ្ហើយចុះ ភារាណី! នាងទុកនាទីនេះអោយខ្ញុំប្រដៅវាវិញ!

រួចហើយ លោកក៏ចាប់ញ៉ឹងហារិនអូសទៅបោះនៅកណ្តាលហ្វូង មនុស្សដែលកំពុងឈរមើលអ៊ូអរ រួចហើយក៏ស្រដីថា :

- ហារិន! ឯងឆ្លើយនៅចំពោះមុខអ្នកទាំងឡាយនេះទៅ ថាឯងសមនឹង ទទួលទោសបែបណាដែរ? ឆ្លើយទៅ!!

លោកហារ៉ាន់ពោលទាំងអស់កម្លាំងចិត្ត។

ស្រាប់តែ... ផាំង..! ស្នូរគ្រាប់កាំភ្លើងលាន់ឡើង ព្រមជាមួយនឹងសំដី ស្រីម្នាក់ស្រែកមករកហារិនពីហ្វូងសាធារណជនមកថា :

- ហារិន! ឯងមិនសមនឹងរស់នៅតទៅទៀតទេ.. ឯងធ្វើបាបយើង... ឯង ធ្វើបាបគ្រួសារយើង.. បំផ្លាញអនាគតយើង.. យើងត្រូវតែសងសឹកឯង..

ភ្លាមនោះ គេឃើញហារិនដួលប្រួសក្នុងថ្លុកឈាមតែម្តង។ សភាព ជ្រួលច្របល់អ៊ូអរ ក៏កើតមានឡើង...

0000000000000000

00000

0

# វគ្គទី១២
# ថ្ងៃមង្គល

ពីរបីថ្ងៃក្រោយមក...

ភារាណីនិងកវីដើរកាន់ដៃគ្នាមកដល់ទួលចារ ដែលធិតានឹងមាណព ធ្លាប់ណាត់ជួបគ្នារាល់ថ្ងៃតាំងពីនៅក្មេងរហូតពេញវ័យ ។ ថ្ងៃនេះ គេក៏បាន មកដល់ទីនេះសាជាថ្មីម្តងទៀត ដើម្បីរំលឹកនូវអនុស្សាវរីយ៍ល្អៗទាំងឡាយ រវាងគេទាំងពីរនាក់ ។ កវីឈរសម្លឹងដើមចារ ដែលនៅតែដុះត្រឈៃដដែល មិនផ្លាស់ប្តូរ ។ បន្តិចមក គេក៏មានវាចាទៅកាន់ភារាណីថា :

- អូនណីឃើញទេ? ដើមចារនៅតែលូតលាស់យ៉ាងស្រស់ត្រកាល ។ ប្រៀ ចិត្តស្នេហារបស់បង ចំពោះទេពអប្សរទួលចារវិញ ក៏នៅតែមានភាពរីក ស្រស់បំព្រងជានិច្ចដូចគ្នាដែរមិនដែលផ្លាស់ប្តូរសោះឡើយ... មិនថាពេលវេលាបានកន្លងទៅយូរប៉ុនណាក៏ដោយ...មិនថាការរង់ចាំអោយទេពអប្សរ វិលវិញនោះមានពន្លឺរស្មីសង្ឃឹមឬគ្មានយ៉ាងណាក៏ដោយ...ក៏កវីនៅតែរង់ចាំ ហើយក៏ធ្លាប់បានមករង់ចាំទេពអប្សរនៅទីនេះរៀងរាល់ថ្ងៃមិនដែលខាន មួយថ្ងៃ ចាប់តាំងតែពីថ្ងៃដែលនាងបែកឃ្លាតពីជីវិតរបស់បងទៅ...

ភារាណីឮវាចានេះកាលណា ក៏ទឹកភ្នែករលីងរលោង អួលក្នុងដើមក អាណិតខ្លួនភ្លាមមួយរំពេច ។ ពេលនោះធិតាបានប្រទះឃើញគំនរម្កុដផ្កា ស្មៅក្រៀមដាក់គរនៅក្រោមដើមចារយ៉ាងច្រើនសន្ធឹកសន្ធាប់ គួរឱ្យកត់សំគាល់ណាស់ ។ ធិតារំភើបចិត្តពេកក៏ស្រដីវិញថា :

- អូនណីឃ្លាតពីបងកវីទៅយូរហើយ... មិនដែលមានឱកាសត្រលប់មកឱ្យ បងកវីបំពាក់ម្កុដសោះ... ពេលនេះ អូននឹកចង់ពាក់ម្កុដផ្កាស្មៅ ចង់ក្លាយជា ទេពអប្សររបស់បងកវីម្តងទៀត តើបងក្រងម្កុដថ្មីបំពាក់អូនមួយបានទេ?

គវីឮហើយក៏ឈ្ងោកមុខសម្លឹងធិតាយើង ក្នុងក្រសៃភ្នែកប្រកបដោយ មន្តស្នេហ៍ផ្អែមស្រទន់ រួចហើយក៏ស្រដីទាំងទឹកមុខញញឹមថា :

- ចៃដន្យ បងបានគិតថាបងឈប់ក្រងម្កុដផ្កាស្មៅទៀតហើយ..

ស្រាប់តែភារាណីទំលាក់ទឹកមុខជ្រប់ សំដែងភាពខកចិត្ត :

- ហេតុអ្វីទៅ បងកវី? បងលែងទទួលរូបអូនជាទេពអប្សរនៅក្នុងបេះដូង របស់បងទៀតហើយមែនទេ?

- មិនមែនទេ.. ការពិតនោះគឺ បងចង់ក្រងអ្វីផ្សេងមួយទៀតសំរាប់អូនឱ្យ សមតាមវ័យរបស់អូនតើហ៎... ហើយរបស់នោះគឺជារបស់តែមួយគត់ដែល កវីប្រគល់អោយចំពោះនារីតែម្នាក់ក្នុងមួយជីវិតនេះ ។

- តើជាអ្វីទៅ បង?

- មិនទាន់ប្រាប់អូនទេ! តែបងចង់សុំប្តូរយកវត្ថុអនុស្សាវរីយ៍ពីអូនវិញដែរ

ព្រោះអីតាំងពីយូរមកហើយ បងមិនទាន់ទទួលវត្ថុអនុស្សាវរីយ៍វិសេស ណាមួយពីអូននៅឡើយទេណា៎!

ភ្លាមនោះ ភារាណីក៏ញញឹមឡើងហើយឆ្លើយថា :

- អញ្ចឹង! នៅថ្ងៃដែលអូនទទួលម្កុដថ្មីពីបង អូននឹងប្រគល់ជូនបងវិញនូវ

វត្ថុអនុស្សាវរីយ៍របស់អូនយ៉ាងមានតម្លៃជូនបងវិញដែរណា៎ ។

កវីព្រះវាចារបស់នារីយើងដូច្នោះក៏ញញឹមឡើង :

- បងនឹងរង់ចាំទទួលពីអូនណីរបស់បងដោយដួងចិត្តរំភើបបំផុត...

គេទាំងពីរក៏ញញឹមដាក់គ្នាសាជាថ្មីយ៉ាងបំព្រង គឺជាភាពញញឹមដែល ជាសក្ខីភាពនៃសុភមង្គលស្នេហាដ៏ភ្លឺថ្លាត្រចង់មួយ...

ពីរបីថ្ងៃក្រោយមក....

មេឃុំផែងចេញដើរក្រៅផ្ទះត្រិប១តែម្នាក់ឯង ។ ភ្លាមនោះ ភារាណី មកទាន់ក៏សួរថា :

- ពុក.. មិនទាន់ស្រួលខ្លួនមែនទែនទេណា.. នេះពុកចង់ចេញទៅណាហ្នឹង?

- គឺ.. ពុកចង់ដើរទៅមើលផ្ទះចាស់របស់យើង..

- ពុកទៅមើលធ្វើអ្វី? នៅទីនោះ មានសល់តែដីវាល នឹងជើងសសរផ្ទះតែ ប៉ុណ្ណោះ ។

- គឺពុកនឹកផ្ទះយើងហ្នឹងណា៎!

- ទីនេះ ក៏ជាផ្ទះរបស់យើងដែរណា៎ពុក! បងកវីបានផ្តាំផ្តាច់ហើយមិន ទាន់អោយពុកត្រលប់ទៅទីនោះទេ ត្បិតគេកំពុងតែសំអាតក្រែងធូលីផេះ

វាធ្វើអោយពុកឈឺឡើងវិញនោះអី ។

រំពេចនោះ ស្រាប់តែមានអ្នកភូមិម្នាក់បរម៉ូតូតាមភ្លឺស្រែមកដល់ :

- អ្នកគ្រូភារាណី! មានភ្ញៀវពីទីក្រុងចង់ជួប តែគេបរឡានមកមិនដល់ ទើបពឹងអោយខ្ញុំមកជំរាប ។

- ហើយចុះគេជានរណាដែរ?

- បាទ អត់ស្គាល់ទេ តែគេនៅចាំនៅតូបលក់ទឹកកក ឯមាត់ផ្លូវឯណោះ ។

ថាហើយបុរសនោះក៏បរម៉ូតូចេញទៅ ។ ភារាណីបែរមើលមុខឪពុក ដែលកំពុងធ្វើទឹកមុខងឿងឆ្ងល់ :

- គេជានរណាទៅកូន?

- ប្រហែលជារតនា ដារ៉ាន់ និងមិត្តរបស់គេក៏មិនដឹងណា៎ពុក ។

- អឺ.. ហើយកវីវ៉ាមិននៅផង.. បាននរណាជូនកូនទៅ?

- ចាំស! កុំបារម្ភអីពុក។ ខ្ញុំដើរទៅកាត់ស្រែតែម៉ាភ្លែតដល់ហើយ។

ភ្លាមនោះ នាងក៏ដើរកាត់ស្រែចេញសំដៅទៅមាត់ផ្លូវធំយ៉ាងលឿន។ មកដល់មុខតូបលក់ទឹកកកភ្លាម ធិតាយើងក៏ប្រទះលោកហារ៉ាន់ដែល ស្លៀកពាក់ជាជនសាមញ្ញធម្មតា អង្គុយរង់ចាំនាងតែម្នាក់ឯង :

- ជំរាបសួរលោកហារ៉ាន់!

- អឺ! សុខសប្បាយទេ ភារាណី? ប៉ាមានការចង់ពឹងកូនបន្តិច..

មាណវីភ្ញាក់ព្រើតដែលលោកហារ៉ាន់ហៅនាងថាកូន។ នាងក៏សួរទៅ លោកវិញថា :

- មានការអ្វីដែរទៅ ចាំស?

ភ្លាមនោះ លោកហារ៉ាន់អូសដៃនាងដើរចេញឆ្ងាយពីតូបទឹកកកបន្តិច ទំនងមិនចង់អោយមនុស្សម្តុំនោះឮការសន្ទនារបស់លោក :

- គឺហារិនចង់ជួបកូនស្រីរបស់គេ.. តើកូនគិតយ៉ាងណាដែរ?

- ហើយចុះហារិន ពេលនេះ គេយ៉ាងណាទៅហើយ?

- នៅមន្ទីរពេទ្យ.. របួសធ្ងន់ត្រង់អវយវៈបន្តពូជ ប្រហែលជាព្យាបាលមិន ជាទេ តែនោះជាបាបកម្មរបស់គេ យើងមិនអាចបន្ទោសនរណាឡើយ។ ពេលនេះ គេចង់ជួបកូនហើយនិងនាងតូចដើម្បីសូមអហោសិកម្ម...

បន្តិចមក ភារាណីក៏នាំលោកហារ៉ាន់ដើរកាត់វាលស្រែសំដៅដីភូមិ របស់កវី។ ពេលនោះ មេឃុំផែងនិងមីងផាវ មានការចម្លែកចិត្តណាស់ ចំពោះវត្តមានរបស់លោកហារ៉ាន់ ដែលធ្លាប់សម្លុតរកស៊ីសាច់មេឃុំនាគ្រា មួយនាអតិតកាល ស្រាប់តែពេលនេះ ក្លាយទៅជាយក្សកាច់ចង្កូមមួយរូប ទៅវិញ។ ទោះជាយ៉ាងណា គឺគាត់ទាំងពីរបានទទួលលោកយ៉ាងសមរម្យបំផុត។ បន្ទាប់ពីសំណេះសំណាល សូមទោសគ្នាទៅវិញទៅមកហើយចាប់ ដៃសាងមិត្តភាពសាជាថ្មី មេឃុំក៏ឃាត់លោកហារ៉ាន់អោយនៅពិសារបាយ តែលោកប្រកែក ទទួលពេលនោះ កវីបានឌុបម៉ូតូនាំសារ៉េតនិងនាងតូច សោភាមកដល់ផ្ទះល្មមពេលគ្នាតែម្តង។

- ភា! មកនេះកូន! (ភារាណីហៅកូន) ជំរាបសួរលោកតាទៅកូន!

- លោកតា? ហេតុអីសោភាមានលោកតាដល់ទៅពីរ? (នាងតូចសួរ)

- ជំរាបសួរគាត់ទៅ! គាត់ជាលោកតារបស់កូន ដូចលោកតាមេឃុំដែរ។

- ជំរាបសួរលោកតា!

លោកហារ៉ាន់សម្លឹងនាងតូចមួយស្របក់ទើបលើកនាងពឡើង :

- តារំភើបចិត្តណាស់ចៅ ដែលតានៅមានឱកាសបានស្គាល់សាច់ឈាមខ្លួន ឯង (រួចហើយលោកហារ៉ាន់បែរទៅភារាណីវិញដោយមានប្រសាសន៍ថា) អរគុណណាស់ ភារាណី! បើកុំតែសេចក្តីក្លាហានរបស់នាង

ម្លេះសមប៉ាមិន បានជួបចៅបង្កើតរបស់ប៉ា ហើយក៏មិនបានដឹងអំពីអំពើទុរយសរបស់នាយ ហារិនដែរ ។ នេះជាមេរៀនដ៏ធំសំរាប់ប៉ា ដែលទំយើកូនហួសហេតុរហូត ដល់កូនលែងដឹងថាអ្វីខុសអ្វីត្រូវអស់រលីង គឺដឹងតែពីខាងបាននិងខាងឈ្នះ រហូតធ្លាប់ខ្លួនខូចអស់...

លោកហារ៉ាន់និយាយទ្រង់អួលដើមក ហើយក៏ស្រវាអោបចៅឡើង យ៉ាងណែន ថែមទាំងពោលថា :

- សោភា! បើប៉ាឯងមិនទទួលខុសត្រូវជីវិតរបស់ចៅទេ.. សូមអនុញ្ញាត្ត ឱ្យតាបានទទួលខុសត្រូវចៅខ្លះណា៎ ក្រែងអាចជួយលាងបាបកម្មរបស់ ហារិនបានខ្លះៗ...

តែនាងតូចមិនយល់ទេ ថាលោកហារ៉ាន់ជានរណា សុខៗស្រាប់តែដើរ ចូលមកក្នុងជីវិតរបស់នាងហើយហៅនាងថាចៅៗពេញមាត់យ៉ាងដូច្នោះ ។ បន្តិចមក លោកហារ៉ាន់ក៏សុំអនុញ្ញាត្តយកនាងតូចទៅជួបហារិន ។ ភារាណី មិនទាន់ឆ្លើយថាម៉េចផង ស្រាប់តែកវីឆ្លើយរឹងជំនួសថា :

- ខ្ញុំមិនអនុញ្ញាត្តទេប៉ាទ! សោភាជាកូនរបស់ខ្ញុំដែលខ្ញុំបានថែរក្សាតាំងពី នៅក្នុងផ្ទៃម្តាយមកម្លេះ ។ បើគេពិតជាចង់ជួបនឹងកូនរបស់គេមែន គេត្រូវ តែមកទីនេះសុំជួបនាងតូចដោយខ្លួនឯង ។ ពេលនេះ លោកល្មមទុកឱកាស ឱ្យហារិនរៀនទទួលខុសត្រូវក្នុងជីវិតខ្លះ មិនមែនចេះតែហារសុំឱ្យឪពុក ម្តាយបំពេញបំណងអោយគ្រប់យ៉ាងតែម្យ៉ាងនោះទេ..

- តែពេលនេះ ហារិនកំពុងគេងពេទ្យព្យាបាលជំងឺនៅឡើយ គេមិនអាច..

- អញ្ចឹងចាំដល់គេជាសះស្បើយសិនទៅ ចាំឱ្យគេមកជួបសោភាចុះ ត្បិត៧ ឆ្នាំកន្លងមកគេមិនបានត្រៀមចិត្តថាគេមាននាងតូចទេ.. ដូច្នេះ ខ្ញុំមិនទាន់ ជឿច្បាស់ក្នុងចិត្តទេ ថាគេអាចទទួលនូវភាពជាឪពុកបាននៅឡើយ ហើយ បើចិត្តគេមិនទាន់អាចទទួលបាន ខ្ញុំក៏មិនទាន់ចង់ឱ្យសោភាជួបគេដែរ ។

លោកហារ៉ាន់ឃើញភាពម៉ឺងម៉ាត់របស់កវី ក៏មិនហ៊ានមាត់តទៅទៀត ដែរ ត្បិតកវីនិយាយត្រូវព្រោះគេមានសិទ្ធិលើជីវិតកុមារីសោភាជាងនាយ ហារិនយ៉ាងពិតប្រាកដ ត្បិតគេជាអ្នកផ្តល់ជីវិតនិងសេចក្តីសុខដល់សោភា ដែលហារិនមិនអាចយកឈ្នះ ថ្វីបើនាយបានឱ្យកំណើតទៅកុមារីក៏ដោយ ។

បន្តិចក្រោយមក លោកហារ៉ាន់ក៏លាអ្នកទាំងអស់ត្រលប់ទៅវិញ ។

នៅព្រលប់ថ្ងៃដដែល...

រាល់គ្នាចូលដំណេកអស់ហើយ នៅតែមាណពយើងម្នាក់ដែលនៅត្រេះ ត្រុះយោលអង្រឹងខាងក្រៅផ្ទះលើរានហាលតែម្នាក់ឯង ។ ភ្លាមនេះភារាណី ក៏លេចឆ្លោមកដល់ :

- បងកវី.. មិនទាន់ចូលសំរាន្តទេហ៎?

- គឺ ធាតុអាកាសក្តៅស្អុះពេក បងគេងមិនលក់...

- មិនមែនទេដឹង? ខ្ញុំថាបងពិតជាតប់ប្រមល់ក្នុងចិត្តរឿងអ្វីហើយ...

តែកវីមិនឆ្លើយទេ ។ គេនៅស្ងៀម មិនស្រដីអ្វីតទៅទៀត ។ ភារាណី ក៏ដើរមកជិតហើយនិយាយថា :

- ណី សុំអង្គុយជិតបងផងណា៎!

ថាហើយ នាងក៏ដាក់ខ្លួនអង្គុយលើអង្រឹងក្បែរកវី ហើយក៏ផ្អែកកេសា លើទ្រូងរបស់បុរសកំពូលដួងចិត្តរបស់នាង :

- ប្រាប់អូនមក ថាបងកំពុងគិតអំពីរឿងកូនភា!

កវីលើកដៃអង្អែលកេសានាងបន្តិរៗ :

- ម៉េចក៏អូនដឹងកើត... ថាបងកំពុងគិតរឿងហ្នឹង?

- គឺទឹកមុខបងនោះអី! ថ្ងៃនេះ បងម៉ឹងម៉ាត់ប្លែកណាស់ ប្លែកខុសពីកវី ម្នាក់នោះដែលអូនធ្លាប់ស្គាល់ពីមុនមក...

- បងម៉ឹងម៉ាត់?... តើបង...ធ្វើអោយអូនខ្វាចចិត្តណាស់ មែនទេ?

- អត់ទេ! គឺអូនពេញចិត្តតើហ៎ ព្រោះឬកពានោះបានបង្ហាញអោយអូន ដឹងច្បាស់ក្នុងចិត្តថាបងពិតជាស្រឡាញ់កូនភាខ្លាំងប៉ុនណា។

កវីក៏ញញឹមឡើង ហើយយកដៃអង្អែលកេសានារីយើងថ្នមៗដោយ ដួងចិត្តរំភើបឥតឧបមា :

- មិនត្រឹមតែស្រឡាញ់កូនភាទេ កវីស្រឡាញ់ទាំងម្ដាយរបស់គេទៀតផង ហើយក៏ស្រលាញ់អស់រយៈពេលជាយូរមកហើយដែរ អូនណីមានដឹងទេ?

ភារាណីក៏ញញឹមតបវិញ :

- ហើយស្រឡាញ់រហូតតទៅឬទេ បង?...

- គឺស្រឡាញ់រហូតតរៀងទៅ.. បើមានជាតិក្រោយទៀត សូមអោយបង បានជួបនឹងអូនជាគូជីវិតរហូតគ្រប់៧ជាតិ កុំអោយឃ្លាតឡើយ។

ពាក្យវាចាដ៏ផ្អែមល្ហែមរបស់មាណព ធិតាក៏បិទនេត្រាហើយផ្អែកកេសា កើយលើទ្រូងរបស់កវីសាជាថ្មី ទទួលយកនូវភាពកក់ក្ដៅក្នុងចិត្តមួយ ដែល នាងបានបាត់បង់ទៅចាំអស់ជាយូរឆ្នាំមកហើយ.. បន្ទាប់មក ធិតាក៏វាចា ខ្សិបៗ តបទៅបុរសកំពូលស្នេហ៍យ៉ាងស្រទន់ថា :

- អូនណីក៏ស្រឡាញ់បងដូចគ្នា... ស្រឡាញ់តាំងពីយូរមកហើយ ហើយក៏ ស្រឡាញ់បងតរៀងទៅ ជាតិនេះ ជាតិក្រោយនិងគ្រប់៧ជាតិទៅមុខទៀត

- ចាប់ពីថ្ងៃនេះតទៅ យើងលែងបែកគ្នាទៀតហើយណាំអូន...

- ចាំស បង! យើងនឹងរស់នៅជួបជុំគ្នាយ៉ាងសុខសាន្តបំផុតក្នុងជីវិត...

កវីស្រវាំអោបធិតាយ៉ាងណែនផ្ទាប់នឹងឱរា ហើយក៏ឱនល្ងោកយក នាសាទៅផ្អែកផ្ទិតលើថ្ពាល់ឆវី ស្រូបស្រង់នូវក្លិនស្នេហ៍ដ៏ក្រអូបដោយដួង ហឫទ័យសែនរំភើបញាប់ញ័រក្រៃលែង។

### សន្សើមដួងចិត្ត

| | |
|---|---|
| សន្សើមត្រជាក់ធ្លាក់រោយស្បៃ | អន្ធការរាត្រីក្រៃងងិត |
| ខ្យល់បក់រហើយស្មើយដួងចិត្ត | ក្បែរគូនៃបនិត្យចិត្តញាប់ញ័រ។ |
| ផ្កែលូល្ងើយៗឆ្លើយចង្រិត | ព្រឺព្រួចខ្ទួចចិត្តត្បិតភ័យអរ |

ក្នុងរង្វង់ដៃថ្លៃបវរ ស្រស់ទេពអប្សរអង្វរស្នេហ៍។
ចន្ទ័រះយន់យូររាហូលេប ត្រកងនិត្យនៃបលេបដួងខែ
រាត្រីកល្យាណក្សាន្តម្លេះទេ គេងកើយទ្រូងស្នេហ៍ថៃក្លិនប្រាណ។
សន្សើមរោយចុះប្រស់ព្រំពរ ជោគជ័យបវរគូកល្យាណ
រាត្រីងងិតចិត្តសុខសាន្ត ស្នេហាថ្កើងថ្កានក្សាន្តរៀងអើយ...

ច្រើនអាទិត្យក្រោយមក...

កវីមើបចេញទៅធ្វើការជួញដូរបាត់តាំងពីព្រហាមដូចរាល់ដង។

- ពុក! ម៉ែ! រៀបចំខ្លួនមក៏... បងកវីមានរឿងសំខាន់មួយចង់ជំរាប!
- មានរឿងអ្វីទៅកូនណើ? (មីងផាវសួរ)
- គឺ ម៉ែពុកស្លៀកពាក់សិនមក៏ បងកវីនាំពុកម៉ែចេញទៅក្រៅ..
- ទៅក្រៅ? ទៅណា?... (មេឃុំផែងសួរ)
- ខ្ញុំក៏មិនដឹងដែរពុក បងកវីប្រាប់ខ្ញុំតែប៉ុនហ្នឹងឯង។

កំពុងតែរៀបចំខ្លួន ស្រាប់តែអ្នកទាំងអស់ឮសូរសន្ធឹកសម្រិបជើងមក ដល់មុខផ្ទះ។ មេឃុំ មីងផាវ សាវេត សោភា និងភារាណើរត់ចេញស្រពីក្នុង ផ្ទះ ទៅរកមើល ស្រាប់តែឃើញអ្នកភូមិមួយហ្វូងធំសែងគ្រែស្នែងមួយគូ មកដល់។ កាលបើឃើញអ្នកទាំងអស់ចេញមកដល់មុខផ្ទះ អ្នកភូមិម្នាក់ ពោលឡើងថា :

- កវីផ្តាំអោយពួកយើងមកទទួលពុកមេឃុំនិងមីងផាវទៅកន្លែងបុណ្យ...
- កន្លែងបុណ្យ? បុណ្យអីទៅ? (មេឃុំសួរទាំងឆ្ងល់)
- បន្តិចទៀត ពុកមេឃុំនឹងដឹងហើយ។

បន្ទាប់មក គេក៏ដាក់មេឃុំផែងនិងមីងផាវលើគ្រែស្នែង ហើយក៏នាំគ្នា សែងចេញទៅ។ ភារាណើក៏ដឹកដៃនាងតូចសោភានិងសាវេត ដើរតាមពី ក្រោយទាំងទឹកមុខញញឹម ក្នុងចិត្តរបស់នាងក៏កំពុងទន្ទឹងដែរថា តើកវីគេកំពុងលលេងអ្វីជាមួយឪពុកម្តាយរបស់គេនោះ។

មួយស្របក់មក អ្នកស្រុកបានសែងគ្រែមកដល់ថ្នល់ធំដែលមានហ្វូង អ្នកភូមិឈរចាំយ៉ាងកុះករ :

- ជយោ! ពុកមេឃុំត្រលប់មកវិញហើយ!

មេឃុំភ្ញាក់ផ្អើលណាស់ដែលឃើញមនុស្សអ៊ូអររត់មកទទួលគាត់ហាក់ បីដូចជាមានការអ្វីធំដុំណាស់អញ្ចឹង។ បន្តិចមក ក្បួនដង្ហែគ្រែស្នែងក៏បែរ ក្បាលតម្រង់ទៅដីភូមិរបស់មេឃុំយើង។ គាត់ក៏បែរសួរមីងផាវថា :

- ម៉ែវាដឹងទេហ៎ ថាគេកំពុងធ្វើអ្វីហ្នឹង?
- អត់ដឹងទេពុកវា! តែចាំម៉ាភ្លែតសិនទៅ បន្តិចទៅដល់ដីភូមិផ្ទះយើង នោះ យើងនឹងដឹងហើយ។

មកដល់មាត់ទ្វាររបងផ្ទះដីភូមិចាស់របស់គាត់ ពេលណា មេឃុំផែង

បើកភ្នែកធំៗប៉ុនពងមាន់ដោយការភ្ញាក់ផ្អើល ត្បិតនៅចំកន្លែងផ្ទះចាស់ របស់គាត់ដែលត្រូវភ្លើងឆេះអស់ទៅនោះ មានផ្ទះថ្មីមួយសង់យ៉ាងជង្គ្រឹង ធំហើយស្អាតជាងមុនទៅទៀត។ ភ្លាមនោះ កវីក៏ដើរចេញមកពីក្នុងផ្ទះ ចុះតាមកាំជណ្ដើរមកដោយទឹកមុខញញឹមយ៉ាងស្រស់បំព្រងបំផុត :

- ពុក! ម៉ែ! ពេញចិត្តទេ? នេះគឺជាស្នាដៃ និងកម្លាំងញើសឈាមរបស់ កវីកូនប្រុសពុកម៉ែហើយ ដោយមានពូសេត ព្រមទាំងអ្នកភូមិម្ដុំយើងនេះ ជួយជ្រោមជ្រែងផង។

មាណពសួរទៅឪពុកម្ដាយ។ មេឃុំក៏ឧទានទាំងត្រេកអរថា:

- ពុកមានមោទនភាពចំពោះកូនណាស់កវី! ពុកមិនដែលគិតស្មានថា កូន អាចជួយពុកបានដល់ម្លឹងទេ។

មេឃុំផែងស្ទុះដើរទៅជិតហើយស្រវាំអោបកូនប្រុសដោយក្ដីរំភើប។

- គឺកូនបានសន្សំប្រាក់នេះយូរហើយ គិតថាសំរាប់សង់ផ្ទះការប្រពន្ធ...

មេឃុំផែងឮដូច្នោះក៏ឧទានសួរថា :

- ហើយចុះបើកូនអាល័យតែយកលុយសន្សំមកចាយសង់ផ្ទះអោយពុក ម៉ែអស់ តើនឹងបានអីសង់ផ្ទះខ្លួនឯង សំរាប់ការប្រពន្ធទៅ? (មេឃុំសួរ)

- នរណាថាកូនមិនការប្រពន្ធ ពេលសង់ផ្ទះថ្មីនេះហើយ? គឺថ្ងៃនេះ ផ្ទះមួយ នេះនឹងនាំមកនូវជោគជ័យពីរយ៉ាងដល់កូន។ មួយគឺ ពុកម៉ែនឹងមានផ្ទះនៅ យ៉ាងស្រស់ស្អាតដាច់គេនៅក្នុងភូមិ។ ទីពីរ ពុកម៉ែត្រូវតែធ្វើជាមេបាឱ្យ ខ្ញុំនិងអូនណី រៀបការជាគូស្វាមីភរិយានឹងគ្នាថ្ងៃនេះតែម្ដង...

- ហ្អាស? កូនថាម៉េចហ្នឹង កវី? (មេឃុំលាន់មាត់ដោយភ្ញាក់ផ្អើលបំផុត)

ាំណពញញឹមឡើងតែមិនឆ្លើយតបទៅគាត់វិញទេ តែបែរជាទៅអូស ដៃភារាណើមកជិតនាយយ៉ាងរហ័ស រួចក៏ពោលទៅកាន់នាងថា :

- អូនណី! កាលពីដើម បងជាក្មេងក្រីក្រ អាចរកបានត្រឹមតែម្ជុលធ្វើពីផ្កា ស្មៅសំរាប់បំពាក់អោយទេពអប្សររបស់បង តែថ្ងៃនេះកវីមានសមត្ថភាព អាចរករបស់ដែលមានតម្លៃបំផុត សម្រាប់ទេពអប្សររបស់បងហើយ...

ភ្លាមនោះ នាយយើងងាកបែរក្រោយមិចភ្នែកដាក់ពូសេត ស្រាប់តែ គាត់លើកភាជន៍មួយមានស្បែដណ្ដប់លាក់ជិតរបស់ដែលដាក់នៅលើភាជន៍ នោះ។ ភារាណីសម្លឹងតាម ទាំងចិត្តត្រេកអររំភើបផង ឆ្ងល់ផង សប្បាយ ផងលាយឡំគ្នា។ មិនថាតែធិតាយើងទេ នរណាៗដែលឈរនៅទីនោះ ក៏ចង់ដឹងដូចគ្នាដែរ ថាតើវត្ថុនៅលើភាជន៍នោះជាវត្ថុអ្វីដែរទៅ?

កវីក៏ភើចគំរបស្បែដ៏ស្អាតនោះចេញ ហើយក៏អូសយករបស់មួយចេញ មកដោយភក្ត្រញញឹម រួចវាចាថា :

- ព្រហាមមិញ បងបានឡើងកាប់ផ្កាស្លា កាត់យកមកក្រងជាម្កុដដ៏សែន ស្រស់ស្អាតមួយដោយដៃរបស់បងផ្ទាល់ ។ ពេលនេះ បងសូមប្រគល់ជូន ទៅទេពអប្សរភារាណីកំពូលដួងចិត្តរបស់បង... តើអូនព្រមទទួលយកម្កុដ ផ្កាស្លាមួយនេះហើយរៀបការជាគូជីវិតរបស់បង ដែរឬទេអូន?

ភារាណីសម្លឹងទៅម្កុដផ្កាស្លា ហើយក៏បែរសម្លឹងភក្ត្ររបស់ករី រួចក៏ធ្វើ ទឹកភ្នែករលីងរលោង ថែមទាំងស្រដីទាំងរំជើបរំជួលឱរាថា :

- ជាកត្តិយសយ៉ាងធំធេងណាស់ដែលអូនបានទទួលម្កុដផ្កាស្លាពីបងករី គឺ.. ភារាណីបានរង់ចាំម្កុដមួយនេះដោយដួងចិត្តបរិសុទ្ធ... ជាយូរមកហើយ

ពោលចប់ ធិតាក៏អោនកេសាទទួលយកការបំពាក់ម្កុដផ្កាស្លាដ៏ស្រស់ ស្អាតមួយនោះពីករីដោយបេះដូងរន្ធត់ញាប់ញ័រ ។ សម្លេងឃ្មោះការក៏បន្លឺ ឡើងយ៉ាងខ្ទ័រខ្ទារពាសពេញភូមិ ដោយមានអ្នកភូមិជាច្រើនចូលរួមយ៉ាង កុះករ ។ នៅឯខាងលើរានហាលមុខផ្ទះ មេឃុំនិងមីងផាវ ឈរកាន់ដៃចៅ ទាំងពីរហើយញញឹមដាក់គ្នាយ៉ាងសែនរីករាយ កាលបើគាត់បានឃើញកូន ប្រុសស្រីទទួលសុភមង្គលយ៉ាងត្រចះត្រចង់បំផុតក្នុងជីវិត ។

ម្កុដផ្កាស្លា

| | |
|---|---|
| ឱ! ទេពអប្សរបវរឯក | ចិត្តរៀមអរត្រេកលើកជូនថ្លៃ |
| នូវម្កុដផ្កាស្លាមានតម្លៃ | សូមឱនចាប់ដៃពៅជាគូ ។ |
| ឱ! ស្រស់ទេវីទីគាប់ចិត្ត | បេះដូងបងពិតសូមផ្ដាច់ប្ដូរ |
| កាត់ជូនកល្យាណអូនជាថ្នូរ | នៃបនិត្យជាគូម្កុដផ្កាស្លា ។ |
| ឱ! មុំមាសស្នេហ៍ខែពេញវង់ | សូមឆ្លើយប្រាប់ផងថាយ៉ាងណា |
| បេះដូងកាត់ថែមលើផ្កាស្លា | ជូនកែវកន្និដ្ឋាម្ចាស់ជីវិត ។ |
| ឱ! ទេពអប្សរដ៏ប្រិមប្រិយ | យល់ដល់ហឫទ័យបងស្នេហ៍ពិត |
| រៀបការនិងបងណាំវរមិត្រ | ជាគូជីវិតរៀងទៅអើយ... |

កំពុងតែសប្បាយរីករាយ ស្រាប់តែមានរថយន្តមួយបោះពួយមកដល់ មាត់របងផ្ទះ ដោយមានផ្ទុកមិត្តរបស់ភារាណីទាំងបីរូប គឺរតនា ដារ៉ាន់ និងលោកកោមល មកផង ។

- ស្លាប់ហើយ ភារាណី ម៉ាជីវិតរៀបការតែម្តង ហេតុអ្វីមិនប្រាប់ពួកម៉ាក មកចូលរួមផង.. យី!.. នេះយើងកំពុងអន់ចិត្តណាស់ ដឹងទេ?

រតនានិយាយផង រត់សំដៅមិត្តផង មកដល់ជិតក៏ចាប់ដៃអ្នកទាំងពីរ អោយកាន់ប្រទាក់គ្នាទៅវិញទៅមក រួចពោលបន្តថា :

- ខ្ញុំសប្បាយចិត្តណាស់ភារាណីដែលឯងមានថ្ងៃនេះ.. គឺថ្ងៃដែលឯងបាន ទទួលនូវសេចក្តីសុខនិងសុភមង្គលបំផុត ។ ខ្ញុំសូមជូនពរអោយអ្នកទាំងពីរ ចាប់ដៃគ្នារួមរស់ជាគូជីវិតដោយសុខសាន្តតទៅ ។

ភារាណីញញឹមហើយក៏ស្រវាអោបមិត្តយ៉ាងណែន :

- អរគុណណាស់រតនា! ហើយ.. យើងក៏ជាមិត្តនឹងគ្នារហូតតទៅដែរ ។

រតនាក៏ញញឹមឡើងដាក់កវីហើយស្រដីខ្សិប១ទៅមាណពថា :

- សូមផ្ញើមិត្តរបស់ខ្ញុំជាមួយបងប្រុសផងណា៎! គេប្រាកដជាត្រូវការ ការ ថ្នាក់ថ្នមលួងលោមពីបងច្រើនណាស់... ត្បិតគេបែកពីបងយូរឆ្នាំហើយ...

ថាហើយ នាងមិចភ្នែកដាក់កវី ហើយក៏ថយចេញទៅ ។ ភ្លាមនោះ ភារាណីក៏ដើរទៅជិតដាវ៉ាន់និងលោកកោមលហើយវាចាឡើង:

- ដាវ៉ាន់! លោកកោមល! អរគុណអ្នកទាំងពីរណាស់ដែលអាចមកចូលរួម ថ្ងៃមង្គលរបស់ខ្ញុំបាន ។

ភ្លាមនោះ នាងក៏លើកដៃសំពះលោកគ្រូកោមល :

- ហើយជាពិសេសទៅទៀត... ភារាណីសូមអរគុណលោកកោមលដែល បានធ្វើកាដូជាកាម៉ារ៉ាវីដេអូ ចំពោះខ្ញុំសំរាប់បុណ្យចូលឆ្នាំត្បិតកាម៉ារ៉ានោះ បានក្លាយជាប្រយោជន៍ចំពោះរូបខ្ញុំនិងក្រុមគ្រួសារយ៉ាងធំធេងបំផុត!!

លោកកោមលលើកដៃសំពះតបវិញ ទាំងបេះដូងរំជួល ដោយការ សោកស្តាយដែលបានឃើញភារាណីមានម្ចាស់បេះដូងរួចទៅហើយ ។ ភ្លាម នោះ ស្រាប់តែមានរថយន្តមួយទៀតបោះពួយមកដល់ទីនោះដែរ ។ លុះគេ នាំគ្នាក្រលេកមើលស្ទ្រូស្រទៅ ក៏ប្រទះនឹងលោកហាវ៉ាន់កំពុងដឹកដៃកូនចុះ ពីលើរថយន្តមក ។ ពេលនេះ ហារិនមិនជានាដូចគេឯងធម្មតាទេ ត្បិតគេ ទាំងឡាយឃើញនាយប្រើឈើច្រត់ទប់ខ្លួនដើរចូលមក ។

នៅចំពោះមុខភារាណីភ្លាម ហារិនក៏ស្រដីទៅកាន់ធិតាថា :

- ភារាណី! ខ្ញុំមកសូមទោសនាងចំពោះការប្រព្រឹត្តដ៏អាស្រូវរបស់ខ្ញុំកាល ពីអតិតកាល ហើយក៏សូមអរគុណផងដែរដែលបានមកជួយបំភ្លឺផ្លូវជីវិតឱ្យ ខ្ញុំសាជាថ្មី.. មិនឱ្យរូបខ្ញុំធ្លាក់នរកភក់ជ្រាំតទៅទៀត ។ អរគុណណាស់ ភារាណី! អរគុណជាអនេកប្បការ!

រួចហើយ ហារិនសម្លឹងមុខធិតា សម្តែងនូវទឹកមុខដែលប្រកបដោយ វិប្បដិសារីពិតប្រាកដមែន ។ បន្ទាប់មក គេក៏បែរទៅកវីហើយស្រដីថា :

- អរគុណណាស់លោកកវីចំពោះទឹកចិត្តដ៏ថ្លៃថ្លារបស់លោក! ឱ្យហារិន សូមទោសលោកផងដែលខ្ញុំវង្វេងសតិ មិនទទួលខុសត្រូវនូវអ្វីដែលខ្ញុំបាន ធ្វើកន្លងមក ។ ថ្ងៃនេះហារិនសូមចូលខ្លួនមកជូនពរអ្នកទាំងពីរ សូមឱ្យចាប់ ដៃគ្នាកសាងគ្រួសារបានសុខសប្បាយរៀងរហូតទៅ ។

រួចហើយគេក៏ខ្សិនខ្សិបដាក់ត្រចៀករបស់កវីថា :

- ខ្ញុំសុំផ្ញើកូនស្រីរបស់ខ្ញុំជាមួយលោកផង! គឺខ្ញុំសង្ឃឹមទាំងស្រុងលើទឹកចិត្ត ដ៏ល្អរបស់លោកចំពោះនាងសព្វបែបយ៉ាង!

ថាហើយ ហារិនក៏ឈ្ងោកមុខថយចេញទៅ។ រំពេចនោះ នាយយើងក៏ដាក់ភ្នែកទៅចំនាងតូចសោភាដែលដើរចុះពីលើផ្ទះមកកាន់ដៃករី ហើយក៏លើកផ្កាឡើងគ្រវីដាក់នាយទាំងទឹកមុខញញឹមគួរអោយស្រលាញ់ទំនងដូច ជាកំពុងស្វាគមន៍រូបគេដូច្នោះដែរ។ មាណពសម្លឹងមុខកុមារីវិញ ដោយដួង ចិត្តរន្ធត់ញាប់ញ័រ។ ការពិត គេនឹកខ្មាសក្នុងចិត្ត មិនហ៊ានហារមាត់ហៅនាងតូចថាយ៉ាងម៉េចឡើយ។ ពេលនោះ គេមានអារម្មណ៍ថា បេះដូងរបស់ គេកំពុងតែទទួលរងនូវភាពពិការ ដែលគេមិនអាចទទួលនូវភាពរីករាយ ដូចជាអ្នកផងដទៃទៅពេលនោះបាន។ មើលចុះ! នាងតូចដែលជាសាច់ឈាមរបស់នាយពិត១ បែរជាឈរកាន់ដៃបុរសដទៃម្នាក់យ៉ាងជិតស្និទ្ធ ហើយថែមទាំងហៅគេថាពុក១យ៉ាងពេញមាត់ទៀតផង។ ពុំន្តែចំពោះ នាយដែលជាឪពុកបង្កើតវិញ កូនបែរជាមិនស្គាល់ មិនស្រលាញ់ មិនមាន ចំណងសម្ពន្ធ័ផ្លូវចិត្តទៅមកនឹងគ្នា ដូចជាឪពុកកូនទូទៅសោះឡើយ... តើ នោះជាកំហុសនរណា?

មែនហើយ កុមារីសោភាស្រស់ស្អាតគួរអោយស្រលាញ់ណាស់! ពេលនោះ ហារិននឹកភ្នកចង់ទៅលើកគេបីពថ្នាក់ថ្នមប្រលែងដូចឪពុកកូនទូទៅ តែក៏នៅនឹកខ្មាសចំពោះស្រមោលអតិតកាលរបស់នាយ ដែលកំពុងលង អារម្មណ៍របស់នាយរាល់ថ្ងៃឡើយ។ គេសម្លឹងមុខនាងតូចយ៉ាងយូរ ហើយ លួចបន់ស្រន់ក្នុងចិត្តតែម្នាក់ឯងថា :

- សោភា! សូមកូនអភ័យទោសដល់ប៉ាផងណាំកូនណាំ! សូមឱ្យកូនស្រី របស់ប៉ាជួបតែសេចក្ដីសុខតរៀងទៅ!

បន្ទាប់មក ហារិនក៏ឡើងទៅឱនថ្វាយបង្គំមេឃុំផែងនិងមីងផាវ :

- ហារិនសូមទោសលោកទាំងពីរ ដែលខ្លួនជាមនុស្សកំសាកមានចិត្ត អន្ធពាល បានដុតបំផ្លាញផ្ទះរបស់ពុកមេឃុំ។ ពេលនេះហារិនបានក្លាយជា ជនពិការ មិនអាចធ្វើអ្វីតបស្នងជូនពុកមេឃុំ ដើម្បីលោះបាបរបស់ខ្លួនបាន ទេ គឺបានត្រឹមតែមកសុំទទួលនូវការអភ័យទោស ពីពុកមេឃុំនិងភរិយា តែម្យ៉ាងប៉ុណ្ណោះ។

មេឃុំផែងឃើញនាយហារិនមកលំទោនលន់តួ ទទួលកំហុសរបស់គេ គាត់ក៏មានប្រសាសន៍ឡើងថា :

- អឺ.. បើដឹងកំហុសនោះ ល្អហើយ! ថ្វីបើពិការកាយ តែសុំកុំអោយពិការចិត្តទៀតទៅបានហើយ។ ឯងនៅក្មេង អាចនៅមានឱកាសសាងអំពើល្អ នឹងមនុស្សដូចគ្នាសាជាថ្មី នោះព្រះលោកនឹងយាងមកប្រោសអោយជីវិត របស់ឯងឱ្យយល់ភាពភ្លឺស្វាងវិញមិនខាន។

រីឯលោកហាក់ន៍វិញ មានចិត្តរីករាយណាស់ កាលបើកូនប្រុសរបស់ គាត់មានការភ្ញាក់រលឹកដោយខ្លួនឯង។ លោកសង្ឃឹមក្នុងចិត្តថា ចាប់តាំងពី ថ្ងៃនេះតទៅ ហារិនប្រាកដជាលែងប្រព្រឹត្តអំពើបាបតទៅទៀតហើយ។ លោកក៏សង្ឃឹមដែរថា ក្រុមគ្រួសាររបស់លោកនិងគ្រួសាររបស់មេឃុំផែង នឹងបានក្លាយជាមិត្ត ជាញាតិសន្តាននឹងគ្នាសាជាថ្មីវិញ ហើយក៏លែងជាសត្រូវនឹងគ្នាតទៅទៀតដែរ។

នៅក្នុងបន្ទប់ផ្សំដំណេក...

- បងករី...! ថ្ងៃមិញហារិនគេខ្សិបប្រាប់បងថាម៉េចខ្លះ?

- ជារឿងរបស់បុរសទេ.. ស្រី១កុំចង់ដឹងអី..! (ករីនិយាយលលេង)

- កុំតែជារឿងដែលគេនាំបងទៅផ្លូវខុសបានហើយ...

- គ្មានទេអូនណើ គ្មានថ្ងៃដែលបងដើរចូលផ្លូវខុសឡើយ...បងសន្យា!!

ភ្លាមនោះ កវីលាន់មាត់សួរកល្យាណីយើងថា :

- នេះយប់ហើយណា៎! ម៉េចអូនណើមិនព្រមដោះម្កុដផ្កាស្លាពីសក់ឥចឹង?

- អត់ទេ.. ព្រោះម្ចាស់គេមិនទាន់ប្រាប់អោយដោះចេញនោះអី!

ព្ទវាចារបស់ទេពអប្សរដូច្នោះ កវីក៏ស្ទុះទៅជិតហើយស្រវាកាន់ដៃ នាងឡើងហើយញញឹមដាក់នាងយ៉ាងពព្រាយ :

- អញ្ចឹង ទេពអប្សរឱនកេសាមក ចាំទេវបុត្រដោះម្កុដអោយបានទេ?

ភាវាណីបំរុងនឹងឱនកេសា អោយនាយដោះម្កុដផ្កាមង្គលទៅហើយ ស្រាប់តែកវីលើកត្រកងកាយនាងបីឡើង បង្វិលពីរបីជុំ :

- មិនបាច់ដោះក៏បានដែរ.. គឺបងចង់អោយអូនក្លាយជាទេពអប្សររបស់បង

កវីរៀងរហូតទៅ!

- អោយជឿបានទេហ្ន៎...ថាទេវបុត្រកវីពេញចិត្តទទួលយកទេបអប្សរទួល

ចារ ដោយបេះដូងស្នេហ៍បរិសុទ្ធពិតមែន?

- ចង់អោយទេវបុត្របង្ហាញអូនពិតមែនទេ ថាទេវបុត្រពិតជាពេញចិត្ត

ទទួលទេពអប្សរទូលចារដោយបេះដូងស្នេហ៍បរិសុទ្ធប៉ុនណា?

ភាវាណីសម្លឹងមុខស្វាមីដោយក្រសែនេត្រាភ្លឺផ្លេកញញឹមស្រស់បំព្រង ហើយក៏ងក់ក្បាលឡើង ។

បុរសយើងក៏ញញឹមតបទៅវិញហើយស្រដីថា :

- ហើយចុះឯណាវត្ថុអនុស្សាវរីរបស់អូនសំរាប់ជាថ្នូរវិញនោះ?

- ថ្នូរនោះគឺ..ជាបេះដូងស្នេហ៍ភក្តីរបស់អូនណើចំពោះបងតែម្នាក់ ពេលនេះ អូនសូមប្រគល់ជូនបងហើយ..

តើសមល្មមនឹងទំហំស្នេហារបស់បងទេ?

ព្ទដូច្នោះ មាណពក៏ញញឹមយ៉ាងមានន័យដាក់ធិតាតែម្តង ហើយលើក កាយឆវីត្រកងឡើងបីបមថៃថើបថ្នាក់ថ្នមអង្អែល ទៅតាមកំសួលនៃដួង ចិត្តស្នេហារបស់គេដ៏សែនរំភើបរំជើបរំជួលញាប់ញ័រក្រៃលែង គឺជាទឹកដម នៃសេចក្តីស្នេហាយ៉ាងធំធេងមួយ ដែលបុរសយើងបានរក្សាលាក់ទុកក្នុង ហឫទ័យយ៉ាងសម្ងាត់ សំរាប់ប្រគល់ទៅទេពអប្សរទូលចាររបស់គេតែមួយ រូបនេះជាយូរមកហើយ ។

ទេពអប្សរកំពូលដួងចិត្ត

| | |
|---|---|
| នេត្រាស្រទន់សមភក្ត្រា | ក្លែបក្លិនកេសាក្រអូបសាយ |
| ដងខ្លួនល្វតល្ងន់គន់មិនណាយ | ថ្ពាល់ខួចលួចរាយសណ្តំស្នេហ៍ ។ |
| ទ្រូងពើងណែនក្បំសមចិត្តបង | ចង្កេះអង្រ្កងល្អម្លេះទេ |
| ត្រគាកលាក់មន្តបន្ទន់កែ | លួចបេះដួងស្នេហ៍ពីទ្រូងរៀម ។ |

ឱ! ទេពអប្សរបវរឯក គន់គាប់កែវភ្នែកពេលឃើញភ្លាម
ចង់ស្ទុះត្រកងក្នុងដៃរៀម ថ្នមថៃមិនស្បៀមចិត្តរំភើប ។
ឱ! ពៅទេវីម្ចាស់ដួងចិត្ត ហប្ញទ័យបងពិតរិតស្រេវស្រើប
ចង់ថ្នមប្រឡែងអង្អែលថើប សមចិត្តរំភើបគំនួចស្នេហ៍...

នៅខាងក្រៅផ្ទះ សូរសៀងឆ្កែលូល្ងើយៗ លាយឡំនឹងសំលេងស្លឹក ឈើបក់លាន់ខ្សាកៗ ក្រោមជំនោរខ្យល់ដើមរដូវវស្សាបានក្លាយជា តូរ្យ តន្ត្រីរណ្តំយ៉ាងពិរោះរំងំ ឆ្លើយឆ្លងនឹងស្នូរសំណើចលាន់ឮរអឹករសាត់ចេញ មកពីបន្ទប់ផ្សំដំណេកកូនកម្លោះនិងកូនក្រមុំរបស់យើង ធ្វើឱ្យបរិវេណដី ភូមិទាំងមូលក្លាយទៅជាពិភពដ៏សែនត្រកាលរមណីយ៍.....

# ចប់

# វាចាចុងក្រោយ

- អំពើហឹង្សា ជាលទ្ធផលនៃ ចិត្តពិការ ឬ សតិវិបត្តិ

- អំពើហឹង្សា មិនអាចដោះស្រាយបញ្ហាអ្វីបានឡើយ ក្រៅតែពីធ្វើអោយ ដំបៅក្នុងចិត្ត ក្នុងគ្រួសារ និងក្នុងសង្គមកាន់តែរីកធំឡើងថែមទៀត ។

- ចិត្តដែលទ្រុស្តមានះ តែងតែនាំមោហ៍បាំងដល់មនុស្ស រហូតលែងដឹង ស្មារតី ថាអ្វីខុស អ្វីត្រូវ ។

- ការព្យាបាទ មិនមែនជាអំពើរបស់មនុស្សដែលមានជោគជ័យក្នុងជីវិត នោះទេ.. ការពិត គឺជាអំពើកំសាករបស់មនុស្ស ដែលស្វែងរកផ្លូវទៅ ជោគជ័យដោយសុក្រិត មិនឃើញ ។

- អ្នកដែលអោយកំណើតក្មេង មិនមែនមានន័យថាគេជាអ្នកមានគុណ ចំពោះកូន រហូតដែរ ។ ជួនកាលអ្នកមានគុណ គឺជាអ្នកដែលមិនបានអោយ កំណើត តែជាអ្នកដែលទំនុកបំរុងឱ្យទារកមានជីវិតឃើញពន្លឺថ្ងៃនិងអោយ គេទទួលសេចក្តីសុខក្នុងជីវិត ។

- អ្នកដែលគួររងអាមាស និងការថ្កោលទោសពីសង្គម គឺជនដែលជាអ្នក បំពារបំពានលើរូបកាយអ្នកដទៃ ។ រីឯអ្នកដែលទទួលរងគ្រោះដោយការ រំលោភបំពារបំពាន ត្រូវទទួលនូវការស្រោចស្រង់និងការលើកកម្លាំងចិត្ត ពីយើងគ្រប់គ្នា ដើម្បីអោយគេអាចតស៊ូក្នុងជីវិតតទៅទៀត យ៉ាងរឹងប៉ឹង ។

អ្នកស្រីកែវចន្ទ័បូរណ៏

អ្នកនិពន្ធ